# រឿង

# លំអងផ្កាស្នេហ៍

ប្រលោមលោកមនោសញ្ចេតនា

និពន្ធដោយ : អ្នកស្រី កែវ ចន្ទ័បូរណ៏
ហៅ មិត្រ មេត្រី
P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
www.angkorwat.com

ខែឧសភា២០០៥

រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO.COM

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៌


១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្ទឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្នេកចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្នេក
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្មើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង លីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីសួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិជេដ្ឋភានុមា
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភួងមាលា
៣៦- រឿង វាយោដួងចិត្ត


CHANBOKEO.COM

## សូមឧទ្ទិសចំពោះ

- លោកឪពុក ប៊ុន ផង និង អ្នកម្ដាយ កែវ យឿង
- លោកឪពុកក្មេក មេង សួង និង អ្នកម្ដាយក្មេក កូវ សារ៉ាន់
- លោក មេងសួងសុវណ្ណធី ជាស្វាមី កុមារី សុវណ្ណធី ធម្មិកាបារមីបុណ្យ ជាបុត្រី
- មិត្តខេមរកវីទាំងអស់នៅ khmerbusiness.com
- លោកអ៊ុម សុនាថ លោកជិនសៅរិន សារពត៌មានកោះសន្តិភាព
- លោកឃីលឿង និងភរិយា ក្រសួង អេសស៊ីស៊ី
- លោកម៉ក់សកលវរៈ និងភរិយា ក្រសួងវៃលឌ័រ



អ្នកស្រី កែវ ចន្ទ័បូរណ៏

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

www.angkorwat.com

## វាចាអ្នកនិពន្ធ

រឿងលំអងផ្កាស្នេហ៍នេះបានត្រូវប្រតិស្ឋឡើង ជានិមិត្តរូបនៃចំណងមិត្តភាព រវាងខេមរកវីជាច្រើនក្នុងសកលលោក ដែលបានជួបនិងស្គាល់គ្នាតាមរយៈប្រពន្ធ័ ឥន្ទ្រីណិតផ្នែកកំណាព្យខ្មែរតាមរយៈវិបសៃ www.khmerbusiness.com ។ ឈ្មោះតួអង្គទាំងឡាយនៅក្នុងសាច់រឿងនេះ សុទ្ធសឹងតែជានាមដែលកវីនិមួយៗ បានប្រតិស្ឋឱ្យដោយផ្ទាល់តែម្តង។

សូមមិត្តអ្នកអានទទួលនូវការកំសាន្តសប្បាយរីករាយអារម្មណ៍ និងបានស្វែងរកឃើញភាពក្សេមក្សាន្តនៅក្នុងដួងចិត្តជាមួយដំណើររឿងរបស់យើងនេះ។ នាងខ្ញុំ អ្នកនិពន្ធសូមទទួលនូវមតិយោបល់ពីប្រិយមិត្តអ្នកអានតាមរយៈអស័យដ្ឋានដូច ខាងក្រោមនេះ :

បណ្ណាល័យខ្មែរវិសាល
Pannalai Khmer Vissal
P.O.Box 600279
Saint Paul, MN 55119
USA
Khmervissal@yahoo.com
www.angkorwat.com

សូមប្រិយមិត្តបានជួបប្រទះតែវឌ្ឍនសុខ និងសុវត្ថិភាពរាល់ទិវារាត្រី ។

អ្នកនិពន្ធ
អ្នកស្រី កែវ ចន្ទ័បូរណ៌
២០ ឧសភា ២០០៥

CHANBOKEO.COM

# វគ្គទី១

# ស្អប់ជិតប់លើ

នៅក្នុងទីក្រុងភ្នំពេញ....

ក្នុងភោជនីយដ្ឋានមួយដ៏ល្បីឈ្មោះមួយ  ដែលគេរាល់គ្នាចំណាំហៅថា"ស្អែកមិនយកលុយ"  មនុស្សម្នាអ៊ូអរកំពុងឈរតំរង់ជួររង់ចាំការអញ្ជើញ ចូលតុអាហារដើម្បីបានស្តាប់អ្នកចំរៀងដ៏ល្បីហើយសង្ហារមួយរូបដែលទើបនឹងមកសំដែងនៅទីនោះជាលើកដំបូងជូនភ្ញៀវទាំងឡាយ ។ គេនោះឈ្មោះ សុបិន អាយុ២៦ឆ្នាំ រាងសង្ហាគាប់ភ្នែកហើយសំលេងក៏ពិរោះក្រៃលែង រួចហើយគេក៏មិនទាន់មានគូស្រករនៅឡើយទៀត ដែលជាហេតុធ្វើអោយនារីក្រមុំៗឈ្លក់វង្វេងនឹងសេចក្តីស្នេហា ចំពោះកំលោះអ្នកចំរៀងយើងនេះ ភ្លូកទឹកភ្លូកដីតែម្តងម្ល៉ោះហើយកំលោះសុបិនក៏ស៊ីជោរវាយឫកក្រអឺត ក្រទមឆ្មើងឆ្មៃចំពោះស្រីៗ លែងនិយាយហើយ ។

ស្នូរទះដៃរំពងលាន់ឮឡើងទ្រហឹងអឺងអាប់ពេញភោជនីយដ្ឋាន ដែល មានចំណុះភ្ញៀវប្រមាណ៥០០នាក់ ។ ពន្លឺភ្លើងលើវេទិកាក៏ជះភ្លិបភ្លែតៗ បញ្ចេញរស្មីរន្ទះភ្លឺច្រាលគួរឱ្យត្រេកត្រអាលក្រៃលែង ។  ឯភ្លេងតន្ត្រីក៏ចាប់ រណ្តំក្នុងៗឡើងធ្វើឱ្យភ្ញៀវទាំងចាស់ទាំងក្មេងប្រុសស្រី ភ្ញាក់ស្មារតីរំភើប រំជើបរំជួលកញ្ជ្រោលយោលបេះដូងស្ទើរតែធ្លាយទ្រូងមកក្រៅ ត្បិតគេកំពុងញាប់ញ័រនឹងស្នូរចង្វាក់ភ្លេងរណ្តំគ្រឹមៗ ស្ទើរច្រឡំនឹងសន្ធឹកផ្គរព្យុះ សង្ឃរា ។ ស្រមោលកំលោះសុបិនបានលេចធ្លោឡើងកណ្តាលវេទិកា ព្រម ជាមួយនឹងសំលេងដ៏ពិរោះគួរចេតនាក្រៃលែង :

រាំ Hello Hi

| | |
|---|---|
| ស្គរលាន់គ្រឹមៗជាចង្វាក់ | បន្ទរបទញាក់ Madison |
| មិត្តអើយឡើងរាំកុំបង្អង់ | ជាមួយនឹងវង់តន្ត្រីយ៍ខ្ញុំ ។ |
| Lady ប្រិមប្រិយ Come N dance | Hi, gentlemen សូមឡើងរាំ |
| Enjoy your time កុំសំងំ | នាំគ្នាឡើងរាំ Hello Hi ។ |
| រាំរាំរាំរាំ Madison | ក្រមុំល្វតល្វន់ dance tonight |
| with handsome men យ៉ាងសប្បាយ | គ្រប់គ្នារីករាយ Madison ។ |

សុបិនតែងខ្លួនសង្ហាណាស់ របៀបដូចអ្នកចំរៀង Elvis Presley ជាតិ អាគាំងជំនាន់ឆ្នាំ៦០ប្លាយឥចឹងរឹងឫកពារិញក៏ក្រអឺតក្រទមគួរសមដែរ ។ គ្រាន់តែច្រៀងចប់ភ្លាម ស្នូរទះដៃលាន់ឮរំពងសាជាថ្មី ។ រំពេចនោះ ទស្សនិកជនជាច្រើនបានយកកំរងផ្កាទៅបំពាក់ឱ្យសុបិន យ៉ាងណែនណាន់ ខ្ពាន់ខ្ពាប់ ។ ក្នុងចំណោមនោះ មាននារីក្មេងម្នាក់ក្នុងសំលៀកធម្មតាៗ មុខ

CHANBOKEO.COM

មាត់សាមញ្ញ បានកាន់កំរងផ្កាម្លិះយ៉ាងស្អាតមួយកំរងយកមកហុចបំរុងនឹង បំពាក់ឱ្យដល់សុបិនទៅហើយ
ស្រាប់តែនាយយើងគេចផ្ទងសឹងបាក់កតែ ម្តង ។ ការពិត សុបិនមិនចូលចិត្តទទួលកំរងផ្កាពីគ្រប់ទស្សនិកជនទាំងអស់ នោះទេ ។
បុរសសង្ហាព្រមទទួលយកកំរងផ្កាល្អៗពីនារីឆើតឆាយ high class សិចស៊ីតែប៉ុណ្ណោះ ។
គេជាមនុស្សមានឫកពាឆ្មើងកន្ទ្រើងណាស់ មិនចូលចិត្តអ្នកក្រឬអ្នកដែលមានរូបរាងមិនស្អាតបាតមិនសង្ហាឡើយ ។ ថ្វី
ត្បិតតែសុបិនបានទទួលប្រជាប្រិយភាពផ្នែកចំរៀងដល់កំពូលក៏ដោយ ក៏ បុរសសង្ហាបានបាត់បង់ការគាំទ្រមួយចំនួនធំដែរ ។
កាលបើ សុបិនគេច មិនព្រមទទួលកំរងផ្កាពីនាង នារីមួយរូបនោះក៏សំដែងទឹកមុខ ហាក់ដូចជា ខកចិត្តណាស់
ក៏គប់កំរងផ្កាចោលព្រួសទៅលើកំរាលវេទិកា ហើយឈ្ងោក មុខដើរចេញទៅយ៉ាងរហ័ស ។ ពេលនោះ ទាំងទស្សនិកជន ទាំងសុបិន
ទាំងតន្ត្រីករនៅលើឆាក បានដាក់ភ្នែកឃើញកំរងផ្កាជ្រុះនៅលើកំរាលគ្រប់ គ្នា ។ ដោយសារភាពអ៊ូអរនៅជុំវិញវេទិកានាពេលនោះ
គេមិនអាចចំណាំ បានទេថា តើនារីនោះជានរណា មុខមាត់យ៉ាងណា ហេតុអ្វីហ៊ានមាក់ងាយ
អ្នកចំរៀងដ៏ល្បីដោយបោះផ្កាចោលលើវេទិកានោះដូច្នោះ? សុបិនថ្លោះទឹក មុខបន្តិចដែរដែលប្រទះហេតុការណ៍ដូច្នោះ
ត្បិតនោះជាលើកទីមួយហើយ ដែលមានភ្ញៀវបោកកំរងផ្កាចោលលើក្តារ នៅចំពោះមុខនាយ និងចំពោះ
មុខទស្សនិកជនទាំងឡាយ ។ សុបិនក៏សង្កើតធ្មេញដើរចុះពីវេទិកាទៅ...

សុបិនផ្លាស់សំលៀកបំពាក់សំដែងចេញហើយ ក៏ដើរចេញពីបន្ទប់បំរុង ត្រលប់ទៅផ្ទះ ។
លុះឆ្លងមកដល់កាច់ជ្រុងជញ្ជាំងមួយស្រាប់តែជំពើបជល់ គ្នាជាមួយនារីមួយរូប ដែលកំពុងលើកថាសអាហារសំដៅទៅចង្រ្កានបាយ
ធ្វើអោយសំណល់អាហារខ្ទាតខ្ចាយព្រោងឡើង ប្រលាក់នាយយើងពេញ ខ្លួនអស់ ។ ពេលនោះសុបិនខឹងក្រេវក្រោធតែម្តង
ម្យ៉ាងដោយសារខ្ពើម ក្លិនអាហារ ម្យ៉ាងទៀតនាយយើងមិនចូលចិត្តអ្នកដែល មានវណ្ណៈតូចទាប ផង ។
នារីម្នាក់នោះក៏ខំស្ទុះមកសូមទោសញាប់មាត់ណាស់ដែរ ប៉ុន្តែសុបិន
បែរជាមានទោសៈលើសដើមហើយក៏យកដៃប្រច្រានរនាងថែមទៀត រហូត
ដល់នាងដួលព្រួសរបូតថាសទៅដីបែកកែវបែកចានអស់រលីង ។ គ្រានោះ សុបិនក៏ទាញយកកូនកន្សែងដៃពីហោប៉ៅខោមកជូតមុខ
ជូតខ្លួនរួចហើយ ក៏យកកន្សែងនោះគប់ទៅលើក្បាលនារីនោះ ព្រមទាំងគំហកថា :
- នែ៎នាង! ដើរបើកភ្នែកខ្លះផងបានទេហ៎? សស្លាក់សស្លើតបែបនេះ សម តែទៅដើរសុំទានតាមផ្លូវទេ
មិនសមនឹងមកបំរើក្នុងហាងល្អៗដូចទីនេះ ឡើយ! យ៉ាប់មែន!

ក្រោយពីគប់កូនកន្សែងប្រលាក់ ទៅលើក្បាលនារីបំរើតុនោះហើយ សុបិនក៏រត់ទៅផ្លាស់ខោអាវម្តងទៀត ។
មួយស្របក់ធំក្រោយមក សុបិន ក៏បញ្ចេះឡានបរចេញមកក្រៅ ស្រាប់តែប្រទះនារីមួយហ្វូងមកឈរចាំ
ស្ទាក់ផ្លូវសុំការណាត់ជួបពិសេសជាមួយនាយ ធ្វើឱ្យសុបិនវាយឫកក្រអឺត តែម្តង ។ ក្រោយពីស៊ីញ៉េណាត់ម្នាក់ពីរហើយ
គេក៏បើកឡានប្រនាបធ្វើឫក ឆីយកាត់ហ្វូងនារីនោះចេញពីធ្លាចតឡានរបស់ភោជនីដ្ឋានកាត់តាមផ្លូវតូច ងងិតមួយ
ស្រាប់តែសុបិនប្រទះយុវជនបួនប្រាំនាក់ចតម៉ូតូរាំងផ្លូវ ។ នាយ យើងនឹកឆ្ងល់ក៏ទុចដំណើរ
ហើយបើកកញ្ចក់បង្អួចស្រែកវ៉ាងឡើងថា :

CHANBOKEO.COM

- អើ អាប្អូន! ចតម៉ូតូអីកណ្ដាលផ្លូវយ៉ាងនេះ? ចតទៅខាងបន្តិចបានទេ ? ឯងចតយ៉ាងនេះ ទើសផ្លូវយើងបើកបរដល់សួរហើយរឺយ...

ស្រាប់តែក្មេងម្នាក់ឆ្លើយវិញថា :

- ផ្លូវម៉ែឯងមកសង់ទុកឬអីបានជានិយាយស្ដីហួងហែងឥតក្រែងដូច្នេះ?

សុបិនឮហើយ ខឹងឆេវតែម្ដង :

- នែ៎ ក្មេងព្រហើន! ចៀសឬមិនចៀស? តិចយើងបើកបុកឥលូវ...

មិនទាន់ពោលចប់ផង ស្រាប់តែយុវជនឈាមរាវម្នាក់យារដំបងដាក់ កញ្ចក់បង្អួចឡានម្ខាងបែកប្រាវ រួចហើយក៏មួយទៀត ហើយមិត្តភក្ដិរបស់ គេក៏ស្រែកកញ្ច្រៀវឡើងធ្វើតាមដូចគ្នាដែរ ធ្វើឱ្យសុបិនភ្ញាក់ស្រលាំងកាំង តែម្ដង ស្រាប់តែក្មេងម្នាក់ហក់មកពីក្រោយ ដាក់នាយមួយដំបងចំសៀត ផ្កាយ៉ាងរហ័ស រកតែសុបិនតដៃវិញក៏មិនទាន់ដែរ។ ពេលនោះក្មេងម្នាក់ ក៏វាចាថា :

- ឯងគ្រាន់បើមែនទេ? បើគ្រាន់បើ ងើបមកតដៃមកមើល៍!

ពេលនោះ សុបិនកំពុងតែបែកអំពិលអំពែកវិលក្បុង ស្ដាប់លែងឮ ពាក្យក្មេងទាំងនោះនិយាយទៅហើយ។ មួយស្របក់ក្រោយមក ក្មេងក៏ អូសសុបិនចេញពីឡាន សំរាតខោអាវយកកាបូបលុយ និងប្រមូលតវ៉ាន់ ល្អៗអស់ពីក្នុងរថយន្តរលីង។ បន្ទាប់មក ពួកគេក៏អូសយកសុបិនដែល កំពុងបាត់ស្មារតីទៅព្រមៀលទំលាក់តាមច្រាំងទន្លេ អោយធ្លាក់ទៅក្នុង ទឹកដែលកំពុងហូរយ៉ាងខ្លួលខ្លាញ់...

ច្រើនម៉ោងកន្លងទៅ...

សុបិនបើកភ្នែកឡើងមើលជុំវិញខ្លួន... ដឹងថាខ្លួនមានរបួសក្បាល យ៉ាងដំណំថែមទាំងមានស្នាមជាំពេញខ្លួនទៀតផង។ ថៃដន្យ នាយមិនបាន ដឹងថា នរណាជាអ្នកសង្គ្រោះនាយមកទីនេះទេ គ្រាន់តែចាំបានថា នាយ ត្រូវក្មេងឈាមរាវសំរាតយកខោអាវអស់ សល់តែខោខ្លីប៉ុណ្ណោះ។ លុះ មាណពប្រែខ្លួនទៅទើបដឹងថា នាយកំពុងគេងនៅលើគ្រែរនាបឬស្សីក្រាល កន្ទេលកក់ ក្នុងខ្ទមស្បូវតូចមួយនៅម្ដុំណាមិនដឹង។ រំពេចនោះ មានដូន ចាស់មួយរូបបានដើរចូលមកដល់ :

- អន្និតអើយ! ដឹងខ្លួនហើយឬចៅ?

សុបិនភ្ញាក់ព្រើតបើកភ្នែកសំលឹងទៅគាត់ ថៃដន្យ នាយក៏មិនដែល ស្គាល់គាត់ពីមុនមកដែរ។ សុបិនឈឺកាយទុរន់ទុរាណាស់ ទ្រាំសឹងមិនចង់ បាន។ កាលបើឃើញវត្តមានដូនចាស់មកដល់ នាយយើងក៏ពោលឡើងៈ

- យាយ! សុំថ្នាំបំបាត់ការឈឺចាប់ពីរបីគ្រាប់បានទេ?...

ស្រាប់តែដូនចាស់ឆ្លើយឡើងថា :

- យាយទើបតែបង្អកចៅឯង ពីរម៉ោងមុននេះទេ កុំទាន់ញ៉ាំថ្នាំទៀតអី ក្រែងលើសកំលាំងណា៎។

តែសុបិនទ្រាំមិនបានសោះនៅតែទទូច :

CHANBOKEO.COM

- ខ្ញុំទ្រាំមិនបានទេយាយ... ខ្ញុំពិតជាឈឺក្នុងខ្លួនណាស់... ហើយចុះហេតុអី យាយមិនយកទៅពេទ្យ.. បែរជានាំខ្ញុំមកទីនេះ កុំអី... ខ្ញុំមិនពិបាកគេង ឈឺចុកចាប់យ៉ាងនេះទេ...

ស្រាប់តែដូនចាស់បើកភ្នែកធំៗ :

- យី! មិនទាន់បានអរគុណចំពោះការដែលមានគេអូសឯងមកពីច្រាំងទន្លេ ម៉ាម៉ាត់ផង ស្រាប់តែមកបន្ទោសយាយថាមិនយកឯងទៅពេទ្យ... ពុទ្ធោ! ចំជាគ្មានសុជីវធម៌មែនហ្ន៎!!

ឮដូនចាស់ស្តីអោយចំចំណុច សុបិននៅស្ងៀមលែងហ៊ានមាត់។ ភ្លាមនោះ សុបិនដាក់ភ្នែកទៅក្រៅតាមបង្អួចខ្ទម ឃើញនារីម្នាក់ទទូរក្រមាដើររាងស្ទាបៗ ទំនងដូចជាភ្នែកមិនប្រក្រតីដូចគេឯងធម្មតា កំពុងរៀបស្នូរ ដាក់ខោអាវហាលនៅឯខាងក្រៅផ្ទះ។ ដូនចាស់បែរឃើញនាងហើយក៏ស្ទុះទៅជួយភ្លាម :

- លំអងអើយ! មិនបាច់ធ្វើទេចៅ! ទុកអោយយាយធ្វើក៏បានដែរ។

- មិនអីទេយាយ! (នារីនោះឆ្លើយ) កិច្ចការប៉ុណ្ណឹងមានទៅពិបាកអី?

- ឃើញចៅធ្វើការពពិមពពើមអញ្ចឹង យាយទើសភ្នែកណាស់។

- ធ្វើម៉េចបើភ្នែកខ្ញុំមានជំងឺទៅហើយ បើអោយខ្ញុំទំរន់តាមជំងឺភ្នែកនោះ ទៅមិនរួចទេយាយ។ ខ្ញុំចង់រស់នៅជាមនុស្សមានប្រយោជន៍ជាជាង មិន ចង់ទំរន់តាមវាសនាខ្លួននោះទេ។

ឃើញថា ឃាត់មិនជាប់ទៅហើយ ដូនចាស់ក៏បណ្តោយអោយនាង ពូតខោអាវលាស់ហាលតែម្នាក់ឯងរហូតដល់រួចរាល់។ ចំណែកដូនចាស់ ក៏ចេញទៅផ្ទះបាយ រៀបអាហារដាក់លើស្តុកបាយហើយក៏ដើរយកមកឱ្យសុបិនដែលកំពុងនៅគេងស្តូកនៅលើកន្ទេលតែម្នាក់ឯង :

- ចៅ! នេះបាយ ឆាប់ងើបមកបរិភោគបន្តិចទៅ ក្រែងមានកំលាំង។

សុបិនឃើញថាសអាហារភ្លាម ក៏ស្ទុះងើបភ្លែត ណាកំពុងតែឃ្លានផង តែលុះដល់ក្រលេកឃើញសម្លម្ជូរស្រែលាយកូនត្រីល្អិតៗ និងបុកម្ទេស១ ចាន ស្រាប់តែគ្រវីក្បាល ហើយលាន់មាត់ថា :

- ស្លាប់ហើយ! ម្ហូបអីក៏យ៉ាប់ម្លេះ? ខ្ញុំមិនចូលចិត្តសម្លប្រហុកទេ មានម្ហូបអីគ្រាន់បើជាងហ្នឹងទេយាយ?

ដូនចាស់សំលឹងមុខនាយហើយឆ្លើយវិញថា :

- មិនមានទេចៅ! នេះជាអាហារដ៏ប្រសើរបំផុតរបស់គ្រួសារយាយហើយ បើមិនទទួលទានទេ ចៅច្បាស់ជាត្រូវដាច់ពោះស្លាប់មិនខាន

- ម៉េចអញ្ចឹងយាយ?

- ព្រោះយាយគ្មានសោហ៊ុយឯណាទៅរកអោយបានថែមមួយមុខទៀតទេ

CHANDBOKEO.COM

- ពុទ្ធោ... ហេតុអ្វីក៏សុបិនខ្ញុំនេះ សំណាងអាក្រក់ម្ល៉េះ មកជួបអ្នកក្រីក្រ អត់មុខអត់ក្រោយយ៉ាងនេះ ព្រះអើយ...

សុបិនរអ៊ូផង យកដៃទះថ្ងាសប៉ាច់ៗផង សំដែងកិរិយាខកចិត្តដល់សួរ ហើយ
ថែមទាំងធ្វើឫកខ្ពើមរអើមបាយសម្លរបស់ដូនចាស់នោះទៀតផង ។ សុបិនក៏ប្រាសខ្លួនដេកភីងវិញទាំងដួងចិត្តតក្កហល
មិនដឹងថាត្រូវធ្វើដូច ម្ដេចនឹងទៅដល់ផ្ទះវិញបើខ្លួនទុរន់ទុរាយ៉ាងនេះ ។ រំពេចនោះ នាងលំអង
ចៅស្រីដូនចាស់នោះដើរចូលមកហើយក៏លើកស្ពកបាយយកទៅបាត់ដោយ មិនស្រដីអ្វីមួយម៉ាត់សោះឡើយ ។ សុបិនប្រែខ្លួនឡើង
ស្រាប់តែបាត់ស្ពក បាយ ។ នាយក៏ស្រែករកឡើងថា :

- យាយ! ឯណាស្ពកបាយរបស់ខ្ញុំ?

ដូនចាស់ក៏ឆ្លើយវិញថា :

- ឃើញចៅឯងមិនបរិភោគ នាងល្អងគេយកទៅទុកបាត់ទៅហើយ ។ យ៉ាងម៉េច...? ដូរចិត្ត ចង់បរិភោគបាយវិញហើយហ្អែស?

សុបិននៅអេះអុញ មិនហ៊ានឆ្លើយ ។  ការពិត  ក្រពះនាយកំពុងតែកូរ
គ្រូកៗទាររកចំណីយូរហើយ   គ្រាន់តែនាយវាយឫក មិនចង់ទទួលអាហារ
របៀបអ្នកក្របែបនោះប៉ុណ្ណោះ ។   លុះទ្រាំលែងបាន មាណពយើងក៏សុខ
ចិត្តអោនលំទោនបន្តិចជាងមុន :

- ខ្ញុំគិតថា ចង់សាកសម្លស្រុកភូមិយាយបន្តិចក្រែងលោប្លែកមាត់ខ្លះ ។

ឮដូច្នោះ ដូនចាស់ញញឹមហើយក៏កូកហៅលំអង :

- ល្អងអើយ! លើកថាសម្ហូបមកវិញផងចៅ!

ស្រាប់តែនាងលំអងឆ្លើយពីផ្ទះបាយមកថា :

- ខ្ញុំបរិភោគសម្លអស់ទៅហើយយាយ... នៅសល់តែបាយនិងបុកម្ទេស ប៉ុណ្ណោះ ត្បិតចៅគិតថា
ប្រហែលជាគ្មាននរណាគេចង់បរិភោគសម្លម្ជូរស្រែ នោះទេ... ត្បិតវាជាអាហារអ្នកក្រ...

ឮនាងលំអងចាក់ផាសំដីមកវិញដូច្នោះ សុបិនខឹងក្រេវតែម្ដង :

- ណ្ហើយ! អត់បាយមួយពេលវាមិនស្លាប់ទេ... ខ្ញុំទៅផ្ទះវិញចុះ ក្រែងបាន ដល់ឆាប់
គ្រាន់ជាជាងនៅដំអក់ទីនេះឱ្យដាច់ពោះស្លាប់ដែរ ។

ថាហើយសុបិនក៏ងើបក្រេះដើរចេញទៅក្រៅផ្ទះត្រុយ... បានតែបួន ដប់ជំហានក៏ទុចង៉ក់ ធ្វើមុខជូរ ត្បិតចុកចាប់ពេញខ្លួន
ស្ទុះទៅទៀតមិនរួច ។ ពេលនោះ សុបិនចោលកន្ទុយភ្នែកមកក្រោយ លបមើលក្រែងម្ចាស់ផ្ទះគេ ហៅត្រលប់ទៅវិញ ។ ការពិត
ពេលនាយដឹងថា ខ្លួនមិនអាចទៅមុខរួចដែរ ហើយក៏នឹកចង់ត្រលប់ក្រោយវិញ តែដោយខ្មាស់សំដីខ្លួនឯងទើបបានជា ស្ទាក់ស្ទើរ
រង់ចាំអោយម្ចាស់ផ្ទះគេឃាត់ ដើម្បីកុំឱ្យសួរបាក់មុខបាក់មាត់ ពេក ។ ចៃដន្យអី ទាំងដូនចាស់ ទាំងនាងលំអងនោះ
គ្មាននរណាឃាត់នាយ មួយម៉ាត់សោះ ។ សុបិនឃើញដូច្នោះក៏នឹកជជេសប្រឹងដើរបានបីបួនជំហាន ទៅមុខទៀត
ស្រាប់តែដួលប្រួសទៅដីទាំងជំហរតែម្ដង ។ ពេលនោះ នាយ យើងទ្រាំលែងបានហើយ បើមិនស្រែកអោយគេឯងជួយ

CHANDBOKEO.COM

គឺច្បាស់ជាត្រូវ អង្រ្គងរោមពេញខ្លួនក្រោមដើមស្វាយមុខផ្ទះនោះជាមិនខានឡើយ ម្ល៉ោះ ហើយ សុបិនក៏ដាច់ចិត្តហើបមាត់បន្ទន់សំនួនពាក្យ ជាលើកដំបូងបង្អស់ក្នុង ជីវិតរបស់នាយ :

- យាយ! ជួយខ្ញុំផង...! យាយ!

ពូដូច្នោះ ដូនចាស់លួចញញឹមបន្តិចហើយក៏ស្ទុះរឹងមកជួយគ្រាហ៍ មាណពឡើង ។ សំណាងមិនល្អ ដូនចាស់មានមាឌតូចហើយទ្រុដទ្រោមដែរ មិនអាចជួយលើកនាយបាន ។ គាត់ក៏កូកហៅចៅស្រី :

- ល្អងអើយ! មកជួយយាយបន្តិចមើល៏ចៅ!

ស្រាប់តែលំអងបែរជាឆ្លើយពីផ្ទះបាយមកថា :

- កាលបើគេមានកំលាំងដើររហូតដល់មុខផ្ទះបាន គេក៏ត្រូវតែមានកំលាំង ដើររហូតដល់ទីដំណេករបស់គេវិញបានដែរ យាយ ។ បើគេទន់ខ្សោយទុរន់ ទុរាហើយតំអូញអោយគេបំរើយ៉ាងនេះ តើថ្ងៃណាទៅនឹងបានរឹងប៉ឹងជាសះ ស្បើយឡើងវិញ? ណ្ហើយចុះ សូមយាយទុកអោយគេសំដែងនូវទឹកចិត្តកូន ប្រុសពេញមុខផងទៅចុះ ណាំយាយ...

អីយ៉ូយ! នាងចាក់ផាស៊ិកស្បៀតសំដីមកអោយសុបិនយ៉ាងឈឺអស្ចារ្យ ធ្វើអោយសុបិនក្តៅត្រចៀកតែម្តង ។ តែណ្ហើយចុះ! ពេលនេះទាល់ច្រក ទៅហើយ បុរសយើងត្រូវតែទ្រាំខាំមាត់ ដើរតតេះតតះត្រលប់ទៅរកគ្រែ រនាបក្រាលកន្ទេលកក់របស់នាយវិញទាំងត្រដរ ។ ទំរាំតែមកដល់ សុបិន ងងិតមុខបែកអំពិលអំពែកមិនដឹងប៉ុន្មានដងទៅហើយទេ ។ ពេលនោះ សុបិននឹកក្តៅចិត្តណាស់ចំពោះនាងលំអង  ហើយសង្រ្កើតធ្មេញគិតតែម្នាក់ ឯងថា  :

- ខ្វាក់ហើយចិត្តខ្មៅទៀត! សមមុខហើយដែលនាងជាអ្នកក្រ... មួយជាតិ នេះ មិនបាច់មានបុរសណាគេអាណិតស្រលាញ់យកនាងជាប្រពន្ធទេ ឱ្យ តែនាងសំដីកោងកាចវាយឫកក្រអឺតយ៉ាងនេះចុះ? មើលចុះ! មុខមាត់ ប្រហែលជាយាប់មើលណាស់ហើយមើលទៅ បានជាទទួរក្រមាឃ្លុំមុខដូច ក្រមុំឥស្លាមមិនហ៊ានអោយនរណាមើលទេ... សង្ស័យតែនាងមុខមានខ្ទួត ស៊ីពេញមុខមិនខានឡើយ ។

នឹកដល់ត្រង់នេះ ស្រាប់តែសុបិនលួចញញឹមឡើង ហើយនឹកបន្តទៅ ទៀតថា :

- អោយស្រលះសាធុទៅចុះ មនុស្សស្រីចិត្តអាក្រក់បែបនេះ សមនឹងមុខ ខ្ទួតរបស់នាងណាស់!

ស្រាប់តែក្រពះរបស់នាយកួរគ្រូកទៀតហើយ ។ សុបិនទ្រាំមិនបានក៏ ដាច់ចិត្តស្រែកទារដូនចាស់ :

- យាយ... ! អោយខ្ញុំសុំបាយមួយចានមក៏!

ដូនចាស់បែរទៅក្រោយផ្ទះសំលឹងរកនាងលំអង ។ លុះឃើញយាយ មានកិរិយាហាក់ដូចជាលើកលែងទោសអោយសុបិន នាងលំអងក៏លើក ស្ពកបាយថ្មីមកអោយ ហើយក៏គេចចេញទៅវិញយ៉ាងរហ័សរកតែសុបិន លួចសំលឹងមើលមុខនាងមិនទាន់ផង ។ លុះដាក់ភ្នែកទៅឃើញមានតែ បាយនិងបុកម្ទេសប៉ុណ្ណោះ សុបិនជ្រួញចិញ្ចើមធ្វើមុខជូរហួញតែម្តង ។ ការពិតទៅ នាយមិនធ្លាប់បរិភោគរបៀបនេះទេ មួយជីវិតនាយទៅ ហើយ ។ ពេលនេះនាយយើងត្រូវតែត្រដរលេបបន្តិច ទោះបីជាក្នុងចិត្តនៅ ខ្ពើមរអើមយ៉ាងណាក្តី ព្រោះមាណពកំពុងចង់អោយមានកំលាំងឆាប់ៗ នឹងអាលត្រលប់ទៅផ្ទះវិញ ។ នៅឯផ្ទះបាយ

CHANBOKEO.COM

លំអងលួចចោលកន្ទុយភ្នែក សំលឹងមើលសុបិនហើយលួចញញឹមម្តងៗ ជាពិសេសពេលឃើញនាយ ឈ្លក់ម្ទេសក្រហមមុខងាំង។ នាងគិតក្នុងចិត្តថា :

- សមមុខអ្នកហើយដែលមាក់ងាយបាយអ្នកក្រ ពេលនេះនាយដឹងហើយ ថា បាយអ្នកក្រមានតម្លៃប៉ុណ្ណា ជាពិសេសកាលបើនាយស្ថិតនៅក្នុងភាព ទាល់ច្រកដូចជាយើងដែរ។

ព្រលប់សន្ធិយាចូលមកដល់...

សុបិនខំទ្រាំធ្មេចគេងក្នុងមុងកញ្ចាស់ដ៏តូចចង្អៀតមួយ ស្ទើរតែស្រែក ទ្រហោរម្តងៗ។ បន្តិចមក នាយក៏រអ៊ូដាក់ដូនចាស់ថា :

- ខ្ញុំមានអារម្មណ៍ស្អុះស្អាប់ខ្លាំងណាស់ យាយ! មានចង្កាល់បក់ទេ?

ដូនចាស់ក៏ឆ្លើយឡើងពីមុងម្ខាងមកថា :

- មិនមានទេ អានាងអើយ! បើឯងក្តៅស្អុះ ចាំយាយយកផ្លិតទៅបក់ អោយចៅចុះណាំ!!

ភ្លាមនោះ ដូនចាស់ងើបទាញផ្លិតធាងស្លាមួយ ហើយឡើងមកអង្គុយ ក្បែរនាយយើង រួចក៏បបក់អោយនាយថ្នមៗ :

- អានាងអើយ! ផ្ទះអ្នកក្រ មានតែប៉ុណ្ណេះឯង មិនមានអ្វីហ៊ឺហាដូចគេ ទេ។ សូម្បីតែស្រុកយើងមានភ្លើងអគ្គីសនីប្រើប្រាស់ពេញភូមិទៅហើយក៏ ដោយ ក៏ផ្ទះយាយមិនអាចមាននឹងគេ ព្រោះយើងក្រពេកមិនមានលុយ បង់ឱ្យគេរាល់ខែបានដែរ សព្វថ្ងៃ រកលុយចិញ្ចឹមក្រពះសឹងមិនគ្រប់ផង។

បន្ទាប់ពីបានទទួលខ្យល់បក់រហើយៗ ពីកំលាំងផ្លិតរបស់ដូនចាស់មក សុបិនហាក់ដូចជាមានអារម្មណ៍ធូរស្រាលក្នុងខ្លួនបន្តិច។ ភ្លាមនោះ នាយ ពោលសួរដូនចាស់ថា :

- ចុះយាយរកស៊ីមុខរបរអ្វីទៅ ដើម្បីល្បេងជីវិត?

- គឺបាននាងល្អងវាទៅធ្វើការនៅផ្ទះបាយអោយគេរាល់ថ្ងៃ បានប្រាក់ខែ ល្មមតែថ្លៃបាយទឹកយាយនិងចៅពីរនាក់ប៉ុណ្ណោះ។ ចៅដឹងទេ ថាថ្ងៃនេះ នាងល្អងគេចេញទៅធ្វើការយឺត ព្រោះអីកាលពីយប់មិញ នាងអាល័យតែ សង្គ្រោះអូសគ្រាហ៍ឯងយកមកពីមាត់ទន្លេ ទំរាំតែគេលាងរបួសអោយ ឯងរួច ថ្ងៃជិតរះទៅហើយ មិនតែប៉ុណ្ណោះថែមទាំងដាំបាយដាំទឹក ទុកឱ្យ ចៅឯងទៀតផង។ ចៅដឹងទេ? គេអន់ចិត្តនឹងចៅឯងណាស់ ព្រោះចៅ វាយប្លុកក្រអឺតក្រទមខុសកន្លែង ខុសពេលវេលា។

សុបិនញញួច្នោះ ហាក់ដូចជានឹកស្តាយក្រោយបន្តិចដែរ ដែលខ្លួនវាយ ប្លុកព្រហើនដាក់ម្ចាស់ផ្ទះក្នុងពេលគេកំពុងមានសន្តានចិត្តចំពោះនាយ ប៉ុន្តែ ពេលនេះ តើឱ្យនាយធ្វើម្តេចទៅបើវាហួសទៅហើយ។ បន្តិចមក នាយក៏ សួរដូនចាស់ថា :

- ហើយចុះពេលនេះ ចៅស្រីរបស់យាយទៅណាហើយ?

- គេទៅធ្វើការវិញទៀតហើយ អាធ្រាតបន្តិចទើបមកវិញ។

ដូនចាស់ស្រដីផង អង្គុយបក់អោយសុបិនផង រហូតដល់នាយធ្មេច លង់លក់ទៅ ទើបគាត់ងើបទៅសំរាន្តខ្លួនឯង។ ប្រហែលពាក់អាធ្រាត សុបិនក៏ឮសូរសំលេងទ្វាររបើក។ ក្រោមពន្លឺចង្កៀងខ្លាញ់ត្រីក្រហមព្រឹមៗ

CHANBOKEO.COM

សុបិនឃើញនារីមួយរូបដើរចូលមកដល់ តែពេលនេះ នាងមិនមានទទូរ ក្រមាដូចកាលពីព្រឹកដូចនាយបានឃើញនោះទេ ។ នារីមានសក់វែងអន្លាយ ខ្មៅរលើប ទំរង់មុខក៏ហាក់ដូចជាមានសោភ័ណគួរអោយចាប់អារម្មណ៍ បន្តិច១ដែរ ។ ចៃដន្យ ស្បៃមុងរបស់សុបិនរាំងដូចក្រាស់បន្តិច ហើយមាន ពណ៌ប្រផេះល្អក់ មិនអាចអោយសុបិនលួចមើលរង្វង់ផ្ទៃមុខរបស់ធិតា យើងបានជាក់ច្បាស់សោះឡើយ ។ សុបិនយើងបានលួចគយគន់មើលគ្រប់ សកម្មភាពរបស់នាងមិនហ៊ានព្រិចឡើយ ។ នេះជាលើកទីមួយហើយ ដែល សុបិនចេះយកភ្នែកលួចសំលឹងនារីធម្មតា១ ។ តាមការពិត នាយក៏មិនដឹង ដែរទេថា ហេតុអ្វីបានជានាយចង់ដឹង ចង់ស្គាល់ នារីមួយរូបនោះម្ល៉េះ? ឬក៏ប្រហែលជាពេលនេះនាយអផ្សុកធុញថប់ក្នុងចិត្តពេកទេដឹង បានជា ចេះតែគេងពិចារណាលើនារីចំលែកនោះមិនឈប់ឈរ ។ បន្តិចមក ធិតាក៏ ចាប់យកខ្មៅដៃនិងកូនសៀវភៅមួយចេញពីថតតុមកសរសេរ ។ ឃើញ ដូច្នោះ សុបិននឹកគិតឆ្ងល់ក្នុងចិត្ត :

- នាងងងិតភ្នែកឬក៏ឈឺភ្នែក? ហេតុអ្វីពេលនាងដើរ ឃើញដូចស្ទាបៗតែ បែរជាមើលអក្សរឃើញទៅវិញ? ឬក៏នាងងិតមើលឆ្ងាយមិនឃើញ តែ អាចមើលជិតៗបាន? បើនាងជាអ្នកក្រយ៉ាងនេះ ហេតុអ្វីក៏ចេះអក្សរដែរ? ឬក៏នាងកំពុងតែរៀនសរសេរអក្សរ?.. សង្ស័យតែខំប្រឹងរៀន ដើម្បីលួច សរសេរសំបុត្រទៅសង្សារទេដឹង? ហ្អើយ...សុបិនអើយ... ហេតុអីក៏គិត ពីនាងក្រមុំសំដីឆ្អាសម្នាក់នេះម្ល៉េះ? មើលទៅសំបុរសំបកមិនគួរអោយ បេតីប្រតិពទ្ធ័ទាល់តែសោះ! យើងគួរប្រឹងធ្វេចយកកំលាំងវិញ ក្រែងថ្ងៃ ស្អែកអាចត្រលប់ទៅផ្ទះបាន ។

សុបិនក៏ធ្វើឫកជាមិនអើពើនឹងនារីមួយរូបនោះទៀត រួចប្រឹងធ្មេចសំងំ គេង តែក៏ទប់ចិត្តមិនបានសោះ ។ នាយយើងចេះតែពិភាល់ចង់ដឹងថា តើ នារីនោះមានមុខមាត់យ៉ាងណា ម្ល៉ោះហើយ មាណពចេះតែលួចអើតមើល ពីក្នុងមុងជាញឹកញាប់ រហូតដល់មាណវីចាប់ភ្លឹកថា នាយយើងហាក់ដូចជា គ្រេះគ្រុះក្នុងមុងខុសធម្មតា ។ ភ្លាមនោះ មាណវីក៏ពន្លត់ចង្កៀងចូលដំណេក ទៅ ទុកអោយសុបិននៅអើតអើមតែម្នាក់ឯងក្នុងមុង មិនអស់មិនហើយ ។

មាន់រងាវខ្ទើយៗ...

សុបិនភ្ញារភ្ញាក់ស្មារតីឡើងជាថ្មី ។ ដូនចាស់លើកភ្លាំទឹកក្តៅមកដល់ ក៏ ជូតខ្លួនអោយនាយយ៉ាងស្អាត ទើបលើកថាសបបរមកអោយ ។ ទោះបីជា ពេលនោះនាយបានទទួលត្រឹមបបរសនិងពងទាប្រៃ ក៏នាយលែងហ៊ានរអ៊ូ ទៀតហើយ ត្បិតដឹងថាទោះបីជារអ៊ូ ក៏ដូនចាស់មិនអាចទៅរកអាហារ ឯណាមកឱ្យបានដែរ ម្ល៉ោះហើយ បុរសយើងក៏ខំប្រឹងលេបទៅទាំងត្រដរ ។

ថ្ងៃនេះ សុបិនមានអារម្មណ៍ថាមានកំលាំងកំហែងគ្រាន់បើវិញហើយ មិនសូវទុរន់ទុរាដូចកាលពីម្សិលទេ ។ នាយក៏សំពះលាដូនចាស់ត្រលប់ទៅ ផ្ទះវិញ ។ ចៃដន្យ នាងលំអងចៅស្រីរបស់គាត់ក៏ចេញទៅធ្វើការបាត់តាំង ពីព្រហាម ទើបនាយមិនបានលាមាណវីយើង ។ ដូនចាស់បានដើរជូននាយ ទៅដល់មាត់ផ្លូវធំដែលមានចរាចរខ្វែងខ្វាត់ ទើបលូកប្រាក់អោយនាយ បួនពាន់រៀល :

CHANBOKEO.COM

- នេះជាប្រាក់ដែលនាងល្អងគេអោយចៅខ្ចីសំរាប់ធ្វើដំណើរទៅផ្ទះ ។ ថ្ងៃ ក្រោយមានឱកាសពេលណា ចាំយកមកសងគេវិញចុះណាំ ។

សុបិននឹកអេះអុញមិនចង់ទទួល តែពេលនេះនាយក៏ទាល់ច្រកបំផុត បើមិនទទួលនោះ ក៏មិនដឹងមានអ្វីជាសោហ៊ុយ

សំរាប់ឱ្យថ្លៃម៉ូតូឌុបដែរ ។

នាយយើងត្រូវតែកាត់ចិត្តទទួលយកប្រាក់កម្ចីពីអ្នកក្រមួយរូប ដែលនាយ មិនដែលគិតពីមុនមកថា នឹងជំពាក់គុណអ្នកក្រឡើយ ។

៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO . COM

# វគ្គទី២
# ក្លិនផ្កាស្នេហ៍

ថ្ងៃនេះ សុបិនមកដល់ផ្ទះផ្លាស់ប្តូររូបកាយក្នុងសំលៀកយ៉ាងស្អាតបាត មុននឹងត្រលប់ទៅជួបថៅកែហាង ស្អែកមិនយកលុយឈ្មោះយូនិក្ស ។ នៅក្នុងបន្ទប់សាលុងពិសេសរបស់ថៅកែ សុបិនទទូចសូមទោសញាប់មាត់:

- ថៅកែ! គឺខ្ញុំពិតជាមានគ្រោះថ្នាក់ពិតមែន មិនបានផឹកស្រាស្រវឹងវាយ គ្នាបែកក្បាលមកធ្វើការមិនរួចនោះទេ ។ លើកលែងម្តងទៅណា៎! ព្រោះ សុបិនមានណាត់ភ្ញៀវច្រើនណាស់ ។ កាលបើថៅកែខឹងហើយដេញខ្ញុំចេញ នោះថៅកែក៏ដាច់ម៉ូយធំៗដែរមិនខានឡើយ ។

គិតមួយស្របក់ ថៅកែយូនិក្សក៏មានប្រសាសន៍ឡើង :

- អើហ៎! បើអញ្ចឹង យើងអោយឱកាសឯងម្តងទៀតចុះ តែកុំធ្វើការខ្ជីខ្ជា បាត់ដំណឹងមិនមកធ្វើការដូចពីម្សិលទៀត ឮហើយនៅ?

- បាទថៅកែ ។

សុបិនត្រេកអរណាស់ក៏ស្ទុះចាប់ក្បាលមេក្រូឡើងឆាកភ្លាម ដោយឥត បង្អង់ ។ ថ្ងៃនេះ ចំនួនភ្ញៀវដែលមកបរិភោគអាហារស្តាប់ចំរៀងហាក់ដូច ជាស្ងើយជាងយប់ដំបូងដែលនាយបានមកសំដែង ។ សុបិនហាក់ដូចជាអស់ កំលាំងចិត្តបន្តិចដោយសារប្រជាប្រិយភាពឱនថយ ត្បិតកាលពីលើកមុនៗ មានភ្ញៀវបានមករង់ចាំស្តាប់ជាច្រើនកុះករ ។ ពេលនេះ នាយត្រូវតែប្រើ ជំនាញឯកទេសប្លែកៗថ្មីទៀត ដើម្បីទាក់ទាញអោយភ្ញៀវវិលត្រលប់មក សាជាថ្មី ពុំនោះសោត ថៅកែនឹងដេញនាយចោលហើយ កាលបើនាយធ្វើអោយបាត់បង់ចំនួនភ្ញៀវពីហាងទៅ ។ ភ្លាមនោះ សុបិនក៏បន្លឺនូវសៀងដ៏ ពិរោះបំផុតនូវចំរៀងមួយបទដែលមានអត្ថន័យថា :

ចំរៀងស្នេហា

ឱភាសពណ៌មាសនាព្រឹកព្រលឹម — ហាក់ភ័ក្រ្តញញឹមមុំស្នេហាបង ក្រ
ពីក្បាតូចធំខៀវស្រស់បំព្រង — គិរីជ្រោះជ្រងកំដរគូស្នេហ៍ ។
ឮដំរីវេហាស៍ពពករសាត់ — ជំនោរផាយផាត់ផ្ការីកហួរហៃ
រៀមបីត្រកងឆោមកែវមាសមេ — ច្រៀងលោមបំពេរសំនៀងភិសម័យ ។
ទឹកជ្រោះបែកផ្សែងប្រលែងថ្មដា — ហាក់ជាសញ្ញាពរជ័យសប្បាយ
ពីព្រហ្មទេវតាដល់យើងពីរកាយ — បងនិងឆោមឆាយគូនិត្យភក្តី ។

CHANBOKEO.COM

ឱទឹកជ្រោះអើយ! ជួយចាំស្នេហ៍យើង ឱព្រៃរុងរឿងសូមជាសាក្សី
មេឃអើយសូមចាំពាក្យពេចន៍សំដី គូគាប់ថ្មោងថ្មីសច្ចាស្នេហ៍ពិត ។
ជាតិនេះជាតិណាប្រាថ្នាជាគូ យើងពិតហ៊ានប្តូរស្មគ្រ័ស្មោះនៃបនិត្យ
សូមយល់សុភមង្គលអម្រឹត ស្នេហ៍យើងសុក្រឹតអង្វែងរៀងអើយ ។

ស្នូរទះដៃលាន់រំពងឡើងយ៉ាងទ្រហឹងអឹងអាប់តែម្តង ហាក់បីដូចជា សញ្ញាប្រាប់ដល់សុបិនយើងថា គេម្នាក់ៗពេញចិត្តនឹងបទចំរៀងនេះណាស់ ពេលនោះមុខសុបិនរីកដូចគ្រាប់ជីរត្រូវភ្លៀងអញ្ចឹង ។ រំពេចនោះ ស្រាប់តែមាននារីរូបស្រស់មួយរូបយកដៃស៊ីញ៉ូនាយពីតុអាហារមក ទំនងដូចជាចង់ និយាយជាមួយនាយ ។ នាងមានរូបស្រស់ប្រិមប្រិយគួរអោយចាប់ចិត្តតែ ម្តង ធ្វើអោយបេះដូងកំលោះរំភើបក្រៃលែង ។ នាយយើងក៏ចាប់ច្រៀងបទថ្មីមួយទៀតសំរាប់នាងភ្លាម ។ គេច្រៀងផង ដើរផង សំដៅទៅរក តុរបស់នារីប្រិមប្រិយ៍នោះ :

ផ្កាចំប៉ី

ចំប៉ីរីកស្រស់នៅចុងមែក ត្រអាលត្រេងត្រេករស្មីសូរ្យ
យោលយោគទៅមកតាមជំនោរ សោភ័ណផ្កាផូរផ្ទើលភ្ញមរា ។
ចំប៉ីសាយគន្ធក្រអូបស្ងួន ត្រដែតលែងខ្លួនលើសអស់ផ្កា
បានស្គាល់បានក្រេបក្លិនបុប្ផា ស្មារតីកាយាភ្លាត់ភ្លាំងភ្លឹក ។
ចំប៉ីញញឹមក្រោមសុរិយ៍ ពិដោរសុះសាយព្រលឹមព្រឹក
រូបឯកក្លិនឯកក្រៃពន្លឹក ជួបហើយគេងនឹកផ្សងជួបទៀត ។
ចំប៉ីខេមរាផ្កាល្អឯក រីកស្រស់ចុងមែកយ៉ាងវរនាថ
ឃ្លាតពីចំប៉ីទ្រូងចង្អៀត បន់វិលម្តងទៀតជួបចំប៉ី ។

សំណាងល្អរបស់សុបិនណាស់! ពេលនាយទៅដល់តុនោះ សុបិនបាន ប្រទះឃើញនារីដល់ទៅបីរូប ដែលមានសោភ័ណលក្ខិណាខុសៗគ្នាបំផុត ។ ម្នាក់ស្លៀកពាក់ធម្មតាៗ ពាក់វ៉ែនតាមីញ៉ូប ចងសក់កន្ទុយសេះ មើលទៅមិនស៊ីវិល័យទាល់តែសោះ ។ ម្នាក់ទៀតស្រស់ស្អាតអស្ចារ្យ មិនចាញ់តារា ភាពយន្តល្បីឈ្មោះម្នាក់ឡើយ ទាំងការស្លៀកពាក់ ទាំងឫកពា គឺសក្តិសម ជាបុត្រីត្រកូលអភិជនណាស់ ។ រីឯនារីទីបីវិញ គឺសិចស៊ីដល់កំរិតតែម្តង ។ នាងឆើតឆាយណាស់ ហើយសំដែងកិរិយាហាក់ដូចជាពេញចិត្តនឹងសុបិន ជាងគេបំផុតដែរ ។ គ្រាន់តែក្រលេកឃើញឆោមសម្ផស្សរបស់នារីសោភាប្រិមប្រិយទាំងពីររូប បេះដូងរបស់សុបិនប្រែទន់ជ្រាយអស់រលីង ។ ពេល នោះ ជើងទាំងគូរបស់នាយក៏បាក់លោងរកដើរចេញពីតុមួយនោះមិនរួច សោះ ។ នាយយើងច្រៀងមួយបទហើយមួយបទទៀត ផ្លែផ្កាផ្តោះផ្តងចុះឡើងចំពោះធិតាដ៏ស្រស់ស្អាតទាំងទ្វេកាយាយ៉ាងរីករាយ ។ ចៃដន្យ គ្រា នោះ

CHANBOKEO.COM

នាយមិនបានចាប់ភ្លឹកចំពោះនារីទីបីដែលអង្គុយជាមួយគ្នានោះឡើយ ត្បិតនាងមានរូបសម្បត្តិសាមញ្ញៗពេក
មិនចូលភ្នែកសុបិនបន្តិចឡើយ ។ កាលបើឃើញសុបិនសំដែងឫកពាភ្លើតភ្លើនតែជាមួយនារីឆើតឆាយ ឆវីរូប
នោះក៏អង្គុយធ្វើមុខស្ងួតស្ងើៗ មិនរីករាយអ្វីនឹងគេទេ ។ បន្តិចមក នាងក៏ លួចសរសេរកាតស៊ីញ៉េប្រាប់មិត្តសុំលាចេញមុន
រួចហើយក៏ងើបទៅបាត់ មុនសុបិនច្រៀងចប់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏សុបិនមិនបានចាប់ភ្លឹក នឹងគួរសមជាមួយនារីឡើយ ។
លុះច្រៀងចប់កាលណា ស្នូរទះដៃក៏លាន់ឮ កាន់តែខ្លាំងឡើង មើលទៅទំនងដូចជាភ្ញៀវក្នុងហាងនោះស្គាល់នារីពីររូប
នោះជាក់ច្បាស់ណាស់អញ្ចឹង ។ នៅបទបន្ទាប់មក បុរសនារីអ្នកចំរៀងថ្មី ពីរនាក់ក៏ឡើងមកលើវេទិកាប្តូរវេនអោយសុបិនសំរាក
ធ្វើអោយសុបិនរីក ថ្លើមប្រមាត់ប៉ុនចង្អេរ ត្បិតនាយកំពុងតែចង់មានឱកាសជជែកជាមួយនឹង
នារីឆោមឆាយទាំងពីររូបនោះដល់សួរហើយ ។ បន្តិចមក ក្រមុំរូបស្អាតក៏ ណែនាំខ្លួនឡើងថា :

- សួស្តី បុរសសំលេងមាស! នាងខ្ញុំចាប់អារម្មណ៍ចំពោះសំនៀងរបស់
លោកជាយូរមកហើយ គឺតាំងពីលោកចេញស៊ីឌីលើកដំបូងមកម្ល៉េះ ។ នាង ខ្ញុំឈ្មោះកិរិយាជាកូនស្រីរបស់ថៅកែយូនិក្ស
សូមស្គាល់លោកផង!

អូហ៎ពុទ្ធោ! គឺកូនស្រីថៅកែយូនិក្សម្ចាស់ភោជនីយដ្ឋានទេតើ! អញ្ចឹង តើបានជាមានគេស្គាល់នាងច្រើនម្ល៉េះ! សុបិននឹករំភើបចិត្តមិនតិចទេដែល រូបគេបានច្រៀងផ្តល់កិត្តិយសដល់នាង ដោយចៃដន្យ ចំកូនក្រមុំថៅកែ ។ ពេលនោះ នាយក៏គិតថាអ្វីដែលនាយកំពុងធ្វើនៅពេលនេះ គឺប្រាកដជា ទិញទឹកចិត្តថៅកែអោយស្រទន់កំហឹងចំពោះនាយបន្តិចមិនខាន ។ បន្ទាប់មក កិរិយាក៏ណែនាំខ្លួននារីសិចស៊ីដែលនៅអង្គុយរួមតុ :

- ខាងនេះ គឺអ្នកនាងកល្យាណ មិត្តស្រីរបស់នាងខ្ញុំ
- សួស្តីលោកសុបិន! រីករាយណាស់ដែលបានស្គាល់គ្នា ។

ព្រះអើយ! បេះដូងសុបិនរំភើបភើតផតស្ទើរតែទប់ចិត្តមិនបានកាល
បើខ្លួនបានទទួលនូវការរាក់ទាក់របស់នារីរូបស្រស់ពីអង្គា ។ បុរសយើងក៏ ញញឹមលែងបិទមាត់ជិត ។
កល្យាណមានសំដីរួសរាយណាស់ ធ្វើឱ្យសុបិន លង់អារម្មណ៍យ៉ាងខ្លាំង ។ បន្តិចមក នារីទាំងពីរក៏បំបែកជួរជំរាបលាបុរស
យើងចេញទៅ ទុកអោយនាយនៅឈរសំលឹងពីក្រោយ ទាំងបេះដូងពុះ កញ្ជ្រោលសួរខ្លួនឯងតែម្នាក់ឯងថា :

- តើមួយណាទៅដែលយើងពេញចិត្តជាងគេរវាងក្រមុំពីររូបនេះ?

ម៉ោង១២អាធ្រាត...

សុបិនដូរសំលៀកបំពាក់សំដែងចេញហើយ ក៏ដើរសំដៅរថយន្តរបស់ ខ្លួនដែលទើបទិញថ្មីមួយទៀត
ស្រាប់តែនាយប្រទះឃើញផ្កាកុលាបពណ៌ សមួយទងព្រមទាំងកាតតូចមួយសន្លឹក សៀតនៅជាប់នឹងកញ្ចក់ឡានខាង មុខ ។
មាណពកំលោះក៏ទាញកាតយកមកអានស្រាប់តែភ្ញាក់ព្រើតត្បិតនៅ លើកាតនោះមានសរសេរកំណាព្យ
ទំនងជាបទចំរៀងឆ្លើយឆ្លងក្នុងបទ ចំរៀងអ្វីមួយអញ្ចឹង :

CHANBOKEO.COM

កន្លង់មាស

កន្លង់ត្រេចចរក្នុងសួនច្បារ អួតអង្គរូបល្អប្រណិត
ហើរក្រេបលំអងឥតបើគិត អោយផ្កាវិបរិតព្រួយរីងរៃ ។
មិនដឹងកន្លង់ចិត្តយ៉ាងណា ក្រេបផ្កាហើយត្រេចចររកថ្មី
ឬកន្លង់មាសស្មោះភក្តី ស្នេហ៍ត្រឹមផ្កាស្រីតែមួយទង ។
កន្លង់មាសអើយសែនសង្ហា ផ្កាលួចគេងគិតទ្រូងសៅហ្មង
ឃើញអ្នកត្រេចចរនែបលំអង ផ្កាស្រីមួយទងព្រួយក្នុងប្រាណ ។
មិនដឹងថ្ងៃណាជាប់អន្ទាក់ កន្លង់មានធ្លាក់មករំខាន
ក្រេបលំអងផ្កាស្រីកល្យាណ ធ្លោយចិត្តធ្លោយប្រាណត្បិតស្នេហ៍ក្លែងក្លាយ...

ហត្ថលេខា : ផ្កា

សុបិនអានមិនយល់សោះ មិនដឹងថាអ្នកសរសេរមកនោះគ្រាន់តែ សរសេរជាទំនុកចំរៀងឆ្លើយឆ្លងសួរមករកចំរៀងរបស់នាយ ឬក៏មានន័យ យ៉ាងណាទៅវិញទេ ។ នាយបោះកាតចោលហើយក៏ដកផ្កាយកមកថើប ។
រំពេចនោះស្រាប់តែសុបិនជ្រួញចិញ្ចើមឡើង ហើយក៏បោះផ្កាចោលភ្លាម ដែរ ។ មែនហើយ ពេលនោះនាយកំពុងនឹកគិតភ័យខ្លួនខ្លាចទទួលផ្កា ប៉ះចំ ម្ចាស់ដែលជានារីអារាត់អារាយណាក៏មិនដឹង ។

ព្រឹកស្អែកឡើង...

សុបិនទាញទូរសព្ទ័សូមការណាត់ជួបជាមួយកញ្ញារូបស្រស់គិរិយា :

- សួស្តី! ឆវីរូបស្រស់! ខ្ញុំសុបិន... គិតថាចង់បបួលអ្នកនាងទៅដើរលេង...
- សូមទោស លោកសុបិន! ថ្ងៃនេះគិរិយាជាប់រវល់មានកិច្ចការបន្តិច មិន អាចទៅជាមួយលោកបានទេ ចាំថ្ងៃក្រោយបានទេ?...

សុបិនទំលាក់ទូរសព្ទ័ចុះ នឹកខកចិត្តស្រលេតតែម្តង ។ តែណ្ហើយ! នៅ សល់ស្រីស្រស់ម្នាក់ទៀត គឺកញ្ញាកល្យាណ :

- អាឡូ! ជំរាបសួរអ្នកនាងកល្យាណ! នេះខ្ញុំសុបិន! អ្នកនាងទំនេរទេ?
- ចាំ! ជំរាបសួរលោកសុបិន ។ លោកចង់ជួបខ្ញុំមានកិច្ចការអ្វីដែរ?

នៅភោជនីយដ្ឋានអណ្តែតទឹកមួយ...

សុបិនដើរចុះពីរថយន្ត ដោយមានកាន់ផ្កាមួយបាច់យ៉ាងស្អាតមកជា មួយផង
សំដៅទៅកាន់តុមួយដែលមាននារីរូបស្រស់សោភាមួយរូបកំពុង រង់ចាំស្រេចតែម្តង :

- អ្នកនាងកល្យាណ!
- អូហ៍... លោកសុបិន!
- នេះគឺបាច់ផ្កាចំពោះអ្នកនាង!
- ស្រស់ស្អាតណាស់! តើលោកអោយផ្កាមកខ្ញុំនេះក្នុងឱកាសអ្វីដែរ?
- គឺ... ( សុបិនខំរកនឹកពាក្យឆ្លើយ ត្បិតមិនបានព្រាងទុកចំលើយជាមុនថា

CHANBOKEO.COM

កល្យាណនឹងសួរដូច្នោះ) គឺ ក្នុងឱកាសដែលយើងចាប់ដៃសាងមិត្តភាពនឹង
គ្នាជាលើកដំបូងនោះអី!

ឮដូច្នោះ កល្យាណញញឹមឡើងបំព្រង ។ ថ្ងៃនោះសុបិនរីករាយណាស់ ដែលកល្យាណរាប់អានរូបគេដោយមិនឆ្មើងឆ្មៃ
ទំនងប្រហែលជានារីយើង ពេញចិត្តនឹងសុបិនដែរហើយ ។

នៅអាទិត្យបន្ទាប់ៗមក សុបិនតែងឃើញកិរិយានិងកល្យាណតែងតែ ទៅជួយលើកទឹកចិត្តរូបគេនៅកន្លែងច្រៀងជានិច្ច
ធ្វើអោយសុបិនរិតតែ គិតវង្វេងម្នាក់ឯងថា ខ្លួនជាមនុស្សមានវាសនាខ្ពស់ក្រៃលែងដែលមាននារី
ត្រកូលអភិជនមកចាប់អារម្មណ៍ចំពោះរូបនាយយ៉ាងពិសេស ។

បីអាទិត្យកន្លងទៅ...

ថ្ងៃនេះសុបិនចេញទៅលេងនៅឯកំពង់សោមជាមួយមិត្តភក្តិពីរបីនាក់ ស្រាប់តែមានទូរសព្ទ័ពីថៅកែយូនិក្សចូលមក...

- សុបិន?

- បាទ ថៅកែ!

- ថ្ងៃស្អែកល្ងាចត្រូវត្រលប់មកច្រៀងជាពិសេស នៅភោជនីយដ្ឋានរបស់ យើង
ត្បិតយើងមានកម្មវិធីពិសេសមួយដែលម្ចាស់កម្មវិធីបានប្រាប់ថាត្រូវ អញ្ជើញសុបិនឯងមកច្រៀងជាកិត្តិយសផង...

- តែស្អែកនេះជាថ្ងៃឈប់សំរាករបស់ខ្ញុំតើហ៍ ថៅកែ...?

- អឺដឹងហើយ... យើងហៅឯងអោយមកវិញ ក៏ព្រោះតែយើងនេះទទួល
កម្មវិធីពិសេសពីភ្ញៀវដែលជាឧត្តមសេនិយ៍ផង ទើបប្រកែកមិនបាន ដូច្នេះ
សូមឯងមកកុំខានឮទេ?

- បាទៗ ថៅកែ ។

សុបិនឆ្លើយទាំងទើសទាក់ ត្បិតកំពុងតែដើរលេងសប្បាយមិនចង់វិល ត្រលប់ទៅធ្វើការវិញទេ ។ ស្អែកឡើង
នាយយើងក៏វិលមកភ្នំពេញវិញ ។ ប៉ុន្តែដោយចិត្តមិនចង់ស្រាប់ផង សុបិនមិនបានត្រៀមខ្លួនត្រឹមត្រូវដូចសព្វ ដងទេ ។
នាយផ្លាស់សំលៀកបំពាក់ឡើងសំដែង ទាំងចិត្តធុញថប់បំផុត ។ លុះនាយចាប់មេក្រូឡើងដល់លើឆាក បំរុងនឹងផ្តើមចំរៀង
ស្រាប់តែភ្ញាក់ ព្រើតព្រោះពិធីនោះ គឺជាពិធីភ្ជាប់ពាក្យរបស់កូនចៅអភិជនមហាសេដ្ឋីនិង កូនលោកឧត្តមសេនិយ៍ផង ។
រីឯកូនក្រមុំក៏មិនមែននរណាក្រៅពីនារីមួយ រូបឈ្មោះកល្យាណ ដែលបានធ្វើអោយបេះដូងរបស់នាយញាប់ញ័រអស់ជា
ច្រើនអាទិត្យមកហើយនោះទេ ។ គេលាន់មាត់ខ្សិបៗតែម្នាក់ឯងថា :

- កល្យាណ? បើអ្នកនាងបំរុងនឹងភ្ជាប់ទៅហើយ តើអ្នកនាងមកលលេង ច្របាច់បេះដូងរបស់ខ្ញុំអោយខ្ទេចខ្ទាំធ្វើអ្វី??

កល្យាណក្រលេកឃើញសុបិនថ្លោះទឹកមុខ ក៏ហាក់ចាប់អារម្មណ៍ខ្លះ ដែរតែដោយសារភាពអ៊ូអរនៃពិធីភ្ជាប់ពាក្យ
នាងក៏បែកអារម្មណ៍រសាយពី សុបិនទៅ ។ ពេលនោះគ្មាននរណាចាប់ភ្លឹកទេថា អ្នកទាំងពីរកំពុងតែលួច
សំលឹងគ្នាទៅវិញទៅមកភ្លេកៗ ។ បន្តិចមក កល្យាណលួចខ្សិបក្នុងចិត្តតែ ម្នាក់ឯងថា :

CHANBOKEO.COM

- សូមទោសណាស់សុបិន ដែលខ្ញុំមិនអាចទទួលសុបិនបាន... ព្រោះសង្គមនិង វណ្ណៈគ្រួសាររបស់យើងឃ្លាតឆ្ងាយគ្នាពេក... ចាស់ៗខាងខ្ញុំពិតជាមិនអាច ទទួលលោកធ្វើជាកូនប្រសារបានទេ... ទោះបីជារូបខ្ញុំពេញចិត្តចំពោះរូប លោកយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនអាចទទួលយករូបលោកដោយបោះបង់ អ្នកមានគុណរបស់ខ្ញុំចោលបានដែរ... ម្យ៉ាងទៀត បុរសដែលជាគូដណ្ដឹង របស់ខ្ញុំក៏មានលក្ខណៈវិសេសខ្លះៗដែលសុបិនមិនមាន។ ដូច្នេះ ការចែក ផ្លូវគ្នារវាងយើងត្រឹមនេះ មិនជាការអាក្រក់មើលពេកនោះទេ។

ពេលនោះ សុបិនឈឺចាប់ណាស់ហើយនឹកអាមាសក្នុងចិត្តពេកក្រៃ។ គេក៏ឡើងច្រៀងចំរៀងដ៏ប្លែកមួយបទថា :

វណ្ណៈស្នេហ៍

ជញ្ជាំងវណ្ណៈប្រាក់ដុល្លារ យាយីប្រហារស្នេហាខ្ញុំ
កាត់យកបេះដូងទាំងបង្ខំ បំបែករូបមុំពីទ្រូងទៅ។
គ្រាមុនគិតថាស្នេហាពិត ឥលូវវិបរិតសោកហ្មងសៅ
អំណាចវណ្ណៈកាចពេកកូវ ពង្រាត់រូបពៅពីបងហើយ។
សែនស្តាយដួងចិត្តដ៏ភក្តី ប្រគល់ជូនស្រីកែវត្រាណត្រើយ
ថ្ងៃនេះនួនបែរប្រែកន្តើយ បេះដូងព្រាត់ហើយពីឱរា។
ផ្គរលាន់គ្រឹមៗពេញដើមទ្រូង ហាក់បីអន្លូងទូងទ័យា
ដាស់ប្រាប់ចំលើយដល់ពំងា គ្រានេះបងលាទាំងអាល័យ...!

ភ្ញៀវទាំងអស់សុទ្ធតែមានអារម្មណ៍ប្លែកៗ កាលបើគេបានឮចំរៀង១ បទនេះ។ ខ្លះទះដៃអបអរ ត្បិតនាយយើងច្រៀងបានល្អហើយពិរោះឥត ខ្ចោះ។ ខ្លះទៀតនឹកថាថ្ងៃនេះជាថ្ងៃមង្គល មិនគួរណានាយច្រៀងចំរៀង ខកចិត្តនោះទេ។ តែក៏មានអ្នកចាប់ភ្លឹកខ្លាំងជាងនេះដែរដូចជាចាស់ៗខាង កូនកំលោះតែម្ដង។ បន្តិចមក គេក៏លួចខ្សិបថៅកែអោយហៅសុបិនចុះពី លើឆាកហើយលែងឱ្យឡើងច្រៀងតទៅទៀត។ តែសុបិនមួម៉ៅពេកក៏នៅ ជជេសច្រៀងថែមបន្តពីរបីបទ ដាក់ផ្លែដាក់ផ្កាចំពោះកញ្ញាកល្យាណទាល់ តែអស់ចិត្តទើបដើរចុះពីវេទិកាដោយខ្លួនឯង។ នៅខាងក្រោយវេទិកា សុបិនស្រវាកែវស្រាលើកអកក្អឹកៗអស់សន្ធឹកកែវហើយ ដើម្បីបំភ្លេចរឿង ស្នេហាខកចិត្តតែក៏ធ្វើមិនបាន... គឺកាន់តែផឹក កាន់តែនឹកខឹងដល់កល្យាណ ទ្វេឡើងតែម្ដង។

ពិធីមង្គលចប់សព្វគ្រប់ហើយ...

ភោជនីយដ្ឋានក៏ចាប់បិទទ្វារបោសសំអាតរៀបចំទុកដាក់ដែរ។ សុបិន ដើរសំដៅមករករថយន្តដែលចតនៅខាងក្រៅក្បែរមាត់ទន្លេ។ រំពេចនោះ ស្រាប់តែមានបុរសពីរបីនាក់ក្នុងទឹកមុខកាចៗបានលេចធ្លោមកដល់ :

CHANBOKEO.COM

- នែ៎ អាប្អូន! ឯងអាងស្អីបានជាហ៊ានប្រលែងលេងនឹងពុកមាត់ខ្លា?

សុបិនកំពុងតែស្រវឹងធ្លាក់ភ្នែក មិនបានស្គាល់ថានរណាជានរណាទេ គេក៏ឆ្លើយវិញថា :

- សុបិនមិនដែលស្គាល់ខ្លាហើយមិនចង់នៅបៀតខ្លាផង ។ សូមចៀសផ្លូវ!

- ដើ! សំដីធំផងហ្អែស នាយសុបិន?

ផាំង! សុបិនមិនបានប្រុងខ្លួន ក៏ត្រូវនាយនោះធាក់មួយជើងដួលខ្ពាក មួយរំពេច :

- ហេតុអីឯង.. មកវាយយើងដូច្នេះ? (សុបិនក្រោកងើបតតេះតតះ)

- ថ្ងៃនេះឯងឡើងច្រៀងបំបាក់មុខលោកវិសុទ្ធ ចៅហ្វាយនាយរបស់យើង ពេលនេះត្រូវតែអោយមេរៀនខ្លះទើបបាន... ដើម្បីឱ្យឯងបានដឹងថាគំនូស

ព្រំដែនរបស់ឯងមានកំរិតត្រឹមណា?

ផាំង! ផាំង! សុបិនត្រូវពីរបីជើងទៀត យ៉ាងដំណំ ។ មួយស្របក់

ក្រោយមក មនុស្សប្រុសទាំងនេះ ក៏ចាប់សុបិនបោះព្រមៀលចោលតាម ច្រាំងទន្លេហើយក៏ចាកចេញទៅ...

សុបិនបើកភ្នែកឡើង ស្រាប់តែឃើញថ្ងៃរះស្រលះ រួចឃើញខ្លួននាយ

បានមកដល់ផ្ទះទ្រុឌទ្រោមរបស់ដូនចាស់នោះវិញដដែល ។ សុបិនយកដៃ ឈ្លីភ្នែកម្តងហើយម្តងទៀត ចង់ដឹងថា តើនាយកំពុងតែយល់សប្តិឬមួយ ក៏យ៉ាងណា? ហេតុអ្វីក៏នាយត្រលប់មកដល់ទីនោះសាជាថ្មី? ច្បាស់ជាមិន មែនយល់សប្តិទេ ព្រោះពេលនោះនាយមានអារម្មណ៍ថា កំពុងឈឺចាប់ អស់ពេញទាំងខ្លួនលែងនិយាយហើយ ។ ភ្លាមនោះដូនចាស់ក៏បានមកដល់ :

- ចៅអើយ! ហេតុអ្វីបានជាត្រូវគេវាយដំទ្រុឌទ្រោមយ៉ាងនេះ? ឈ្លោះ នឹងអ្នកណាមែនទេហ៍?

ដូនចាស់មានប្រសាសន៍ផងយកកន្សែងពោះគោជ្រលក់ទឹកក្តៅឧណ្ហៗ មកជូតខ្លួនអោយនាយផង ។ សុបិនមិនឆ្លើយទេ ត្បិតនាយកំពុងតែមាន អារម្មណ៍សើងមើងនៅឡើយ ។ ដូនចាស់ក៏មានប្រសាសន៍បន្តថា :

- មើលទៅលើកនេះ ដូចជាធ្ងន់ជាងលើកមុនឆ្ងាយណាស់ ។ ចៅប្រហែល

ជាត្រូវឈឺគេងកន្ទេលយូរថ្ងៃទៀតហើយទើបជាសះស្បើយវិញ...

មែនហើយ.. នោះក៏ព្រោះតែការខ្វះសតិរបស់នាយដែរ ដែលបណ្តាល អោយរូបនាយទទួលរងទណ្ឌកម្មដូច្នោះ ។ សុបិនមិនហ៊ានមាត់ទេត្បិតដឹង ខ្លួនខុស ។ រំពេចនោះ នាយក៏បើកភ្នែកបែរមើលជុំវិញខ្លួន ហាក់ដូចជាកំពុង សំលឹងរកនរណាម្នាក់ ។ ដូនចាស់ឃើញដូច្នោះ ក៏កាត់យល់ភ្លាម :

- នាងល្អងគេមិននៅទេចៅ! គេទៅធ្វើការហើយ មិនបាច់ខ្វាចចិត្តទេណ៎!

សុបិនឮដូច្នោះ ហាក់ដូចជាធូរពោះបន្តិច ហើយនឹកគិតក្នុងចិត្តថា :

- មិនបានជួបនោះប្រសើរហើយ ព្រោះខ្ញុំមិនចង់ជួបមុខនាងទេ រូបសម្បត្តិ ក៏យ៉ាប់ សំដីក៏ពិបាកស្តាប់

ហើយថែមទាំងជាអ្នកក្រទៀត...

CHANBOKEO.COM

ភ្លាមនោះ ដូនចាស់ស្រវាឆ្វឹតស្រទបស្លាមួយមកអង្គុយបក់ឱ្យសុបិន ថ្នមៗ មួយៗ ជួយដេញមូស កុំអោយមករំខានដំណេករបស់បុរសយើង ធ្វើ អោយបុរសយើងបែរជាមានអារម្មណ៍ចំលែកហើយនឹកក្នុងចិត្តថា :

- ហេតុអ្វីដូនចាស់មួយរូបនេះ មានសំដីពិរោះ សន្តានចិត្តល្អ តែនាងក្រមុំ ម្នាក់នោះបែរជាមានឫកពាហាក់ដូចជារមាំងរមោកគំរោះគំរើយរកលេខ ដាក់គ្នានទៅវិញ គឺផ្ទុយស្រលះពីជីដូនរបស់នាងដូចមេឃនិងដីតចឹង ។

បន្តិចមក នាយយើងក៏សួរដូនចាស់ថា :

- យាយ! ហេតុអ្វីបានជាខ្ញុំមកដល់ទីនេះ?

- គឺ នាងល្អងវាឃើញឯងដេកសន្លប់នៅមាត់ទន្លេពេលវាចេញពីធ្វើការមក ហើយឃើញចៅមានរបួសផង ទើបគ្រាហ៏ឯងដាក់រទេះរុញយកមកដល់ ផ្ទះទៅ ។

- ចៅស្រីរបស់យាយទៀតហើយ? ហេតុអ្វីក៏ចៃដន្យម្លេះហ្ន៎?

- អឺ! សំណាងចៅហើយ ដែលនាងល្អងគេដើរតាមផ្លូវនោះទៅមកធ្វើការ រាល់ថ្ងៃ បើសិនជាគេដើរផ្លូវផ្សេងវិញនោះ ប្រហែលជាមិនបានប្រទះចៅ ទេ កុំអី... ចៅឯងពិបាកធំហើយ!

ពេលនោះ សុបិននឹកអរក្នុងចិត្តផង ដែលខ្លួនមានមនុស្សមកជួយយក អាសារទាន់ពេល តែក៏ខកចិត្តបន្តិចដែរត្បិតអ្នកដែលជួយយកអាសារនោះ ជាមនុស្សដែលសុបិនគ្មាននិស្ស័យនឹងចងមិត្តជាមួយទាល់តែសោះ ។ សុបិន នឹកធុញថប់ក្នុងចិត្តយ៉ាងណាមិនដឹង និយាយមិនត្រូវសោះ ។ ម្យ៉ាងទៀត នាយក៏ហាក់ដូចជាមិនទាន់អស់ជាតិស្រវឹងពីខ្លួននៅឡើយទេ ។ គេមាន អារម្មណ៍ធឹងធោងណាស់ ម្ល៉ោះហើយក៏សំងំធ្មេចយកកំលាំងវិញ ។ មិនដឹង ជាលក់យូរប៉ុណ្ណាទេ លុះដល់សុបិនបើកភ្នែកសាជាថ្មីឃើញរសៀលថ្ងៃជ្រេ ទៅហើយ ។ នាយយើងភ្ញាក់ព្រើតខំក្រោកស្ទុះយ៉ាងរហ័ស តែក៏ងើបទាំង លំបាក ត្បិតនាយមានរបួសយ៉ាងដំណំនៅលើប្រាណដោយសារកំលាំងទាត់ ធាក់របស់មាឌធំៗប៉ុន្មាននាក់នោះ ។ ការពិតសុបិនជាបុរសមាឌធំសង្ហាមួយ រូបហើយក៏ជាអ្នកកីឡាចំណាប់គួរសមដែរ ។ ចៃដន្យ នាយបានរងគ្រោះ ថ្នាក់ដល់ទៅពីរដង ដោយសារស្មារតីធ្វេសប្រហែសរបស់នាយ កុំអីសុបិន ច្បាស់ជាបានសម្តែងឫទ្ធិឱ្យមើលមិនខាន ។ បន្តិចមក មាណពក៏ងើបចុះពី គ្រែរនាបដើរទប់ខ្លួនតាមជញ្ជាំងចេញទៅក្រៅរកម្ចាស់ផ្ទះ ស្រាប់តែឃើញ ស្ងាត់ច្រៀប គ្មាននរណានៅម្នាក់សោះឡើយ ។ នាយយើងនឹកឆ្ងល់ណាស់ ក៏បែរមើលជុំវិញទីនោះ តែមិនឃើញនរណាម្នាក់ដដែល ។ លុះនាយដើរ ត្រលប់ចូលទៅក្នុងផ្ទះវិញ ក៏ប្រទះស្លក បាយសម្លគ្របចោលនៅកូនតុឈើ មួយក្បែរគ្រែរបស់នាយថែមទាំងមានក្រដាសតូចមួយសរសេរប្រាប់ថា :

- សូមទោសដែលយើងមិននៅផ្ទះ ត្បិតមានការផ្ទាល់ខ្លួន ។ យើងបានរៀប អាហារ ព្រមទាំងថ្នាំបំបាត់ការឈឺចាប់ចំនួនបួនគ្រាប់ ទុកជូនលោកពិសារ សង្ឃឹមថាលោកមិនខ្ពើមរអើមអាហារអ្នកក្រទេ ។ លំអង!...

អានសំបុត្រចប់ សុបិនក៏លាន់មាត់ឡើង :

CHANBOKEO.COM

- យី! នាងចេះសរសេរអក្សរបានស្អាតណាស់តើហ៎...

សុបិនក៏បើកគំរបស្ពកអាហារសំលឹងមើលម្ហូប ឃើញមានតែកូនត្រី ចង្វារចៀននិងបាយមួយចានតែប៉ុណ្ណោះ។ បុរសយើងជ្រួញចិញ្ចើមធ្វើមុខ ជូរនឹករកផ្លូវគេចទៅផ្ទះវិញក៏ទៅមិនរួច ណាមួយទ្រោមក៏ទ្រោម ហេវក៏ ហេវ ហើយ...លុយកាក់...ខោអាវរបស់នាយទៀតសោត គឺអស់រលីងដូច ថ្ងៃមុនឥចឹង...ត្រូវគេសំរាតយកអស់គ្មានសល់ទេ។ រំពេចនោះ បុរសយើង នឹកគិតផ្តេសផ្តាសថា :

- មិនដឹងថាពួកជើងកាងទាំងនោះសំរាតខោអាវយកកាបូបលុយយើងឬក៏ នាងលំអងក្រមុំម្ចាស់ផ្ទះនេះ ជាអ្នកលួចកាបូបលុយយើង នៅពេលយើង កំពុងបាត់ស្មារតី? អ្នកក្រយ៉ាងនេះ ស្អីក៏ហ៊ានធ្វើដែរ អោយតែបានប្រាក់... មើលទៅមិនគួរអោយទុកចិត្តសោះឡើយ។

ដោយហេតុសុបិនហេវបាយពេក នឹងទ្រាំវាយឬករើសអើងយូរទៀត មិនបានឡើយ។ នាយក៏ប្រឹងទំពារបាយកកជាមួយកូនត្រីចង្វារចៀនទាំង ត្រដររហូតដល់អស់បាយពីចាន។ បន្តិចមក នាយក៏ប្រាសខ្លួនគេងវិញ រក នឹកសាជាថ្មី ថាខ្លួននាយត្រូវរកមធ្យោបាយអ្វីដើម្បីអោយបានទៅដល់ផ្ទះ របស់ខ្លួនវិញឆាប់ៗ។ កំពុងតែគិតស្រាប់តែនាយយើងបានឮសំលេងនារី ម្នាក់ច្រៀងរហ៊ឹមៗពីចំងាយ រសាត់តាមខ្យល់មកដល់ ធ្វើអោយនាយយើង ចាប់ភ្លឹកភ្លាមតែម្តង។ សំនៀងរបស់នាងពិតជាពិរោះមែន... បើសិនបាន ឡើងច្រៀងជាដៃគូរបស់នាយនៅលើវេទិកា ប្រហែលជាសក្តិសមគ្នាពេក ក្រៃ។ សុបិនលួចផ្ទៀងស្តាប់ទាំងចិត្តអំណរ :

សុំត្រឹមសុបិនឃើញបង

១. មិនបាននៅនែបនិត្យ ក៏ស្រីវរមិត្តសុំត្រឹមសុបិន
ស្រម័យអាល័យប្រុសថ្លៃមាសឆ្អិន ទេវបុត្រភូមរិន្ទ ម្ចាស់ដួងចិន្តា។

២. ស្នេហ៍គេមិនដឹងខ្លួន លបលួចលាក់ពួន វិយោគអាត្មា
លួចគេងសុបិន នឹកដល់រៀមរ៉ា រាល់ពេលសន្ធិយា និទ្រាទឹកភ្នែក។

បន្ទរ. សង្ឃឹមថ្ងៃស្អែក (ស្រីបន្ទរ. ជួបប្រុសល្អឯក)
ចូលមករំលែក (ស្រីបន្ទរ. ទុក្ខព្រួយសង្វេគ)
រំពឹងថ្ងៃស្អែក ក្រែងជួបដូចប្រាថ្នាអើយ...

សុបិនក៏លួចច្រៀងតបវិញម្នាក់ឯងខ្សិបៗទៅម្ចាស់សំនៀងថា :

ក្លិនផ្កាស្នេហ៍

| | | |
|---|---|---|
| ១. | ផ្កាអើយក្រអូបជិតនាសា | សាយក្លិនគន្ធា គាប់ដួងថៃ |
| | បានត្រកងនែបក្លិនពិសី | ក្នុងដួងហឫទ័យសែនញាប់ញ័រ។ |
| ២. | ផ្កាអើយក្រអូបគ្មានរសាយ | ស្រូបហើយសប្បាយកាយត្រេកអរ |
| | ផ្ការីកឥតមែកពិដោរចរ | គន្ធាកេសរអង្វរស្នេហ៍។ |

បន្ទរ. ឱ! ផ្កាក្រពុំដើមឯណា? ម្ដេចរសគន្ធាទេពម្ល៉េះទេ?
បេះដូងកវីលង់ចិត្តស្នេហ៍ ផ្សងសូមថ្នមថៃផ្កាឥតមែក ។
៣. គ្រប់ជាតិរៀមសូមប្រាថ្នាស្នេហ៍ ផ្កាស្រស់វរលក្ខណ៍ល្អចំលែក
ពិដោរត្រកាលវិសាលឯក ចិន្ដារំលែងត្រេកក្លិនផ្កាស្នេហ៍ ។

រំពេចនោះ សុបិននឹកភ្ញាកចង់ទៅរកលួចមើលថាតើម្ចាស់សំនៀងជា នរណា ហេតុអ្វីក៏ច្រៀងពិរោះពេញចិត្តបុរសយើងម្ល៉េះ? នាយក៏ងើបលបៗ
ទៅលួចអើតមើលតាមបង្អួចទៅខាងក្រោយផ្ទះ ឃើញស្រមោលមនុស្ស ស្រីមួយរូបព្រាលៗ
តាមចន្លោះស្លឹកត្របែកស្លឹកឡៀបដែលដាំនៅក្រោយ ផ្ទះ ។ សុបិននឹកពិភាល់ក្នុងចិត្តយ៉ាងណាមិនដឹង ក៏លបដើរតតេះតតះចេញ
ពីផ្ទះសំដៅទៅរកម្ចាស់ស្រមោល ។ នៅក្រោយគុម្ពផ្កាម្លុលធំៗ សុបិនដកក
លួចមើលឃើញនារីមួយរូបចងពុងអង្គុយលើស្ពានឫស្សីទំលាក់ជើងទៅក្នុង ស្រះឈូកមួយដែលមានទឹកថ្លាឆ្វេង ។
ធិតាអង្គុយបែរខ្នងមកសុបិន កៀង សក់ទំលាក់ទៅខាងមុខបញ្ចេញសាច់សខ្ចីរលោងចាំងភ្នែកកំលោះយើង ធ្វើ
អោយបេះដូងបុរសកំរើកឱបឌាក់ៗញាប់ញ័រ ដោយដួងចិត្តប្រតិពទ្ធ័យ៉ាង ចំលែករកស្មានមិនត្រូវ ។ សុបិននឹកគិតតែម្នាក់ឯងថា :
- តើនាងជានរណាទៅហ្ន៎? ហេតុអ្វីក៏មានរូបរាងទ្រង់ទ្រាយស្រស់ស្អាតដូច ទេពធិតាម្ល៉េះ? ចុះមុខមាត់របស់នាងយ៉ាងណាដែរ?

សុបិនស្រម័យឃើញធិតាមួយរូបនោះមានវង់ភក្ត្រ័ដ៏ស្រស់ស្អាតហើយ ញញឹមយ៉ាងស្រស់មករកនាយ ។
- ឬមួយក៏នារីម្នាក់នោះជា?... ពុទ្ធោ...!

ភ្លាមនោះ សុបិននឹកភ្ញាកដល់នាងលំអងចៅស្រីដូនចាស់មួយរូបនោះ
ធ្វើអោយនាយក៏ស្រកស្រុតទឹកចិត្តរំភើបអំបាញមិញអស់រលីងតែម្ដង រួចក៏ បែរដើរឆ្កយចូលផ្ទះវិញដោយអស់កំលាំងចិត្ត
ថែមទាំងនឹកថា :
- គួរអោយស្ដាយណាស់ បើធិតាដ៏សោភាជានាងលំអងដ៏គំរោះគំរើយនោះ
ពិតមែន ។ ណ្ហើយចុះ! យើងមិនត្រូវលង់ស្នេហ៍សព្វបើនារីក្រីក្រមានជំងឺ ភ្នែកនោះឡើយ ។ ខ្វះអ្វីស្រីល្អៗក្នុងលោក...
រូបប្រហែលសុបិននេះ មិនខ្វះ
ទេមនុស្សស្រីអ្នកមានហើយស្អាតៗតម្រង់ជួរសុំស្នេហា...

ស្រាប់តែ នាយនឹកភ្ញាកទៅដល់កល្យាណ ហើយក៏នឹកខ្មាសខ្លួនសាជាថ្មី
ថែមទាំងបន្ទោសខ្លួនឯងថា :
- សុបិនអើយ! ថ្ងៃក្រោយកុំលីលាផឹកស្រាបាត់ស្មារតីដូច្នេះទៀត ។ បើសិន ជាអ្នកបាត់បង់សេចក្ដីថ្លៃថ្នូរហើយ
នាយក៏នឹងបាត់បង់ប្រិយភាពដែរ ។

CHANBOKEO.COM

គិតដល់ត្រង់នេះ មាណពប្រឹងបិទភ្នែក បិទទ្វារដួងចិត្តប្រឹងបំភ្លេច ស្រីស្រស់កល្យាណចេញពីអារម្មណ៍... មួយស្របក់ក្រោយមក នាយក៏ឮ សូរសិរ៍បជើងដើរចូលមកក្នុងផ្ទះ ។ សុបិនមិនបើកភ្នែកមើលទេ ត្បិតនាយ គិតថាគ្មាននរណាក្រៅពីដូនចាស់ម្ចាស់ផ្ទះនោះឡើយ ។ ពេលនោះ បុរស យើងនឹកអរភើតពោះតែម្តង :

- ហោចណាស់ក៏ដូនចាស់មួយរូបនេះមានសទ្ធាខ្ពស់ ធ្វើអោយយើងស្រាក ស្រាន្តទុក្ខកង្វល់ជានិច្ច មិនថាផ្លូវកាយឬផ្លូវចិត្តទេ ពេលយើងនៅក្បែរគាត់ យើងមានអារម្មណ៍ថា មានម្តាយមួយរូបដែលតែងតែគ្រងរក្សារូបយើង អោយមានសេចក្តីសុខជានិច្ច ។

សុបិនក៏ធ្មេចភ្នែកគេងធ្វើមិនដឹង ។ ស្រាប់តែមានដៃមួយមកស្ទាប ថ្ងាសនាយ ហើយក៏ទាញក្រមាដណ្តប់អោយ រួចហើយក៏យកផ្ចិតមកអង្គុយ បក់ផ្ទមៗបបោសខ្យល់រំភើយៗមកលើខ្លួនសុបិន ធ្វើឱ្យនាយយើងមាន អារម្មណ៍ស្រទន់ រកលង់លក់ជាថ្មី ។

បន្តិចមក នាយក៏បើកភ្នែកប្រែខ្លួន បំរុងនឹងរកសួរអ្វីទៅហើយ ស្រាប់ តែភ្ញាក់ស្រលាំងកាំងតែម្តង ព្រោះអ្នកដែលអង្គុយបក់ផ្ចិតអោយនាយនោះ មិនមែនជាដូនចាស់ឯណា ។ ការពិត គឺនាងលំអងចៅស្រីរបស់គាត់ទេតើ ពុទ្ធោអើយ!

លុះឃើញសុបិនប្រែខ្លួនបើកភ្នែកបែរមកសំលឹងចំនាង លំអងស្រវា យកក្រមាលើកទទូរក្បាលរុំមុខដើរត្រុយចេញទៅក្រៅយ៉ាងរហ័ស ដោយ មិនមានស្រដីអ្វីមួយម៉ាត់ជាមួយមាណពឡើយ ។ សុបិនធ្វើមុខភាំង ត្បិត មិនឃើញនាងវាចាអ្វីជាមួយនាយសោះ ។ ភ្លាមនោះ មាណពក៏ញញឹម ឡើង ហើយគិតក្នុងចិត្តថា :

- យើហ៎! ថ្ងៃនេះចិត្តល្អម្ល៉េះ មកលួចបំរើយើង? ឬក៏ជីដូនប្រើមក៍? ឬក៏ នាងកំពុងលង់ស្នេហ៍នឹងភាពសង្ហាររបស់យើង? ថាមិនត្រូវដែរ... បើមិន ដូច្នោះទេ ហេតុអ្វីក៏នាងបន្ទន់កិរិយាបថមកបំរើយើងដូច្នេះហ្ន៎?

សុបិននឹកពិភាល់ចង់ដឹងចំលើយណាស់ តែមិនដឹងថាត្រូវធ្វើយ៉ាងណា នឹងបានចំលើយ ។ រំពេចនោះ នាយក៏សួរទៅធិតាថា :

- លំអង! យាយគាត់មិននៅផ្ទះទេហ៎?

លំអងគ្រវីក្បាល :

- ថ្ងៃនេះថ្ងៃសីល គាត់ទៅសុំសីលនៅវត្តបាត់ទៅហើយ ។

- អូហ៎... អញ្ចឹងនាងត្រូវនៅផ្ទះតែម្នាក់ឯងហើយ ។

សុបិននិយាយផង ដើរចេញមកក្រៅផង ទំនងចង់មកអង្គុយលើរាន ឬស្សីជិតធិតាយើងដើម្បីសន្ទនា ។ ភ្លាមនោះសុបិនក៏ពោលបន្តថា :

- នាងមិនខ្លាចទេហ៎ ដែលត្រូវនៅផ្ទះម្នាក់ឯង?

- ខ្លាច ម៉េចក៏ថាមិនខ្លាច? មនុស្សសម័យឥលូវនេះទុកចិត្តមិនបានទេ...

- ចុះនាងខ្លាចខ្ញុំដែរទេហ៎?

- អត់ទេ... មើលទៅលោកដូចជាទ្រុឌទ្រោមណាស់ ម្យ៉ាងទៀត ខ្ញុំគិតថា លោកមិនយកខ្លួនមកប្រលាក់ប្រលូសជាមួយស្រីអ្នកក្រដូចខ្ញុំនេះទេ...

CHANBOKEO.COM

ចំចំណុចខ្សោយ សុបិនបើកភ្នែកមូលក្លំនឹកក្នុងចិត្តថា:

- យី! នាងប៊ុនទាយមែនតើហ៎! គឺដូចមើលឃើញអញ្ចឹង! រូបនាងមិនមែន
ជានារីក្នុងក្តីស្រម៍យរបស់សុបិនឡើយ ទុកចិត្តចុះ ខ្ញុំពិតជាមិនធ្វើអ្វីនាងទេ

បន្តិចមកសុបិនក៏សួរបន្ថែមថា :

- ចុះថ្ងៃនេះ នាងមិនទៅលាងចានអោយគេទេហ៎?

- ខ្ញុំសុំគេឈប់សំរាក ត្បិតយាយគាត់មិនទៅ គ្មាននរណាមើលផ្ទះ...

ឮប្រយោគនេះ សុបិនក៏កាត់យល់ទៅហើយថា នាងត្រូវជីដូនចាប់ឱ្យ នៅបំរើនាយពេលគាត់មិនទៅ ។ មាណពអង្គុយសំលឹងធិតាពីចំហៀង ប្រឹង លួចសង្កេតមើលភិនភាគរូបកាយរបស់នាង ហើយនឹកឆ្ងល់ក្នុងចិត្តមិនដឹង ថាហេតុអ្វីនាងចូលចិត្តទទូរក្រមា គេចមុខមិនអោយនាយស្គាល់មុខនាង ដូច្នេះ? រំពេចនោះ សុបិនក៏សួរនាងចំៗ តែម្តងថា :

- សុំសួរមួយបានទេ លំអង? ហេតុអ្វីក៏នាងចូលចិត្តទទូរក្រមាហើយគេច មុខមិនព្រមអោយខ្ញុំស្គាល់នាងផងយ៉ាងនេះ?

- គឺខ្ញុំមានជំងឺរលាកភ្នែកជាយូរមកហើយ... ហ៊ឺ..បើយើងជាមនុស្សចំលែក ចំពោះគ្នាស្រាប់ទៅហើយ
យើងមិនចាំបាច់ស្គាល់ឬចំណាំមុខគ្នាក៏បានដែរ ។
បន្តិចទៀត លោកជាសះស្បើយហើយក៏ចាកចេញទៅហើយ យើងក៏អស់
សម្ពន្ធ័នឹងគ្នាតទៅទៀតដែរ...

- នាងនិយាយមើលតែខ្ញុំនេះជាមនុស្សចិត្តខ្មៅណាស់អញ្ចឹង?

- ខ្ញុំមិនដឹងទេថាលោកជាមនុស្សយ៉ាងម៉េច តែប្រសិនបើលោកមិនមែនជា
មនុស្សចិត្តខ្មៅទេនោះ លោកក៏មិនគួរបារម្ភដែរ ថាខ្ញុំមានរូបសម្បត្តិយ៉ាង ណា... ម្យ៉ាង មនុស្សក្រីក្រដូចពួកយើងនេះ តើនរណាខ្លះទៅមានទឹក ចិត្ត នឹកចង់រាប់អានយកជាមិត្តឬជាញាតិសន្តានរបស់គេទៅ?

សុបិននៅស្ងៀម កាលបើឮដូច្នោះ ។ មែនហើយ សុបិនក៏មិនចូលចិត្ត អ្នកក្រឡើយ ។ គេខ្លាចភាពក្រីក្រណាស់ហើយក៏ខ្លាចមិនហ៊ានសេពគប់អ្នក ក្រទៀតផង ត្បិតគេតែងតែគិតថា ពពួកអ្នកក្រសុទ្ធតែជាមនុស្សស្មូមទាន ចាំតែបបេះបបោចសុំស៊ីស្រាប់ៗ ដោយគ្មានចិត្តប្រឹងប្រែងបណ្តុះលូតលាស់ ជីវិតដោយកំលាំងខ្លួនឯង ។ ការពិត សុបិនធ្លាប់ឃើញអ្នកក្រពាសពេញ ក្រុងភ្នំពេញដែលជាស្មូមយាចក រង់ចាំតែលើកដៃសុំស៊ី ឬអ្នកដែលចាំតែ លួចឆក់ មិនព្រមយកកម្លាំងកាយកម្លាំងប្រាជ្ញទៅរកស៊ីផ្លូវសុចរិត ទើប សុបិនក្លាយទៅជាគិតប្រមាថអ្នកក្រីក្រទាំងអស់ដូចគ្នាថា ជាមនុស្សខ្ជិលឬ ជាបញ្ញើក្អែករបស់សង្គមតែប៉ុណ្ណោះ ។ កាលបើឃើញមាណពស្ងៀមស្ងាត់ លំអងក៏ប្តូរសាច់រឿងវិញ :

- ហើយចុះលោកវិញ? ស្រួលគ្រាន់បើហើយឬនៅ? ចង់អោយខ្ញុំជូនលោក ត្រលប់ទៅផ្ទះវិញទេហ៎?

- ខ្ញុំអន់ឈឺចាប់បន្តិចហើយ បើមិនរំខានពេកទេ នាងអាចជូនខ្ញុំដល់មាត់
ផ្លូវធំក៏បានដែរ ចាំខ្ញុំឡើងម៉ូតូឌុបទៅផ្ទះចុះ ។

CHANBOKEO.COM

ពូដូច្នោះ លំអងក៏ជួយរៀបចំសុបិន ហើយជួយគ្រាហ៍នាយសំដៅទៅ
មាត់ផ្លូវធំទាំងយ៉ាប់យ៉ឺន។ លុះឃើញសុបិនហាក់ដូចជាទុរន់ទុរានៅឡើយ លំអងក៏សួរថា :

- លោកទៅរួចទេហ៎?
- មិនអីទេ អាចទៅបាន...

សុបិនខាំមាត់ឆ្លើយវិញ។ ការពិត នាយយើងមិនហ៊ានរំខានចិត្តមនុស្ស
មិនស្គាល់គ្នា ណាមួយមិនចង់ជំពាក់សគុណអ្នកក្រ ណាមួយក៏គ្មានអារម្មណ៍
ល្អនឹងនៅក្បែរមនុស្សស្រីរូបរាងមើលមិនបានយ៉ាងនោះដែរ។ ម្យ៉ាងទៀត នារីនោះមានថ្វីមាត់ណាស់
សុបិនមិនចូលចិត្តអោយនរណាចាក់កែងនាយ ដូច្នេះឡើយ។ បន្ថែមពីលើនោះ សុបិនក៏ខ្លាចនាងបំផុតដែរ គឺខ្លាចនាងធ្វើ
អាហារយ៉ាប់ៗ អោយនាយបរិភោគតែម្តង។

តែចំលែកណាស់ សុបិនលួចសំលឹងធិតាមិនដាក់ភ្នែកទេ ពេលដែល នាងគ្រាហ៍នាយតាមផ្លូវរហូតមក។
ខ្លួននាងមានក្លិនក្រអូបប្រហើរហើយ ល្វតល្វន់គួរអោយចង់ត្រកងម៉្លេះទេ... សុបិនហាក់ដូចជាមានអារម្មណ៍ប្លែក
ក្នុងបេះដូងយ៉ាងណាមិនដឹង កាលបើគេបានមកកៀកកាយជិតស្និទ្ធជាមួយ នារីចំលែកម្នាក់នោះ កាន់តែប៉ះ
កាន់តែមានអារម្មណ៍រំភើបចំលែករក ពន្យល់មិនត្រូវ តែម្តង...

មួយស្របក់ក្រោយមក អ្នកទាំងពីរក៏បានមកដល់មាត់ថ្នល់ធំដែល មានចរាចរខ្វែងខ្វាត់។
លំអងក៏ហៅម៉ូតូឌុបមួយមករួចក៏ហុចថ្លៃម៉ូតូអោយ
គេជាមុន ទើបជួយទប់សុបិនអោយឡើងម៉ូតូធ្វើដំណើរចេញទៅ។

បន្តិចមក ធិតាក៏ឈ្ងោកមុខដើរត្រលប់មកផ្ទះវិញដោយស្ងៀមស្ងាត់។ នៅក្រោមភ្លើងចង្កៀងដ៏ស្រទន់
ធិតាអង្គុយសរសេរកំណត់ហេតុប្រចាំថ្ងៃ ចូលទៅក្នុងកូនសៀវភៅតូចមួយ ស្រាប់តែឮសូរិបជើងដើរចូលមកដល់
មាត់ទ្វារផ្ទះ :

- យាយ? ហេតុអ្វីក៏ត្រលប់មកផ្ទះវិញទាំងយប់ដូច្នេះ?

លំអងក៏ស្ទុះងើបទៅបើកទ្វារ ស្រាប់តែនាងភ្ញាក់ព្រើតត្បិតនោះមិន មែនជាដូនចាស់ឯណា ការពិតគឺ...

- គឺខ្ញុំតើហ៎... លំអង!

មាណវីស្ទុះយ៉ាងរហ័សទៅទាញក្រមាមករុំកេសា ហើយទើបត្រលប់ ទៅមាត់ទ្វារវិញទើបឆ្លើយតបថា :

- ក្រែងលោកទៅផ្ទះវិញហើយមិនមែនទេហ៎?
- ទៅហើយ.. តែក៏នឹកចង់ត្រលប់មកវិញ...

ការពិតគឺសុបិនតើហ៎។ ឱតើគេមានការអ្វីទៅហ្ន៎? ភ្លាមនោះ លំអង សួរនាយឡើងថា:

- លោកភ្លេចអ្វីនៅទីនេះមែនទេ?
- ពិតជា.. ភ្លេចមែនហើយ... លំអង!

CHANBOKEO.COM

- ភ្លេចអ្វីទៅ... ចាំខ្ញុំជួយរកអោយណា៎...

- គឺ... ភ្លេច... មិនបានអរគុណនាង ចំពោះការដែលនាងបានជួយសង្គ្រោះ រូបខ្ញុំដល់ទៅពីរដង... (សុបិនស្រដីទាំងអេះអុញ)

- អូហ៎ រឿងបន្តិចបន្តួចប៉ុណ្ណឹង មិនមានគុណមានស្រ័យអ្វីទេ ។ លោកកំពុងតែមិនស្រួលខ្លួនផង ធ្វើដំណើរទៅមកញឹកញាប់ តិចលោដរមុខរបួសណា៎ ។

ញញូច្នោះ សុបិនជ្រួញចិញ្ចើមនឹកក្នុងចិត្តថា :

- ចំលែកណាស់! ថ្ងៃមុនហាក់ដូចជាគំរោះគំរើយដាក់យើងសឹងអី ចុះហេតុអ្វីថ្ងៃនេះ នាងបែរជានិយាយស្ដីសមរម្យធម្មតាៗទៅវិញ?

កំលោះយើងនៅដើរត្រុនៗ ទៅដាក់ខ្លួនលើគ្រែរនាបឫស្សីរួចវាចាបន្តឡើងទៅកាន់មាណវីថា :

- គឺ... ខ្ញុំឃើញនាងនៅផ្ទះម្នាក់ឯង ទើបខ្ញុំមិនដាច់ចិត្តទៅចោល...

លំអងក៏ញញឹមឡើង :

- ខ្ញុំធ្លាប់រស់នៅបែបនេះយូរហើយ មិនអីទេ ។ ម្ដុំនេះមានសន្តិសុខណាស់ គ្មានអ្នកស្រុកណាគេមករំខានខ្ញុំទេ ។ អរគុណណាស់ដែលជួយបារម្ភ!

ការពិត សុបិនមិនយល់ទេថាហេតុអ្វីបានជានាយដូរចិត្តត្រលប់មកផ្ទះនាងលំអងវិញ ។ មែនហើយ! កាលប៉ុន្មានម៉ោងមុន ម៉ូតូឌុបបានដឹកបុរស យើងដល់ផ្ទះមែន តែលុះឈានជើងចូលដល់ផ្ទះកាលណា នាយក៏កើតមាន ចិត្តតប់ប្រមល់ ត្រេះត្រុះមួយសន្ទុះ មិនដឹងធ្វើដូចម្ដេចដើម្បីបំបាត់ការធុញ ថប់នៅក្នុងចិត្តបាន ក៏សំរេចចិត្តវិលត្រលប់មកទីនេះតែម្ដងទៅ ។ បន្តិច មក សុបិនក៏ពោលទៅកាន់លំអងថា :

- តើខ្ញុំរំខានចិត្តនាងទេ បើខ្ញុំសុំស្នាក់ទីនេះបណ្ដោះអាសន្ន?

លំអងនឹកឆ្ងល់ណាស់ តែមិនហ៊ានសួរវិញ ក៏ឆ្លើយថា :

- បើលោកមិនប្រកាន់គ្រែរនាបឫស្សីទេ កន្លែងមួយនេះ លោកអាចសំរាន្តបានជានិច្ច (ធិតាចង្អុលទៅគ្រែដែលនាយធ្លាប់គេងថ្ងៃមុន)

- អរគុណណាស់ លំអង!...

មើលទៅ សុបិនហាក់ដូចជាកំពុងកណ្ដោចកណ្ដែងក្នុងចិត្ត ចង់បានមិត្ត មកជជែកលេងបន្ធូរអារម្មណ៍តប់ប្រមល់ហើយ ។ ថៃដន្យ ពេលនេះ មាណពមិនដឹងជានឹករកប្រយោគអ្វី មកនិយាយជាមួយលំអងបានសោះ ក្រៅពីលួចសំលឹងនាងធ្វើអើតអើមតែប៉ុណ្ណោះ ។ កាលបើឃើញបុរសយើង នៅស្ងៀមស្ងាត់ ធិតាក៏មិនហ៊ាននៅរំខានដែរ ។ បន្ទាប់ពីបញ្ចប់ស្នេររបស់ នាងហើយ ធិតាក៏លូនចូលគេងនៅគ្រែម្ខាងទៀតបាត់ទៅ ទុកអោយសុបិនលួចគេងសំលឹងមាណវីភ្លៀកៗ ដោយអារម្មណ៍ប្លែកៗ... មួយយប់ទល់ភ្លឺ ។ គេធ្មេចមិនលក់សោះមិនដឹងថាមកពីហេតុអ្វី... យូរៗម្ដង គេតែងងើបលួច មើលធិតាដែលគេងលក់ស្ងៀមស្ងាត់ មើលទៅហាក់ដូចជាគ្មានបារម្ភពីអ្វី សោះឡើយ ។

CHANBOKEO.COM

ចុះហេតុអ្វីបានជានាយបែជ្រាទឹករសាប់រសល់ចំលែកៗ ចំពោះធិតានេះទៅវិញ? ក្នុងជំរៅចិត្តរបស់សុបិន គេហាក់ដូចជាចង់ដឹង ចង់ស្គាល់នារីមួយរូបនេះណាស់ ត្បិតមើលទៅនាង ហាក់ដូចជាកំពុងមាន អាថិកំបាំងអ្វីម្យ៉ាងក្នុងជីវិតដែលមិនចង់អោយនរណាដឹង ។ ប៉ុន្តែ តើនាង មានអាថិកំបាំងអ្វីទៅ? ហេតុអ្វីបានជានាងរស់នៅលាក់លៀមមុខមាត់ពី អ្នកផងដូច្នេះ? ម្យ៉ាងទៀត នាងធ្វើការតាំងពីព្រឹកព្រហាមរហូតដល់យប់ អាធ្រាតរាល់ថ្ងៃ តើនាងពិតជាទៅលាងចានអោយគេនៅភោជនីយដ្ឋាន មែនឬមិនមែន? ឬក៏នាងរកស៊ីអ្វីផ្សេង? ឬក៏នាងជាស្រីរកស៊ីផ្លូវភេទ? ពុទ្ធោ! សុបិនទឹកឡើង ព្រឺក្នុងចិត្តខ្វាកតែម្តង កាលបើគិតមកដល់ត្រឹម នេះ ។ គេក៏ប្រឹងរំលត់ចិត្តរសាប់រសល់របស់គេ :

- ណ្ហើយចុះ!... នាងធ្លាប់មានសន្តានចិត្តជួយសង្គ្រោះសុបិនដល់ទៅពីរដង ដូច្នេះ សុបិនសូមមិនគិតអាក្រក់ពីនាងទេ... សង្ឃឹមថានាងជាមនុស្សល្អ ម្នាក់ហើយមិនបានប្រព្រឹត្តអំពើលាមកណាមួយទាំងនោះឡើយ ។

សុបិនផ្តេកកេសាលើខ្នើយ បែរមុខទៅរកធិតា លួចសំលឹងរូបនាង តាមចន្លោះស្បៃមុង គិតពិចារណាមិនអស់មិនហើយ តាំងពីពាក់អាធ្រាត រហូតដល់មាន់រងាវ ។ នាយមិនយល់ចិត្តរបស់ខ្លួនឯងទេ ថាហេតុអ្វីពេល នេះ គេបែរជាមកចាប់អារម្មណ៏ចំពោះនារីធម្មតាមួយរូបដូចជាលំអងនេះ ទៅវិញ ។ ហេតុអ្វីក៏វាសនាចារនាំរូបនាយអោយមកដើរជំពប់ឧប្បត្តិហេតុ ដល់ទៅពីរដង ធ្វើអោយសុបិនដែលជាបុត្រត្រកូលខ្ពង់ខ្ពស់ម្នាក់ ក្លាយជា ជនដែលជំពាក់សគុណអ្នកស្រុកសាមញ្ញក្រីក្រយ៉ាងនេះ? គិតទៅ ក្នុងភព ជីវិតយើងពិតជាមានកង់ត្រាចកង់ធ្នង់វិលវង់ទៅមកពិតមែន ចៀសមិនរួច ឡើយ តួយ៉ាងដូចជាសុបិននេះជាដើម... ខំគេចអ្នកក្រមួយអាយ៉ូសមក ហើយ ឥលូវបែរជាមកជំពើបលើអ្នកក្រគេចមិនរួច ហើយថែមទាំងជំពាក់ សគុណរបស់អ្នកក្រយ៉ាងច្រើនទៀតផង...

៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO.COM

# វគ្គទី៣

# ផ្កាយអាប់ពន្លឺ

ស្មែកឡើង...

លំអងត្រូវត្រលប់ទៅធ្វើការវិញ មិនអាចនៅកំដរសុបិនបាន ម្ល៉ោះ ហើយបុរសយើងក៏ត្រូវលំអងបង្ខំចិត្តអោយឡើងម៉ូតូឌុបត្រលប់ទៅផ្ទះ វិញសាជាថ្មី ។ លុះនាយមកដល់ផ្ទះភ្លាម បើកទ្វារដើរចូលទៅ ស្រាប់តែសុបិនភ្ញាក់ព្រើតនឹងវត្តមានបុរសចំណាស់ម្នាក់នៅទីនោះ ។ មាណពយើងក៏ លាន់មាត់ឡើងទាំងភ្ញាក់ផ្អើលថា :

- លោកប៉ា?

ថាផង នាយក៏ស្ទុះទៅអោនលំទោនប្រណិបតន៏លោកផង ។ នោះគឺ លោកសៅរិនថៅកែផលិតកម្មការ៉ាអូខេដ៏ល្បីមួយ :

- កូនប្រុសប៉ា? មានរឿងអ្វីកូនបានជាមុខមាត់យ៉ាប់យ៉ឺនដល់ម្លឹង?

តែសុបិនមិនឆ្លើយទេ បែរជាសួរទៅឪពុកវិញ :

- ចុះលោកប៉ាវិញ ការងារនៅអាមេរិកយ៉ាងណាដែរ?

- ធម្មតាៗមិនអីទេកូន ។ មើល៏! ប្រាប់ប៉ាមកកូន ហេតុដូចម្តេចបានជាមាន របួសជាំអីពេញខ្លួនយ៉ាងនេះ?

សុបិនឈ្ងោកមុខហើយក៏សួរទៅលោកវិញដដែល :

- អ្នកស្រីលីដាភរិយារបស់លោកប៉ាមិនមកជាមួយទេ?

- គឺ ម៉ាក់ចុងរបស់កូន មានកិច្ចការត្រូវធ្វើច្រើនទៀតមិនអាចត្រលប់មក ជាមួយប៉ាបាន ទើបប៉ាមកមុននេះអី ។ អាទិត្យក្រោយទើបគេមកដល់!

សុបិនឈ្ងោកមុខ សំដែងការមិនពេញចិត្តចំពោះម្តាយចុង ។ ឃើញ ដូច្នោះ លោកសៅរិនក៏មានប្រសាសន៏ឡើង :

- គេជាមនុស្សល្អ ហើយគេមិនដែលធ្វើអោយមានផុសរមាស់ក្នុងគ្រួសារ របស់យើង ហេតុអ្វីក៏កូនសំដែងកិរិយាហាក់ដូចជាស្អប់ម្តាយចុងរបស់កូន ម្ល៉េះ ហ្អាសកូនសំលាញ់?

សុបិននៅស្ងៀមមួយស្របក់ក៏ស្រដីតបថា :

- គឺមកពីកូនមិនចូលចិត្តអោយគាត់ចាប់ផ្គូ រូបកូន ជាមួយកូនក្រមុំលោក ណាមិនដឹង... ប៉ាមិនចាំទេហ៏?

- អូហ៏ គឺនាងអម្ពរនោះមែនទេហ៏? ការពិត ប៉ាក៏យល់ដូចម៉ាក់ចុងរបស់ កូនដែរ ថានាងអម្ពរជាគូស្រករដែលសក្តិសមនឹងរូបកូនបំផុតហើយ ។ នាង ជាកូនស្រីរបស់មិត្តភក្តិម្នាក់ ហើយប៉ាគិតថា បើកូនបានស្គាល់នាង កូន ច្បាស់ជាពេញចិត្តរូបនាងដូចប៉ានិងម៉ាក់ចុងរបស់ឯងអញ្ចឹងដែរ ។

CHANBOKEO . COM

- ប៉ុន្តែ... លោកប៉ា... អាពាហ៍ពិពាហ៍ជាជីវិតរបស់កូន ហើយមានតែកូន ប៉ុណ្ណោះដែលគួរណាស់តែជាអ្នកសំរេចចិត្ត...
- អឺ! អឺ យើងដឹងហើយតើហ៎ ។ ការពិតយើងមានបានបង្ខំកូនឯណា គ្រាន់ តែចង់អោយជួបហើយស្គាល់គ្នាសិន ក្រែងឯងពេញចិត្តណា៎ ។ បើសិនជា មិនត្រូវចិត្តទេក៏ហីទៅ ។ ដឹងទេហ៎ នៅយប់ស្អែកនេះ ប៉ាមានទទួលបើក ពិធីជប់លៀងជួបជុំញាតិនៅផ្ទះយើងនេះ ហើយប៉ាក៏បានអញ្ជើញលោក សុនាថ ភរិយាលោក និងនាងអម្ពរមកផង ។ ត្រៀមខ្លួនចាំជួបគេទៅណា៎!
- លោកប៉ា! អារឿងចាប់កូនភ្ជុំគ្នារបៀបនេះ វាហួសសម័យហើយប៉ា!
- អឺ!! ហួសអីក៏ហួសទៅ... តែយ៉ាងណា សូមមេត្តាជួយទុកមុខមាត់ឱ្យប៉ា ហើយជួយទទួលភ្ញៀវអោយសមរម្យផងណា៎កូន ។

សុបិននឹកខកចិត្តណាស់ដែលលោកសោរិនជាឪពុក ហាក់ដូចជាបង្ខំចិត្ត នាយអោយធ្វើតាមចិត្តម្តាយចុងជានិច្ច ។ លុះងូតទឹកជំរះកាយហើយ នាយ យើងក៏ស្ទុះវិញចេញទៅក្រៅ ដោយមិនមាត់ជំរាបឪពុកថាទៅណាទេ ។ លោកសោរិនឃើញដូច្នោះក៏គ្រវីក្បាលហួសចិត្ត ។ សុបិនបើកឡានត្រលប់ ទៅភោជនីយដ្ឋានស្អែកមិនយកលុយដើម្បីជួបថៅកែយូទិក្ស តែថៅកែមិន នៅទេ នៅតែនាយចាត់ការរងដែលបានប្រាប់នាយថា ថៅកែអោយនាយ សំរាកបួនដប់ថ្ងៃដែលនាយបានធ្វើអោយខូចបរិយាកាសក្នុងភោជនីយដ្ឋាន កាលពីថ្ងៃមុនបណ្តាលអោយថៅកែត្រូវមាត់ភ្ញៀវមិនស្មើរ ។ សុបិនក៏នឹក តប់ប្រមល់ក្នុងចិត្តជាថ្មី ។ នាយក៏បរឡានទៅអង្គុយមាត់ទន្លេ ដើម្បីលំហែ ចិត្តអោយសប្បាយ ស្រាប់តែនឹកភ្នកដល់អ្នកដែលធ្លាប់ជួយសង្គ្រោះអូស យករូបនាយពីមាត់ទន្លេមកដល់ទៅពីរដង...

សុបិនឈប់រថយន្តនៅមាត់ច្រកតូចមួយហើយក៏ផ្ញើរថយន្តជាមួយអ្នក ជិតខាងរួចក៏ដើរចូលតាមច្រកទៅរហូតទៅដល់ដីឡូត៍មួយដែលមានដំណាំ ដាំដុះជុំវិញ ។ នាយយើងឈរសំលឹងទីនោះមួយស្របក់ទើបដើរចូលទៅ ។ មែនហើយ! នាយបានមកដល់ទីនេះ ពីរបីដងហើយតែមិនដែលចាប់ភ្លឹក នឹងសំលឹងមើលទិដ្ឋភាពទីនេះទេ ។ ការពិត ថ្វីបើទីនេះគ្រាន់តែជាដីឡូត៍ ធម្មតា១ មានរបងឫស្សីខ្ចាស់ពទ្ធ័ជុំវិញ មានកូនផ្ទះមួយតូចនៅចំកណ្តាល និងស្រះឈូកនៅពីក្រោយព្រមទាំងដំណាំស៊ីផ្លែដុះជុំជិត តែមើលយូរទៅ មនោរម្យគួរអោយចង់រស់នៅណាស់... ត្រជាក់ត្រជុំជាងលំនៅក្នុងទីក្រុង ដែលពោរពេញទៅដោយភាពអ៊ូអរលាយឡំនឹងផ្សែងឧស្ម័ន ។ ពេលនោះ សុបិនហាក់ដូចជាមានអារម្មណ៍ថា ខ្លួននាយហាក់ដូចជាធ្លាប់បានមកដល់ ទីនេះពីមុន១ម្តង... ជាយូរមកហើយ.... តែរកនឹកមិនឃើញសោះថាបាន មកពីអង្កាល់ ។ បន្តិចមក សុបិនក៏ដើរចូលទៅដល់មាត់ទ្វារផ្ទះ លើកដៃ គោះតិច១ ហើយស្រែកហៅ :
- យាយ! លំអង! នៅផ្ទះទេហ៎?

ស្ងាត់ច្រៀប គ្មាននរណាឆ្លើយសោះ ។ សុបិនក៏ដើរពទ្ធ័ទៅក្រោយផ្ទះ ដាក់ខ្លួនចុះ លើស្ពានឫស្សីដែលនាយធ្លាប់ប្រទះនារីមួយរូបមកអង្គុយលេង ទឹកនៅទីនោះ ។ នាយយើងបណ្តែតអារម្មណ៍ស្រម័យអណ្តែតអណ្តូងតែ ម្នាក់ឯង គ្រានេះនាយមិនយល់ទេថាហេតុអ្វីនាយត្រលប់ជាមកចាប់

CHANBOKEO.COM

អារម្មណ៍ចំពោះទីនេះទៅវិញ? ឬក៏ប្រហែលជាពេលនេះ នាយយើងធុញ ថប់នឹងជីវិតអ៊ូអរក្នុងទីក្រុងទេដឹង ។ សុបិនអង្គុយនៅស្ងៀមស្ងាត់អស់ជា យូរ ទើបនាយងើបដើរឡើងច្រាំងបំរុងនឹងត្រលប់ទៅផ្ទះវិញ ស្រាប់តែប្រទះឃើញលំអងដើរមកដល់ល្មម :

- លោក...?

- លំអង!... នាងមកវិញហើយ? ចុះឯណាយាយ?

សុបិនត្រេកអរណាស់កាលបើយល់វត្តមានរបស់នារីយើងភ្លាម ហើយ ក៏ចាប់ផ្ដើមញញឹមដាក់នាងជាលើកដំបូងដែរ ។ លំអងព្យដូច្នោះក៏ឆ្លើយថា :

- យាយនៅក្នុងផ្ទះតើហ៎...? គាត់មិនបានទៅណាទេ ។

- ខ្ញុំមកដល់ទីនេះយូរហើយហើយក៏បានគោះទ្វារច្រើនដង តែមិនឮគាត់ តបវិញសោះ ឬក៏គាត់ចេញទៅណាទេដឹង?

លំអងព្យដូច្នោះក៏ស្ទុះរឹងច្រានទ្វារចូលទៅ ។ សុបិនលាន់មាត់ :

- ពុទ្ធោ! ទ្វារមានចាក់សោរឯណា?

មាណពក៏ស្ទុះរឹងតាមពីក្រោយលំអងចូលទៅក្នុងផ្ទះ ស្រាប់តែប្រទះ ដូនចាស់កំពុងសំរាន្តស្តូកស្ដឹងសន្ធឹងសន្ធៃតែម្នាក់ឯង ។ លំអងយកដៃស្ទាប ខ្លួនគាត់ ស្រាប់តែលាន់មាត់ឡើង :

- យាយកំពុងតែមិនស្រួលខ្លួនតើហ៎!

សុបិនឃើញដូនចាស់គ្រុនក្ដៅខ្លាំងណាស់ក៏ពោលទៅកាន់លំអង :

- យកគាត់ទៅពេទ្យវិញទៅ ប្រហែលជាគាត់ឈឺធ្ងន់ហើយ...

- មិនអីទេលោក! ប្រហែលជាយាយគ្រុនធម្មតាៗទេ អោយគាត់ពិសារថ្នាំ មួយស្របក់ទៅនឹងបានស្រួលបួលហើយ ។ អរគុណណាស់ដែលលោកបារម្ភ ចំពោះសុខទុក្ខរបស់យាយ ។

ល្ងាចនោះ សុបិនតប់ប្រមល់មិនចង់ទៅផ្ទះទេ ត្បិតខ្លាចជួបលោកប៉ា របស់នាយបង្ខំរឿងរៀបការជាមួយនារីដែលនាយមិនពេញចិត្ត ណាមួយ ឃើញដូនចាស់មិនស្រួលខ្លួនទៀត ក៏យកលេសធ្វើជាគ្រេចនៅជួយកំដរ ទៅ ។ ការពិត ពេលនេះនាយយើងកំពុងទាល់ច្រកមិនដឹងថាចង់ទៅឯណា ដែរ ដើម្បីគេចពីបញ្ហាអាមាសកាលពីប៉ុន្មានថ្ងៃមុនផង និងដើម្បីគេចពី លោកសេរីរននិងអ្នកស្រីលីដាផង ។

រាត្រីនោះ...

សុបិននៅអង្គុយផ្អែកសសរក្រៅផ្ទះសំលឹងលោកខែដ៏សែនស្អាត នឹក គិតទៅដល់អតីតកាលមួយដែលនាយធ្លាប់មានម្ដាយឪពុកនៅជួបជុំ រួចថ្ងៃ មួយម្ដាយរបស់គេចែកឋានទៅ លោកសេរីរនក៏រៀបការភរិយាថ្មីទៀត ធ្វើ អោយសុបិនកាន់តែឃ្លាតឆ្ងាយមនោសញ្ចេតនាចំពោះឪពុកខ្លួន ហើយចេះ តែប្រកាន់អារិចិត្ត មានះមិនព្រមទទួលស្គាល់ម្ដាយចុងនោះឡើយ ថ្វីបើ គាត់បានធ្វើល្អចំពោះនាយយ៉ាងណាក៏ដោយ ។ កំពុងតែគិតលង់អារម្មណ៍ ស្រាប់តែមានសូរបជើងដើរចូលមកជិត :

CHANBOKEO.COM

- លោកមិនទាន់ចូលសំរាន្តទេហ៎?

សុបិនក៏ងាកមកម្ចាស់សំលេង ក៏ឃើញលំអងដើរចូលមក ។ ពេលនេះ នាងមិនបានទទូរក្រមាដូចរាល់ដងទេ ប៉ុន្តែ ថែដន្យពន្លឺដ៏ស្រទន់របស់ដួងខែ ក៏មិនអាចជួយអោយសុបិនបានឃើញមុខនាងច្បាស់ដែរ គ្រាន់តែដឹងថា នាងមានទំរង់មុខពងក្រពើ សម្បុរជ្រះ ហើយមានសក់វែងអន្លាយតែ ប៉ុណ្ណោះ ។ សុបិនសំលឹងនាងយ៉ាងភ្លូន់ភ្លឹកអស់មួយស្របក់ ក៏សួរខ្លួនឯង ក្នុងចិត្តថា :

- ហេតុអ្វីទៅហ្ន៎បានជាយើងបែរមកចាប់អារម្មណ៍ជាមួយនារីលំដាប់វណ្ណៈ អន់ៗដូចជានាងលំអងនេះទៅវិញ?

ភ្លាមនោះ ធិតាបន្លឺវាចាសួរសុបិនថា :

- របួសរបស់លោកយ៉ាងណាដែរហើយ ឥលូវនេះ?

- ខ្ញុំមិនអីទេ... បានគ្រាន់បើហើយ.. នៅឈឺតិចៗប៉ុណ្ណោះ ។

- ប៉ុន្តែ ហេតុអីក៏លោកបែរជាស្រពាប់ស្រពោនជាងរាល់ដងទៅវិញ?

- គឺ... វិយោគផ្លូវចិត្តវាំរំខាននោះអី...

ឮដូច្នោះ មាណវីក៏នៅស្ងៀម បន្តិចក៏ឆ្លើយឡើង :

- បើដូច្នោះមែន លំអងមិនអាចជួយលោកអ្វីបានទេ...

- ខុសហើយ! ការពិត... គឺនាងបានជួយសំរាលទុក្ខរបស់ខ្ញុំច្រើនណាស់មក ហើយណ៎ា គ្រាន់តែនាងធ្វើខ្លួនជាមិត្តរបស់ខ្ញុំម្នាក់ ក៏ខ្ញុំមានអារម្មណ៍ធូរ ស្រាលជាងមុនច្រើនណាស់ ។ ពេលនេះ នាងដឹងទេ... ថាហេតុអ្វីខ្ញុំបាន ជាខ្ញុំគេចខ្លួនមកទីនេះទៅវិញ?

- លំអងមិនដឹងទេ... ហេតុអ្វីទៅ?

- គឺខ្ញុំកំពុងគេចខ្លួនពីការចាប់បង្ខំរបស់ចាស់ទុំនោះអី ហើយបើខ្ញុំសំងំនៅ ជាមួយសាច់ញាតិឬអ្នកស្គាល់គ្នា លោកប៉ាច្បាស់ជាតាមរកខ្ញុំឃើញមិនខាន

- លោកប៉ារបស់លោកចាប់បង្ខំរឿងគូស្រករមែនទេ?

- ហេតុអ្វីក៏នាងដឹង?

- ខ្ញុំមិនដឹងទេ គ្រាន់តែទាយលេងតែប៉ុណ្ណោះ ។

សុបិនដកដង្ហើមយូ បន្ធូរទ្រូង ហើយវាចាថា :

- ការពិត អ្វីដែលធ្វើអោយខ្ញុំតប់ប្រមល់ជាងគេនោះ គឺរឿងម្តាយចុង របស់ខ្ញុំដែលកំពុងផ្សំផ្គុំរូបខ្ញុំជាមួយសាច់ញាតិរបស់គាត់ ។

- គាត់ជាមនុស្សយ៉ាប់ណាស់ទៅឬអី បានជាលោកមិនចូលចិត្តគាត់ដូច្នេះ?

- គាត់មិនដែលធ្វើអ្វីខ្ញុំទេ តែខ្ញុំមិនចូលចិត្តឃើញមនុស្សថ្មីក្នុងកន្លែងម៉ាក់ខ្ញុំ ម្យ៉ាងទៀត ខ្ញុំក៏មិនទុកចិត្តនរណាដែលមិនបានបង្កើតរូបខ្ញុំដែរ ។

- មិនមែនម្តាយចុងទាំងអស់ សុទ្ធតែអាក្រក់នោះទេ ហើយខ្ញុំជឿថាលោក ក៏មិនមានសំណាងអាក្រក់រហូតដល់មានម្តាយចុងអបលក្ខណ៍ដែរ...

សុបិនភ្ញាក់ព្រើត :

CHANBOKEO.COM

- ហេតុអីក៏នាងមានជំនឿដល់ម្លឹង?

- គឺការបើកចិត្តអោយទូលាយ សំលឹងអ្វីៗដោយសុទិដ្ឋនិយមនោះអី...

សុបិនភ្ញាក់ព្រើត នឹកក្នុងចិត្ត :

- ព្រះអើយ នាងនិយាយហាក់ដូចជាមនុស្សមានការសិក្សាឥចឹង?

រំពេចនោះ មាណវីក៏ពោលបន្តថា :

- យ៉ាងហោចក៏លោកនៅមានសំណាងជាងខ្ញុំដែរ ។ លោកនៅមានឪពុក មានទ្រព្យធន មានមុខមាត់និងកេរ្តិ៍ឈ្មោះ ។ រីឯខ្ញុំវិញ គ្មានទាំងម្តាយ គ្មានឪពុកឬសាច់សន្តានទេ ។ ក្រៅពីយាយចិត្រ លំអងគ្មានញាតិឡើយ ដូច លោកឃើញស្រាប់ហើយថាជីវិតយើងទីនេះយ៉ាងម៉េចខ្លះ... ប៉ុន្តែយើងមិន ដែលតូចចិត្តនឹងវាសនាទេ គឺតែងតែប្រឹងប្រែងជានិច្ចដើម្បីផ្លាស់ប្តូរជីវិត អោយភ្លឺថ្លាជាងមុន មិនថាយើងត្រូវលំបាកបែបណាក៏ដោយ ។

ពោលមកដល់ត្រង់នេះ ធិតាក៏ទុចម៉ក់ ឈប់ស្រដី ។ សំដីរបស់នាងចុង ក្រោយនេះ បានធ្វើអោយសុបិនរំជួលចិត្តណាស់ ។ មែនហើយ នាយពិតជា មានសំណាងជាងលំអងឆ្ងាយហៅមិនឮ ។ នាយមិនដែលលំបាកអ្វីផងក្នុង មួយជីវិតនេះ ក្រៅតែពីការបាត់បង់ម្តាយតែម្យ៉ាង ក្រៅពីនោះនាយមានអ្វី សព្វគ្រប់ទាំងអស់ ប៉ុន្តែហេតុអ្វីបែរជានាយមិនព្រមទទួលស្គាល់រួចហើយ ត្រេកត្រអាលជីវិតនោះទៅ? ចាំបាច់អីមកអង្គុយមួហ្មង ធ្វើដូចជាមនុស្ស អស់សង្ឃឹមក្នុងជីវិតគ្មានច្រកដើរដូច្នេះទៅវិញ ។ មើលចុះ! នារីម្នាក់ដែល អង្គុយនៅចំពោះមុខនាយមួយរូប គេមិនមានវាសនាខ្ពង់ខ្ពស់ដូចនាយផង ហេតុអ្វីគេអាចសាងជំហរអារម្មណ៍របស់គេបានយ៉ាងរឹងមាំដូច្នេះ? សុបិន គិតមកដល់ចំណុចនេះ ក៏ញញឹមឡើង ហើយក៏លូកចាប់ដៃលំអងមកកាន់ រួចហើយក៏ស្រដីទៅកាន់នាងថា :

- អរគុណនាងណាស់លំអង! រូបនាងមិនខុសពីកូនចង្កៀងតូចមួយ ដែល មកជួយបំភ្លឺផ្លូវជីវិតដ៏សែនងងិតរបស់ខ្ញុំនោះទេ ។

លំអងនឹករអៀសខ្លួនណាស់ដែលត្រូវបុរសកាន់ដៃ ក៏ប្រញាប់ដកដៃ មកវិញយ៉ាងរហ័ស ។ សុបិនភ្ញាក់ព្រើត នឹកខ្មាសខ្លួនបន្តិចដែរ ក៏លួច ចោលកន្ទុយភ្នែកសំលឹងមើលនារីយើង ហើយក៏នៅស្ងៀមមិនហ៊ានស្រដីអ្វី តទៅទៀត ។ រំពេចនោះស្រាប់តែឮសូរសម្លេងមាត់ដូនចាស់ពីក្នុងផ្ទះមក ។ អ្នកទាំងពីរស្ទុះរឹងព្រមគ្នាទៅរកមើលគាត់ភ្លាម ក៏ប្រទះឃើញដូនចាស់ កំពុងដង្ហក់នៅលើគ្រែ ។ លំអងភ័យណាស់ ក៏ពោលទៅកាន់សុបិនថា :

- លោក! អោយខ្ញុំសូមផ្ញើយាយមួយភ្លែត... ខ្ញុំទៅតាមពេទ្យសិន ។

ថាហើយនាងក៏រត់យ៉ាងលឿនចេញទៅ រកតែសុបិនឃាត់អ្វីនិយាយអ្វី ក៏មិនទាន់ ។ ការពិតនាយយើងចង់ប្រាប់គាត់ដាក់ឡាន ដែលនាយចតនៅ មាត់ផ្លូវដើម្បីដឹកទៅមន្ទីរពេទ្យវិញ ជូនលំអងភ័យពេកក៏រត់ចេញទៅ ដោយមិនបានពិគ្រោះគ្នា ។ នាយក៏ទ្រាំនៅកំដរយាយតទៅទៀត រង់ចាំ ក្រែងលំអងត្រលប់មកវិញឆាប់ ។ រំពេចនោះ ដូនចាស់ក៏ចាប់ដៃនាយ :

- ចៅអើយ...! យាយ... ប្រហែលជា... ឆ្លងមិនផុត... យប់នេះទេ...

CHANBOKEO.COM

- យាយ! យាយពិតជាមិនអីទេ (សុបិនឆ្លើយតប) បន្តិចទៀតលំអងគេនាំ ពេទ្យមកដល់ហើយ... ទ្រាំបន្តិចទៅបាទ!

- ចៅ... អោយយាយសុំ.... អ្វី... ម្យ៉ាងបានទេ?

- មានការអ្វីទៅយាយ...

ដូនចាស់ខំប្រឹងត្រដរនិយាយទាំងដង្ហក់ៗ ថា :

- ចៅ... បើយាយគ្មាន...ឱកាសរស់...នៅឃើញ...ពន្លឺថ្ងៃស្អែកទេ... អោយយាយសូម... ផ្ញើលំអង... នឹងចៅផង... បានទេ?

- យាយ... យាយមិនទៅណាទេ... យាយ....

- ចៅ... សន្យាសិនមក៏.... តើចៅអាច...ទទួលពាក្យយាយ... បានទេ...?

សុបិនជ្រួញចិញ្ចើម ប្រកែកមិនទទួលយក :

- យាយ... ខ្ញុំជាមនុស្សចំលែកម្នាក់... មិនគួរអោយទុកចិត្តទេ... យាយកុំ ផ្ញើចៅស្រីជាមួយខ្ញុំអី... ខ្ញុំមិនអាចទទួលយកបានទេ... ម្យ៉ាងទៀត....

- ចៅអើយ... យាយមិនស្គាល់នរណានឹងផ្ញើលំអងទេ... មានតែ...ចៅឯង តែម្នាក់... ដែលបាននៅទាន់ដង្ហើមរបស់យាយ... សូម... ចៅទទួលសំដី របស់... យាយផង... ណាំចៅ... ជួយមើលលំអងផង...!!

- យាយ... យាយ...

ដូនចាស់ស្រវាចាប់ដៃសុបិនយ៉ាងណែន រួចក៏ដង្ហក់កាន់តែខ្លាំងឡើង ។ មួយស្របក់ក្រោយមកដៃគាត់ក៏បន្ធូរទៅវិញ ឯទឹកមុខក៏កាន់តែស្លេកទៅៗ ធ្វើអោយមាណពយើងរន្ធត់ចិត្តអន្ទះសាខ្លាំងណាស់ មិនដឹងថាត្រូវធ្វើដូច ម្តេចទៀត ។ រំពេចនោះលំអងក៏បានមកដល់ដោយមាននាំពេទ្យចំណាស់ មួយរូបមកដល់ ។ ក្រោយពីពិនិត្យរោគរបស់យាយហើយ លោកគ្រូពេទ្យក៏មានប្រសាសន៍ថា:

- មើលទៅទាល់តែយកជីដូនរបស់នាងទៅមន្ទីរពេទ្យហើយ...!!

នៅក្នុងមន្ទីរពេទ្យ លំអងអង្គុយទទូរក្រមាបាំងមុខស្ទើរតែជិតអស់ ។ យូរៗម្តង នាងលួចយកជាយក្រមាផ្ចិតទឹកភ្នែកដែលហូរស្រក់មកលើថ្ពាល់ រង់ចាំដំណឹងពីលោកគ្រូពេទ្យ ។ នៅក្បែរនោះ សុបិនអង្គុយនៅស្ងៀមស្ងាត់ សំលឹងមើលធិតាដោយដួងចិត្តខ្វាយខ្វល់ ។ បន្តិចមកលោកគ្រូពេទ្យក៏ចេញពីបន្ទប់អ្នកជំងឺមកដល់ចំពោះអ្នកទាំងពីរ ។ លំអងងើបមុខឡើងសួរយ៉ាង រហ័សថា :

- លោកគ្រូពេទ្យ! តើជីដូនរបស់ខ្ញុំយ៉ាងណាហើយ?

លោកគ្រូពេទ្យសំលឹងមុខនាងហើយគ្រវីក្បាល:

- សូមទោសណាំ! ខ្ញុំបានប្រឹងអស់សមត្ថភាពហើយ តែមិនអាចជួយអ្វីបាន ទេ... ពេលនេះ...!

ឮដូច្នោះ លំអងក៏ស្រែកទ្រហោរឡើង :

- យាយ...!!!

ឮសំលេងទ្រហោរដ៏សែនរន្ធត់របស់ធិតា សុបិនក៏ស្លុតក្នុងចិត្តមិនតិច

CHANBOKEO.COM

ឡើយ ។ ពេលនេះ មាណពមានអារម្មណ៍ច្របូកច្របល់ណាស់ ។ នាយពិត ជាមិនអាចទទួលបណ្ដាំរបស់ដូនចាស់បានទេ ប៉ុន្តែក៏មិនដាច់ចិត្តដើរចោល លំអងដែលធ្លាប់មានសគុណមកលើរូបនាយដែរ ។  ការពិត គ្មានអ្វីដែល មករំខានចិត្តនាយជាជាងពាក្យអង្វររបស់ដូនចាស់ឡើយ ។ ហ៊ឺ! តើអោយ នាយគិតយ៉ាងម៉េចទៅ? ទោះបីជាពេលនេះ នាងលំអងមិនបានដឹងអំពី បណ្ដាំរបស់ជីដូនចំពោះសុបិនជាចុងក្រោយក៏ដោយ ក៏មនសិការរបស់ សុបិនកំពុងតែទូងអន្ទូងរណ្ដំក្នុងចិត្តក្នុងអារម្មណ៍របស់បុរសយើងយ៉ាងខ្លាំង ដាស់បេះដូងនាយអោយនឹកឃើញនូវគ្រប់ម៉ាត់ដែលដូនចាស់បានផ្ដែផ្ដាំមិន អោយភ្លេចមួយនាទីណា... តើសុបិនត្រូវគិតយ៉ាងណាទៅ?

នៅក្នុងព្រះវិហារវត្តបាខែង លំអងអុជធូបថ្វាយបង្គំព្រះលួចសំរក់ទឹក ភ្នែកម្នាក់ឯង... ។ សុបិនលូនចូលទៅដល់ពីក្រោយ យកដៃទៅអង្អែលស្មា នាងបន្ដើរៗ រួចពោលទៅកាន់នាងដោយវាចាយ៉ាងស្រទន់ លួងលោម ចិត្ត នាងអោយស្បើយសេចក្ដីទុក្ខ :

- លំអង! កាត់ចិត្តទៅ! យាយរបស់នាងបានទៅដល់សុគតិភពហើយ! នៅតែនាងទេដែលត្រូវប្រឈមមុខក្នុងជីវិតតទៅទៀត... សូមថែខ្លួនផង ណា៎! កុំបណ្ដោយអោយសេចក្ដីទុក្ខមកបំបាក់ទឹកចិត្តរបស់នាងបានឱ្យសោះ

លំអងនៅស្ងៀមមួយស្របក់ទើបឆ្លើយថា :

- ខ្ញុំមិនអីទេ... អរគុណលោកណាស់ដែលបាននៅជួយលើកទឹកចិត្តខ្ញុំពេល នេះ... អរគុណ...!

សុបិនគិតមួយស្របក់ក៏ញញឹមដាក់មាណវី សំដែងការលើកកំលាំង ចិត្តដល់នាង រួចក៏ពោលបន្តថា :

- ណើ្ហយចុះ! នាងក៏មាននៅសល់រូបខ្ញុំម្នាក់ដែរ... បើមិនប្រកាន់ទេ សូម នាងគិតថា ខ្ញុំនេះជាមិត្តដ៏ល្អរបស់នាងម្នាក់ផងចុះ ហើយខ្ញុំក៏ពេញចិត្តនឹង ជួយដោយស្រាយទុក្ខធុរៈរបស់នាងដែរ បើសិនជានាងត្រូវការ...

លំអងឈ្ងោកមុខយកដៃជូតទឹកភ្នែក ។ សុបិនក៏ញញឹមដាក់នាងជា ចុងក្រោយហើយក៏ធ្វើដំណើរចាកចេញទៅ...

៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩៩

៩

CHANBOKEO.COM

# វគ្គទី៤

រន្ទះស្នេហ៍ផ្លេកបន្ទោរ?

ថ្ងៃនេះ សុបិននឹកចំលែកចិត្តណាស់ដោយឃើញផ្ទះរបស់នាយមានការ តុបតែងផ្ទះយ៉ាងស្អាតប្លែកតែម្តង។ រំពេចនោះស្ត្រីចំណាស់មួយរូបក្នុង សំលៀកបំពាក់ថ្លៃថ្នូរក៏លេចធ្លោឡើងហើយនិយាយមកកាន់សុបិនថា :

- សុបិន! មកដល់ហើយឬកូន? នុ៎ះ លោកប៉ារង់ចាំមើលផ្លូវកូនឡើងផ្សា ភ្នែកពីរថ្ងៃមកហើយ។

សុបិនឃើញសុភាពស្ត្រីនោះហើយ ក៏លើកដៃប្រណម្យសំពះតែមិន និយាយអ្វីជាមួយគាត់ដែរ ព្រមទាំងមិនក្រលេកមើលទៅឪពុករបស់នាយ ដែលកំពុងបក់ដៃហៅនោះផង។ នាយបែរជាឈ្ងោកមុខដើរប្រុយហួសទៅ ដោយមិនមានគួរសមនឹងនរណាទៀតឡើយ។ ការពិត នាយកំពុងច្របូក ច្របល់ក្នុងចិត្តណាស់។ ថ្មីៗនេះនាយក៏បាត់បង់នាងកល្យាណទៅ រួចហើយ ក៏ត្រូវជូនចាស់បង្ខំអោយទទួលបណ្តាំចុងក្រោយរបស់គាត់។ នៅវេលាជប់លៀងយប់នេះ នាយនឹងត្រូវឪពុកនឹងម្តាយចុងរបស់នាយបង្ខំអោយជួប ត តួជាមួយនឹងនារីម្នាក់ដែលគាត់រៀបចំណាត់អោយមកជួបគ្នា។ ម្យ៉ាង ទៀត សុបិនគេនឹកខកចិត្តណាស់ដែលឪពុកបានប្រាប់ថា ម្តាយចុងគេមកពីអាមេរិកវិញនៅរវាងអាទិត្យក្រោយឯណោះ។ មិនទាន់បានប្រាំថ្ងៃស្រួល បួលផង ស្រាប់តែគាត់មកដល់ទៅហើយ។ មែនហើយ សុភាពស្ត្រីចំណាស់ អំបាញមិញនោះគឺគ្មាននរណាក្រៅពីអ្នកស្រីលីដាភរិយារបស់លោកសៅរិន នោះឡើយ ហើយក៏ជាមនុស្សដែលសុបិនចូលចិត្តដើរគេចមួយអាយ៉ូសទៅ ហើយដែរ។ នៅក្នុងបន្ទប់ សុបិនអង្គុយច្រងុកតប់ប្រមល់តែម្នាក់ឯង។ ភ្លាមនោះ ស្រាប់តែមានអ្នកបំរើប្រុសម្នាក់ចូលមក :

- លោកសុបិន!

- អូហ៏! នាយកុក? មានការអីហ្អែស?

- គឺថា លោកប្រុសអោយមកជំរាបអញ្ជើញលោកចុះទៅក្រោម ព្រោះអីមានភ្ញៀវមកជួបជុំហើយហើយលោកក៏ចង់បើកកម្មវិធីឥលូវនេះ។

- ជំរាបលោកប៉ាទៅ ថាខ្ញុំអស់កំលាំង មិនអាចចុះទៅបានទេ។ សូមសំរាក បន្តិចសិន។

- មិនបានទេ! លោកមានប្រសាសន៏ថា... បើខ្ញុំអញ្ជើញលោកចុះទៅមិន បានទេ នោះលោកនឹងដេញខ្ញុំចោលលែងអោយធ្វើការហើយ។

លុះឃើញនាយកុកធ្វើមុខជូរហួញ សុបិនក៏ស្ទុះងើបឡើង ឆ្លើយថា :

- ណ្ហើយចុះ! យើងក៏មិនចង់ឃើញនាយកុកឯងអស់ការធ្វើដែរ។

CHANBOKEO.COM

ថាហើយ សុបិនស្រវាអាវធំពាក់ពីក្រៅមួយហើយក៏ចុះជណ្ដើរចេញ ទៅ។ នៅក្នុងសួនច្បារមុខផ្ទះដែលមានការតុបតែងវេទិកា និងតុអាហារ ជប់លៀងយ៉ាងប្រណិត សុបិនបានឃើញភ្ញៀវជាច្រើនសិបនាក់មកចូលរួមសុទ្ធតែមានលក្ខណៈជាអភិជន។ ភ្លាមនោះ   នារីស្រស់ស្អាតមួយរូបបានផុសឆ្លោឡើងមកដល់ :

- សួស្ដីលោកសុបិន!

គ្រាន់តែក្រលេកឃើញនារីដ៏ស្រស់ឆើតឆាយនោះភ្លាម ស្រាប់តែបុរស យើងញញឹមភ្លែតតែម្ដង។ គេក៏ទទួលការចាប់ដៃរាក់ទាក់ពីធិតាមួយរូប នោះយ៉ាងរហ័ស :

- សួស្ដី អ្នកនាងកិរិយា! បែកគ្នាយូរ នៅតែស្រស់ស្អាតគ្មានប្លែកសោះ!

ពេលនោះ បេះដូងសុបិនប្រែជារីកស្រស់បំព្រងក្រៃលែងកាលបើបាន ជួបមុខរាជនីដ៏សោភា។ រំពេចនោះកិរិយាក៏ណែនាំខ្លួនមិត្តស្រីម្នាក់ដែល នៅឈរក្បែរនាងថា :

- លោកសុបិន នេះគឺមិត្តស្រីរបស់ខ្ញុំឈ្មោះ អម្ពរ...

ស្រាប់តែលោកសេរីនប្រកាសហៅពីលើវេទិកាកាត់ការសន្ទនារបស់ អ្នកទាំងពីរមួយរំពេចៈ

- សួស្ដី! អស់លោកនិងភ្ញៀវកិត្តិយសទាំងឡាយ។ ពេលនេះ ខ្ញុំមានសេចក្ដីសោមនស្សនឹងណែនាំវត្តមានកូនប្រុសរបស់ខ្ញុំឈ្មោះសុបិន...

កាលបើឮឪពុកហៅចំឈ្មោះពីវេទិកាមក សុបិនក៏បែកអារម្មណ៍មិនបានគួរសមនឹងនាងអម្ពរជាមិត្តរបស់កិរិយាដែលនៅឈរស្ងៀម១ក្បែរនោះ ទេ។ គេគ្រាន់តែញញឹមដាក់កិរិយារួចហើយក៏ស្ទុះដើរឡើងឆាកទំនងមាន កំលាំងចិត្តប្លែកជាងពីថ្ងៃរសៀល។ នោះព្រោះហេតុអ្វីទៅហ្ន៎? ប្រហែលជា មកពីវត្តមាននារីរូបស្រស់ក្នុងកម្មវិធីនោះទេដឹង។ ពេលនោះសុបិនរីករាយចិត្តញញឹមបិទមាត់មិនជិតស្ទើរតែស្ងួតជើងធ្មេញអស់ទៅហើយ។ បន្តិចមកនាយក៏ឡើងច្រៀងនូវបទចំរៀងពិសេសមួយបទ ជូនដល់ហ្វូងនារីក្រមុំ១ សោភាទាំងឡាយយ៉ាងពិសេស :

ស្មៀងបេះដូង

| | | |
|---|---|---|
| ១- | សៀងបេះដូង ទូងរណ្ដំ | សូររងំក្នុងដួងចិន្ដា |
| | ស្រែកហៅ ហៅម្ចាស់ឱរា | ស្នេហាកំពូលជីវី ។ |
| ២- | សៀងបេះដូង ច្រៀងអង្វរ | ឆោមកេសរបវរអញ្ចលិ |
| | ក្រោមមេឃលើធរណី | ជីវីបងផ្ញើស្រីហើយ ។ |
| បន្ទរ- | ឆ្លើយចាំ ណាំពៅពិសី | សូមប្រណីកុំនៅកន្ដើយ |
| | ឆ្លើយប្រាប់ឆាប់ណាំត្រាណត្រើយ ចំលើយថាស្ម័គ្រមេត្រី ។ | |
| ៣- | សៀងបេះដូងយំប្រាថ្នា | តែបុផ្ផាផ្កាកល្យាណី |
| | សច្ចាបូជាសង្ឃ័យ | ដើម្បី ក្ដីស្នេហ៍តែមួយ ។ |

CHANDOKEO.COM

ស្នូរទះដៃលាន់រំពងឡើងយ៉ាងគគ្រឹកគគ្រេងព្រមទាំងស្នូរស្រែកហ៊ោរ យ៉ាងសប្បាយរបស់ភ្ញៀវទាំងឡាយ ។ បន្តិចមក អ្នកស្រីដាលីម្តាយចុង របស់សុបិនក៏រត់មកកេះបុរសយើងហើយខ្សិបថា :

- សុបិន! លោកប៉ាចង់ណែនាំអោយកូនស្គាល់មនុស្សម្នាក់ណា៎!

- គឺនារីដែលមានឈ្មោះអម្ពរនោះមែនទេ?

- មែនហើយ! នាងកំពុងអង្គុយជាមួយលោកប៉ាឯតុខាងក្រោយឯនុ៎ះ ។

សុបិនក្រលេកទៅឃើញលោកប៉ារបស់នាយកំពុងតែជជែកគ្នាជាមួយ នារីមួយរូបពាក់វ៉ែនតាស ចងសក់កន្ទុយសេះ ស្លៀករ៉ូបពណ៌សសុភាព១មិន ឆើតឆាយទាល់តែសោះ ។ នាយហាក់ដូចជាចាប់ភ្លឹកថាបានឃើញនាងនៅ ត្រង់ណាម្តងតែរកនឹកមិនឃើញសោះ ។ ចៃដន្យ សុបិនជាបុរសដែលចូល ចិត្តតែនារីស៊ិចស៊ីវ៉ៃយ៉ហ៊ឺហា ។ កាលបើឃើញធិតានោះហាក់ដូចជាតុបតែង កាយហាក់ដូចជាសាមញ្ញពេក នាយយើងមិននឹកចាប់អារម្មណ៍អ្វីឡើយ ។ គេក៏បែរញញឹមដាក់ម្តាយចុងហើយក៏ពោលថា :

- សូមទោសអ្នកស្រី រាត្រីនេះ ខ្ញុំមានគូរាំហើយ មិនចង់ទទួលគូថ្មីទេបាទ!

ថាហើយសុបិនក៏ដើរចេញទៅអញ្ជើញនារីហ៊ឺហាឈ្មោះគិរិយា ឡើងរាំ ធ្វើព្រងើយដោយមិននឹកនាខ្វល់ថា ម្តាយចុងរបស់នាយ ឬឪពុកនាយមាន អារម្មណ៍យ៉ាងណាចំពោះនាយនៅពេលនេះទេ ។ មួយស្របក់ក្រោយមក សុបិនលួចសង្កេតឃើញអ្នកស្រីដាលីដើរសំដៅទៅអោនខ្សិបដាក់នាងអម្ពរ រួចហើយក៏នាំគ្នាដើរចេញទៅ ។ បន្ទាប់មក អ្នកស្រីក៏ត្រលប់មកវិញតែ ម្នាក់ឯង ។ សុបិន ឃើញដូច្នោះនឹកអរព្រួចក្នុងចិត្តតែម្តង :

- សាធុ! ភាំង! ពេលនេះសុបិនស្រលះដួងចិត្តហើយ រាំអោយសប្បាយម្តង

មែនហើយ សុបិនបានដៃគូស្រស់ឆើតឆាយហើយពូកែរាំយ៉ាងប្រណិត ដូចអ្នកនាងគិរិយានោះ នាយក៏ជ្រះបាត់អស់ការតប់ប្រមល់អស់រលីងពីក្នុង ចិត្តតែម្តង ។ ភ្ញៀវទាំងឡាយក៏សំណេះសំណាលគ្នាយ៉ាងសប្បាយ ខ្លះក៏ ឡើងរាំ ខ្លះក៏នាំគ្នាដើរកំសាន្តកសួនក្នុងបរិវេណផ្ទះ គ្មាននរណាចាប់ភ្លឹកពី នរណាទេ ។ បន្តិចមក ស្រាប់តែ ភ្លេងដូរចង្វាក់ទៅជាចង្វាក់ក្បាច់ប្រពៃណី ខ្មែរមួយបទយ៉ាងពិរោះបំផុត ធ្វើអោយភ្ញៀវទាំងឡាយបែរមើលទៅលើ ឆាកវេទិកាគ្រប់ៗគ្នាតែម្តង ។ រីឯសុបិនដែលកំពុងតែសើចយ៉ាងក្អាកក្អាយ ជាមួយគិរិយានិងមិត្តភក្តិរួមតុ ក៏ទុចសំណើចង៉ក់បែរមើលទៅវេទិកានឹងគេ ដែរ ។ ភ្លាមនោះ តរុណីមួយរូបយ៉ាងសោភាក្នុងសំលៀកនារីប្រពៃណីដើរ ឡើងឆាកមួយៗដោយមានបន្លឺសៀងយ៉ាងពិរោះ តាមរយៈឃោសនសព្ទ អមដោយសំនៀងតន្ត្រីយ៉ាងរងំជូនភ្ញៀវទាំងអស់ :

## ស្នេហាផ្កាឈូករតន៍

ឱផ្កាឈូករតន៍ភ្លាត់ស្នេហ៍សុរិយា
យល់រង្សីថ្លាផ្ការជោនិច្ច
ឈូករតន៍សប្បាយភ្លេចគិតថ្ងៃលិច
រាត្រីដល់ធ្មេចឱនសោកសង្រេង ។

CHANDBOKEO.COM

ថ្ងៃរីកយប់រោយគ្មាននរណាដឹង ស្នេហ៍សូរ្យព្រលឹងស្មារតីវង្វេង
មិនហ៊ានវាចាសព្ទ័សារថ្លាថ្លែង ក្នុងចិត្តគិតក្រែងគេមិនប្រណី ។

ខ្លួនទាបដៃខ្លីហេតុអ្វីប៉ងភ្នំ រួចហើយគេងយំសោកាហប្ញទ័យ
ជាតិជាបុផ្ផាប្ញសជាប់នៅដី ម្ដេចហ៊ានលូកដៃឈោងចាប់វេហាសី ។

ឱ! ទិនករអើយអាសូរផ្កាទេហ៍ ឈូករតន៏លង់ស្នេហ៍ព្រះសែងសុរិយា
ទោះបីជាខ្ពស់ហួសក្ដីប្រាថ្នា ត្រឹមរង្សីថ្លាក៏គង់ឱ្យផ្កាញញឹមបានមួយគ្រា...

ពិរោះណាស់ ពិតជាពិរោះគាប់សោតាតែម្ដង ។ សុបិនឈរស្ដាប់នាង ឡើងភ្លឹកស្មារតី ស្ទើរមិនហ៊ានព្រិច មិនហ៊ានដកដង្ហើម ។ ធិតាមានរូបរាង ស្រស់ស្អាតណាស់ ហើយក៏មានសំនៀងទន់ភ្លន់គួរអោយចេតនាក្រៃលែង ។ សុបិនមិនដែលប្រទះនារីណាម្នាក់ក្នុងជីវិតនាយដែលអាចច្រៀងពិរោះគាប់ ចិត្តនាយឡើយ ។ នេះជាលើកដំបូងហើយដែលនាយចាប់ភ្លឹកឈរស្ដាប់បទ ចំរៀងរបស់នាង តាំងពីដើមរហូតដល់ចប់ ដោយមិនព្រិចភ្នែក ហើយមិនបែកអារម្មណ៍ ។ ស្នូរទះដៃក៏លាន់រំពងឡើងយ៉ាងខ្សៀវខ្វា ។ បន្ទាប់មក ឆវី មួយរូបនោះក៏លំទោនកាយលាភ្ញៀវ ថយខ្លួនទៅនៅខាងក្រោយវេទិកា

បាត់ទៅ ។ សុបិនឃើញដូច្នោះក៏ពោលទៅកិរិយាថា :

- សូមទោសណ៎អ្នកនាងរូបស្អាត! ខ្ញុំសូមខ្លួនមួយភ្លែត បន្តិចខ្ញុំនឹងត្រលប់ មកវិញ ។

កិរិយាញញឹមហើយងក់ក្បាល ទំនងមិនបានចាប់ភ្លឹកនឹងប្ញកពារបស់ សុបិនទេ ។ នាងក៏បែរទៅជជែកជាមួយមិត្តភក្តិរបស់នាងបន្តទៀត ។ រីឯ កំលោះយើងក៏ឆ្លេឆ្លាមកដល់ក្រោយឆាក តែមិនបានប្រទះនរណាឡើយ ។ លុះនាយសួរអ្នកយាមនៅទីនេះ គេប្រាប់ថា ធិតាអ្នកចំរៀងរូបនោះបាន ដើរចេញទៅក្រៅសំដៅទីជប់លៀងវិញហើយ មិនបាននៅទីនោះទៀត ទេ ។ សុបិនក៏ត្រលប់ដើរត្រលប់មកដល់ធ្លាខាងក្រៅ ស្រាប់តែប្រទះនឹង លោកសោរិន ឪពុករបស់នាយ :

- សុបិន! មានការអីហ្នឹងកូន បានជាធ្វើប្ញកពា ឆ្លេឆ្លា១?

- គឺ... តាមរកគេម្នាក់នោះណ៎លោកប៉ា...

- គេណាទៅ ដែលសំខាន់រហូតដល់ឯងរត់តាមរកយ៉ាងតក្កហលបែបនេះ?

- គឺ.. គឺ... ( ឮឪពុកសួរជាន់កែង សុបិនក៏ឆ្លើយលែងរួចតែម្ដង )

ពេលនោះ អ្នកស្រីលីដាក៏មកដល់ភ្លាមដែរ :

- មានការអ្វីសុបិនកូន?

CHANBOKEO.COM

សុបិននៅស្ងៀម តែភ្នែកនាយនៅតែរេចុះរេឡើងតាមរកនារីមួយរូប នោះដដែល ។ ឃើញដូច្នោះ អ្នកស្រីលីដាក៏មានប្រសាសន៍ថា :

- សុបិន! ចង់អោយមីងណែនាំនារីដែលច្រៀងពិរោះអំបាញមិញនេះ ដល់ កូនទេ?

ចំចំណុច សុបិនក៏ឈរអេះអុញនិយាយលែងចេញតែម្តង ។ បន្ទាប់មក អ្នកស្រីក៏អួសដៃសុបិនភ្លែតព្រមទាំងមានប្រសាសន៍បន្តថា :

- ម៉ោះ! ទៅខាងនេះ មីងបានប្រទះគេអំបាញមិញ ឃើញរៀបចំបំរុងនឹង ឡើងរថយន្តត្រលប់ទៅផ្ទះវិញហើយ ។

ទើបតែពេលនេះទេដែលសុបិនបណ្តោយអោយអ្នកស្រីលីដាម្តាយចុង របស់នាយអួសដៃបានដោយគ្មានប្រកែកមួយម៉ាត់សោះឡើយ ។ អ្នកស្រី ក៏បាននាំមាណពមកដល់មាត់របងភូមិគ្រឹះ ស្រាប់តែអ្នកទាំងពីរប្រទះនារី ដ៏សោភាមួយរូបនោះកំពុងឡើងរថយន្តជិះចេញដំណើរទៅបាត់ ទោះចង់ រត់ទៅឃាត់ក៏ឃាត់មិនទាន់ផង ។ សុបិនឈរធ្វើមុខស្មឿកដោយខកចិត្ត មិនបានជួបមុខជួបសន្ទនាជាមួយនារីសោភា ។ ភ្លាមនោះសុបិនក៏សួរទៅ អ្នកស្រីលីដាថា :

- អ្នកស្រី! តើនារីមួយរូបនោះជានរណាដែរទៅ?

- អូហ៎! គេគឺជាកូនចៅសាច់ញាតិរបស់ភ្ញៀវយើងនារាត្រីនេះឯង ។

ពេលនោះស្រាប់តែលោកសេរិនមកដល់ :

- សុបិន! មានចាស់ទុំសុំហៅអោយកូនឡើងច្រៀងជូនគាត់មួយបទតលូវ នេះ ច្រៀងបានទេកូន?

សំណូមពរនេះក៏បានមកកាត់ចង្វាក់សន្ទនារបស់សុបិនជាមួយអ្នកស្រី លីដាភ្លាម ម្ល៉ោះហើយសុបិនក៏លែងបានសួរនាំថាមាណវីនោះជានរណា ។

ពិធីជប់លៀងបានបញ្ចប់ទៅដោយរីករាយ...

សុបិនដើរទៅដើរមកក្នុងបន្ទប់ នឹកឆ្ងល់ក្នុងចិត្តថាតើនារីសោភានោះ ជានរណា ហើយហេតុដូចម្តេចបានជាមកបង្ហាញខ្លួនភ្លិបភ្លែតដូចជាអំពិល អំពែកមួយភ្លែតក៏បាត់ខ្លួនទៅវិញ ។ តើនាងជាមនុស្សដែលលោកសេរិន និងអ្នកស្រីលីដាចង់ណែនាំអោយនាយស្គាល់ឬក៏មិនមែនទេ? សុបិនចង់ ដឹងណាស់ តែមិនហ៊ានមុខស្តើងមុខក្រាសចេញទៅសួរឪពុករបស់ខ្លួនដែរ បើអោយទៅសួរអ្នកស្រីលីដាទៀត គឺរឹតតែស្រេចណាស់ទៅទៀត ត្បិត នាយមិនដែលចូលចិត្តម្តាយចុងមួយរូបនោះរួចទៅហើយ ។ ដោយធុញថប់ តប់ប្រមល់ពេក សុបិនក៏ស្លៀកពាក់ហើយបញ្ចេះឡានបំរុងចេញទៅក្រៅ..

- សុបិនទៅណាទាំងយប់អញ្ចឹងកូន?

កំលោះបែរមុខទៅ ឃើញឪពុកឈរមើលពីលើរានហាលជាន់ទីពីរមក ក៏ឆ្លើយជំរាបលោកថា :

- កូនមានការទៅជួបមិត្តភក្តិមួយភ្លែត បន្តិចកូនមកវិញហើយ លោកប៉ា!

CHANBOKEO.COM

ថាហើយនាយយើងក៏ថយឡានចេញទៅ ។ លុះមកដល់ក្រៅរបង ស្រាប់តែនាយចាប់ភ្លឹកថា នៅលើកញ្ចក់ឡានខាងមុខ មានផ្កាកុលាបមួយ ទងសៀតជាប់នៅទីនោះ ថែមទាំងមានភ្ជាប់កូនកាតមួយសន្លឹកផង :

ជំរៅចិត្តបងយ៉ាងណា

| | |
|---|---|
| ពេលផ្កាបានយល់កែវភ្នែកថ្លាយង់ | ឆ្លើយប្រាប់នួនល្អងថាគួរសង្ឃឹម |
| ចិត្តផ្ការំភើបលបលួចញញឹម | លង់ចិត្តសង្ឃឹមលើស្នេហ៍ប្រុសថ្លៃ ។ |
| បានស្តាប់សូរសៀងសំនៀងក្រអួន | ចំរៀងស្នេហ៍ស្ងួនចិត្តសែនអរភ័យ |
| ផ្កាពិតចង់ដឹងចង់យល់អត្ថន័យ | បងពិតភក្តីផ្កាមួយឬទេ? |
| ផ្កាពិតចង់ដឹងព្រលឹងបងឆ្លើយ | ប្រាប់មកគ្រាណាត្រើយបងគិតម្តេចដែរ |
| រាប់គ្នាជាមិត្តឬគូបុព្វេ | មុំគិតច្រើនទ្វេខ្លាចបងមុសា ។ |
| ឆ្លើយប្រាប់ផ្កាភ្លាមឆ្លើយមកដោយត្រង់ | អ្នកជាកន្លង់ក្រេបរសបុផ្ផា |
| សប្បាយមួយគ្រារួចហើយសាវ៉ា | លាតដៃលាផ្កាយាត្រាថ្មីទៀត? |
| | ហត្ថលេខា : ផ្កា |

សុបិនភ្ញាក់ក្រញាងដូចគេចាប់គ្រវែង ត្បិតនេះជាលើកទីពីរហើយ ដែលនាយទទួលកាតនេះពីនារីឈ្មោះផ្កា :

- តើនាងជានរណា? ហេតុអ្វីហ៊ានត្រឹមសរសេរមិនហ៊ានជួបមុខគ្នា? តើ នេះជាកំណាព្យឬក៏ជាចំរៀងឆ្លើយឆ្លងជាមួយសុបិន? ខ្ញុំពិតជាមិនយល់ទេ ហេតុអ្វីក៏នាងចាំធ្វើខ្លួនជាមនុស្សអាថិកំបាំងផង?

សុបិនអង្គុយសំកុកមួយស្របក់ក៏បើកឡានចេញទៅ...

តុក! តុក! តុក!

- នរណាគេហ្នឹង?
- គឺខ្ញុំណ៎ាលំអង... ខ្ញុំ...សុបិន....!!

មែនហើយ... មិនដឹងជាយ៉ាងម៉េចទេ នាយយើងបើកឡានត្រេះត្រុះ ទៅមកៗជាច្រើនសា មិនដឹងថាចង់ទៅណាទេស្រាប់តែបានមកដល់មុខផ្ទះ របស់លំអងដោយមិនដឹងខ្លួន ។ ធិតាបើកទ្វារឡើងឃើញសុបិនក៏ភ្ញាក់ស្រលាំងកាំង លាន់មាត់ឡើងថា :

- លោកសុបិន?
- បាទ! អោយខ្ញុំសុំចូលទៅក្នុងផ្ទះផងបានទេ?

លំអងក៏អុជចង្កៀងឡើង ។ សុបិនដាក់ខ្លួនអង្គុយនៅលើគ្រែរនាប រួចហើយក៏សួរនារីយើងថា :

- សុខទុក្ខយ៉ាងណាហើយ លំអង?
- ចាំស! ខ្ញុំមិនអីទេ! ចុះលោកមានការអ្វីដែរ...ទាំងយប់អាធ្រាត?

CHANBOKEO.COM

- គឺ... ខ្ញុំនឹកឃើញថា នាងនៅម្នាក់ឯង... ទើបបារម្ភ...

- ពុទ្ធោ! អរគុណណាស់ដែលលោកយកចិត្តទុកដាក់ចំពោះលំអងដល់ម្លឹង! តែខ្ញុំពិតជាមិនអីមែនណា៎! លោកមិនបាច់បារម្ភទេ ។ ខ្ញុំពិតជាអាចជួយខ្លួន ឯងបាន ថ្វីត្បិតខ្ញុំមានជំងឺភ្នែកមើលមិនសូវឃើញដូចគេធម្មតាបាន តែមិន ពិការកំសត់រហូតដល់ជួយខ្លួនឯងមិនរួចនោះដែរ ។

- នាងពិតជាមនុស្សរឹងប៉ឹងមែនលំអង! ខុសអ្វីតែខ្ញុំ តាំងចិត្តមិនបានរឹងប៉ឹង ដូចនាងសោះ ។

- លោកមានបញ្ហាអ្វីក្នុងជីវិតទៀតហើយមែនទេ?

សុបិនងក់ក្បាលហើយសំលឹងមុខលំអង ។ ទោះបីជាពេលនេះនាងមិន បានទទូរក្រមាក៏ដោយ ក៏មាណពមិនអាចមើលមុខនាងច្បាស់ដែរ ត្បិតអី ចង្កៀងខ្លាញ់ត្រីមួយនោះបញ្ចេញពន្លឺព្រឹមៗពន់ពេក ណាមួយនាងក៏អង្គុយ ឆ្ងាយរហូតទៅដល់កៀនជញ្ជាំងឯណោះ ។ ទោះជាយ៉ាងណា សុបិនហាក់ ដូចជាចាប់ភ្លឹកថាទំរង់មុខរបស់នាងមានសោភ័ណគួរអោយចេតនាណាស់ ។ កំលោះយើងសំលឹងលំអងមិនហ៊ានព្រិចទេ មើលទៅគេហាក់ដូចជាលួច ចាប់អារម្មណ៏អំពីរូបនាងក្នុងចិត្តតិចៗដែរហើយ ។ កាលបើឃើញសុបិន អង្គុយសំលឹងមកនាងមិនដាក់ភ្នែក ធិតាយើងក៏ទាញក្រមាយកមកទទូរ វិញជាប្រញាប់ ។ ឃើញដូច្នោះ សុបិនក៏លួចញញឹមហើយសួរថា :

- នាងមិនទុកចិត្តខ្ញុំទេ មែនទេ?

លំអងនៅស្ងៀម លួចកេះក្រចកមិននិយាយស្តី ។ សុបិនក៏វាចាបន្ត :

- លំអង! តើយើងអាចធ្វើជាមិត្តនឹងគ្នាបានទេ?

- ស្លាប់ហើយ! មិនបានទេ ! (លំអងឆ្លើយវិញ)

- ហេតុអ្វីក៏មិនបាន?

- ជាបុរសនិងស្ត្រី យើងត្រូវតែរក្សាព្រំដែនបន្តិចហើយណា៎ ។

សុបិននៅស្ងៀម ។ ការពិតមិនដឹងមកពីហេតុអ្វីទេ នាយយើងហាក់ ដូចជាចូលចិត្តការសន្ទនាជាមួយធិតាយើងអ្វីម្ល៉េះ ។ កាលពីមុននាយយើង ហាក់ដូចជាមិនចូលចិត្តនាងសោះ តែលុះដល់ស្គាល់នាងយូរទៅ សុបិនបែរ ជាគិតថា នាងជាមនុស្សម្នាក់ដែលតែងតែនាំភាពកក់ក្តៅហើយសប្បាយ រីករាយមកដល់ដួងចិត្តរបស់នាយជានិច្ច ។ រំពេចនោះ នាយយើងក៏សួរថា :

- លំអង! នាងមានសង្សារហើយនៅ?

លំអងភ្ញាក់ដូចគេកន្ត្រាក់កាលបើឮសំនួរដូច្នោះ ។ នាងក៏ឆ្លើយថា :

- មនុស្សក្រីក្រ សុខភាពអន់ៗ រូបរាបអន់ៗដូចជាខ្ញុំនេះ តើមាននរណាគេ ខ្វះទៅនឹងយកភ្នែកមើល?...

- ខ្ញុំថា គេច្បាស់ជាមិនយកភ្នែកមើលនាងទេ លំអង! ប្រហែលជាគេយក ដួងចិត្តមកសំលឹងនាងវិញទេដឹង (សុបិនឆ្លើយទាំងញញឹមលាក់គំនួច )

CHANBOKEO.COM

ឮដូច្នោះ ស្រាប់តែលំអងត្រជាក់ដៃស្រេបតែម្តង។ មាណវីនឹកខ្មាស បុរសយើងណាស់ដែលចេះតែនាំសួរសំនួរផ្ទាល់ខ្លួនច្រើនពេក។ ភ្លាមនោះ តរុណីយើងក៏ស្ទុះរត់ចូលពួនក្នុងមុងបាត់ មិនព្រមនៅជជែកលេងជាមួយ នឹងសុបិនទៀតឡើយទុកឱ្យនាយនៅអង្គុយញញឹមតែម្នាក់ឯង នឹករំភើប ចិត្តដោយឃើញនាងអៀនខ្មាសចំពោះនាយដែលកំពុងលលេង។ បន្តិចមក សុបិនក៏រៀបចងមុងចូលដំណេកដែរ ប៉ុន្តែ...នាយយើងនៅតែរសាប់រសល់ ក្នុងចិត្តមិនស្ងៀមសោះ ក៏ស្ទុះងើបចេញពីមុងមកបបួលនាងលំអងនិយាយ គ្នា បន្តទៅទៀត :

- លំអងចង់ដឹងទេ ថាថ្ងៃនេះ នៅផ្ទះរបស់ខ្ញុំមានរឿងអ្វីកើតឡើងខ្លះ?

រំពេចនោះ លំអងប្រែខ្លួន តែសុបិនមិនឮនាងសួរអ្វីសោះ។ គេក៏ និយាយបន្តទៅទៀតថា :

- គឺខ្ញុំបានប្រទះនារីមួយរូបនៅក្នុងពិធីជប់លៀងនោះ... ថៃដន្យយើងមិន មានឱកាសជួបចាប់ដៃចងសម្ពន្ធ័មិត្តនឹងគ្នា។ ប៉ុន្តែ គួរអោយចំលែកណាស់ ពេលដែលខ្ញុំបានឃើញនារីមួយរូបនោះភ្លាម ស្រាប់តែខ្ញុំនឹកដល់នាងតែម្តង ណាំ ដឹងទេហ៎...?

រំពេចនោះស្រាប់តែលំអងប្រែខ្លួនឡើងហើយឆ្លើយថា :

- សង្ស័យតែនារីនោះមុខមាត់មើលមិនបានដូចខ្ញុំដែរហើយ...

- ខុសហើយ.. គេមានរូបរាងស្រស់ស្អាតសោភាខុសពីនាងឆ្ងាយណាស់ ប៉ុន្តែអ្វីដែលខ្ញុំចាប់ភ្លឹកជាងគេនោះគឺ... នាងមិនអនុញ្ញាត្តអោយខ្ញុំចូលជិត ឃើញមុខរបស់នាងជិតៗទេ គ្រាន់តែឃើញម៉ាក្រលេកក៏គេចបាត់ទៅ...

- លោកចង់ថាខ្ញុំនិងនាងជាមនុស្សតែមួយមែនទេ?

- មិនមែនទេ... បើសិនជានាងនិងនារីម្នាក់នោះជាមនុស្សតែមួយ ម៉្លេះសម សុបិនសប្បាយចិត្តស្លាប់ហើយ មិនមែនមកអង្គុយពិបាកចិត្តនៅវេលានេះ ទេណាំ...

- អូហ៎... នេះ សង្ស័យតែលោកលួចស្រលាញ់គេហើយទេដឹង?

- មែន... នាងមានរូបសោភាណាស់ ហើយមានសៀងពិរោះទៀតផង។ មួយបទដែលនាងច្រៀងចេញមកនៅក្នុងពិធីបុណ្យនោះ បានច្របាច់បេះ ដូងដៃករបស់សុបិនអោយជ្រាយដូចស្ករកៅស៊ូ តែម្តង។

សុបិនលួចចោលកន្ទុយភ្នែកមើលទៅលំអង ក្នុងចិត្តបន់អោយនាង ងើបមកនិយាយសាសងជាមួយនាយនៅខាងក្រៅមុង តែនាងនៅតែមិន ព្រមចេញមកសោះ។ សុបិនក៏និយាយថែមទៀតថា :

- លំអង... នាងជឿទេ ថាខ្ញុំកំពុងតែលង់ក្នុងរន្ទះស្នេហាផ្លេកបន្ទោរ?

- ចឹក៏មិនជឿ...

- ម៉េចក៏នាងជឿកើត?

- គឺមកពីលោកអន្ទះសារត់មកប្រាប់ខ្ញុំទាំងយប់នេះអី...

លំអងនិយាយត្រូវប៉ាកតែម្តង។ សុបិនសើចខឹកៗដែលធិតាទាយចំ។ មែនហើយ សុបិនហាក់ដូចជាសប្បាយចិត្ត លែងតប់ប្រមល់ទៀតហើយ កាលបើបានជជែកជាមួយនារីយើងពីនេះពីនោះ រហូតលង់ដំណេកទៅ...

CHANBOKEO.COM

CHANBOKEO.COM

# វគ្គទី៥

# កន្លង់ស្លាបមាស

ព្រឹកស្អែកឡើង...

សុបិនភ្ញាក់ឡើង ឃើញស្លកបបរមួយដាក់លើតុទុកអោយនាងស្រេច ថែមទាំងមានកូនសំបុត្រមួយសរសេរប្រាប់ថា :

- លំអងត្រូវទៅធ្វើការហើយ មិនអាចនៅបំរើលោកបានទេ ។ សូមពិសារ បបរនិងពងទាប្រៃដែលខ្ញុំដួសទុកជូននេះចុះ... លំអង!

សុបិនមិនដែលចូលចិត្តបរិភោគបែបនេះទេ ប៉ុន្តែលុះនឹកឃើញដល់ទឹក ចិត្តដែលលំអងខំក្រោកដាំទុកអោយនាយសុខចិត្តអង្គុយបរិភោគម្នាក់ឯង ស្មៀមស្ងាត់រហូតដល់អស់ពីចាន ។ បន្តិចមក នាយក៏រៀបចំខ្លួនត្រលប់ទៅ ផ្ទះវិញ ។ នៅរសៀលថ្ងៃដដែល សុបិនក៏ត្រលប់ទៅធ្វើការនៅហាងស្អែក មិនយកលុយតាមការណាត់របស់អ្នកចាត់ចែង ត្បិតអីថៅកែយូនិក្សមិន នៅ ។ សុបិនក៏ឡើងច្រៀងលើឆាកដូចធម្មតាឡើងវិញ ។ មនុស្សម្នានិង ភ្ញៀវទាំងឡាយបានចូលមកសាទរចំពោះអ្នកចំរៀងសុបិនយើងយ៉ាងកុះ ករក្រៃលែង ធ្វើអោយនាយយើងរីកមុខដូចគ្រាប់ជីរ ។

បន្ទាប់ពីបញ្ចប់បទដ៏ពិរោះមួយដែលសុបិនឡើងច្រៀងបើកឆាកដំបូង ភ្ញៀវជាច្រើនបានឡើងមកក្បែរឆាកពពាក់ពពូនដើម្បីពាក់កំរងផ្កាអោយ នាយ ។ ភ្លាមនោះ សុបិនបានក្រលេកឃើញតរុណីមួយរូបពាក់មួកកន្តិប ពាក់វ៉ែនតាស ហើយចងសក់កន្ទុយសេះ យកផ្កាមួយកំរងមកហុចបំរុងនឹង បំពាក់ឱ្យនាយដែរតែសុបិនមិនបានចាប់អារម្មណ៍ទេ ត្បិតមើលទៅនាងជា មនុស្សសាមញ្ញៗ ម្ល៉ោះហើយក៏ពើមិនព្រមទទួលពីនាងឡើយ ។ កាលបើ ឃើញសុបិនវាយឫកឆ្មើងកន្ទ្រើង ធិតានោះក៏បោះផ្កាព្រូសទៅលើកំរាល វេទិកាភ្លែតហើយដើរចេញទៅវិញភ្លាម ។ សុបិនធ្លាប់ឃើញឥរិយាបថបែប នេះម្តងកាលពីលើកមុនម្តងហើយ ។ ពេលនោះនាយក៏ចាប់ភ្លឹកភ្លាមដែរថា នារីនោះប្រហែលជាមនុស្សដដែលកាលពីថ្ងៃមុននោះហើយ ។ សុបិនក៏ស្ទុះ រត់ទៅចុងជាយវេទិការកមើលមុខនារីព្រហើន ហ៊ានបោកផ្កាចោលចំពោះ មុខទស្សនិកជនរាប់រយ ។ ចៃដន្យនាយមើលមុខធិតាមួយរូបនោះមិនទាន់ ទាល់តែសោះ គ្រាន់តែឃើញភ្លិបភ្លែតៗពីក្រោយប៉ុណ្ណោះ ។ អ្វីដែលបុរស យើងចាប់បាននៅពេលនេះគឺនាយយើងចំណាំបានថា ពេលសក់កន្ទុយសេះ របស់នាងយោលទៅយោលមក.. បុរសយើងបានឃើញប្រជ្រុយក្រហម មួយនៅលើកញ្ចឹងកខាងក្រោយរបស់នាងតែប៉ុណ្ណោះ ។ សំណាងល្អ លើក នេះ សុបិនហាក់ដូចជាមិនខឹងក្រេវក្រោធចំពោះនារីនោះដូចមុនទេតែនាយ បែរជាចាប់អារម្មណ៍ចំពោះនាងទៅវិញថា ទំរង់មុខមួយហ្នឹង ស្លៀកពាក់ ស្រដៀងៗហ្នឹង... គឺនាយធ្លាប់ឃើញពីមុនមកនៅត្រង់ណា... តែក៏រកនឹក មិនឃើញទាល់តែសោះ ។ ពេលនេះ

CHANBOKEO.COM

នាយហាក់ដូចជាចាប់ផ្ដើមចាប់ភ្លឹក ចំពោះនារីចំលែកនោះបន្ដិចហើយ ហើយក៏ចង់ដឹងណាស់ដែរថានារីរូបនោះ ជានរណា។ នៅពាក់កណ្ដាលអាធ្រាតចប់ការងារ សុបិនក៏ដើរសំដៅទៅ រថយន្តបំរុងនឹងបើកត្រលប់ទៅផ្ទះវិញ ស្រាប់តែប្រទះនឹងកូនកាតតូចមួយ ព្រមទាំងផ្កាកុលាបមួយទង សៀតនឹងកញ្ចក់ឡានខាងមុខជាថ្មីម្ដងទៀត ហើយ។ សុបិនភ្ញាក់ព្រើតទាញកាតយកមកអាន :

កន្លង់ស្លាបមាស

ឱកន្លង់អើយកន្លង់ស្លាបមាស ស្អាតដូចឱភាសនាព្រឹកព្រលឹម
កន្លង់សង្ហារូបាគ្មានផ្ទឹម កន្លង់ញញឹមត្រអាលអស់ផ្កា។
ឱកន្លង់អើយត្រេចចរលេងខ្លួន មិនលាក់មិនពួនអំនួតកាយា
កន្លង់ស្លាបមាសលង់លិចកាមា ត្រេចចរស្វែងផ្កាក្រពុំគ្រប់មែក។
ឱកន្លង់អើយកន្លង់សង្ហា បើភ្លេចអាត្មាតិចលង់សង្វេគ
សប្បាយថ្ងៃនេះកុំភ្លេចថ្ងៃស្អែក មេឃរាំងដីបែកអស់មែកព្រឹក្សនៅ។
កង់ត្រាចកង់ផ្គងវិលវង់ម្ដងម្នាក់ ឡើងខ្ពស់អាចធ្លាក់ក្នុងជ្រោះរណ្ដៅ
បើភ្លេចអាត្មាច្បាស់ធ្លោយលង់ជ្រៅ កន្លង់នោមឆ្លៅនៅស្មារតីឬទេ?

ហត្ថលេខា : ផ្កា

ពេលនេះ សុបិនស្វាងងងុយធេងតែម្ដងកាលបើឃើញកំណាព្យមួយ នេះ។ ពិតហើយ កាលពីលើកមុនៗ នាយមិនដែលចាប់ភ្លឹកទេ ថាកំណាព្យ នោះសរសេរមានន័យយ៉ាងណា ដើម្បីអ្វី។ តែពេលនេះ សុបិនដឹងច្បាស់ថា កវីឈ្មោះផ្កាកំពុងចាក់ផាផ្លែផ្កាដល់នាយហើយ។ តើនរណាទៅដែលតែង តែលួចសរសេរកាព្យចំរៀងបញ្ចោះបន្ទោរកអោយបុរសយើង?

រំពេចនោះ នាយឮសូរសំណើចរអឹកឡើងពីក្រោយខ្នង។ សុបិនបែរ មើលទៅឃើញកញ្ញាឆើតឆាយកិរិយា កំពុងដើរអោបដៃលោកយូនិក្សជា ឳពុកចេញពីភោជនីយដ្ឋានសំដៅទៅរថយន្ត។ កាលបើប្រទះមុខគ្នា កិរិយា ក៏ពោលវ៉ាងឡើង :

- អេហ៍ លោកសុបិន! មិនទាន់ចេញទៅផ្ទះទេហ្នឹង?

- បាទ! បំរុងទៅហើយអ្នកនាងកិរិយា។

ភ្លាមនោះ លោកយូនិក្សក៏មានប្រសាសន៍ថា :

- អើហ៍ មកជួបមុខដូច្នេះល្អហើយ ហ្នក់ កិរិយា បបួលសុបិនទៅក្រែងគេ ទំនេរអាចជូនកូនបានណ៎ា ត្បិតព្រឹកស្អែកនេះ ប៉ាមានការរវល់ណាស់។

សុបិនឮដូច្នោះ ក៏ឈរធ្វើភាំងមិនដឹងរឿង។ ស្រាប់តែកិរិយាញញឹម ពព្រាយឡើងហើយក៏ឧទានឡើងថា :

CHANBOKEO.COM

- មែនហើយ! ហេតុអ្វីក៏កូននឹកមិនឃើញសោះអញ្ចឹង? អរគុណលោកប៉ា ដែលបានរំលឹក ( ស្រដីទៅឳពុកចប់ហើយ កិរិយាក៏បែរមករកសុបិនវិញ ហើយពោលបន្ត) លោកសុបិន! ស្អែកជូនខ្ញុំទៅតាខ្មៅបានទេហ៎? មានការ ផ្ទាល់ខ្លួន ត្រូវការអង្គរក្សជូនដំណើរបន្តិច....

ឮហើយ សុបិនអរព្រើត ឆ្លើយភ្លាម :

- បាទ! មិនជាប់រវល់អីទេ អាចជូនអ្នកនាងបាន ។

កិរិយាក៏ញញឹមបញ្ចេញធ្មេញសស្គុសឡើង :

- អរគុណណាស់លោកសុបិន! ស្អែកជួបគ្នា!

- បាទជំរាបលាអ្នកនាងកិរិយា ជំរាបលាលោកថៅកែ ។

បន្តិចមក លោកយូនិក្សក៏នាំកូនស្រីបររថយន្តចេញទៅ ។ សុបិនក៏បោះ កាតនិងផ្កាចូលក្នុងឡានហើយក៏បរចេញតាមក្រោយទៅដែរ ។

រាត្រីដដែល...

សុបិនដើរចុះដើរឡើងក្នុងបន្ទប់ គិតប្លែកៗតែម្នាក់ឯង ។ បន្តិចមក ស្រាប់តែចាប់កូនសោរឡានរឹងដើរចេញទៅ ។ លោកសេរីវនឃើញសុបិន ចេញពីផ្ទះទាំងយប់ក៏សួរកូនប្រុសថា :

- ទៅណាទៀតហើយកូនប្រុសប៉ា? នេះយប់អាធ្រាតហើយណា៎កូន! មិន ដេកមិនពួនទេឬអី? តិចលោអត់ងងុយក្លាយជាឈើខានធ្វើការទៅ ។

- បាទ! លោកប៉ា! កូនមានការមួយភ្លែត បន្តិចមកវិញហើយ ។

ថាហើយសុបិនក៏អោនគោរពលោកហើយបើកឡានចេញទៅ ទុកឱ្យ លោកសេរីវននិងភរិយាឈរមើលមុខគ្នាធ្វើឡឹងឡង់ ។ បន្តិចមកអ្នកស្រី លីដាមានប្រសាសន៍ថា :

- លោកសេរីវន! សុបិនគេធំពេញវ័យល្មមអាចគ្រប់គ្រងជីវិតរបស់គេបាន ហើយ... សូមកុំបារម្ភពីគេពេកអីណា៎!

លោកសេរីវនញញឹមហើយឆ្លើយថា :

- ទោះជាកូនមានវ័យប៉ុណ្ណា ក៏ឳពុកម្តាយនៅតែបារម្ភដូចគ្នា... យ៉ាងណាក៏ ខ្ញុំនៅតែកាត់ចិត្តបណ្តោយគេមិនបានដែរ តែបើគេពិតជាធំដឹងក្តីពិតមែន ខ្ញុំសូមបន់អោយគេជួបប្រទះសេចក្តីសុខនិងប្រព្រឹត្តតែអំពើល្អជានិច្ច...

លោកទាំងពីរក៏នាំគ្នាវិលចូលដំណេកវិញទៅ ។ រីឯសុបិនយើងវិញគេ រសាប់រសល់ក្នុងចិត្តណាស់ នឹកគិតមិនអស់មិនហើយពីនារីឈ្មោះផ្កា ដែល សរសេរកំណាព្យផ្ញើផ្កាអោយនាយ...

តុក! តុក! តុក!

- នរណាហ្នឹងចាស?

- លំអង!... គឺ ខ្ញុំសុបិនណា៎!

CHANBOKEO.COM

- លោកសុបិន? មានការអ្វីទៀតហើយ ទាំងពាក់អាធ្រាត?

សុបិនហាក់ដូចជាសប្បាយចិត្តណាស់ កាលបើឃើញលំអងនៅផ្ទះ ។ គេក៏ឆ្លើយទៅនាងវិញថា :

- គឺខ្ញុំមានរឿងចង់ពិគ្រោះ... តប់ប្រមល់ពេកមិនដឹងទៅណា ទើបមករក នាងនៅទីនេះទៅ ។

ថាហើយនាយយើងក៏ដាក់ខ្លួនអង្គុយចុះ រួចបែរមើលទៅលំអងដែល កំពុងលូនចូលមុងវិញ :

- លំអង! នាងនៅជជែកលេងជាមួយខ្ញុំសិនបានទេ?

- លោកនិយាយទៅ ខ្ញុំចាំស្តាប់ហើយ...

- តែនាងកុំគេងលក់ចោលខ្ញុំណា៎...

- បើលោកមានរឿងពិរោះនិយាយអោយស្តាប់ ខ្ញុំមិនលក់ចោលងាយៗទេ

- អញ្ចឹងចេញសិនមក... អង្គុយនិយាយគ្នាខាងក្រៅមុងវិញ

- អត់ទេ! ខ្ញុំគេងខាងនេះចុះ ហើយលោកនិយាយរឿងលោកមក៏!

សុបិនសំលឹងធិតាតាមចន្លោះស្បៃមុង ទំនងចង់ដឹងថា នាងនៅស្តាប់រឿងរបស់នាយដែរឬទេ ។ លុះឃើញនាងគេងកើយដៃ បែរមុខមករកខ្លួន សុបិនក៏ពោលឡើងថា :

- លំអងដឹងទេ? ថ្ងៃនេះខ្ញុំមានរឿងភ្ញាក់ផ្អើលដល់ទៅពីររឿង...

- អូហ៎? ប្រហែលជារឿងសប្បាយហើយទើបរំភើបចិត្តរត់មកប្រាប់ខ្ញុំទាំងយប់អាធ្រាតដូច្នេះ?

- មែនហើយ! គឺថា... ស្អែកព្រឹកនេះ មាននារីរូបស្រស់មួយរូបគេបបួលខ្ញុំទៅកំដរគេមួយថ្ងៃ ។

- លោកពិតជាមានសំណាងណាស់ ។ ប្រហែលជាគេមានចិត្តមកលើលោក ហើយមើលទៅ ។

- ខ្ញុំក៏បន់អញ្ចឹងដែរព្រោះនាងមានរូបស្អាតហើយជាកូនអភិជនទៀតផង ។ បើសិនបានរូបនាងជាគូជីវិតគឺពិតជាសំណាងរបស់ខ្ញុំខ្ពស់ណាស់ ។

- ចុះរឿងភ្ញាក់ផ្អើលមួយទៀតនោះ?

- គឺ... ខ្ញុំទទួលលិខិតអនាមិកនិងផ្កាកុលាបពីនារីឈ្មោះផ្កាដល់ទៅបីដង

- គេសរសេរលើកទឹកចិត្តចំពោះទេពកោសល្យរបស់លោកមែនទេ?

- មិនមែនទេ! គឺគេសរសេរដាក់ផ្លែផ្កាអោយខ្ញុំតើហ៎!

- អូហ៎! លោកធ្វើអ្វីអោយគេអាក់អន់ស្រពន់ចិត្តទេដឹងហើយបានជា...

ឮដូច្នោះ សុបិនឈ្ងោកមុខ... មួយស្របក់ក៏ឆ្លើយឡើងថា:

- ប្រហែលអញ្ចឹងទេដឹង ការពិត ខ្ញុំមិនចូលចិត្តនារីដែលតាមជ្រែបុរសទេ

- មាននារីតាមជ្រែហើយ លោកមិនសប្បាយចិត្តទេហ៎?

CHANBOKEO.COM

- មិនទេ.. ឃើញមនុស្សកណ្តាចកណ្តោច ខ្ញុំខ្លាចមិនហ៊ានចង់បៀត...

- ធ្វើម៉េចនឹងដឹងទៅថាគេជាមនុស្សកណ្តាចកណ្តោច?

- ការស្លៀកពាក់តុបតែងខ្លួននោះអី... មើលទៅ មិនចូលភ្នែកសោះ...

- ប៉ុន្តែ ត្រឹមសំលៀកបំពាក់សំបកក្រៅ ធ្វើម៉េចនឹងអាចវាស់បានទៅថា គេជាមនុស្សកណ្តាចកណ្តោចទៅ?

- ខ្ញុំមិនដឹងទេ... តែប្រយត្ន័ខ្លួន...ប្រសើរជាងបណ្តោយខ្លួនអោយធ្លាក់ចូល ហ្វូងមនុស្សអារាត់អារាយដែរ...

មែន! សុបិនពោលក៏សមរម្យម្យ៉ាង លំអងពោលក៏សមម្យ៉ាងទៀត ។ បន្តិចមក សុបិនក៏ដកកាតពីហោប៉ៅចេញមក ហើយក៏ពោលថា :

- ខ្ញុំបានទទួលកាតបីសន្លឹកហើយ តែខ្ញុំបានបោះចោលកាតលើកដំបូងទៅ ។ ឥលូវនៅសល់ពីរសន្លឹក... នាងចង់ដឹងទេ... ខ្ញុំនឹងអានអោយស្តាប់...

- បើគេសរសេរចាក់ផាអោយលោកឈឺចិត្តនោះ ខ្ញុំមិនចង់ស្តាប់ទេ...

- ហេតុអ្វីទៅ លំអង?

- ព្រោះមិនចង់ឃើញលោកខ្វល់ខ្វាយចិត្ត ដោយសារពាក្យពេចន៍របស់គេ ប៉ុន្មានម៉ាត់នោះ...

សុបិនឮលំអងឆ្លើយដូច្នោះ ក៏រំភើបចិត្តព្រួចក្នុងពោះ :

- នាងនឹកគិតបារម្ភពីសុខទុក្ខរបស់ខ្ញុំដែរ?

- អត់ទេ ខ្ញុំបារម្ភពីសុខទុក្ខរបស់ខ្លួនឯងតើ ព្រោះខ្លាចត្រូវអង្គុយអត់ងងុយ ស្តាប់លោកត្អូញពិបាកចិត្តមួយយប់ទល់ភ្លឺនោះតើហ៎...
( ថាហើយធិតា សើចរលាក់ខឹកៗយ៉ាងរីករាយតែម្តង)

សុបិនឮដូច្នោះក៏ញញឹមទាំងឃ្នាន់ខ្នាញ់ :

- ពុទ្ធោ! នេះ លំអងជាមិត្តរបស់ខ្ញុំ ឬក៏ជាមិត្តរបស់បក្សពួកម្ខាងទៀត?

- គឺ... មិនមែនទាំងសងខាងហ្នឹងណា៎!...

លំអងនៅតែសើចខឹកៗដដែល ធ្វើអោយសុបិននឹកខ្នាញ់ចង់តែទៅស្ទុះ អូសនាងចេញពីមុងមកបូតច្រមុះលេងម្តងៗទៅហើយ ។ រាត្រីនោះ សុបិន គេងញញឹមតែម្នាក់ឯង នឹករំភើបចិត្តដែលលំអងមិនមែនជាមនុស្សគំរោះ ដូចនាយនឹកស្មាននោះឡើយ ។ ការពិតកាលពីមុន នាយក៏មានចំណែកខុស ខ្លះៗដែរ ដែលខ្លួនវាយឫករើសអើងឆ្មើងកន្ត្រើង មិនមើលកាលៈទេសៈ ។ ឥលូវនេះ សុបិនហាក់ដូចជាមានអារម្មណ៍សប្បាយរំភើបចិត្តណាស់ ពេល ណាដែលបានសន្ទនាជាមួយលំអង ជាពិសេសនាងតែងតែមានពាក្យឆ្លើយ តបប្រកបដោយគតិរិះគិតវែងឆ្ងាយ ហើយមានចិត្តទូលំទូលាយទៀតផង ។ គិតយូរៗទៅ សុបិនចេះតែឆ្ងល់ឡើងថាបើលំអងជាអ្នករស់នៅទីទ័លម្លឹងៗ ហេតុអ្វីក៏សំដីមើលទៅរបៀបអ្នកដែលបានរៀនសូត្រទៅវិញ? ឬក៏នាង ធ្លាប់ជានិស្សិតតែត្រូវព្រាត់ការសិក្សាព្រោះថវិកាខ្សត់ខ្សោយ... គិតទៅ គិតមក នាយក៏លង់ដំណោកទៅ ។

CHANBOKEO.COM

ព្រឹកស្អែកឡើង...

សុបិនភ្ញាក់មិនដែលទាន់ដំណើររបស់លំអងចេញទៅធ្វើការទេ ។ ព្រឹក នោះ នាងទុកបាយកកនិងស្ករផែនមួយដុំលើតុព្រមទាំងចំណារតូចមួយថា:

- ថ្ងៃនេះលំអងក្រោកយឺតទើបបបរជូនមិនទាន់ ។ សូមពិសារបាយកកនិង ស្ករផែនសិនទៅ ។ ថ្ងៃក្រោយបើចង់ពិសារអាហារព្រឹក សូមកុំនាំលំអង ជជែកយប់ជ្រៅទៀតណា៎ ។

សុបិនអានចប់ក៏ញញឹមម្នាក់ឯង ។ ថ្វីបើបាយកកនិងស្ករផែនមើលទៅ ដូចជាគ្មានរសជាតិអ្វីសោះ ជាពិសេសសំរាប់សុបិនយើងដែលជាមនុស្ស រើសចំណីបំផុត ប៉ុន្តែចំពោះសន្តានចិត្តរបស់លំអងដែលតែងតែយកចិត្តទុកដាក់ចំពោះនាយ មាណពមិនដាច់ចិត្តទុកបាយកកនោះអោយនៅក្រៀម ផ្អូមចោលដោយឯកឯងឡើយ ។ គេហាក់ដូចជានឹកអាណិតស្រលាញ់ លំអងណាស់ ត្បិតនាងតែងចែករំលែកនូវអ្វីដែលនាងមាន ដល់រូបនាយជានិច្ចមិនថាពេលណា ។ ភ្លាមនោះ គេយកស្លាបព្រាគាស់ស្ករផែនដាក់ជា មួយបាយកក ហើយក៏ប្រឹងទំពារលេបរហូតទាល់តែអស់ ទើបធ្វើដំណើរ ចេញទៅ ។

ថ្ងៃនេះសុបិនមានអារម្មណ៍ស្រស់ថ្លាក្នុងចិត្តណាស់ ។ នាយក៏មកទទួល កិរិយាធ្វើដំណើរទៅតាខ្មៅទាំងអស់គ្នាដូចការណាត់ ។ បន្ទាប់ចប់កិច្ចការរួច រាល់ហើយ កិរិយាក៏បបួលសុបិនទៅបរិភោគអាហារនៅអាហារដ្ឋាន មាត់ទឹកមួយយ៉ាងឆ្ងាញ់ពិសារ ។ ប៉ុន្តែមាណវីសោភាយើងមិនមានបញ្ចេញ អាកប្បកិរិយាណាជាសញ្ញាថានាងពេញចិត្តបុរសយើងទេ ។ សុបិនឃើញនាងមានចរិតស្មើៗជាមិត្តធម្មតាប៉ុណ្ណោះ ។ រសៀលបន្តិច គេក៏នាំគ្នា ត្រលប់មកផ្ទះវិញ ត្បិតសុបិនត្រូវត្រលប់ទៅបំពេញនាទីជាអ្នកចំរៀងវិញ ដូចប្រក្រតី ។ លុះមកដល់ផ្ទះផ្លាស់សំលៀកបំពាក់រួចហើយ គេក៏ចាប់កូនសោរបំរុងនឹងបររថយន្តចេញទៅធ្វើការ ស្រាប់តែ លោកសៅរិននិង អ្នកស្រីលីដាក៏បានមកដល់ផ្ទះ :

- សុបិន! បន្តិចមានភ្ញៀវមកលេងផ្ទះយើង កូនមានពេលបួនដប់នាទីទេ?

- បាទ! អត់ទេ លោកប៉ា! ខ្ញុំដល់ម៉ោងត្រូវទៅធ្វើការហើយ ។

- អឺ! ថ្ងៃណាដែលកូនទំនេរ កុំភ្លេចប្រាប់ប៉ាផង ដើម្បីណាត់អោយត្រូវ ពេលគ្នាណា៎កូន ។

- បាទ! ជំរាបលាសិនហើយលោកប៉ា ! អ្នកមីង!

សុបិនក៏សំពះលាលោកទាំងពីរហើយថយឡានចេញទៅ ។ រំពេចនោះ រថយន្តថ្មីស្រឡាងមួយក៏បានចូលមកដល់ ជ្រលួសគ្នានឹងរថយន្តរបស់សុបិន ដែលកំពុងថយចេញទៅក្រៅ ។ លុះនាយយើងចោលកន្ទុយភ្នែកទៅស្រាប់ តែប្រទះនឹងនារីមួយរូបពាក់វ៉ែនតាស ហើយចងសក់កន្ទុយសេះ អង្គុយនៅ បាំងខាងក្រោយ ។ នាយភ្ញាក់ព្រើតនឹកចង់បកត្រលប់ចូលផ្ទះវិញ ។ ចៃដន្យ ពេលនោះ នាយក៏ដល់ម៉ោងត្រូវឡើងសំដែងដែរ ម្ល៉ោះហើយក៏ត្រូវខក មិនអាចបកក្រោយបាន ។ មាណពជ្រួញចិញ្ចើមលួចមើលតាមកញ្ចក់ រថយន្តទៅក្រោយ ឃើញនារីនោះចុះពីរថយន្តមកឱនសំពះអ្នកស្រីលីដា និងលោកសៅរិនដោយអាការៈស្និទ្ធស្នាល ។

CHANBOKEO.COM

សុបិនខំរកនឹកឈ្មោះធិតា នោះក្នុងចិត្ត តែរកនឹកយ៉ាងណាក៏មិនឃើញសោះ គ្រាន់តែចាំបានថា នាយធ្លាប់បានឃើញនាងពីមុនមក... ។

សុបិនភ្ញាក់ក្រញ្ញាងពេលនាយចូលមកដល់ភោជនីយដ្ឋានភ្លាម ត្បិតថ្ងៃ នោះ ថៅកែយូនិក្សបានរើសបុគ្គលិកអ្នកចំរៀងល្បីៗថែមពីររូបទៀតដែល មានរូបរាងសង្ហាមិនចាញ់នាយឡើយ ។ រីឯថ្វីដៃទេពកោសល្យនិងទឹកដម សំនៀងរបស់គេទាំងពីរក៏ល្អឆ្នើមពិបាកនឹងប្រកួតជាមួយ ។ ម្នាក់មានទេពកោសល្យមិនចាញ់អ្នកចំរៀងព្រាបសុវត្ថិឡើយ ។ គេមានឈ្មោះថាតាវ៉ៅ ។ ចំណែកម្នាក់ទៀតមានទឹកដមសំនៀងប្រជេញគ្នាជាមួយនឹងលោកអធិរាជ សំនៀងទេពស៊ិនស៊ីសាមុត ។ គេមានឈ្មោះថា កាសូ ។ រាត្រីនោះ សុបិនក៏ ត្រូវភ្ញៀវពិសេសប្រចាំហាងបង្ខំអោយឡើងច្រៀង ប្រកួតជាមួយនឹងអ្នក ចំរៀងថ្មីទាំងពីររូបនោះ ។ ចៃដន្យការទះដៃគាំទ្រប្រជាប្រិយភាពនិងទេព កោសល្យរបស់នាយ ត្រូវចាញ់ថ្វីដៃរបស់នាយតាវ៉ៅដាច់ ហៅលែងឮតែម្តងធ្វើអោយសុបិនបាក់មុខអស់ទឹកចិត្តរលីង ។ មាណពក៏សូមថៅកែឈប់ សំរាកមុនម៉ោងហើយចុះពីលើវេទិកាសំដៅទៅអង្គុយនៅតុមួយតែម្នាក់ ឯង បន្ទាប់មកក៏ហៅអ្នកបំរើចាក់ស្រាអោយនាយផឹក ដើម្បីបំបាត់ក្តីអាមាសដែលថ្វីដៃរបស់នាយកំពុងត្រូវរលកថ្មីបោកផ្ទប់ពន្លិច ។ កំពុងតែ លើកកែវស្រាអក ស្រាប់តែមានសំលេងមនុស្សប្រុសម្នាក់និយាយរកនាយ ពីតុមួយនៅជិតនោះថា :

- ផឹកស្រា.... ព្រោះចាញ់ដៃគេ... ផឹក... ផឹកអោយណាណីតែម្តងទៅ!

សុបិនកំពុងតែស្រវឹងស្រឿងៗ កាលបើឮវាចាដូច្នោះ ក៏ងាកផាំងបែរ មើលម្ចាស់សំដី ក៏ប្រទះនាយកាសូដែលកំពុងស្រវឹងធ្លាក់ភ្នែក ។ មាណព ភ្ញាក់ព្រើតត្បិតមិននឹកស្មានថា កាសូដែលជាអ្នកចំរៀងជើងខែងម្នាក់បែរជាធ្លាក់បុណ្យមកផឹកស្រាដូចនាយដែរ ។ គេក៏ងើបចេញពីតុខ្លួនដើរសំដៅ ទៅរកតុរបស់កាសូហើយក៏ដាក់ខ្លួនអង្គុយចុះ សួរថា:

- ហើយចុះលោកប្អូនវិញ ផឹកស្រាដោយសារចាញ់ដៃនាយតាវ៉ៅដែរឬអី?

តែនាយកាសូមិនឆ្លើយទេ បែរជាអង្គុយសំលក់កែវស្រារបស់នាយ មិនពព្រិចភ្នែកឡើយ ។ សុបិនឃើញហើយក៏វាចាថែមឡើងទៀតថា :

- លោកប្អូនហ្អា!... គេចាក់ស្រាសំរាប់ផឹក មិនមែនសំរាប់យកមកអង្គុយសំលក់ទេណា៎ នែ៎...បើមិនផឹកទេ ទុកអោយសុបិនផឹកជំនួសចុះ ។

ថាចប់ សុបិនក៏ស្រវាកែវស្រាពីដៃនាយកាសូលើកអកខ្វាប់អស់រលីងតែម្តង ។ ស្រាប់តែនាយកាសូបើកភ្នែកធំៗឡើង ហើយសួរសុបិនថា :

- ហើយនេះ ល្បងឯងចង់ផឹកស្រាសំលាប់ខ្លួន ដូចខ្ញុំដែរមែនទេ?

- អត់ទេ! ខ្ញុំផឹកអោយសប្បាយតើហ៎... វាយ៉ាងម៉េចឬល្បង?

- អូហ៎ បើអញ្ចឹង ល្បងឯងផឹកស្រាក្នុងកែវរបស់ខ្ញុំនេះធ្វើអ្វី? ការពិតខ្ញុំ បានដាក់ថ្នាំបំពុលក្នុងកែវស្រា បំរុងនឹងផឹកសំលាប់ខ្លួនខ្ញុំតើហ៎...

CHANBOKEO.COM

ញដូច្នោះ សុបិនភ្ញាក់ដូចគេចាប់គ្រវែងក្នុងទន្លេទឹកកកអញ្ចឹង គឺស្រាប់ តែរងាកកក្ដាមឯង១តែម្ដង ។ នាយយើងឧទានខ្លាំង១ថា :

- ពុទ្ធោពុទ្ធំ ធម្មំ សង្ឃំ ទំពាំងស្លកាវី.... ម៉េចបានលោកប្អូនឯងមិនប្រាប់ បងមុនផង ថាឯងដាក់ថ្នាំបំពុលក្នុងស្រានេះ....?

- ចុះនរណាទៅដឹងថា ល្បងឯងឆក់ស្រាខ្ញុំទៅផឹកដូច្នេះ?

ភ្លាមនោះ កាសូនឹកឃើញមធ្យោបាយមួយភ្លាម :

- មិនអីទេល្បង បើមិនទាន់ចង់ងាប់ទេ ហារមាត់មក ចាំខ្ញុំជួយព្យាបាល អោយ ដើម្បីកុំឱ្យងាប់...!

សុបិនភិតភ័យពេក គិតអីមិនទាន់ ក៏ហារមាត់ឡើង ។ នាយកាសូក៏ យកចង្អុលដៃរបស់នាយរុកចូលក្នុងបំពង់ករបស់សុបិនភ្លាម :

- នេះនែ៎ យើងចេះអាក្បួនពេទ្យបុរាណនេះយូរហើយវ៉ើយ តែប៉ុណ្ណេះល្បង ឯងលែងងាប់ស្រេច ។

- វ៉ក (សុបិនក៏ក្អួតឡើង)

- អីយ៉ាស់... ខ្ញុំខំជួយអោយល្បងឯងក្អួតចេញអស់ថ្នាំពុលពីពោះ កុំអោយ ងាប់ ចុះហេតុអីជាក្អួតដាក់ខ្ញុំទៅវិញ? យ៉ាប់មែន (កាសូលាន់មាត់ខ្លាំង១)

ពេលនោះ សុបិនកំពុងតែក្អួតវ៉ក១ ដង្ហក់ខ្យល់ប្រផិតប្រផើយឆ្លើយ ទៅវិញមិនរួចឡើយ ។ កាសូក៏ក្រលាប់ផើងផ្កា ចាក់ដីចេញ ហើយក៏លើក យកផើងមកត្រងកំអួតរបស់សុបិន បន្តិចមកក៏សើចវ៉ាស១ឡើង :

- ថ្ងៃនេះ កាសូយើងមានរាសីណាស់វ៉ើយ ដែលមានមនុស្សមករងគ្រោះ ជំនួស ហាំសហាំ១ !!

សុបិនកំពុងតែដង្ហក់ខ្យល់ កាលបើឮដូច្នោះ គេខឹងណាស់ ក៏បែរមុខ បំរុងនឹងរកទាត់នាយកាសូលេងទៅហើយ ស្រាប់តែមានមនុស្សម្នាក់លូក ហុចកូនកន្សែងអោយនាយជូតកំអួតចេញពីមុខ ហើយគេក៏ដើរចេញទៅ ។ គ្រាន់តែទទួលកន្សែងជូតមុខរួចហើយ នាយក៏បែររកកាសូ ស្រាប់តែបុរស នោះដើរចេញទៅក្រៅបាត់ ធ្វើអោយសុបិនខកចិត្តស្រលះផេង ។ នាយ យើងក៏ដាក់ខ្លួនចុះ ដកដង្ហើមបន្ធូរពោះមួយស្របក់ ទើបមានអារម្មណ៍ថា បានគ្រាន់បើបន្តិច ។ នាយក៏ទាញយកកូនកន្សែងមកលាត បំរុងនឹងជូត ញើសដែលកំពុងតែស្រក់ពីថ្ងាស ស្រាប់តែភ្ញាក់ព្រើតស្វាងស្រាផេងតែម្ដង ត្បិតនោះគឺជាកូនកន្សែងដែលនាយបានយកគប់ក្បាលនារីម្នាក់ ដោយ កំហឹងកាលពីថ្ងៃមុននោះតើហ៎ ។ នាយក៏ទំលាក់កន្សែងចុះនៅលើតុហើយ ស្ទុះឆ្លេឆ្លាតាមរកមើលមនុស្សដែលហុចកន្សែងមករកនាយ ចៃដន្យសុបិន មិនបានចំណាំគេម្នាក់នោះទេថាជានរណា ម៉្លោះហើយមាណពក៏ត្រូវខកចិត្ត ក្រៃលែង ដែលខ្លួនមិនអាចរកឃើញថា នរណាមួយហុចកន្សែងនេះដល់ នាយ ។ បន្តិចមក នាយយើងក៏ដើរចេញសំដៅរថយន្ត ស្រាប់តែប្រទះនឹង ផ្កាកុលាបមួយទងព្រមទាំងកូនកាតមួយដែលសរសេរថា :

CHANBOKEO.COM

តស៊ូ...!

រលកបោកបក់មិនឈប់ឈរ    ជូនទៅជូនមកតាមទិសខ្យល់
ម្ដៃចាញ់ម្ដៃឈ្នះពិតវិលវល់    ម្ដេចឡើយអំពល់រឿងប៉ុណ្ណឹង។
ថ្ងៃខ្លះយើងឈ្នះខ្លះយើងចាញ់    ជារឿងសាមញ្ញទេព្រលឹង
ទោះឈ្នះឬចាញ់គួរកុំខឹង    កោសល្យមាំរឹងពឹងចិត្តស៊ូ។
បើចាញ់ថ្ងៃនេះប្រឹងថ្ងៃស្អែក    ចាប់កោសល្យប្លែកយកមកប្ដូរ
កុំបាក់ទឹកចិត្តភ្លេចតស៊ូ    ព្យាយាមយូរៗគង់ថ្កើងវិញ។
បើធ្លាក់ទឹកចិត្តធ្វើបាបខ្លួន    កោសល្យនឹងសូន្យយន់ទោម្ទេញ
ថ្វីដៃជាច្រើនទាំងនោះមិញ    រលាយទៅវិញសូន្យអាសារ។
ច្នៃគប្បីគិតសាជាថ្មី    ស្វែងរកស្នាដៃកោសល្យការ
ប្លែកៗបំរើញាតិការ    ស្អែកងើបឡើងស្ការល្បីម្ដងទៀត។
    ហត្ថលេខា ផ្កា

ចំលែកមែន! រាល់ដងដែលផ្កាសរសេរមកសុបិន គេតែងតែលេងផ្លែ សំដីចំពោះរូបសុបិនណាស់។ តែលើកនេះ គេបែរជាសរសេរលើកទឹកចិត្ត ដល់បុរសយើងទៅវិញ។ អានចប់ សុបិនលើកផ្កាមកសំលឹងមួយស្របក់ ក៏បង្អោននាសាថើបផ្កា ហើយពោលខ្សឹបៗតែម្នាក់ឯងថា :

- អរគុណផ្កា ចំពោះកំណាព្យដ៏ល្អមួយនេះ... !

ស្រាប់តែនាយនឹកឃើញដល់កូនកន្សែង ដែលនាយបោះចោលនៅលើ តុ ក៏ស្ទុះរត់ទៅយកវិញ ស្រាប់តែឃើញអ្នកបំរើសាតុអស់ ហើយរៀបជា ថ្មីយ៉ាងស្អាត។ នាយយើងក៏សួរអ្នកបំរើថា :

- ប្អូន! មានឃើញកូនកន្សែងខៀវមួយរបស់បងនៅលើតុនេះទេ?

អ្នកបំរើក៏ឆ្លើយវិញថា :

- បាទ! អ្នកបំរើមានច្រើនគ្នាណាស់ដែលមកសំអាតតាមតុ មិនដឹងថាមួយ ណាគេមកសំអាតទេ ប៉ុន្ដែបើសិនពួកយើងប្រទះ ចាំយើងរើសទុកជូនបាទ!

- អឺ! អរគុណណាស់ប្អូន!

សុបិនបើកឡានផង សំលឹងផ្កាផង នឹកឆ្ងល់មិនអស់មិនហើយនៅក្នុង ចិត្តតែម្នាក់ឯង។ ប៉ុន្ដែលើកនេះ សុបិនមិនបោះផ្កាចោលដូចលើកមុនៗទេ។ គេបែរជាកាន់ផ្កាយករហូតទៅដល់ផ្ទះ។ ពេលនោះ លោកសោរិននិង អ្នកស្រីលិដាមិនទាន់ចូលដំណេកនៅឡើយទេ។ កាលបើឃើញសុបិនកាន់ ផ្កាចូលផ្ទះ ធ្វើទឹកមុខងឿងឆ្ងល់ផងរីករាយផង លោកសោរិនសំលឹងមុខ ភរិយាធ្វើឡឹងឡង់ តែគ្មាននរណាម្នាក់និយាយអ្វីសួរនាយអីអ្វីទេ។ រីឯ

CHANBOKEO.COM

សុបិនដែលកំពុងផ្តោតអារម្មណ៍ទៅលើម្ចាស់ផ្កាដ៏អាថិកំបាំង ក៏មិនបាននឹក

ចាប់ភ្លឹកដល់វត្តមានរបស់ឪពុកនិងម្តាយចុងរបស់ខ្លួនវេលានោះដែរ ។ គេក៏ ដើរហួសឡើងជណ្តើរចូលបន្ទប់បាត់ទៅ ។

នៅរាត្រីនោះ សុបិនគេងមិនលក់ទេ ។ គេរសាប់រសល់ក្នុងចិត្តសាជាថ្មី ទៀតហើយ ។ សុបិននឹកគិតមិនអស់ចិត្តសោះ អំពីម្ចាស់កំណាព្យ និងផ្កា កុលាបដែលនាយយើងបានទទួលបីបួនដងហើយ ជាពិសេសបំផុតគឺនឹកទៅ ដល់អ្នកដែលយកកូនកន្ទ្រេងមកប្រគល់អោយនាយវិញ មិនដឹងថាគេជា នរណា ។ ដែលគួរអោយឆ្ងល់បំផុតនោះ គឺហេតុម្តេចរូបនាយក្លាយជាតួអង្គ ក្នុងរឿងម្ចាស់ផ្កាអាថិកំបាំងនេះទៅវិញ ។ កាលគ្រាមុនៗ សុបិនចាប់ អារម្មណ៍ចំពោះតែនារីស៊ិចស៊ីឆើតឆាយសោភាទេ ។ ប៉ុន្តែនៅ ពេលថ្មីៗនេះ សុបិនហាក់ដូចជាបោះជំហានឃ្លាតឆ្ងាយពីជំហរនោះហើយ ។ គេបែរជា ចាប់ភ្លឹកចង់ដឹងចង់តាមដានរឿងថ្មីទៅវិញថាតើ តើនារីអាថិកំបាំងនោះជា នរណា ហើយតើនាងតាមឆាឆៅរូបនាយក្នុងបំណងអ្វីដែរ ។ សុបិនដើរទៅ ដើរមកក្នុងបន្ទប់មិនអស់ចិត្ត ក៏ស្ទុះរឺងបររថយន្តចេញទៅ ។ លោកសៅរិន មើលពីលើផ្ទះមកឃើញសុបិនចេញពីផ្ទះទាំងយប់អាធ្រាត ក៏លាន់មាត់ សួរភរិយារបស់លោកថា :

- ហើយចុះ សុបិនគេទៅណា រៀងរាល់យប់អញ្ចឹង? ប្លែកណាស់! កាលពី ដើមរៀងមក គេមិនដែលដើរចោលផ្ទះពេលយប់ម្តងណាទេ តែពេលនេះ បាត់អោយរាល់យប់តែម្តង ។

អ្នកស្រីលីដាញញឹមហើយឆ្លើយថា :

- ខ្ញុំគិតថា ប្រហែលជាគេកំពុងស្វែងរកភាពកក់ក្តៅ សំរាប់បេះដូងដ៏សែន រងារបស់គេហើយមើលទៅ ។

លោកសៅរិនឮដូច្នោះក៏មានប្រសាសន៍តបវិញថា :

- បើពិតមែននោះ បងបន់ស្រន់សូមអោយម្ចាស់បេះដូងរបស់គេនោះ ជា មនុស្សដ៏ល្អប្រសើរម្នាក់ផងចុះ ។

- ខ្ញុំក៏សង្ឃឹមអញ្ចឹងដែរណាបង! សុបិនជាមនុស្សរើសអើងដៃគូណាស់ នារីល្មមៗ មិនអាចទិញបេះដូងរបស់សុបិនបានដោយងាយៗឡើយ ។

ថ្លែងពីសុបិនវិញម្តង...

បន្តិចក្រោយមក គេក៏បានមកដល់ផ្ទះលំអង ។ តែ ថ្ងៃនេះចំលែកមែន សុបិនបានគោះទ្វារជាច្រើនដងហើយ តែស្ងាត់ច្រៀបមិនឃើញនាងចេញ មកបើកទ្វារទទួលដូចរាល់ដងឡើយ ។ សុបិននឹកពិភាល់ចំលែកក្នុងចិត្ត យ៉ាងម៉េចមិនដឹង កាលបើមិនបានជួបលំអង ។ គេនៅរេរាមួយស្របក់ នឹក គិតបំរុងនឹងដើរត្រលប់ទៅឡានវិញ ស្រាប់តែនាយយើងឮសំលេងច្រៀង រហ៊ឹមៗពីខាងក្រោយផ្ទះមក ។ មាណពកំលោះភ្ញាក់ស្មារតីព្រើតលួចផ្ទៀង ស្តាប់ តែម្នាក់ឯង :

បក្សីកំព្រា

សូរសៀងទឹកហូរជំនោររាត្រី អង្វែលហប្ញទ័យបបោសចិន្តា
អាធ្រាតជ្រៅស្ងាត់មានចន្ទ័តារា ក្រអូបក្លិនផ្កានាសាផ្តេកផ្តិត ។

ចម្រៀតបំពេរបង្វៃអារម្មណ៍ ទីទុយមៀមយំកាត់ស្បៃងជិត
ចុងព្រឹក្សយោលយោគទិសខ្យល់ជីវិត រាត្រីងងិតព្រឺព្រួចអាត្មា ។
អាកាសត្រជាក់ថ្មមអង្អែលកាយ ចន្ទ័រះពណ្ណរាយព្វដ៏វេហាស៍
ពពករសាត់ណាត់ក្លិនបុផ្ផា រសាយចិន្តាពីទុក្ខកំសត់ ។
រស្មីព្រិច១លើផ្ទៃគង្គា ហាក់លោមឱរាផុតផ្សារន្ធត់
ជីវិតចាបព្រៃហៅសែនតក់ស្លុត ថ្ងៃណាឆ្លងផុតភាពកំព្រាអង្គ....?

ពិតមែនតែសំនៀងនោះព្វខ្សិបតិច១ពិតមែនតែមានភាពស្រទន់ពិរោះ គួរអោយចាប់ចិត្តចេតនាក្រៃលែង ។ សុបិនស្តាប់ព្វហើយនឹករំជួលរំភើប ក្នុងចិត្តចំលែករកថាមិនត្រូវ ។ បុរសក៏ដើរសំដៅទៅរកទិសសំលេងនោះ ភ្លាម ។ មកដល់ក្រោយផ្ទះដែលមានស្រះឈូកយ៉ាងធំ គេបានឃើញនារី មួយរូបអង្គុយតែម្នាក់ឯងលើស្ពានឫស្សី សំយុងជើងក្នុងទឹកទំលាក់កេសា រំសាយ បែរខ្នងមករកនាយ ងើបមុខសំលឹងទៅព្រះចន្ទ័ដែលកំពុងរះភ្លឺថ្លា ពណ្ណរាយ ។ គេសំលឹងនារីនោះមិនដាក់ភ្នែកសោះ ត្បិតអីទិដ្ឋភាពក្រោម ក្រសែភ្នែករបស់នាយពេលនោះ ស្រស់ស្អាតដូចគំនូរវិចិត្រកម្មអញ្ចឹង មិន តែប៉ុណ្ណោះគឺថែមទាំងមានអមដោយសំនៀងដ៏ពិរោះរបស់នារីដែលអង្គុយ លើស្ពានយោលជើងទៅក្នុងនោះទៀតផង ធ្វើឱ្យសុបិនលួចគយគន់មើល យ៉ាងភ្លន់ភ្លឹកស្មារតីស្ទើរតែភ្លេចដកដង្ហើមម្តង១ទៅហើយ :

- ពិរោះណាស់! ស្អាតណាស់... គួរអោយប្រតិពទ្ធ័ម្ល៉េះទេ ( សុបិនលួចគិត ព្រឺព្រួចរំភើបក្នុងចិត្តតែម្នាក់ឯង) ឱ សុបិនអើយ! ពេលនេះ ហេតុអ្វីក៏ បេះដូងរបស់អ្នករំភើបញាប់ញ័រចំលែកបែបនេះ? គ្រាន់តែព្វសំនៀងរបស់ គេភ្លាម យើងក៏លួចស្នេហ៍គេពេញឱរាទៅហើយ? ហេតុអ្វី? ហេតុអីក៏ រហ័សម្ល៉េះហ្ន៎?

លុះព្វសូរិបជើងរបស់នាយយើង នារីនោះក៏ងាកមកយ៉ាងរហ័ស ។ សុបិនខ្លាចនាងភិតភ័យ ក៏ស្រដីថា :

- គឺខ្ញុំទេណាំលំអង... ខ្ញុំ.... សុបិន!
- អុំះ! លោកសុបិន... ខ្ញុំនឹកស្មានថា លោកមិនមកទេ យប់នេះ...
- នាងកំពុងនៅចាំផ្លូវរបស់ខ្ញុំមែនទេ...?
- គឺ... ខ្ញុំឃើញលោកមកទីនេះពេលយប់ជាញឹកញាប់ ទើបបានជានៅចាំ មិនទាន់ហ៊ានចូលគេង ។

សុបិនដើរមកជិត ហើយស្រដីថា :

- សុបិនសុំអង្គុយក្បែរ និយាយសន្ទនាលេងជាមួយនាងបានទេ?

លំអងញញឹម ហើយក៏រំកិលខិតខ្លួនចេញទុកកន្លែងឱ្យបុរសយើងដាក់ ខ្លួនអង្គុយក្បែរ ។ សុបិនសំរុតខ្លួនចុះរួចហើយក៏វាចាទៅលំអងថា :

- នាងច្រៀងពិរោះណាស់ លំអង! ចេះច្រៀងយូរហើយមែនទេ?
- ខ្ញុំចេះតែច្រៀងលេង កំដរអផ្សុកប៉ុណ្ណោះ យកជាការមិនបានទេ

CHANBOKEO .COM

- តែខ្ញុំចូលចិត្តស្តាប់សំនៀងរបស់នាងណាស់... ឮហើយរំភើបចិត្តតែម្តង

- អរគុណ...

- ប៉ុន្តែថ្ងៃនេះ មើលទៅនាងដូចជាសោកសៅចំលែក.. នឹកឃាយមែនទេ?

លំអងនៅស្ងៀម... បន្តិចមកក៏សួរសុបិនវិញ :

- លោក... ធុញទ្រាន់នឹងមកទីនេះទេហ៎?

ឮដូច្នោះ សុបិនសំលឹងមុខនាងជាថ្មី ។ ក្រោមពន្លឺដួងខែដ៏ត្រចះ សុបិន បានឃើញវង្ងង់ភក្ត្រ័លំអងហាក់ដូចជាច្បាស់ជាងមុន ។ នាងមានទឹកមុខ ស្លូតបូតស្រទន់ មិនកាចឆ្នាសដូចជានាយធ្លាប់នឹកគិតពីមុខមកនោះទេ ហើយទំនងហាក់ដូចជាកំពុងលាក់ទុកកង្វល់ធំមួយក្នុងចិត្តទៀតផង ។ ភ្លាម នោះ សុបិនបែរជាសួរត្រលប់វិញថា :

- ហើយចុះលំអងវិញ? នាងទើសទាល់ក្នុងចិត្តទេ កាលបើខ្ញុំមកទីនេះញឹក ញាប់ដូច្នេះ?

លំអងឈ្ងោកមុខមួយស្របក់ក៏ បែរមើលមុខបុរសយើង ហើយឆ្លើយ តបទៅវិញថា :

- លំអងទេវិញទេ ដែលខ្លាចលោកទើសទាល់ក្នុងចិត្ត ត្បិតជីវិតរបស់ខ្ញុំខ្វះ មុខខ្វះក្រោយ មិនអាចទទួលបានសមរម្យតាមឋានៈរបស់លោកបាន..

- អត់ទេ... លំអងកុំពោលអញ្ចឹងអី... ការពិត... គឺ... គឺ... ខ្ញុំចូលចិត្តមក ទីនេះណាស់... មិនដឹងជាមកពីហេតុអ្វីទេ គ្រាន់តែដឹងថា កាលណាខ្ញុំបាន មកដល់ទីនេះ ចិត្តខ្ញុំក៏រីករាយដោយឯង១ប៉ុណ្ណោះ ជាពិសេសទៅទៀត គឺ ពេលណាដែលខ្ញុំបានជួបមុខនាងហើយបានសន្ទនាជាមួយនាង  ខ្ញុំតែងតែ... មានអារម្មណ៍ក្សេមក្សាន្តក្នុងចិត្តជានិច្ច ។

លំអងឮមាណពស្រដីដូច្នោះក៏ញញឹមឡើង ។ សុបិនសំលឹងភក្ត្រនារី យើងមួយស្របក់ ស្រាប់តែលើកដៃស្តាំរបស់នាយហុចមកលំអង :

- សុបិនសូមកាន់ដៃនាងផងបានទេ?

លំអងភ្ញាក់ក្រញាង ត្បិតមិនដែលគិតថាសុបិនមានអារម្មណ៍ជិតស្និទ្ធ ចំពោះនាងដល់ម្លឹងទេ ។ សុបិនឃើញធិតារារែក ក៏លូកស្រវាទាញដៃនាង មកក្តាប់កាន់ស្រាក់ម្រាមជាមួយដៃរបស់នាយយ៉ាងណែន  រួចហើយក៏ ពោលខ្សិប១ថា :

- លំអង!...

ពោលហៅឈ្មោះនាងបានតែពីរម៉ាត់ ស្រាប់តែសុបិនស្លាក់សំដីរកទឹក ពាក្យនិយាយតទៅទៀតលែងចេញអស់រលីង ។ រីបេះដូងរបស់គេវិញក៏ ទូងរណ្តំរំភើបញាប់ញ័រយ៉ាងចំលែករកថាមិនត្រូវ ។ ចំណែកលំអងក៏រន្ធត់ ចិត្តត្រជាក់ដៃត្រជាក់ជើងស្រេបភ្លាមតែម្តង ។ ឃើញដូច្នោះ សុបិនក៏សួរ ទៅមាណវីថា :

- លំអង... រងាមែនទេ?

ធិតាងក់ក្បាល ។ សុបិនក៏ស្រវាដោះអាវក្រៅរបស់ខ្លួនទៅបំពាក់ឱ្យ

CHANBOKEO.COM

មាណវីហើយក៏ស្រវាត្រកងចង្កេះធិតា ទាញដងខ្លួនលំអងមកផ្អិបនឹងខ្លួន របស់នាយយ៉ាងណែន សំដែងនូវការថ្នាក់ថ្នមយ៉ាងកក់ក្តៅមួយ ដែលបុរស យើងមិនដែលធ្វើបែបនេះ ចំពោះនារីណាម្តងសោះក្នុងមួយជីវិតរបស់គេ ។ រំពេចនោះ ស្រាប់តែសុបិនឃើញលំអងលួចយកដៃផ្តិតទឹកភ្នែករបស់នាង ដែលកំពុងលួចហូរស្រក់មកលើផ្ទៃមុខស្ងាត់ៗ :

- លំអង! យំ... រឿងអ្វីហ្នឹង...?

តែនាងមិនឆ្លើយទេ គ្រាន់តែឈ្ងោកមុខនៅស្ងៀមមិនស្រដីអ្វីឡើយ ។ សុបិនក៏យកដៃបបោសខ្នងនាងបន្តើរៗ :

- កណ្តោចកណ្តែងក្នុងចិត្តណាស់មែនទេ?... លំអង! បើទឹកភ្នែកអាចជួយ សំរាលទុក្ខរបស់នាងបាន សូមនាងយំរំសាយអោយអស់ទុក្ខនោះពីបេះដូង ទៅ ។ សុបិននៅទីនេះកំដរនាង មិនទៅណាទេ... យំទៅណាំក្រែងបានធូរក្នុងទ្រូងខ្លះៗ! សូមអោយក្តីកង្វល់ទាំងឡាយ ហូរចេញទៅតាមដំណក់ទឹក ភ្នែកនោះអោយអស់ចុះ..!

លំអងផ្តេកកេសាកើយលើស្មាសុបិននៅស្ងៀមស្ងាត់ មិននិយាយស្តីអ្វី ឡើយ ។ មួយស្របក់ក្រោយមក សុបិនក៏ពោលទៅកាន់នាងថា :

- លំអងចង់ស្តាប់បទចំរៀងមួយបទទេហ៎?

លំអងងក់ក្បាល ។ សុបិនក៏យកដៃបបោសកេសារបស់នារីថ្នមៗ រួច ហើយក៏ចាប់បន្លឺសៀងយ៉ាងពិរោះមួយ ដើម្បីថ្នាក់ថ្នមលួងលោមដួងចិត្ត មាណវីយើងឱ្យយល់នូវភាពក្សេមក្សាន្តភិរម្យមកវិញ :

ភិរម្យស្នេហា

១. ត្រជាក់ភិរម្យពេញដួងហឫទ័យ ក្រោមស្បៃរាត្រី រៀមនិងពិសីថ្នមស្នេហ៍
បរិសុទ្ធ សៀងបេះដូងញាប់ញ័រន្ទត់ ស្នេហាធំធេងប្រាកដ
សមុទ្ទក៏ប្រៀបពុំបាន ។

២. លើស្ពានឫស្សីស្នេហ៍ត្រអាលត្រេក សន្សើមពីមេឃរោយចុះត្រជាក់
អង្អែលថ្នមប្រាណ បងច្រៀងលោមបំពេរកល្យាណ ក្រោមពន្លឺរស្មីចន្ទ័
អោយភុំផានក្សេមក្សាន្តកាយ ។

បន្ទរ. រលកផ្ទៃបឹង ព្រិចៗឆ្លុះពណិ ហាក់ជួយត្រេកអរសប្បាយ ជំនោរផាយផាត់
ពីជើងមេឃឆ្ងាយ ប្រៀបហាក់ជាចំណងដៃពរជ័យថ្ងៃបាចផ្កាស្លា ។

៣. សូមអោយវេលាឈប់នឹងនៅ ដីយប់វិលទៅ អោយរៀមបាននែបនិត្យកន្និដ្ឋា
យប់អើយកុំឆ្លងនាំសុរិយា អោយបងបានថ្នាក់ថ្នមផ្កា
ស្នេហាផ្អែមល្ហែមរៀងអើយ......

សំនៀងចំរៀងដ៏ផ្អែមពិរោះបានលួងលោមហឫទ័យឆវីអោយអណ្តែត ត្រសែតទៅភពសុខសាន្តមួយ ដែលធិតាមិនធ្លាប់បានជួបប្រទះមកសោះ ក្នុងជីវិតរបស់នាង ។ ធិតានៅស្ងៀមស្ងាត់ស្តាប់សំនៀងបំពេរដ៏ក្រអួនរបស់

CHANBOKEO.COM

បុរសយើងដោយដួងចិត្តរំភើបញាប់ញ័រ ។ រីសុបិនវិញក៏មិនខុសពីធិតាយើង ដែរ ។ ពេលនេះ មាណពមានអារម្មណ៍ថា បេះដូងរបស់នាយបានទទួលនូវ ឥទ្ធិពលមួយយ៉ាងចំលែក ធ្វើអោយនាយរំភើបឯកឯង ហើយក៏រីករាយសប្បាយលើសពេលណាៗទាំងអស់ក្នុងជីវិត ។ ទាំងគូអង្គុយកាន់ដៃគ្នានៅស្ងៀមស្ងាត់អស់រយៈពេលយ៉ាងយូរទើបសុបិនផ្ដើមបន្លឺវាចាសាជាថ្មីថា :

- លំអងដឹងទេ ថាយាយបានផ្ដែផ្ដាំផ្ញើអ្វីខ្លះជាមួយនឹងខ្ញុំ នៅមុនពេលដែលគាត់អនិច្ចកម្មទៅនោះ?

ស្រាប់តែលំអងងើបបែរមើលមុខសុបិនយ៉ាងរហ័សទំនងហាក់ចង់ដឹងចំលើយ ។ សុបិនឃើញដូច្នោះ ក៏ពោលបន្ត :

- គឺ... គាត់បានផ្ដាំ ផ្ញើ... អោយខ្ញុំជួយមើលថែរក្សារូបនាង...

លំអងសំលឹងមើលសុបិនមួយស្របក់ក៏សួរវិញថា :

- អញ្ចឹង មានន័យថា... លោកខំមកទីនេះ ដោយសារតែពាក្យបណ្ដាំរបស់ យាយតែប៉ុណ្ណឹងទេ មែនទេ?

- គឺ... ខ្ញុំធ្វើតាមពាក្យរបស់យាយ... ក៏ប៉ុន្តែ.. មិន...

- ការពិត... លោកមិនមែនមកទីនេះដោយសារចិត្តលោកចង់មកឯណា... មែនទេហ៎? (លំអងសួរកាត់)

- អត់ទេ... គឺ... គឺ... មិនមែនអញ្ចឹងទេ

ស្រាប់តែលំអងស្រដីកាត់ឡើងថា :

- លំអងថា... បើលោកមកទីនេះដោយការបង្ខំចិត្ត ថ្ងៃក្រោយមិនបាច់មក ទៀតក៏បានដែរ លំអងពិតជាខ្លាចចិត្តមិនហ៊ានរំខានលោកទៀតឡើយ ។

ភ្លាមនោះ លំអងក៏រលាស់ដៃពីសុបិន ហើយស្ទុះងើបយ៉ាងរហ័សរត់ ចូលទៅក្នុងផ្ទះវិញ ។ សុបិនស្ទុះរត់ទៅដល់តាមក្រោយដែរ តែលំអងបិទ ទ្វារជិតយ៉ាងលឿន មិនអោយនាយចូលឡើយ :

- លំអង! ស្ដាប់ខ្ញុំសិនបានទេ... លំអង! (សុបិនគោះហៅពីក្រៅ)

តែធិតាមិនឆ្លើយទេ... នាងនៅសំងំយំខ្សឹកខ្សួលស្ងៀមស្ងាត់នៅក្នុងផ្ទះតែម្នាក់ឯង ។ មួយស្របក់ធំក្រោយមក ដោយនាងលែងឮមាត់សុបិន លំអងក៏អុជចង្កៀងដើរចេញមកក្រៅរកមើលស្រាប់តែបើកទ្វារទៅប៉ះនឹងមាណពយើងដែលអង្គុយច្រងុកនៅមុខមាត់ទ្វារនោះតែម្ដង :

- លោកសុបិន... មិនទាន់ទៅផ្ទះទេហ៎?

មាណពងើបឈរឡើង រួចឆ្លើយថា :

- ផ្ទះរបស់ខ្ញុំក៏នៅទីនេះដែរ តើនាងដេញអោយខ្ញុំទៅណាវិញ ?

- តែផ្ដាស... នេះជាផ្ទះរបស់ខ្ញុំទេ!

CHANBOKEO.COM

- តែយាយគាត់បានប្រគល់អោយមកសុបិនរួចហើយ... ដឹងហើយនៅ?

- លោកសុបិន...!!

លំអងងើបមុខសំលឹងប្រឈមមុខសុបិនដោយឆ្ងល់ចិត្ត ។ តែពេលនេះ សុបិនបែរជាលែងខ្លាចចិត្តនាងក្រមុំដូចគ្រាមុនៗទៀតហើយ ។ គេបែរជា ឈរពើងទ្រូងសំលឹងកែវភ្នែករបស់នាង ដោយក្រសែភ្នែកយ៉ាងមុតស្រួចលប់ ទៅនាងវិញ ។ ក្រោមរស្មីភ្លើងចង្កៀងក្របាមព្រឹមៗ សុបិនរន្ធត់ចិត្តយ៉ាង ណាមិនដឹង កាលបើប្រទាក់ក្រសែនេត្រាជាមួយធិតាយើង... គន់ភក្ត្រ័នាង យូរទៅរិតតែចាប់ចិត្តប្រតិពទ្ធ័ធិតាឡើង សំលឹងយូរទៅរិតតែញាប់ញ័រ រំភើបរំជើបរំជួលក្នុងឱរាឡើង... សុបិនទ្រាំលែងបាន ក៏អោនថើបថ្ពាល់ របស់លំអងលាន់ខ្សឺត ។ មាណវីភ្ញាក់ក្រញាង ស្រែកភ្លាត់មាត់ :

- ផ្តេសផ្តាស!!

នាងក៏យារដៃប្រច្រានទ្រូងនាយយ៉ាងខ្លាំង ទំនងចង់បណ្តេញនាយ ចេញពីផ្ទះ ។ តែសុបិនមិនបានចាប់អារម្មណ៍ទេ ។ ពេលនេះគេហាក់ដូចជា រំភើបក្នុងចិត្តញាប់ញ័របេះដូងរកថាមិនត្រូវទៅហើយ ។ ភ្លាមនោះ គេក៏ ស្ទុះត្រលប់ចូលមកវិញ លូកដៃកញ្ឆក់ស្រវាត្រកងអោបលំអងយ៉ាងណែន ពេញរង្វង់ដៃ ធ្វើអោយលំអងនឹកភិតភ័យក្នុងចិត្តមួយរំពេច:

- លោកសុបិន... លែងមើស៍...! ព្រហើន.... នែ៎... លោកចង់ធ្វើអីហ្នឹង?

ស្រាប់តែសុបិនអោនយកបបូរមាត់របស់នាយ ដាក់ផ្ទិបនឹងបបូរមាត់ របស់ធិតាមិនអោយនាងស្រែករួចឡើយ រួចហើយក៏ផ្តួលកាយនាងទៅលើ គ្រែរនាបយ៉ាងរហ័ស ។ លំអងភិតភ័យតក្កមាទន់ដៃទន់ជើងប្រឹងរើបំរះ ទាំងត្រដររហូតរាវកូនចង្កៀងនៅលើតុដែលកំពុងអ៊ុំរអស់ខ្លាញ់នោះ ធ្លាក់ ក្រលាប់មកដីរលត់រស្មីឈឹងមួយរំពេច...

មាន់រងាវខ្ទើយៗហើយ...

មេឃក៏ចាប់បញ្ចេញរស្មីក្របាមព្រឿងៗឯបូព៌ាទិស ។ សុបិនប្រែខ្លួន ឡើងយកដៃរាវរកលំអងស្រាប់តែបាត់រូបនាងពីរង្វង់ដៃទៅ ។ មាណព ភ្ញាក់ស្វាងស្មារតីធេងតែម្តង ក៏ស្ទុះក្រោកទៅរកនាងនៅស្រះទឹកក្រោយផ្ទះ ក៏មិនឃើញ ដើររកជុំវិញដីចំការក៏មិនឃើញ ។ សុបិនត្រលប់ចូលផ្ទះវិញ អង្គុយសំកុកនឹកស្តាយក្រោយនូវអំពើដែលខ្លួនបានប្រព្រឹត្តពីយប់មិញ មិន ដឹងថាហេតុអ្វីទេ ដែលជំរុញចិត្ត នាយអោយវង្វេងអស់ស្មារតីយ៉ាងនេះ ។ សុបិនឈ្លីសក់យ៉ាងខ្លាំងស្ទើរតែរបោចអស់ពីក្បាល ហើយនឹកបន្ទោសខ្លួន ឯងមិនឈប់ឈរ:

- ហេតុអ្វីបានជាយើងក្លាយជាមនុស្សដែលខ្វះស្មារតី ខ្វះសតិដូច្នេះទៅ វិញ? ឬប្រហែលជា... កាលពីយប់មិញយើងស្រវឹងស្រាខ្លាំងពេកទេដឹង? ឬក៏ស្រាដែលយើងផឹកពីយប់មិញ មានលាយជាតិថ្នាំញៀននៅក្នុងនោះ? លំអង! តើពេលនេះនាងនៅឯណា? ឱ្យសុបិនសូមទោសផងណា៎... សូម ទោស ចំពោះការប្រព្រឹត្តអសីលធម៌របស់ខ្ញុំទៅលើរូបនាង ។ ចាប់ពីថ្ងៃ នេះតទៅ សុបិនសន្យាថាលែងបរិភោគស្រាទៀតហើយ ត្បិតស្រាបាន នាំឱ្យសុបិនវង្វេងបាត់អស់សេចក្តីថ្លៃថ្នូរ ជាកូនប្រុសដ៏ល្អអស់រលីង មិនតែ

CHANBOKEO.COM

ប៉ុណ្ណោះថែមទាំងនាំផលវិបត្តិយ៉ាងអាមាសទៅលើនាងទៀតផង ។ ស្រា បានធ្វើអោយខ្ញុំលែងគ្រប់គ្រងសតិស្មារតីបាន... ហើយនេះមិនមែនជា លើកទីមួយដែរដែលស្រាបាននាំវិបត្តិមកដល់ជីវិតសុបិន ការពិត សុបិន ធ្លាប់រងគ្រោះច្រើនដងហើយ ។ ដោយសារតែឥទ្ធិពលរបស់ស្រា ស្មារតី របស់សុបិនក្លាយវង្វេងសែនមហាវង្វេងលែងស្គាល់ខុសត្រូវល្អអាក្រក់អស់ ហើយ ។ ពេលនេះ សុបិនយល់ជាក់ច្បាស់ហើយថា ស្រាមិនមែនជា ញាតិសន្តានរបស់មនុស្សទេ ដូច្នេះ ត្រូវតែបង្ខំចិត្តកាត់វាចោលពីជីវិតរបស់ខ្លួនអោយទាល់តែបានជាដាច់ខាត!!!

៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩៩

៩

CHANBOKEO . COM

# វគ្គទី៦
# ជញ្ជីងដួងចិត្ត

គ្រាន់តែសុបិនបរឡានមកដល់មុខផ្ទះវិញ ស្រាប់តែបុរសយើងប្រទះ ឃើញរថយន្តប៉ូលីសជាច្រើន នៅឡោមពទ្ធ័ជុំវិញភូមិគ្រិះរបស់លោក សៅរិន ។ មាណពនឹកឆ្ងល់ពិភាល់ក្នុងចិត្តចំលែកក្រៃលែង ក៏ឈប់ឡានវែក ហ្វូងមនុស្សដែលនៅឈរត្រៀបត្រាទាំងអំបាលម៉ាន ស្ទុះចូលទៅក្នុងផ្ទះវឹង ឥតបង្អង់ ។ ពេលនោះ សុបិនក្រលេកឃើញលោកសៅរិននិងអ្នកស្រីលីដា ត្រូវប៉ូលីសដាក់ខ្នោះបណ្ដើរចូកក្នុងឡានហើយបរចេញទៅយ៉ាងលឿន :

- លោកប៉ា... អ្នកស្រីលីដា!

សុបិនរត់តាមឡានប៉ូលីសស្រែកហៅលោកពីក្រោយ តែក៏ត្រូវប៉ូលីស ឃាត់ជាប់មិនអាចទៅណាបាន ។ លុះនាយបែរក្រលេកមកក្នុងផ្ទះវិញ ស្រាប់តែប្រទះនារីមួយរូប ពាក់វ៉ែនតាស ចងសក់កន្ទុយសេះ ពាក់មួក កន្ដិបក្នុងឯកសណ្ឋានជាប៉ូលីសយោធា កំពុងឈរបញ្ជាកិច្ចការចុះឡើងៗ ។ ភ្លាមនោះ សុបិនបានឃើញប៉ូលីសយកផ្លាកទៅវាយខ្ទែងនៅលើជញ្ជាំងជា សញ្ញាថាផ្ទះរបស់នាយត្រូវច្បាប់អូសយកហើយ... ឃើញដូច្នោះសុបិន រន្ធត់ក្នុងចិត្តក្រៃលែង ឈរលែងនឹងជាប់នឹងដីតែម្ដង... ពុទ្ធោ! ពេលនេះ នាយរលាយអស់រលីងនូវអ្វីៗក្នុងជីវិត... នឹងចង់យំក៏យំមិនចេញ នឹងចង់ ហារស្ដីវិញក៏ស្លាក់និយាយមិនរួច ។ ពេលនេះ តើមាណពត្រូវធ្វើយ៉ាងណា ។ រំពេចនោះ ស្រាប់តែសុបិននឹកចាប់ភ្លឹកដល់នារីនាយកងប៉ូលីសមួយរូបនោះ ភ្លាម ។ មែនហើយ! នាយចាំច្បាស់ណាស់... គឺនាយបានជួបមាណវីមួយរូប នោះច្រើនដងហើយ តែនាយមិនដែលនឹកឃើញយកចិត្តទុកដាក់ម្ដងណា សោះ ទើបតែពេលនេះនាយចាប់ភ្លឹកសំលឹងមើលរូបនាងអោយកាន់តែ ច្បាស់ម្ដង ។ រំពេចនោះ មាននាយប៉ូលីសមួយរូបដើរមកដល់ជិតនារីនាយ កង រួចហើយគំនាប់ថា :

- អ្នកនាងអម្ពរ! កិច្ចការរួចរាល់អស់ហើយបាទ!

នារីប៉ូលីសឈ្មោះអម្ពរ ក៏ងើបមុខឡើងសំដែងទឹកមុខយ៉ាងមាំហើយ ពោលថា :

- បើដូច្នោះ យើងរៀបចំត្រលប់ទៅក្រសួងវិញ ។

អូហ៍មែនហើយ នាងឈ្មោះអម្ពរ! ការពិតនោះគឺជានារីដែលលោកប៉ា របស់សុបិននិងអ្នកស្រីលីដា ធ្លាប់ចង់ណែនាំរូបនាយអោយជួបជាញយដង តែក៏ចេះតែឃ្លាងរហូតមកនោះតើហ៏ ។ ពេលនេះ សុបិនយើងនឹកឆ្ងល់ ណាស់ថា ហេតុអីក៏ធិតានោះប្រែក្លាយជានាយកងប៉ូលីសមកចាប់ខ្លួនឳពុក របស់នាយទៅកើត ។

CHANBOKEO.COM

តើលោកសេរិនបានប្រព្រឹត្តទោសកំហុសអីទៅកាល បើគេល្បីរន្ទឺជានិច្ច ថាលោកជាមនុស្សមានចិត្តធម៌បំផុតនៅភ្នំពេញនេះ ។ សុបិននឹកឡើងនឹកចុះមិនអស់ចិត្តក៏ស្ទុះទៅក្បែរកញ្ញាអម្ពរ :

- អត់ទោសអ្នកនាង... ខ្ញុំសូមសួរបន្តិចបានទេ?

ស្រាប់តែអម្ពរបែរមុខចេញធ្វើព្រងើយមិនខ្ចីធ្វើព្ធឬឆ្លើយតបមកនាយ យើងវិញទេ ។ មាណវីក៏បែរស៊ីញ៉ូអោយនាយកងប៉ូលីសមួយរូបទៀតមក ទទួលសំនួរពីសុបិន ហើយនាងក៏ដើរចេញទៅដោយមិនខ្ចីទាំងមើលមុខបុរសយើងផង ។ នេះជាលើកទីមួយហើយដែលនារីរូបមើលមិនបានម្នាក់ សំដែងកិរិយាមើលងាយសុបិនយើងចំពោះមុខតែម្តង ។ ឃើញដូច្នេះ សុបិន ខឹងច្រលោតណាស់ ប៉ុន្តែតើនាយទៅធ្វើស្អីដល់គេបានទៅ? ធិតានោះជា នាយកងប៉ូលីសមួយរូបថ្មីត្បិតតែមិនឃើញពាក់សក្តិនៅលើស្មា តែបើតាម ទំនងមើលទៅ នាងក៏ជាមនុស្សក្នុងឋានៈគ្រាន់បើក្នុងក្រសួងមួយរូបដែរ ត្បិតក្រុមប៉ូលីសនៅទីនោះ សំដែងកិរិយាហាក់ដូចជាផ្តល់ការគោរពដល់ នាងណាស់ ។ ការពិតនាយយើងគ្រាន់តែចង់ដឹងថាតើគេនាំខ្លួនឪពុករបស់ នាយទៅឃុំនៅឯណាប៉ុណ្ណោះ ។ លុះព្ធនាយសួរដូច្នោះ ប៉ូលីសមួយរូបឆ្លើយ វិញថា :

- ដោយសារការសម្ងាត់របស់ក្រសួងពេលនេះ យើងមិនទាន់អាចជំរាប លោកបានទេថា តុលាការនឹងបញ្ជូនលោកសេរិននិងភរិយាទៅឃុំនៅទី ណា ។ បើលោកមានការសំខាន់ចង់ទាក់ទង សូមអញ្ជើញទៅទាក់ទងនៅឯការិយាល័យទៅបាទ ។

សុបិនឈ្ងោកមុខ ឈរសំកុកនៅមុខផ្ទះរបស់ខ្លួន ដែលមានគំនូស ក្រដាសពណ៌លឿងខ្វែងជើងក្អែកបិតនៅពីមុខជាសញ្ញានៃការរឹបអូសពី សំណាក់តុលាការ ។ ប៉ូលីសចេញទៅអស់ហើយ មនុស្សម្នាទាំងអំបាលម៉ាន ដែលឈរមើលហេតុការណ៍នៅទីនោះយូរហើយក៏នាំគ្នាចាកចេញទៅរពុយ រពុយអស់ដែរ សល់តែសុបិនទេដែលឈរសំកុកម្នាក់ឯងយំមិនចេញ ។

រាត្រីមកដល់...

សុបិនក៏បរឡានរឹងទៅដល់ភោជនីយដ្ឋាន ស្វែកមិនយកលុយដើម្បី ទៅបំពេញការងារជាអ្នកចំរៀងដូចប្រក្រតី ។ គ្រាដែលនាយបានមកដល់ ភ្លាម ស្រាប់តែគេប្រទះនាងកញ្ញារូបស្រស់ឈ្មោះកិរិយាកំពុងអង្គុយញ៉ាំ ទឹកកកជជែកគ្នាលេងយ៉ាងស្និទ្ធស្នាល ជាមួយនាយកាសូ អ្នកចំរៀងថ្មីដ៏ សង្ហាមួយរូបប្រចាំភោជនីយដ្ឋាន ។ នាយខំប្រឹងញញឹមលើកដៃរាឡើង ចំពោះកិរិយានិងកាសូ ស្រាប់តែអ្នកទាំងពីរបែរចេញធ្វើមិនដឹង ហាក់ដូចជាមនុស្សដែលមិនធ្លាប់ស្គាល់គ្នាពីមុនៗមកអញ្ចឹង ។ សុបិនខកចិត្តណាស់ ជាពិសេសចំពោះធិតាឆើតឆាយកិរិយានោះតែម្តង ត្បិតនាយតែងតែគិត ច្រលំថាកិរិយាមានការពេញចិត្តចំពោះរូបនាយ តែការពិតនាងប្រហែលជាតាមជ្រែបុរសលេងសើចសប្បាយតែប៉ុណ្ណោះ ។ មើលទៅពេលនេះ នាង ហាក់ដូចជាលែងចាប់អារម្មណ៍នឹងសុបិនទៀតហើយ ។ មាណពគ្រវីក្បាល ធ្វើមុខស្លូតដោយការខកចិត្តហើយក៏ដើរឡើងជណ្តើរទៅខាងក្រោយហាង ដើម្បីទៅផ្លាស់សំលៀកបំពាក់បំរុងឡើងឆាក ស្រាប់តែមានអ្នកបំរើម្នាក់ ចូលមកដល់ :

CHANBOKEO.COM

- ជំរាបលោកសុបិន! លោកថៅកែយូនិក្ស មានប្រសាសន៍ហៅលោកឱ្យ ទៅជួបគាត់ឥលូវនេះ ។

សុបិន ពូដូច្នោះក៏ប្រញាប់ចេញទៅ ។ នៅក្នុងបន្ទប់សាឡុងការងារមួយ សុបិនឱនប្រណិបតន៍គោរពលោកយូនិក្សហើយសួរថា :

- លោកមានប្រសាសន៍ហៅខ្ញុំមកទីនេះមានការអ្វីដែរបាទ?

លោកយូនិក្សសំលឹងមុខសុបិនមួយស្របក់ទើបវាចាថា :

- លោកសុបិន! កុំថាខ្ញុំចិត្តមិនបានអីណាំ... ការពិត...គឺថា.. ហាងយើងឥលូវនេះពិតជាមិនអាចទទួលអោយលោកនៅច្រៀងទីនេះបានទៀតទេ...

ឮដូច្នោះ សុបិនភ្ញាក់ក្រញ្ញាង :

- លោកមានប្រសាសន៍ថាម៉េច? ហេតុអ្វីក៏ខ្ញុំច្រៀងតទៅទៀតមិនបាន?

- លោកជ្រាបហើយតើហ៎... គ្រួសាររបស់លោកកំពុងមានរឿងផ្ទៃកច្បាប់ ជាមួយតុលាការ ។ បើហាងយើងអនុញ្ញាត្តអោយលោកច្រៀងតទៅទៀត ហាងយើងនឹងអស់ប្រជាប្រិយភាពមិនខានដោយសារតែអ្នកចំរៀងរបស់យើងមានប្រវត្តិក្រុមគ្រួសារមិនស្អាត ។

សុបិនឈ្ងោកមុខរន្ធត់ចិត្តមួយស្របក់ទើបពោលតបថា :

- នោះជាអំពើរបស់លោកប៉ាខ្ញុំ... ខ្ញុំមិនបានដឹងរឿងអ្វីទេ ហេតុអ្វីក៏ខ្ញុំត្រូវ ទទួលទណ្ឌកម្មនឹងគេដែរ...?

- មិនមែនរូបខ្ញុំជាអ្នកដាក់ទណ្ឌកម្មលោកសុបិនឯងទេ គឺសង្គមទេតើដែល ជាអ្នកដាក់ទោស... កាលបើគេមិនចូលចិត្តប្រវត្តិគ្រួសាររបស់លោក គេ ប្រហែលជាឈប់គាំទ្ររូបលោកនិងទេពកោសល្យរបស់លោកហើយ រួចបើខ្ញុំនៅតែទទួលលោកជាតារាកិត្តិយសបន្តទៀត នោះប្រិយភាពហាងរបស់ យើងនឹងធ្លាក់ថយចុះមិនខាន ។ សូមទោសផងណាំសុបិន... យើងពិតជា មិនអាចទទួលលោកអោយធ្វើការតទៅទៀតបានពិតមែន...

សុបិនក៏លើកដៃសំពះប្រណិបតន៍លាលោកយូនិក្ស ដើរចេញមកក្រៅ ទាំងរសេះរសោះដៃជើងក្រៃលែង ។ ហេតុអ្វីក៏រាសីរបស់នាយធ្លាក់ចុះដាប ទាន់ហន់ដល់ថ្នាក់នេះផង? សុបិនពិតជាសំរួលចិត្តមិនទាន់ទេ... បន្តិចមកគេក៏បើកឡានទៅអង្គុយមាត់ទន្លេមុខវាំង ។ កំដៅព្រះអាទិត្យចាំងជះមក លើដៃនពសុធាយ៉ាងពេញអនុភាព តែមិនបានធ្វើអោយបុរសយើងក្រៃង រអែងឥទ្ធិពលកំដៅនឹងកាំរស្មីដ៏ភ្លឺខ្លាំងក្លានោះបន្តិចឡើយ ។ សុបិនបែរជា យល់ថានៅពេលនេះពិភពលោកទាំងមូល បែរក្លាយជាងងិតសូន្យសុង ហើយរងា បំផុតចំពោះរូបនាយយើង ។

ថ្ងៃលិចហើយ... គេនៅតែសំកុកដដែល...

លុះយប់ជ្រៅបន្តិច ស្រាប់តែមានដៃមួយមកទះស្មានាយបន្ថើរៗ :

- លោក...! ពាក់អាធ្រាតហើយណ៎ា មិនទៅផ្ទះទេហ៎?

សុបិនភ្ញាក់ព្រើតបែរក្រោយ ឃើញតម្រួតសន្តិសុខមួយរូបឈរញញឹម មកនាយ ។ សុបិនក៏ញញឹមតបវិញ តបថា :

- មែនហើយ យប់ជ្រៅណាស់ហើយតើហ៎!

CHANBOKEO.COM

សុបិនក៏ប្រញិបប្រញាប់ឡើងរថយន្តបរចេញទៅ ។ មកដល់មុខវិទ្យា ដ៏ស្តុកស្តម្ភរបស់នាយវិញ សុបិនក៏ឈប់រថយន្តអង្គុយសំលឹងពីក្រៅរបង យ៉ាងយូរ... បន្តិចមក ទឹកភ្នែកពីរដំណក់បានរត់ចេញមកប្រលែងនឹងកែវនេត្រារបស់បុរសយើងភ្លាម ។ សុបិនយកដៃជូតយ៉ាងរហ័ស... នឹកអាមាស ក្នុងចិត្តដែលកាលពីមុនៗមក នាយមិនដែលគិតថាជីវិតរបស់ខ្លួននឹងបាន មកជួបសភាពទាល់ច្រកដូចថ្ងៃនេះអញ្ចឹងឡើយ ។ គេធ្លាប់កើតនៅផ្ទះនេះ រស់នៅផ្ទះមួយនេះ ស្គាល់តែភាពសំបូរសប្បាយ មានលុយកាក់ចាយវាយ មិនអស់.. មិននឹកស្មានថាក្នុងមួយប៉ព្រិចភ្នែក ជីវិតរបស់នាយក្លាយជាក្រលាប់ចក្រធ្លាក់នរកទាំងភ្នែកស្រស់ ។ ពេលនេះ តើនាយត្រូវធ្វើយ៉ាង ម៉េចទៅវិញ? មួយស្របក់ក្រោយមក នាយក៏ថយឡានចេញទៅ...

តុក! តុក! តុក!

- លំអង... នៅផ្ទះទេ?... នេះខ្ញុំណាំសុបិន...

តុក! តុក! តុក!... ស្ងាត់ច្រៀប ។ សុបិនក៏លូកដៃច្រានទ្វារសាកមើល៍ ស្រាប់តែទ្វាររបើកឃ្វាំង ។ សុបិនក៏ទាញពិលមួយចេញមកឈ្លបមើល តែ គួរអោយស្តាយ នាយយើងមិនបានយល់វត្តមានរបស់លំអងឡើយ ។ រំពេច នោះ សុបិនស្ទុះចេញទៅរកនាងនៅឯស្រះក្រោយផ្ទះ... ប៉ុន្តែ សុបិននៅមិន ប្រទះស្រមោលនាងដដែល ។ ពេលនេះ គេរន្ធត់ចិត្តណាស់... ស្ទើរគាំង បេះដូងស្លាប់តែម្តង ។ មែនហើយ! លំអងជាទីពំនឹងពំនាក់ផ្លូវចិត្តរបស់ នាយតែមួយគត់! តើពេលនេះ លំអងគេនៅឯណា? សុបិនរសេះរសោះដៃ ជើងណាស់ ។ បុរសយើងមានអារម្មណ៍ហាក់ដូចជាបាត់បេះដូងពីដើមទ្រូង ឥចឹង ។ គេសោកសៅណាស់ ស្រពោនចិត្តណាស់ ត្បិតមិនដឹងថានឹងទៅរក លំអងនៅឯណាកណ្តាលយប់ស្ងាត់យ៉ាងនេះ?... គួរអោយអាមាសអ្វីម្លេះ! នៅរៀងរាល់ដងដែលនាយមានទុក្ខមានសោក លំអងតែងតែមកដល់រួច ជួយសង្គ្រោះរូបនាយភ្លាម ។ ចៃដន្យនាយបែរជាលូកថ្លើមរបស់ធិតាសង ជាសគុណចំពោះសន្តានចិត្តដ៏ល្អរបស់នាងទៅវិញ ។ ឥលូវនេះ នាយយើងកំពុងតែប្រទះនឹងសេចក្តីទុក្ខសាជាថ្មី...ឯលំអងក៏បាត់ខ្លួនទៅ.. សុបិនមាន អារម្មណ៍ថា ខ្លួនកំពុងតែធ្លាក់នរកទាំងរស់ហើយ :

- លំអង... នាងនៅទីណា... ឆាប់មករកខ្ញុំផង... លំអង... ខ្ញុំពិតជាត្រូវការ អោយរូបនាងមកនៅក្បែរខ្ញុំណាំ... តើពេលណា.. នាងត្រលប់មកវិញ...? លំអង... ខ្ញុំនឹកនាងណាស់ នាងដឹងទេហ៏...? ខ្ញុំនឹកនាងណាស់...!!

សុបិនអង្គុយសំកុកតែម្នាក់ឯង ហៅរកតែឈ្មោះលំអងមួយយប់ទាល់ ភ្លឺ... តែអនិច្ចា... លំអងមិនបានវិលត្រលប់មករកនាយដូចដែលដួងចិត្ត របស់នាយដង្ហោយហៅនោះឡើយ ។ មាន់រងាវខ្ទើយៗពីចំការជិតៗនោះជាច្រើនដងហើយ... តែ... លំអងនៅតែបាត់ស្រមោលដដែល....

សុបិនបានអង្គុយសំកុកនៅលើស្ពានឫស្សីនោះ អស់មួយយប់មួយថ្ងៃ មកហើយ មិនព្រមងើបទៅណាមកណាសោះ ក្រៅពីឈ្ងោកមុខសំដែង ភាពស្រងូតស្រងាត់នៅក្នុងចិត្តហើយ និយាយតែម្នាក់ឯងដូចមនុស្ស រវើរវាយមិនមានសតិ

CHANBOKEO.COM

ជូនឈ្លីបោចសក់ខ្លួនឯង ដកដង្ហើមឃ្វូៗ... ហាក់ដូច ជាដើមទ្រូងរបស់នាយណែនណាន់ស្ទើរស្ទះស្លាប់អញ្ចឹង ។ នេះជាលើកទីមួយហើយដែល សុបិនប្រទះនឹងភាពតានតឹងនិងភាពទាល់ច្រកក្នុងជីវិត មិនតែប៉ុណ្ណោះមនុស្សដែលជាព័ទ្ធនាក់ដួងចិត្តរបស់គេក៏បាត់ពីជីវិតនាយទៅ អស់ព្រមពេលជាមួយគ្នាទៀត តើឱ្យគេគិតយ៉ាងណា? សុបិនពិតជា គិតមិនចេញទាល់តែសោះ ។

អស់ចិត្តហើយ សុបិនក៏ងើបចេញពីស្ពានដើរចូលទៅក្នុងផ្ទះ ស្រវាយក ខ្នើយរបស់លំអងមកថើបអង្អែលថ្នមៗ :

- សូមបារមីនៃវត្ថុសក្តិសិទ្ធជួយបណ្តាលចិត្តលំអង ឱ្យត្រលប់មករកសុបិន
វិញផង! សុបិនពិតជានឹកនាងណាស់ លំអង! នឹកគ្មានអ្វីប្រៀបបានឡើយ!

សុបិនឈ្ងោកយកនាសាទៅផ្ទិតលើខ្នើយរបស់លំអងហើយក៏ដាក់ផ្តេក
ក្បាលលើខ្នើយតម្រង់ខ្លួនបិទភ្នែកសង្ងំសំរាកយកកំលាំង ព្រោះនាយមិន បានផ្ទេចពេញមួយយប់មួយថ្ងៃមកហើយ ហើយក៏មិនបានបរិភោគអ្វីទៀត ផង ។ ដោយអស់កំលាំងពេក មាណពក៏យន់ដំណេកទៅ...

មិនដឹងជាអស់ពេលយូរប៉ុណ្ណាទេ... សុបិនក៏ភ្ញាក់ពីដំណេកបើកភ្នែក ឡើងងើបអង្គុយ
រួចលើកដៃមើលនាឡិកាឃើញម៉ោង៨យប់ ។ លុះនាយ ដាក់ភ្នែកទៅម្ខាងស្រាប់តែឃើញស្លាកបាយនៅលើតុមានអាហារបីបួនចាននៅក្នុងនោះផង ។ សុបិនអរភើតស្ទាងងងុយធេងតែម្តង :

- លំអង?.... នាងមកផ្ទះវិញហើយមែនទេ?

សុបិនត្រេកអរកខិបកខុបតែម្នាក់ឯង ស្ទុះរត់ចេញមកក្រៅផ្ទះរកនាង ភ្លាម ។
តែសេចក្តីរីករាយរបស់នាយក៏រលាយបាត់ទៅវិញឯងៗ ត្បិតលំអង បានបាត់ស្រមោលទៅវិញហើយ ។
ពេលនោះសុបិនមានអារម្មណ៍ថា ឆរី យើងកំពុងតែដាក់ទោសនាយហើយ ដែលខ្លួនបានប្រមាថកត្តិយសរបស់ នាង ។ ប៉ុន្តែទោះបីជាយ៉ាងណា ក៏សុបិនហាក់ដូចជាមានអារម្មណ៍ស្រស់ បស់ជាងមុនតែម្តង ត្បិតនាយបានដឹងថា លំអងនៅយកចិត្តទុកដាក់ចំពោះ សុខទុក្ខរបស់នាយនៅឡើយ បើមិនដូច្នោះ នាងក៏មិនត្រលប់មករៀបចំទុកដាក់អាហារសំរាប់នាយដូច្នេះដែរ ។ គេក៏ដាក់ខ្លួនអង្គុយចុះ យកដៃ បើកគំរបស្លាកឡើង ។ ចៃដន្យលើកនេះលំអងមិនមានសរសេរបណ្តាំខ្លីៗអ្វី ឱ្យនាយទេ នៅលើស្លាកគឺមានតែបាយប៉ុណ្ណោះ ។ សុបិនក៏ឧទានខ្សិបៗថា :

- លំអង! ទោះបីជានាងខឹងមិននិយាយរក មិនសរសេររកខ្ញុំ ក៏ហ៊ីចុះណា៎
អោយតែនាងត្រលប់មកផ្ទះធ្វើអាហារឱ្យខ្ញុំបែបនេះរាល់ថ្ងៃ ក៏សុបិនមាន សេចក្តីសុខគ្រប់គ្រាន់ហើយ ព្រោះយ៉ាងណាក៏សុបិនដឹងថា នាងនៅមាន សន្តានចិត្ត មានការចាប់អារម្មណ៍មកលើសុខទុក្ខរបស់ខ្ញុំនៅឡើយ បើមិន ដូច្នោះទេ ប្រហែលជានាងទុកអោយខ្ញុំដេកដាច់ពោះស្លាប់នៅទីនេះបាត់ ទៅហើយ ។

សុបិនក៏ស្រវាបាយចុកមាត់ភ្លាមដោយភ្លេចគិតថានៅលើស្លាកមានម្ហូប បែបណាទៀតហើយ ។
អ្វីដែលនាយចាប់អារម្មណ៍បំផុតគឺ បាយដែលនាយ កំពុងទំពារលេបនោះ មានរសជាតិផ្អែមជាងស្ករទៅទៀត ។ បន្តិចក្រោយ មក នាយយើងក៏ដើរចេញមកក្រៅធ្វើរេរាៗ ហាក់ដូចជាកំពុងចាំមើលផ្លូវ ក្រែងលោលំអងគេត្រលប់មកវិញឆាប់ៗ ។
ប៉ុន្តែក្តីសង្ឃឹមរបស់នាយពុំមាន រស្មីទេ ត្បិតលំអងមិនព្រមលេចមុខមកអោយនាយឃើញឡើយ ។ លុះ អស់ចិត្តហើយ

CHANDOKEO.COM

សុបិនក៏វិលចូលផ្ទះវិញ... ។ គេអង្គុយសំកុកមួយស្របក់ក៏ ដើរសំដៅទៅរកកូនតុដែលលំអងធ្លាប់អង្គុយសរសេរ ។ នាយយើងក៏ដាក់ខ្លួនចុះ រួចក៏រពឹសដៃហូតថតតុបើកមើល ស្រាប់តែនាយភ្ញាក់ព្រើត បើកភ្នែកធំៗធ្វើស្រលាំងកាំង :

- ហ្ហា៎ស? ហេតុអ្វីបានជាមកនៅទីនេះទៅវិញ?

សុបិនទាញកូនកន្សែងខៀវមួយចេញពីថតតុមក ។ មែនហើយ! ការពិត នោះគឺជាកូនកន្សែងរបស់នាយតើហ៎ ។ នាយយើងចាំបានថាខ្លួនធ្លាប់យកកន្សែងនេះគប់មុខនារីម្នាក់នៅឯភោជនីយដ្ឋានស្នេកមិនយកលុយ រួច ក្រោយមកមានគេម្នាក់យកកន្សែងនេះដដែលមកអោយនាយជូតកំអួត ហើយឥលូវស្រាប់តែវាមកនៅពួននៅក្នុងថតតុលំអងទៅវិញ ។ សុបិនក៏
លាន់មាត់តែម្នាក់ឯងថា :

- លំអង... នារីមួយរូបនោះគឺជានាងមែនទេ?

នឹកដល់រឿងទាំងពីរកាលណា សុបិននឹកអាមាសខ្លួនរិតតែខ្លាំងឡើង :

- លំអង! ខ្ញុំពិតជាមនុស្សយ៉ាប់ណាស់... ប៉ុន្តែ បើខ្ញុំឥតមារយាទដាក់នាង ដល់ម្លឹងហេតុអ្វីក៏នាងនៅតែយកចិត្តទុកដាក់នឹងខ្ញុំមិនដែលខាន? ខ្ញុំពិត ជាមិនយល់ទេ លំអង...

សុបិនហក់រឹងឡើងរថយន្ត បរសំដៅទៅភោជនីយដ្ឋាន ស្នេកមិនយក លុយយ៉ាងលឿន ។ គ្រាន់តែទៅដល់ភ្លាម នាយយើងស្ទុះទៅរកនាយចាត់ ការរងនៅទីនោះភ្លាម :

- សួស្តីសុបិន! មានការអីហ្អែស?

- បាទ គឺថា ខ្ញុំចង់មករកនារីម្នាក់ឈ្មោះលំអងធ្វើការនៅទីនេះ

ស្រាប់តែនាយចំណាត់ការគ្រវីក្បាល :

- បុគ្គលិកស្រីៗរបស់យើងនៅទីនេះគ្មានឈ្មោះលំអងទេ

- គឺ... ឈ្មោះលំអង មានជំងឺភ្នែក គឺថា នាងមើលអ្វីមិនសូវច្បាស់... គឺ..

- អត់ទោសទៅចុះសុបិន! ខ្ញុំគិតថា លោកមករកខុសកន្លែងហើយ ។

នាយចំណាត់ការក៏ចេញទៅធ្វើការវិញទៅ ។ តែសុបិនមិនអស់ចិត្ត ឡើយ ។ គេនៅអង្គុយសំកុកនៅមាត់ច្រកចូលធ្វើការសំលឹងមើលបុគ្គលិក ទាំងឡាយដែលដើរចេញទៅផ្ទះ សង្ឃឹមក្រែងលោប្រទះលំអងនៅទីនោះ ថៃដន្យ ពួកគេចេញអស់ស្ងាត់ច្រៀបអស់ទៅហើយ នាយនៅតែមិនបានជួបលំអងដដែល ។ ទោះជាយ៉ាងណាក៏ដោយក៏សុបិនមិនបោះបង់ការ ព្យាយាមរបស់នាយដែរ ត្បិតនាយបានយល់ហើយថា មូលហេតុដែលនាំឱ្យ លំអងគេចខ្លួននេះ ក៏ព្រោះតែរូបនាយជាបុព្វហេតុទាំងអស់ ។ ហើយទោះបីជាខកចិត្តយ៉ាងណាក៏សុបិននៅតែវិលត្រលប់មករង់ចាំផ្លូវលំអងនៅឯផ្ទះ របស់នាងវិញរាល់ថ្ងៃ ដោយឥតលោះវេលាណា ។

ថ្ងៃមួយ...

CHANBOKEO.COM

សុបិនដើរតម្រង់ទៅការិយាល័យមួយ បំរុងដាក់ពាក្យសុំការងារធ្វើ
ស្រាប់តែប្រទះនឹងតាវៅតារាចំរៀងជើងឆើតនៅកាច់ជ្រុងផ្លូវ :
- ហ៉ៃកី ល្បងសុបិន! សុខសប្បាយទេ?
- បាទ! សុខតែមិនសប្បាយទេ...
- កំពុងរកការធ្វើមែនទេហ៎?
- មែនហើយ! តាំងពីតាវៅឯងវាយដាច់នៅហាងស្អែកមិនយកលុយនោះ មក សុបិនក៏ត្រូវដើរទាត់ខ្យល់តែម្តង ។
ស្រាប់តែតាវៅនិយាយវ៉ាសឡើង :
- ល្បងហ្អ៎ ! បើចង់បានការធ្វើពិតមែន ចាំខ្ញុំនាំទៅជួបមិត្តខ្ញុំម្នាក់
- ធ្វើការអ្វីទៅ? ជាអ្នកចំរៀងដែរទេហ៎?
- អត់ទេ... គឺធ្វើប៉ូលីសសំងាត់ ។ គេកំពុងតែត្រូវការមនុស្សថែមទៀត ។
- ហើយចុះខ្ញុំមិនដែលមានការហ្វឹកហ្វឺនខាងហ្នឹងផង ធ្វើប៉ូលីសសំងាត់ដូច ម្តេចកើតទៅ?
- គេរើសយកតែមាឌធំៗដូចល្បងសុបិនឯងអញ្ចឹង អារឿងហ្វឹកហ្វឺននោះ វាងាយទេណា៎ ធ្វើម៉េចអោយបានចូលធ្វើការសិនទៅ ។
សុបិនកំពុងតែអត់ការធ្វើស្រាប់ ពេលនេះរកប្រកែក ក៏មិនកើតដែរ ។ គេក៏ធ្វើដំណើរទៅជាមួយតាវៅ
រហូតដល់ការិយាល័យក្រុមប៉ូលីសសំងាត់ មួយ ។ បន្ទាប់ពីតាវៅណែនាំមក លោកនាយប៉ូលីសក៏ចាប់សម្ភាសន៍សុបិន ហើយ
ក៏ចាប់ហៅពេទ្យមកពិនិត្យសុខភាពរបស់នាយមុននឹងចូលធ្វើការ ។ ថ្វីបើប្រាក់បៀវត្សរ៍វាតិចអើយសែនតិច
ចំពោះមុខការថ្មីដែលគេកំពុងរើស យកបុគ្គលិក សុបិនក៏ត្រូវតែបង្ខំចិត្តទទួលយកទាំងបង្ខំចិត្តដែរ ព្រោះពេល នេះ
មាណពទាល់ច្រកអស់អំនួតហើយ ។ ថៃដន្យ លោកអធិការផុនបាន ដាក់នាទីអោយនាយចូលរួមក្នុងកងស៊ើបអង្កេត
ក្នុងករណីពិសេសមួយ ។ នៅលើផ្ទាំងសបញ្ចាំងរូបយន្ត លោកអធិការចំណាស់នោះឈរពន្យល់កិច្ច
ការម្តងមួយៗរហូតដល់ចប់សាច់រឿងសំរាប់យកការណ៍ ។ ដំបូងគេបញ្ចាំង រូបមនុស្សប្រុសចំណាស់មួយរូបក្នុងសំលៀកយ៉ាងសង្ហារ
:
- បុរសនេះឈ្មោះលោកសុនាថ ជាពាណិជ្ជករជាន់ខ្ពស់រកស៊ីជំនួញ រវាង មាឡេស៊ីនិងស្រុកយើង
ប៉ុន្តែកំពុងជាប់សង្ស័យថាមានរឿងជួញដូរមនុស្ស ខុសច្បាប់និងជួញដូរគ្រឿងញៀនទៀតផង ។
បន្ទាប់មក គេក៏បញ្ចាំងរូបនារីម្នាក់ពាក់មួកកន្តិប ពាក់វ៉ែនតាមីញ៉ូប
ចងសក់កន្ទុយសេះ ស្លៀកពាក់ក្នុងឯកសណ្ឋានប៉ូលីសយោធា ។ សុបិនភ្ញាក់ កន្ត្រាក់កាលបើក្រលេកឃើញរូបនាងភ្លាម ។
លោកអធិការក៏វាចាបន្ត :
- នារីមួយរូបជាជាអនុសេនិយទោឈ្មោះអម្ពរជាកូនស្រីរបស់លោកសុនាថ
នាងស្ថិតនៅក្នុងជួររបស់កងអាវុធហត្ថជាតិរបស់យើងដែរ ។ ដូច្នេះហើយ
កិច្ចការរបស់យើងទាំងអំបាលម៉ានត្រូវរក្សាជាការសំងាត់បំផុត ចៀសវាង

CHANBOKEO.COM

រឿងដង្កូវចេញពីសាច់...

បន្ទាប់មក កងសំងាត់ក៏បំបែកជួរចេញធ្វើការរៀងខ្លួន។ សុបិនហាក់ ដូចជាសប្បាយចិត្តផង ព្រួយចិត្តផងយ៉ាងណាមិនដឹង... សប្បាយចិត្តព្រោះ នាយកំពុងតែចាប់ស្គាល់ធិតាឈ្មោះអម្ពរនោះតិចៗហើយ តែក៏ព្រួយមិន ដឹងករណីដែលនាយកំពុងធ្វើការនេះ មានជាប់ទាក់ទងនឹងករណីរបស់ឪពុក នាយដែរឬយ៉ាងណា ត្បិតលោកសោរិនក៏ជាមនុស្សចេញចូលបរទេសញឹក ញាប់ដូចគ្នាហើយក៏រកប្រាក់បានច្រើនចំលែកណាស់ទៀតផង។

សុបិនមកដល់ផ្ទះលំអងវិញពីព្រលប់ខុសធម្មតា។ លុះមកដល់មាត់ ច្រករបងចូល ស្រាប់តែនាយឃើញទ្វារផ្ទះចំហធ្លង។ សុបិននឹកអរភើត ស្ទុះរឹងចូលក្នុងផ្ទះយ៉ាងរហ័ស ស្រាប់តែប្រទះមាណវីមួយរូបកំពុងកេះឈើ គូសអុជចង្កៀងបំភ្លឺផ្ទះ។ សុបិនក៏ញញឹមឡើង ឧទានហៅនារីយើងទាំង រំភើបត្រេកអរក្នុងចិត្តបំផុត :

- លំអង...!

រួចហើយក៏ស្ទុះរត់ទៅស្រវាអោបនាងពីក្រោយយ៉ាងណែន ដោយដួង ចិត្តរំភើបញាប់ញ័រ :

- លំអង!... ខ្ញុំនឹកនាងណាស់ លំអង...! នឹករកអ្វីមកប្រៀបអោយស្មើមិន បានឡើយ... ខ្ញុំត្រេកអរអ្វីម្លេះទេកាលបើនាងត្រលប់មកវិញ....

ស្រាប់តែលំអងបែរជាឈរធ្មឹង មិនឃើញសំដែងសេចក្តីត្រេកអរអ្វីជា មួយនាយយើងទេ។ នាងលូកចាប់បេះដៃនាយចេញពីខ្លួនហើយឈ្ងោកមុខ ដើរចេញទៅក្រៅ តែសុបិនស្រវាទាញនាងមកវិញយ៉ាងរហ័ស :

- អត់ទេ... លំអង... កុំទៅណាចោលខ្ញុំអី...ខ្ញុំមិនអោយនាងទៅទេ...

តែលំអងនៅតែប្រឹងរលាស់ដៃចេញដដែល។ សុបិនឃើញដូច្នោះក៏ វាចាថែមទៀតយ៉ាងរហ័ស ថា :

- លំអង... ឱ្យបងសូមទោសណាំអូន ដែលបងបានធ្វើមិនគប្បីចំពោះអូន កន្លងមក... សូមមេត្តាទុកឱកាសអោយបងបានកែកំហុសផងបានទេហ៎? បងដឹងថាអូននៅខឹងនឹងបង ទើបអូនមិនស្រដីរកបងយ៉ាងនេះ! លំអង! បងបានបំផ្លាញអនាគតរបស់អូនអស់ទៅហើយ.. ពេលនេះ បងក៏គ្មានអ្វី សងជូនរូបអូនទេ...ក្រៅពីជីវិតរបស់បង...!! ហើយបើសិនជាអូនដើរចេញ ពីជីវិតរបស់បងទៅរហូតមែន សុបិនក៏មិនដឹងជាខំត្រដរប្រឹងរស់ក្នុងជាតិ នេះ ដើម្បីនរណាតទៅទៀតដែរ...

សុបិនវាចាទាំងនេត្រារលីងរលោង... មែនហើយ... នេះជាសំដីដំបូង បង្អស់ដែលធ្លាយពីមាត់របស់នាយដោយឯកឯង។ ប៉ុន្តែបើនាយមិនស្រដី ពេលនេះទេ មិនដឹងថាថ្ងៃណានាយមានឱកាសនឹងប្រាប់លំអងឱ្យដឹងដែរ។ ឮសំដីរបស់សុបិនដូច្នោះ លំអងក៏ទុចង់ក់ឈរទ្រឹងនៅមួយកន្លែង។ សុបិន ឈ្ងោកមុខសំលឹងដីនៅស្ងៀមមួយស្របក់ ក៏មានវាចាបន្ថែមទៀតថា :

CHANBOKEO.COM

- សូមទោស លំអង... បងមិនគួរវាចាបង្ខំចិត្តអូនទេ! គ្រានេះ... បើសិន ជាអូនមិនពេញចិត្តនឹងឃើញមុខបងតទៅទៀត... គឺបងទេដែលត្រូវដើរ ចាកចេញពីទីនេះទៅ មិនមែនរូបអូនទេ ព្រោះអីផ្ទះមួយនេះជាផ្ទះរបស់ អូន ។ ចំពោះបងដែលគ្រាន់តែជាអ្នកក្រៅម្នាក់ គួរតែជាអ្នកដែលត្រូវ ដើរចេញទៅវិញ ទើបសម...

សុបិនក៏ព្រលែងដៃមាណវីហើយ ក៏បែរខ្លួនថយដើរចេញទៅ ស្រាប់តែលំអងសួរកាត់យ៉ាងរហ័សថា :

- លោកបំរុងអញ្ជើញទៅណា?

សុបិនទុកង៉ក់ រួចហើយឆ្លើយដោយឥតងាកក្រោយឡើយ :

- បងមិនដឹងទេ ព្រោះឥលូវនេះបងកំពុងតែវង្វេងផ្លូវ... មិនដឹងថាខ្លួនបង មានដំណើរជីវិតទៅខាងណាឡើយ...

សុបិនឆ្លើយទាំងសោកសៅ ស្រាប់តែលំអងសួរបន្ថែមទៀតថា:

- តែលំអងបានដាំអាហារឆ្អិនហើយ លោកពិសារទេហ៎?

កាលបើឮដូច្នោះ សុបិនភ្ញាក់ព្រើត ហើយក៏ត្រេកអររំភើបចិត្តដែរ ។ នាយក៏បែរក្រោយហើយញញឹមឡើងទាំងរលីងរលោងទឹកភ្នែក :

- គឺបង...បរិភោគគ្រប់អាហារទាំងអស់ ដែលលំអងធ្វើសំរាប់បងជានិច្ច មិនដែលនឹកប្រកែកមួយម៉ាត់សោះ តាំងពីយូរមកហើយ!...

សុបិនរំភើបចិត្តណាស់ រហូតចង់ស្រក់ទឹកភ្នែក ដោយក្តីរំភើបត្រេកអរ ត្បិតដឹងថា លំអងកំពុងអភ័យទោសអោយនាយហើយ ថ្វីបើនាងមិនបាន និយាយអ្វីច្រើនជាមួយនាយយើងក៏ដោយ ។ គេបែរចូលផ្ទះវិញយ៉ាងរហ័ស ហើយដាក់ខ្លួនអង្គុយក្នុងផ្ទះ សំលឹងមុខលំអងទាំងបេះដូងរន្ធត់ញាប់ញ័រ ។

រាត្រីនោះ...

លំអងប្រែខ្លួនឡើងបែរសំលឹងទៅក្រៅមុង ឃើញសុបិនអង្គុយច្រងុក មិនព្រមចូលគេង នាងក៏សួរថា:

- ម៉េចក៏លោកមិនទាន់ចូលសំរានដូច្នេះ?...
- គឺ បងកំពុងនៅអង្គុយកំដរអោយអូនគេង...
- យប់ជ្រៅណាស់ហើយ... លោកនៅអត់ងងុយយូរ ប្រយត្ន័ឈឺណា!
- បងមិនអីទេ កុំបារម្ភអី... អូនគេងទៅណា!

ការពិត មិនមែននាយមិនចង់ចូលដំណេកទេ តែមកពីនាយមិនដាច់ ចិត្តចូលគេងតើហ៎ ព្រោះគេខ្លាចលំអងគេចទៅបាត់ចោលរូបគេទៀត ។ លំអងហាក់ដូចជាយល់ជំរៅចិត្តរបស់នាយ ក៏ពោលឡើងថា :

- លោកចូលសំរាន្តទៅ! លំអងមិនទៅណាទេ ឈប់បារម្ភទៅ ។

សុបិននៅអេះអុញមួយស្របក់ក៏ពោលថា :

- ... លំអង... អោយបងសូមគេងក្បែរ... កំដរអូនផងបានទេហ៎?

CHANBOKEO.COM

លំអងភា្ញក់ព្រើត... ត្រជាក់ដៃស្រិបតែម្តង កាលបើឮនាយយើង ពោលដូច្នោះ ។ នាងមិនទាន់ឆ្លើយផង សុបិនក៏វាចាបន្តថា :

- លំអង!... បងសន្យាថា នឹងគោរពព្រំដែនរវាងយើងទាំងពីរ... គឺបង លែងប្រព្រឹត្តលាមកលើរូបអូនទៀតហើយណា៎!... បងគ្រាន់តែសុំគេង នៅ ក្បែរអូនតែប៉ុណ្ណោះ....

លំអងនៅស្ងៀម ហាក់ដូចជារារែក ។ សុបិនឃើញនាងមិនមាត់ក៏មិន ហ៊ានស្រដីអ្វីដែរ ។ បុរសយើងនៅអង្គុយសំកុកផ្អែកសសរធ្វើភ្នែកភ្លឹះៗ ។ មិនយូរប៉ុន្មាននាយក៏ទន់ត្របកភ្នែកទៅ.. ស្រាប់តែភា្ញក់ព្រើតឡើងវិញ ត្បិតនាយឃើញលំអងយកក្រមាមួយមកដណ្តប់អោយនាយ ។ មាណពក៏ ស្រវាចាប់ដៃនាងជាប់ :

- អូននៅគិតពីសុខទុក្ខរបស់បងដែរឬលំអង?

ស្រាប់តែនាងរលាស់ដៃចេញហើយតបថា :

- លោកមិនចូលសំរាន្តទេហ៏? ចុះឯណាដែលថាគេងកំដរលំអងនោះ?

សុបិនភា្ញក់ព្រើតកាលបើឮនាងវាចាដូច្នោះ ។  នាយក៏ស្ទុះងើបឡើង ស្រវាអោបនាងយ៉ាងណែនពេញរង្វង់ដៃដោយទឹកមុខត្រេកអរ :

- អរគុណ.. ដែលអូនបានអភ័យទោសអោយបង... អរគុណណាស់លំអង!

ព្រឹកព្រហាមថ្ងៃថ្មី...

សុបិនភ្ញាក់បើកភ្នែកឡើង ស្រាប់តែបាត់លំអងពីផ្ទះដូចរាល់ដង ដែល នាងទំលាប់ចេញទៅពីព្រហាម ។ សុបិនភា្ញក់មិនដែលទាន់ធិតាយើងទេ ។ គេដាក់ភ្នែកទៅលើតុឃើញនាងរៀបស្លកបាយទុកអោយស្រេច ព្រមទាំង កូនសំបុត្រដែលសរសេរថា :

- សូមលោកពិសារលាងពោះខ្លះទៅមុននឹងចេញទៅធ្វើការ... លំអង!

រំពេចនោះសុបិនភា្ញក់ព្រើត :

- ម៉េចក៏នាងដឹងថា យើងចេញពីព្រឹកទៅធ្វើការ? ឬក៏នាងចេះតែនិយាយ គ្រាន់តែជាសុជីវធម៌?

សុបិនក៏ដាក់ខ្លួនចុះស្រវាអាហារមកបរិភោគភ្លាម ក្នុងចិត្តនឹកបន់ថាៈ

- ល្ងាចនេះ សូមអូនវិលមកផ្ទះយើងវិញកុំខានណា៎លំអង!

សុបិនបរិភោគហើយក៏ចេញដំណើរទៅ ។ លុះមកដល់ការិយាល័យ ដើម្បីបង្ហាញខ្លួន ស្រាប់តែមានបុរសម្នាក់យកសំបុត្រមួយច្បាប់មកហុច អោយនាយ :

- លោកសុបិន! មានភ្ញៀវផ្ញើសំបុត្រមកជូន ។

CHANBOKEO . COM

សុបិនភ្ញាក់ព្រើត នឹកឆ្ងល់ក្នុងចិត្តយ៉ាងចំលែក ។ នេះជាថ្ងៃទីពីរដែល នាយបានចូលធ្វើការ ។ នាយមិនទាន់បាននិយាយប្រាប់នរណាម្នាក់ផង ម៉េចក៏មានគេដឹងថានាយធ្វើការនៅទីនេះ? សុបិនក៏ចាប់សំបុត្រអាន:

- ជំរាបលោកសុបិន! នៅម៉ោង៩ព្រឹកនេះ នឹងមានឡានមួយទៅទទួលលោកពីទីស្នាក់ការពេលលោកចូលមកបង្ហាញខ្លួនដើម្បីធ្វើការ ។សូមលោក ត្រូវមកជួបនឹងខ្ញុំកុំខាន ដើម្បីជជែកគ្នាពីរឿងជួយឪពុករបស់លោកអោយ រួចពីការជាប់ឃុំឃាំង ។

សុបិនភ្ញាក់ស្រលាំងកាំងដូចគេចាប់គ្រវែងចូលក្នុងទន្លេ ។ រំពេចនោះ ស្រាប់តែមានរថយន្តថ្មីស្រលាងមួយចូលមកដល់ ។ បុរសម្នាក់ចុះពីរថយន្ត ដើរសំដៅមករកនាយ :

- លោកសុបិនមែនទេ?
- បាទ មែនហើយ!
- គឺខ្ញុំត្រូវមកទទួលលោកទៅឥលូវនេះ បាទ!

សុបិនបែរមើលទៅលោកអធិការផុន ដែលកំពុងឈរនៅទីនោះដែរ ។ លុះឃើញមានមនុស្សមកទទួលសុបិន លោកអធិការក៏សួរថា :

- ទើបមកដល់ការិយាល័យអំបាញមិញ មិនទាន់បានផ្តើមធ្វើការផង ចុះ ឥលូវនេះចង់ទៅណាហើយហ្នឹង លោកសុបិន?

ពេលនេះ សុបិនរារែកណាស់... តើនាយត្រូវគោរពវិន័យការងារ ឬក៏ គេចខ្លួនពីការងារដើម្បីឪពុករបស់នាយ? យ៉ាងណាក៏ដោយ ពេលនេះនាយ គ្មានពេលគិតច្រើនទេ សុខទុក្ខរបស់ឪពុកនាយសំខាន់ណាស់ ។ ណាមួយ មាណពក៏ចង់ដឹងដែរថាតើលោកសោរិននៅឯណា ជាប់ឃុំរឿងអ្វី ។ ភ្លាម នោះ នាយក៏គំនាប់លានាយកោយយ៉ាងរហ័សហើយក៏ហក់ឡើងរថយន្ត ចេញទៅ ។ លោកអធិការសំលឹងមើលតាមនាយទាំងទឹកមុខងឿងឆ្ងល់ក្រៃ លែង ។ បន្តិចមក រថយន្តបាននាំសុបិនមកដល់វិឡាមួយយ៉ាងស្កុកស្កម្ភ ។ សុបិនបោះជំហានចុះពីរថយន្តសំលឹងជុំវិញខ្លួន តែមិនឃើញមានអ្វីគួរឱ្យសង្ស័យឡើយ ។ ម្យ៉ាងទីនោះគ្រាន់តែជាភូមិគ្រឹះដ៏សង្ហារមួយតែប៉ុណ្ណោះ គ្មានអ្នកយាមប្រសេចប្រសាចអ្វីគួរអោយកត់សំគាល់ដែរ ។ បន្តិចមកបុរស ក៏ដើរមកដល់បន្ទប់ទទួលភ្ញៀវមួយ ដែលមានការតុបតែងយ៉ាងប្រណិត ស្រាប់តែប្រទះនឹងបុរសចំណាស់មួយរូបក្នុងសំលៀកបំពាក់ថ្លៃថ្នូរនៅអង្គុយរង់ចាំ ទីនោះស្រេច ។ ក្រលេកឃើញបុរសនោះភ្លាម សុបិនក៏ឧទានខ្សិប១ថា :

- លោកសុនាថ!

មែនហើយ បុរសចំណាស់នោះគឺលោកសុនាថ ដែលនាយបានឃើញ ក្នុងរូបភាពសំកាំងដែលក្រសួងប៉ូលីសសម្ងាត់បញ្ចាំង កាលពីម្សិលមិញនេះ

CHANDOKEO.COM

ឯង ។ រំពេចនោះ លោកសុនាថញញឹមឡើងហើយមានប្រសាសន៍ថា :

- សួស្តី! លោកសុបិន! សូមអញ្ជើញអង្គុយសិនមក!

សុបិនផ្តិតដៃសំពះសួរលោករួចទើបដាក់ខ្លួនអង្គុយចុះ ។ លោកសុនាថ ក៏ពោលបន្តថា :

- ខ្ញុំជាមិត្តរបស់លោកសៅរិនដែលជាឪពុករបស់លោក ។ ឥលូវនេះខ្ញុំមាន សំណើពិសេសមួយជូនលោក ជាថ្នូរក្នុងការជួយសំរួលកិច្ចការ ដើម្បីឱ្យ លោកសៅរិនរួចទោសឃុំខ្លួនមកវិញបាន ។
- លោកប៉ាជាមនុស្សដែលខ្ញុំគោរពហើយស្រលាញ់បំផុត ។ អ្វីក៏ខ្ញុំអាចបូជា បានដែរអោយតែខ្ញុំអាចជួយលោកបាន!!
- ពិតជាចិត្តកូនប្រុសមែន! ខ្ញុំជ្រើសរើសរូបលោកពិតជាមិនខកបំណងទេ
- ឥចឹង លោកអាចមានប្រសាសន៍បានទេ ថាខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីជួយ លោកប៉ារបស់ខ្ញុំបានទៅ?
- ងាយទេណា! គឺថាបើលោកទទួលខ្លួនធ្វើជាកូនប្រសារពេញច្បាប់របស់ខ្ញុំ នោះខ្ញុំសន្យាថា នឹងជួយលោកសៅរិនអោយចេញមកវិញបានទាន់ពេលថ្ងៃ ចងដៃរបស់លោកតែម្តង...
- លោកមានប្រសាសន៍ថាម៉េច? អោយខ្ញុំរៀបការ... ជាមួយកូនស្រីរបស់ លោក? អ្នកនាងអម្ពរនោះមែនទេ?
- មែនហើយ! លោកសុបិនបានស្គាល់នាងហើយមែនទេ?
- មិនស្គាល់ទេ.. គ្រាន់តែធ្លាប់ឃើញពីចម្ងាយម្តងពីរ...
- បើអញ្ចឹង លោកគិតយ៉ាងណាដែរ ចំពោះរឿងនេះ?
- សូមទោសលោកសុនាថ ! មើលទៅមិនកើតទេ! យើងមិនដែលស្គាល់ គ្នាផង តើអោយរៀបការយ៉ាងម៉េចនឹងកើត?
- អើហ៎ បើអញ្ចឹង ជួបគ្នាដើរលេងជាមួយគ្នាបន្តិចទៅ ស្គាល់គ្នាហើយ
- អត់ទេហ៎... ខ្ញុំថា... ខ្ញុំមិនអាចធ្វើតាមសំណូមពរនេះបានឡើយ...
- លោកសុបិនមិនចង់ជួយអោយឪពុកឱ្យចេញពីមន្ទីរឃុំឃាំងវិញទេហ៎?

សុបិនយកដៃឈ្ញីសក់... នឹកឆ្ងល់ផង ព្រួយក្នុងចិត្តផង ថាហេតុអ្វីរូប គេក្លាយទៅជាចំណុចអំបោះជំពាក់មុខទៅវិញ?នាយស្រលាញ់ឪពុកណាស់ ហើយក៏ចង់ជួយអោយលោកមានសេរីភាពវិញដែរ តែនាយមិនអាចទទួល សំណូមពរពីលោកសុនាថបានដែរ ។ គេមិនយល់សោះថា ហេតុអ្វីបានជា លោកសុនាថទាមទារឱ្យនាយរៀបការនឹងកូនស្រីរបស់លោក ដើម្បីជាថ្នូរ ទៅជួយលោកសៅរិនឱ្យចេញពីការឃុំឃាំង ។ ចុះនាងអម្ពរនោះ? មើល ទៅនាងមានឫកពា ដូចជាមានមោទនភាពចំពោះខ្លួនយ៉ាងឧត្តុង្គឧត្តម តែហេតុអ្វីបានជានាងបែរជាទទួលយល់ព្រម អោយឪពុកនាងជ្រើសរើសគូ ស្រករសំរាប់នាងដោយមិន បានស្គាល់ចិត្តថ្លើមមារយាទរបស់គូស្រករខ្លួន ដូច្នេះទៅវិញ? ចុះរឿងមុខនាទីរបស់នាយ ដែលត្រូវធ្វើជាប៉ូលីសសំងាត់ តាមដានសកម្មភាពរបស់លោកសុនាថនោះ តើនាយត្រូវគិតយ៉ាងណា? ហើយបើធ្វើតាមគេដើម្បីរំដោះឪពុក

CHANBOKEO.COM

តើនាយត្រូវយកលំអងទៅទុកនៅ ឯណាវិញទៅ? គិតទៅគិតមក សុបិនមានអារម្មណ៍រឹតតែស្រាក់ជំពាក់ ឡើង។ ម្យ៉ាងជាការងារ មួយជាឳពុក មួយទៀតជានារីដែលគេប្រតិពទ្ធ័ ពេញបេះដូង តើគេត្រូវជ្រើសរើសផ្លូវមួយណា?

ដោយមិនអាចជូនចំលើយដល់លោកសុនាថបាន សុបិនក៏គោរពលា លោកត្រលប់ចេញមកវិញ។ គ្រាន់តែមកដល់ការិយាល័យ លោកអធិការ ចេញមកជួបនាយដល់មាត់ទ្វារ :

- លោកសុបិន! លោកចេញទៅជួបពាណិជ្ជករអភិជនឈ្មោះសុនាថនោះ
ក្នុងឋានៈជាប៉ូលីសសំងាត់ឬជាមិត្តផ្ទាល់ខ្លួន? លោកមានស្គាល់ព្រំដែនការ ងារថាមានរបងនៅកំរិតត្រឹមណាដែរទេ?

សុបិនឈ្ងោកមុខមិនហ៊ានឆ្លើយតបទេ ហើយក៏មិនដឹងថាត្រូវតបទៅ
វិញ យ៉ាងណាផង។ លោកអធិការក៏មានប្រសាសន៍បន្តថា :

- លោកសុបិន! បើមិនទាន់មានអារម្មណ៍ល្អដើម្បីបំរើការងារអោយបាន ហ្មត់ចត់ទេនោះ លោកទៅសំរាកសិនចុះ...
ចាំមានអារម្មណ៍ល្អសឹមត្រលប់ មកធ្វើការវិញ។

ឮសំដីលោកអធិការដូច្នោះ បុរសយើងក៏គំនាប់លាលោកចេញទៅ។

នៅរាត្រីនោះ...

សុបិនអង្គុយរង់ចាំមើលផ្លូវលំអងឡើងផ្សារភ្នែក មិនចេះឃើញនាង មកដល់សោះ។ នាយទឹកពិភាល់ក្នុងចិត្តយ៉ាងណាមិនដឹង នឹកភ័យក្នុងចិត្ត ក្តុកក្តាក់ៗក្រែងនាងមិនមក់។ ម៉ោង១២អាធ្រាតទៅហើយ លំអងនៅតែ មិនទាន់មកដល់ទៀត។ មាណពចង្អៀតចង្អល់រសាប់រសល់ក្នុងចិត្តពេក ក៏ដើរចេញទៅអង្គុយលេងនៅលើស្ពានឬស្សី ស្រាប់តែភ្ញាក់ព្រើតដែល នាយប្រទះឃើញលំអងនៅអង្គុយច្រងុកនៅទីនោះតាំងពីអង្កាល់មិនដឹង:

- លំអង...

សុបិនក៏ញញឹមឡើងរួចក៏ដើរទៅជិតដាក់ខ្លួនអង្គុយជិតធិតាភ្លាម :

- អូនមកដល់តាំងពីអង្កាល់? បងខំអង្គុយចាំអូន យូរអើយសែនយូរ.. ដឹង
ទេថាបងនឹកអូន... នឹករកអ្វីប្រៀបមិនបានទេ...!!

សុបិនលូកដៃត្រកងចង្កេះលំអងពីក្រោយ ហើយពោលបន្តថា :

- លំអងគឺជាកំលាំងចិត្តដ៏ធំមាំមួយសំរាប់ជីវិតបង... នៅ រៀងរាល់ពេល ដែលបងបានឃើញរូបអូន
បងមានសេចក្តីសុខក្នុងចិត្តណាស់ អូនដឹងទេ?

លំអងបែរសំលឹងសុបិន មួយស្របក់ក៏សួរថា :

- លំអងគ្រាន់តែជានារីសាមញ្ញមួយរូបប៉ុណ្ណោះ ម្តេចលោកចាប់អារម្មណ៍ ពីនាងអ្វីដល់ម្លឹងផង?

- លំអង... បងមិនដឹងទេ ថាបងចាប់ប្រតិពទ្ធ័រូបអូន តាំងពីពេលណាមក ប៉ុន្តែអ្វីដែលបងដឹងជាក់ច្បាស់នោះគឺ ពេលនេះ ឥលូវនេះ អូនគឺជាបេះដូង របស់បងតែមួយគត់...

សុបិនយកដៃអង្អែលកេសាធិតាថ្នមៗ...ហើយក៏និយាយបន្ត:

CHANBOKEO.COM

- ពិតមែនតែបងស្គាល់រូបអូនក្នុងពេលវេលាដ៏ខ្លី... តែបងជឿជាក់ក្នុងចិត្ត ថាបងគ្មានថ្ងៃស្ដាយក្រោយឡើយ ដែលបានជ្រើសរើសយករូបអូនជាគូ ជីវិតរបស់បង...

លំអងឈ្ងោកមុខយកជើងទទះទឹកលេង រួចក៏មានវាចាសួរនាយថា :

- បើសិនពេលនេះលោកព្រមទទួលស្គាល់លំអងពិតមែន តើឪពុកម្ដាយ របស់លោកគេនឹងគិតយ៉ាងណា? តើលោកព្រមទទួលស្គាល់នារីរូបអន់ៗ វណ្ណៈអន់ៗ ដូចខ្ញុំនេះដែរឬអ្វី?

- បងជឿថា... លោកប៉ារបស់បង ច្បាស់ជាពេញចិត្តរូបអូន ដូចបងពេញ ចិត្តអូនអញ្ចឹងដែរ!

- ចុះពេលនេះ លោកប៉ារបស់បងនៅឯណា?

-គឺ... គឺ... លោកកំពុងរងការចោទប្រកាន់មួយ ។

- ពុទ្ធោ... អញ្ចឹងលោកត្រូវដោះស្រាយយ៉ាងម៉េចទៅ?

- បងមិនទាន់ដឹងទេ ហើយពេលនេះ បងក៏មិនទាន់ដឹងដែរថាលោកជាប់ ឃុំនៅកន្លែងណាផង... មានតែមនុស្សម្នាក់ទេដែលដឹង...

- អញ្ចឹង ម៉េចក៏លោកមិនពឹងពាក់គេអោយជួយលោកប៉ារបស់លោកទៅ?

- គឺ... បានទៅពិគ្រោះរួចហើយ តែបងមិនអាចទទួលយកសំណូមពររបស់ គេនោះបានឡើយ ។

- ព្រោះអ្វីទៅ?

- គឺ មកពីគេសុំអោយបងធ្វើជាកូនប្រសាររបស់គេ ។ កូនស្រីរបស់គេគឺ ជាអនុសេនិយទោ...អ្នកគ្រប់គ្រងករណីរបស់លោកប៉ាតែម្ដង....

- ហេតុអ្វីក៏លោកទទួលមិនបាន? ជាកូន ត្រូវតែកតញ្ញូចំពោះអ្នកមាន គុណ ពលិកម្មត្រឹមរៀបការដើម្បីរំដោះលោកអោយមានសេរីភាពវិញនោះ មិនគួរណាជាការពិបាកទេ ។

- អូននិយាយខុសហើយ... បើបងរៀបការដើម្បីរំដោះលោកប៉ា... បងនឹង ក្លាយជាបុរសដែលមានបេះដូងឧក្រិដ្ឋចំពោះស្នេហារបស់ខ្លួនហើយ...

- អូហ៏លោកចេះមានស្នេហាដែរ?... ពិតមែនហ្អែស?

- លំអង! បងស្រលាញ់អូនណាស់ ពិតជាស្រលាញ់អូនមែន... បងមិន ដែលមានអារម្មណ៍បែប នេះពីមុនមកទេ... ឬក៏មិនទាន់ទុកចិត្តបងនៅ ឡើយ មែនទេ?

- តែធ្វើម៉េចឱ្យលំអងដឹងបានទៅថា  ដួងចិត្តរបស់លោកមិនដើររាយមាយ ឆក់បេះដូងនារីគ្រប់ទីកន្លែងតទៅទៀតនោះ?

- ខុសហើយអូន! កាលពីដើម បងប្រហែលជាបុរសមានបេះដូងរាយ មាយបន្តិចមែន ។ តែពេលនេះបងផ្លាស់ប្ដូរហើយមិនដូចពេលមុនទេ ។ បង ដឹងថាបងបានស្វែងរកឃើញស្នេហាពិតហើយ... ហើយនារីនោះគឺជាលំអង ដែលបងស្រលាញ់អស់ពីដួងចិត្ត... អូនគឺជាបេះដូង ជាជីវិត ជាអ្វីទាំងអស់ របស់សុបិនបងនេះ! បើអូនមិនជឿចិត្តបង... សូមទុកឱកាសអោយបង ណា ដើម្បីអោយបងបានបង្ហាញនូវចិត្តបងចំពោះអូនពិតប្រាកដ ។

CHANBOKEO.COM

សុបិនវាចាផង យកដៃអង្អែលខ្នងធិតាថ្នមៗផង ដោយទឹកចិត្តស្នេហា យ៉ាងធំធេងមិនអាចរៀបរាប់បាន ។ លំអងផ្តេកកេសាកើយស្មាបុរសយើង ទំនងហាក់ដូចជាកំពុងសំដែងនូវទំនុកទុកចិត្តរបស់នាង ចំពោះបុរសយើង ហើយជាលើកដំបូង ។

រាត្រីនោះ សុបិនមានអារម្មណ៍រំភើបប្លែកលើសពេលណាៗទាំងអស់ ត្បិតនាយបានទទួលនូវភាពទន់ភ្លន់របស់លំអង ជាការឆ្លើយតបចំពោះដួង ចិត្តស្នេហាដែលនាយបានសារភាពចំពោះនាងទាំងអំបាលម៉ាន ។ ពេលនេះ បុរសយើងបានយល់ជាក់ច្បាស់ហើយថា ទឹកដមនៃសេចក្តីស្នេហាមិនមែន ស្ថិតនៅលើកាយសម្ផស្ស ទ្រព្យសម្បត្តិ ឬឋានៈវណ្ណៈអ្វីអស់នោះឡើយ ។ ការពិតសុភមង្គលពិតប្រាកដគឺការយល់ចិត្តគ្នា យល់ទុក្ខធុរៈគ្នានិងការពលី ដើម្បីរក្សាសេចក្តីស្នេហាបរិសុទ្ធ ។ ពិតមែនតែនាយមិនទាន់ស្គាល់ប្រវត្តិ របស់លំអងថាអតិតកាលរបស់នាងយ៉ាងណា តែពេលនេះសុបិនអាចសរុប បានទាំងអស់ថា នាងគឺជានារីមួយរូបដែលមានសន្តានចិត្តប្រពៃ ។ នាង តែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់នាយរៀងរហូតមក សូម្បីតែ នាយមិនដែលស្គាល់នាងពីមុនមកផង ។ អ្វីដែលនាយមិនទាន់យល់នោះគឺ.. តើនិស្ស័យអ្វីទៅដែលនាំអោយលំអងដើរចូលក្នុងជីវិតរបស់នាយយ៉ាងនេះ ជាពិសេសទាំងពីរលើកដែលនាយប្រទះនឹងឧប្បដ្ដិហេតុ ហេតុអ្វីក៏លំអង តែងតែមកដល់ទាន់សភាពការណ៍ដើម្បីសង្គ្រោះនាយជានិច្ចដូច្នោះ?សុបិន ហាក់ដូចចាប់ភ្លឹកបន្តិចហើយថា ធិតាពិតជាស្គាល់រូបនាយ មុនពេលដែល នាយបានជួបហើយស្គាល់រូបនាង... តែសុបិននៅតែគិតមិនឃើញដដែល ថានាយធ្លាប់ជួបលំអងពីមុនមកដែរឬក៏អត់? ឬក៏មកពីការវាយឬកឆ្មើង កន្រ្ទើងរបស់គេទេដឹង ដែលនាំអោយខ្លួនគេមើលរំលងរូបនាងរហូតមក?

នៅក្នុងមុងកញ្ចាស់ លំអងសំងំគេងលក់យ៉ាងសុខសាន្ត ក្នុងរង្វង់ដៃ បុរសយើងដែលគេងបើកភ្នែកភ្លិះៗ ពិចារណាពីនេះពីនោះមួយយប់មក ហើយ... កាន់តែថ្លឹងថ្លែង កាន់តែជំពាក់ចិត្តអាណិតអាសូរធិតាឡើង... មាណពពិតជាមិនដាច់ចិត្តបោះបង់ផ្កាមួយទងនេះ អោយលិចភក់ជ្រាំបាន ឡើយ ។

៙៙៙៙៙៙៙៙៙៙៙៙៙៙៙៙

៙៙៙៙៙

៙

CHANBOKEO.COM

# វគ្គទី៧

# លំអងផ្កា

សុបិនរលឹកពីដំណេកឡើង មានអារម្មណ៍ហាក់ដូចជាសប្បាយរីករាយ ក្នុងចិត្តខុសប្រក្រតី ។ លុះនាយរៀបចំខ្លួនបំរុងងើបមកបរិភោគបបរដែល លំអងបានរៀបទុកដាក់អោយស្រាប់តែប្រទះនឹងចំណារតូចមួយរបស់នាង នៅលើតុ ។ សុបិនក៏លើកយកមកអានមានសេចក្តីថា :

- នេះជាស្លាកចុងក្រោយហើយដែលលំអងអាចជូនលោកបាន ។ ចាប់ពី ថ្ងៃនេះតទៅ លោកត្រូវត្រលប់ទៅបំពេញនាទីជាកូនដ៏ល្អរបស់ឪពុកវិញ ។ ពេលនេះ ឪពុករបស់លោកប្រហែលកំពុងរង់ចាំកូនប្រុសឱ្យមកជួយដោះ ស្រាយជីវិតរបស់លោកហើយ ។ លំអងគ្រាន់តែជាកំទេចលំអងធូលីតូចៗ មួយប៉ុណ្ណោះគ្មានតម្លៃអ្វីទេ ទុកអោយគេអណ្តែតត្រសែតទៅតាមវាសនា កម្ម ជាលំអងល្អិតស្ទើរតែឥតរូបនោះទៅចុះ ។ ភាពកតញ្ញូចំពោះឪពុកមាន តម្លៃណាស់... ជាកូនប្រុសគប្បីតែជ្រើសរើសនូវជីវិតដ៏ត្រឹមត្រូវបំផុត សំរាប់អ្នកមានគុណ.... លំអង!!

- លំអង?... អូនកំពុងចាកចេញទៅណា?

សុបិនរន្ធត់តក់ស្លុតក្នុងចិត្តណាស់ កាលបើបានអានចំណារសំបុត្រនោះ ចប់ភ្លាម ។ គេមិនយល់ទេ ថាហេតុអ្វីលំអងដាច់ចិត្តដើរចេញពីជីវិតរបស់ នាយយ៉ាងងាយៗដូច្នេះ? ទឹកភ្នែកពីរដំណក់បានវិលមកប្រលែងកែវ នេត្រារបស់សុបិនសាជាថ្មី...

- លំអង... ហេតុអ្វីក៏អូនធ្វើយ៉ាងនេះចំពោះបង? ឬក៏អូននៅមិនទាន់ ទុកចិត្តបងថាបងពិតស្រលាញ់អូនយ៉ាងស្មោះស្ម័គ្រ? ប៉ុន្តែទោះបីជាយ៉ាង ណាក៏ដោយ ក៏បងនឹងបង្ហាញអោយអូនដឹងដែរថា ជាតិនេះ បងទទួលយក នារីរ មួយរូបគត់ជាម្ចាស់បេះដូង... នោះគឺរូបអូនណា លំអង!...

សុបិនអង្គុយលង់សោកាក្នុងចិត្តតែម្នាក់ឯង កណ្តោចកណ្តែងអស់ជា ច្រើនម៉ោង... ទើបដាច់ចិត្តងើបដើរចេញទៅ...

នៅក្នុងការិយាល័យកងប៉ូលីសសំងាត់ លោកអធិការមានប្រសាសន៍ ទៅកាន់សុបិនថា :

- លោកដឹងពីព្រំដែនតួនាទីច្បាស់លាស់ហើយមែនទេហ៎?

- បាទ! ច្បាស់លាស់បំផុត! (សុបិនឆ្លើយវិញ)

- គឺគ្មានសម្ពន្ធ័ចំណងមិត្តភាពឬគ្រួសារមកលាយឡំក្នុងមុខនាទីទេណា៎

CHANBOKEO.COM

- ពិតប្រាកដណាស់ ។

លោកអធិការមានប្រសាសន៍បញ្ជាក់ច្រើនដង តែសុបិននៅតែឆ្លើយ ដាច់ណាត់ដដែល ។ មើលទៅលោកអធិការដូចជាមានការសង្ស័យអ្វីមួយ លើនាយទេដឹង? សុបិនគិតក្នុងចិត្តថា :

- សូមលោកកុំសង្ស័យអ្វីអំពីទំនាក់ទំនងរវាងខ្ញុំនឹងលោកសុនាថ ។ ខ្ញុំពិតជាមិនអោយមុខនាទីក្រសួងមានការប្រលាក់ប្រលូសទេ ។ម្យ៉ាងទៀតខ្លួនខ្ញុំ ក៏មិនអាចទទួលយកសំណើរបស់លោកសុនាថបានដែរ ត្បិតខ្ញុំមិនដឹងច្បាស់ ថាតើលោកសុនាថអាចជួយឪពុករបស់ខ្ញុំបានពិតមែន ឬក៏គ្រាន់តែជាល្បិច អ្វីមួយ... ដែលខ្ញុំមិនទាន់ស្រាវជ្រាវដឹង...!!!

ព្រលប់នោះ សុបិនត្រូវចេញទៅប្រតិបត្តិការជាមួយកងភ្នាក់ងារ សំងាត់ច្រើនរូបទៀត ដែលចេញទៅបង្កប់ខ្លួននៅកំពងផែចំលង ដែលមាន ទូកចតរកេតរកូតពាសពេញ ។ នៅលើកប៉ាល់ធំមួយ ដែលកំពុងចតនៅក្បែរច្រាំង គេឃើញបុរសចំលែកពីរក្រុមកំពុងប្តូរតវ៉ាន់គ្នា :

- ឈប់ភ្លាម! ដាក់អាវុធចុះ...! (កងប៉ូលីសសំងាត់ស្រែកបញ្ជាពីចំងាយ)

តែក្រុមទាំងសងខាង បែរជាគេចខ្លួនយ៉ាងរហ័ស ហើយក៏មានការ បាញ់កាំភ្លើងតបវិញផង ។ សុបិនក៏ហក់គេចជាមួយភ្នាក់ងារមួយរូបទៀត រត់ទៅពន្លឺពីមួយចំហៀងទិសថ្មីម្ខាងវិញ ។ ភ្លាមនោះ ស្រាប់តែនាយប្រទះនឹងបុរសចំណាស់មួយរូបកំពុងតែត្រូវក្រុមម្ខាងទៀត ក្បៀបកអូសយកជា ចំណាប់ខ្មាំង ។ សុបិននិងគូកនក៏ហក់ទៅធ្វើអន្តរាគមន៍ ហើយក៏ចាប់បំបែក ជនជាប់ពិរុទ្ធបានទាំងពីរនាក់ ។ រំពេចនោះកងកំលាំងប៉ូលីសសំងាត់ក៏បាន មកដល់ព្រមៗគ្នាដែរ... ស្នូរកាំភ្លើងក៏រលត់ស្ងាត់ទៅវិញ ។ លោកអធិការក៏ បានមកដល់យ៉ាងរហ័ស ហើយក៏ស្រវាបើកស្ទាប់មុខរបស់បុរសចំណាស់ ដែលត្រូវសុបិនចាប់ក្រៀក ស្រាប់តែលោកអធិការឧទានទាំងភ្ញាក់ផ្អើល :

- លោកសុនាថ?

លោកសុនាថធ្វើមុខស្មឿកមិននិយាយស្តី ។ លោកអធិការក៏បញ្ជាឱ្យបើកសំពៀតដែលចាប់បានពីពិរុទ្ធជននោះឡើង ស្រាប់តែគេប្រទះឃើញ ប្រាក់ដុល្លារទាំងបាច់ៗនៅក្នុងនោះ ។ ភ្លាមនោះ លោកអធិការក៏វាចាថា :

- មើលទៅ យើងប្រហែលត្រូវការលោកសុនាថអោយទៅជួយផ្តល់ដំណឹង ពតិមាននៅការិយាល័យយើងហើយ ។

រំពេចនោះ ស្រាប់តែលោកសុនាថស្រវាទាញដៃសុបិនអោយឈ្ងោក មកជិតលោក ហើយពោលខ្សិបៗដាក់ត្រចៀកនាយថា :

- លោកសុបិន! ខ្ញុំផ្ញើនាងអម្ពរកូនស្រីខ្ញុំជាមួយលោកផង! មានតែលោក ទេ ដែលខ្ញុំទុកចិត្តបំផុត ។

សុបិនបើកភ្នែកធំៗធ្វើមុខភាំង ។ លោកអធិការក្រលេកមកទាន់ក៏ គ្រហែមសំលុតឡើង :

- នែ៎ ខ្សិបអីហ្នឹង?

CHANBOKEO.COM

សុបិនភ្ញាក់ព្រឺតឈ្ងោកមុខនៅស្ងៀម ។ លោកសុនាថញញឹមដាក់ នាយហើយក៏បែរខ្នងដាក់នាយ រួចក៏លួចទំលាក់កូនសោរមួយចូលក្នុងដៃ របស់សុបិនយ៉ាងរហ័ស បន្ទាប់មកក៏បែរអោយប៉ូលីសនាំខ្លួនចេញទៅ ។ សុបិននឹកឆ្ងល់រិតតែខ្លាំងថា ហេតុអ្វីបានជាលោកសុនាថអោយកូនសោរ មួយនោះមកនាយ ។ តើកូនសោរនោះមានសារៈសំខាន់អ្វី?

សុបិនបានវិលមកដល់ផ្ទះវិញ អង្គុយចាំលំអងដូចដែលនាយធ្លាប់ចាំ រាល់ដង... ប៉ុន្តែ លំអងបាត់ស្រមោលទៅមិនឃើញត្រលប់មកវិញឡើយ ។ មួយថ្ងៃហើយមួយថ្ងៃទៀត លំអងនៅតែបាត់ស្រមោលដដែល :

- ហេតុអ្វីទៅលំអង បានជាអូនធ្វើបាបចិត្តបងអោយនៅឯកា រង់ចាំការ វិលវិញរបស់អូនដូច្នេះ.?.. បងពិតជាមិនយល់ទេ.. មិនយល់ទេ.. អូននៅ ឯណា ព្រលឹងមាសបង? បងនឹកអូនណាស់...!...

សុបិនតែងតែមកអង្គុយសំកុករៀងរាល់ថ្ងៃ លើស្ពានឫស្សីដែលនាយ និងលំអងធ្លាប់អង្គុយសាសងក្រោមពន្លឺដួងខែ ។ ខ្មៅតហើយរនោច រនោច ហើយខ្មៅតវិញ... សុបិននៅតែរង់ចាំដដែល... ប៉ុន្តែលំអងក៏នៅតែបាត់ទៅ គ្មានដំណឹង...

ស្ពានឫស្សី

មើលហ្ន៎! មេអំបៅហិចហើររេរា ត្រងត្រកែកគន្ធាបុប្ផាឧទ្យាន
ទឹកហូររឹមៗគ្រហឹមក្រោមស្ពាន ឋានសួគ៌វិមានសួនអនុស្សា ។
វាំយោត្រសៀកប្រផាស់ចុងព្រឹក្ស ភ្ញែកសំលឹងភ្លឹកពន្លឺវេហាស៍
សព្វសត្វស្រែកច្រៀងរំពងខ្សែវខ្សា ទិដ្ឋភាពសោភានាគ្រាសាយណ្ហ៍ ។
អង្គុយឯកាចិន្តាត្រអាល ទេសភាពត្រកាលពន្លឺមាសឆ្អិន
ឱ!ធម្មជាតិអើយ ខ្ញុំសូមស្រង់ក្លិន នាសាមិនញិនក្លិនបុប្ផាព្រៃ ។
រសៀលត្រជាក់ធ្លាក់ខ្យល់ជំនោរ ចិន្តាទន់ទោរនឹកដល់ចរណៃ
ធ្លាប់បានជួបអ្នកលើស្ពានឫស្សី កន្លងខែថ្ងៃថ្លៃបាត់សូន្យឈឹង ។
ស្នេហ៍នៅទីណាមេត្តាឆ្លើយប្រាប់ បេះដូងធុញថប់ត្បិតបាត់ដំណឹង
បងនៅរងចាំក្នុងចិត្តរំពឹង ចាំជួបព្រលឹងលើស្ពានស្នេហ៍យើង ។

សុបិនតែងតែមកធ្វើការជាប្រក្រតី មិនដែលលោះមួយថ្ងៃទេ ប៉ុន្តែអ្វី ដែលចំលែកបំផុតនោះ សុបិនបានក្លាយទៅជាបុគ្គលថ្មីមួយរូបដែលលែង មាត់ក រួសរាយដូចពីមុនទៀតហើយ ហើយក៏ឈប់ព្រោកប្រាជ្ញឱ្យដឹងលែប ខាយនារីណាដែរ កុំថាឡើយនាងមានរូបសម្បត្តិឆើតឆាយសិចស៊ីប៉ុណ្ណា ។ ម្យ៉ាងទៀត ឫកពាឆ្មើងកន្ទ្រើង មានជំនោរនឹងប្រជាប្រិយភាពរបស់ខ្លួន ផ្នែកចំរៀងក៏ថមថយអស់រលីង ។ គេឈប់ទៅច្រៀងដាក់ស៊ីឌីឫឌីវីឌីឱ្យ ក្រុមហ៊ុនផលិតកម្មណាទាំងអស់ ហើយក៏លែងចេញច្រៀងតាមសេចក្តី អញ្ជើញចូលក្នុងក្នុងពិធីមង្គលពិសេសៗដែរ ។ ក្រៅពីធ្វើការនៅក្រសួង គេតែងតែត្រលប់មកផ្ទះរបស់លំអងសំកុករង់ចាំនាងជារៀងរាល់ថ្ងៃ ។ គេ បានតាំងចិត្តសង្ឃឹមរឹងមាំថា លំអងនឹងវិលត្រលប់មកវិញនៅថ្ងៃណាមួយ មិនខាន ។ សុបិនមិនព្រមលះបង់សេចក្តីសង្ឃឹមរបស់គេទេ ។ ចំពោះនាយ

CHANBOKEO.COM

លំអងគឺជានារីតែម្នាក់គត់ ដែលតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខ របស់នាយជាទីបំផុត ជាពិសេសពេលណានាយមានទុក្ខ លំអងមានវត្តមាន មកដល់ទីនោះភ្លាម ។ មកដល់ពេលនេះហើយ ក៏នាយនៅតែមិនជឿថា មាណវីដាច់ចិត្តចាកចេញពីជីវិតរបស់នាយទៅដោយឥតហេតុផលឡើយ ។

ច្រើនថ្ងៃកន្លងទៅ...

សុបិនរើខោអាវរៀបចុះរៀបឡើង ក៏ជ្រុះកូនសោរមួយធ្លាក់ដីលាន់ រ៉ុង១ ។ នាយស្ទុះអោនរើសយកមកមើល ក៏នឹកភ្នកទៅដល់លោកសុនាថៈ

- តើលោកប្រគល់កូនសោររបស់លោកមកអោយខ្ញុំធ្វើអ្វី? នេះជាសោរផ្ទះ ឬជាសោរទូដែកសំងាត់? ហើយចុះហេតុអ្វីលោកទទូចសុំអោយខ្ញុំរៀបការ នឹងកូនស្រីគាត់ រួចហើយទោះបីជាដឹងថាខ្ញុំប្រកែកមិនទទួលសំណើនោះ ហើយ ម្ដេចក៏លោកនៅតែសុំផ្ញើកូនស្រីជាមួយខ្ញុំទៀត?

គិតមិនអស់មិនហើយ សុបិនក៏បើករថយន្តចេញទៅ ។ មកដល់វិឡា របស់លោកសុនាថ សុបិនចុះចតហើយដើរចូលចុចកណ្ដឹងទ្វារ... ប៉ុន្តែគ្មាន នរណាឆ្លើយសោះ ។ គេនៅរេរាមួយស្របក់ នឹកថាចង់ត្រលប់ទៅវិញ ហើយ ស្រាប់តែនឹកឃើញដល់កូនសោរដែលលោកសុនាថប្រគល់អោយ ។ គេក៏ហូតចេញមកយកទៅចាក់សោររបង.. ស្រាប់តែសោររបើកខ្វាក ។ សុបិនភ្ញាក់ព្រើតនឹកចំលែកចិត្តណាស់ ។ នាយក៏បើកទ្វាររបងដើរចូលទៅ ។ មែនហើយ នៅទីនោះមានសួនឧទ្យានស្អាតណាស់ ប្រកបដោយការថែទាំ យ៉ាងល្អ ។ តែចំលែកបន្តិចត្បិតលោកសុនាថបានត្រូវចាប់ខ្លួនទៅយូរថ្ងៃមក ហើយ ហេតុដូចម្ដេចក៏ទីនេះមានលក្ខណៈដូចជាមានមនុស្សនៅថែទាំ អញ្ចឹង? ឬក៏អម្ពរកូនស្រីរបស់លោកគេជាអ្នក ពុទ្ធោ! ចុះបើនាងនៅផ្ទះ ហើយឃើញនាយយើងដើរចូលមក ដោយមិនមានការអញ្ជើញពីម្ចាស់ផ្ទះ ដូច្នេះ តើគេគិតយ៉ាងណា? សុបិនថយខ្វាកបែរក្រោយបំរុងនឹងត្រលប់ទៅ វិញ... ស្រាប់តែឮសំលេងមនុស្សស្រីវ៉ាចាពីក្រោយខ្នងមកថា :

- អត់ទោស! លោកមានការរកនរណាដែរ?

សុបិនភ្ញាក់ព្រើតបែរក្រោយយ៉ាងរហ័ស ក៏ប្រទះស្ត្រីចំណាស់មួយរូប យកដៃបង្វិលកង់រទេះពិការនាំខ្លួនខិតចូលមកជិតនាយ ។ សុបិនក៏ឆ្លើយ ទាំងតតាក់តតុបថា :

- គឺ... គឺ... ... ខ្ញុំ...

ពេលនោះអណ្ដាតរបស់នាយក្លាយជាកករឹងអស់និយាយមិនរួច ស្រាប់ តែស្ត្រីចំណាស់មានប្រសាសន៍សួរឡើងថា :

- សុបិន មែនទេហ៏?

ពុទ្ធោ! ហេតុអ្វីក៏ស្ត្រីចំណាស់ស្គាល់ឈ្មោះរបស់នាយដែរ? សុបិនមិន ទាន់នឹងឆ្លើយផង ស្ត្រីចំណាស់ក៏ឆ្លើយជំនួសស្រេច :

- ព្រះអើយ! រូបសម្បត្តិខាងក្រៅសង្ហាជាងនៅក្នុងទូរទស្សន៍ឆ្ងាយណាស់!

CHANBOKEO.COM

តែថ្មីៗនេះ យើងតែងតែរង់ចាំអោយលោកឡើងវេទិកាទៀត តែមិនដែល
ឃើញលោកចេញមុខមកបង្ហាញសំនៀងបទថ្មីអ្វីទៀតសោះ...

សុបិននៅស្ងៀមមិនហ៊ានស្ដី គ្រាន់តែលើកដៃផ្គុំសំពះប្រណិបតន៍ស្ត្រី ចំណាស់ប៉ុណ្ណោះ ។ បន្ទាប់មកគាត់ក៏ពោលឡើងថា :

- ម៉ោះ! ចូលលេងក្នុងផ្ទះសិនមកក្មួយ!

សុបិនក៏ជួយរុញរទេះពិការជូនស្ត្រីនោះត្រលប់ចូលមកក្នុងផ្ទះវិញ :

- អ្នកមីងនៅផ្ទះតែម្នាក់ឯងទេហ៎?...

ស្ត្រីចំណាស់ងក់ក្បាល :

- ឆ្នាំនេះ រាសីយើងមិនល្អ គ្រប់ៗគ្នាក្នុងផ្ទះនេះចេះតែមានរឿងគ្រោះថ្នាក់ នេះ រវល់នោះ ឈឺនោះ ឈឺនោះមិនឈប់ឈរ ម្លោះហើយ មិនដែលបាន នៅផ្ទះជួបជុំគ្នាសោះ.... ហើយចុះក្មួយមកផ្ទះយើង មានការអ្វីដែរ?

មើលទៅអ្នកស្រីនោះមានសំដីរួសរាយទន់ភ្លន់រាក់ទាក់ណាស់ ។ សុបិន ឮស្ត្រីចំណាស់មានប្រសាសន៍សួរដូច្នោះ ក៏លើកកូនសោរហុចជូនគាត់ភ្លាមៈ

- លោកសុនាថបានផ្ដាំអោយយកកូនសោរផ្ទះមកជូន?

- អូហ៎! ហើយចុះលោកសុនាថមានប្រាប់ទេថាលោកទៅណា? បាត់មុខ យូរថ្ងៃហើយ មិនឃើញមកផ្ទះសោះ!

- អ្នកស្រីជាភរិយារបស់លោកសុនាថមែនទេហ៎ បាទ?

- មែនហើយក្មួយ! មីងឈ្មោះបូព្រឹក្សជាភរិយាលោកសុនាថ ។ ពេលនេះ ដូចក្មួយឃើញស្រាប់ហើយ មីងពិការអាមណាម...ទើបលោកសុនាថ គេ មិនសូវហ៊ាននាំដើរទៅណាទេ... ហ៊ឹ! សព្វថ្ងៃ មីងកណ្ដោចកណ្ដែងណាស់... បើសិនគ្មាននាងអម្ពរមកនៅកំដរទេនោះ... មីងពិតជាពិបាកធំហើយ...

ស្រាប់តែអ្នកស្រីបើកភ្នែកធំៗហើយសួរនាយថា :

- អូហ៎ ហើយចុះលោកសុនាថគេទៅណាបានជាអោយក្មួយយកកូនសោរ ផ្ទះមកសងមីងអញ្ចឹង?

- គឺ... ខ្ញុំក៏មិនដឹងដែរ... លោកមានការចេញទៅប្រញាប់ពេក ទើបសុបិន មិនហ៊ានសាកសួរ ។

រំពេចនោះ មានពេទ្យនារីមួយរូបចុចកណ្ដឹងចូលមក ។ អ្នកស្រីបូព្រឹក្ស ក៏ងាកទៅប្រាប់សុបិនថា :

- ក្មួយនៅអង្គុយលេងម៉ាភ្លែតសិនទៅ ។ មីងត្រូវអោយពេទ្យពិនិត្យសុខ ភាពម៉ាភ្លែតសិន បន្តិចទៀត មីងមកវិញហើយ ។

ពេទ្យនារីនោះក៏នាំអ្នកស្រីចូលទៅក្នុងបន្ទប់ទៅ ។ សុបិនក៏ដាក់ខ្លួន អង្គុយនៅចាំក្នុងសាលុង ។ នាយយើងក៏ដាក់ភ្នែកមើលការរៀបចំតុបតែង ផ្ទះឃើញថា មានភាពរមនាស្រស់ស្អាតគួរអោយចង់រស់នៅក្រៃលែង ។ លុះនាយដាក់ភ្នែកទៅលើតុមួយក្បែរនោះ ស្រាប់តែប្រទះរូបថតនារីជំទង់ មួយរូបអាយុប្រមាណ១៤-១៥ឆ្នាំឈរញញឹមបញ្ចេញថ្ពាល់ខួចយ៉ាងស្រស់ ចងសក់ទីទុយក្នុងសំលៀកសិស្សសាលាដាក់តាំងនៅលើតុ ។ សុបិនហាក់ដូចជាចាប់អារម្មណ៍នឹងរូបថតមួយនេះណាស់ ។ ម្យ៉ាងទៀតនាយក៏ដូចជា ចាប់ភ្លឹកថា នាយហាក់ដូចជាធ្លាប់បានជួបក្មេងស្រីមួយរូបនេះនៅកន្លែង ណាមួយ តែនាយអង្គុយនឹកមួយស្របក់ទៅហើយ

CHANBOKEO.COM

នៅតែនឹកមិនឃើញថា ខ្លួនធ្លាប់ជួបនាងនៅឯណាឡើយ ។ លុះនាយដាក់ភ្នែកទៅម្ខាងទៀត ស្រាប់តែប្រទះផ្កាកុលាបមួយទងដាក់នៅក្នុងថូ ធ្វើឱ្យសុបិននឹកភ្នកទៅ ដល់ម្ចាស់ផ្កាកុលាប ដែលតែងតែប្តូងកំណាព្យនឹងផ្កាអោយនាយជាញឹក ញាប់ឯភោជនីយដ្ឋានស្នេកមិនយកលុយ ។ ប៉ុន្តែ តាំងពីនាយឈប់ធ្វើការ នៅកន្លែងនោះមក នាយក៏លែងបានទទួលផ្កាទៀតទៅ ។ សុបិនងើបព្រួស យ៉ាងរហ័សដើរទៅមើលផ្កា ក៏ប្រទះនឹងកូនសៀវភៅតូចមួយដែលដាក់ ផ្តេកនៅក្បែរថូផ្កា ។ នាយក៏បំរុងលើកបើកមើលទៅហើយស្រាប់តែ :

- មីងមកវិញហើយក្មួយ! នៅចាំមីងយូរ បែបអផ្សុកហើយយ៉ាង!

សុបិនដាក់សៀវភៅទុកយ៉ាងរហ័ស ហើយក៏បែរញញឹមដាក់អ្នកស្រី បូព្រឹក្ស ដែលត្រូវពេទ្យនារីដាក់រទេះរុញត្រលប់ចូលមកក្នុងបន្ទប់សាលុង វិញ ។ ថៃ្ងដន្យ គេក៏ដល់ម៉ោងត្រូវចូលធ្វើការផង ម្ល៉ោះហើយ គេមិនអាច នៅសំណេះសំណាលយូរ ក៏ជំរាបលាអ្នកស្រីចេញទៅ ។

ថ្ងៃនោះ សុបិនហាក់ដូចជាមានអារម្មណ៏សោប់សល់ចំលែកយ៉ាងណា មិនដឹង ។ នាយអង្គុយមិនសុខ ឈរមិនសុខ ដើរមិនសុខទេ ។ ក្នុងចិត្តនឹក ទៅលំអងស្ទើរតែទ្រហោរយំម្តង១ ណាមួយនឹកឆ្ងល់នឹងម្ចាស់ផ្កាកុលាបនិង ចំណារទាំងឡាយដែលនាងសរសេរមកនាយ ។ តើផ្កាកុលាបដែលនាយ ឃើញនៅផ្ទះអ្នកស្រីបូរព្រឹក្ស និងកុមារីជំទង់នោះ មានទំនាក់ទំនងជាមួយ
ម្ចាស់ផ្កាកុលាបនោះដែរឬទេ?

ភ្លាមនោះ  នាយយើងក៏ស្ទុះបរឡានរឹងសំដៅទៅភោជនីយដ្ឋានស្នេក មិនយកលុយយ៉ាងលឿន ។ លុះនាយចតឡានហើយ ក៏ស្ទុះដើរចូលទៅក្នុង ភោជនីយដ្ឋាន ដើរជុំវិញមួយត្រួសសំលឹងរកមើលក្រែងឃើញមានមនុស្ស ណាដែលមានភិនភាគដូចមនុស្សដែលនៅក្នុងចិត្តរបស់នាយ ។ មួយស្របក់ ក្រោយមក គេក៏ដាក់ខ្លួនអង្គុយចុះនៅតុមួយក្បែរមាត់ផ្លូវចូល ហើយក៏ ហៅអ្នកបំរើអោយយកទឹកក្រូចមួយកែវមកអោយ ។ នាយអង្គុយស្តាប់ ភ្លេងប្រគំមួយបទហើយមួយបទទៀត តែចិត្តនាយនៅតែមិនសប្បាយ ដដែល ។ រំពេចនោះ នាយក៏ដាក់ភ្នែកសំលឹងទៅក្រៅ ស្រាប់តែឃើញ ស្រមោលមនុស្សភ្លិបភ្លែតនៅក្បែរឡានរបស់នាយ ។ សុបិនភ្ញាក់ព្រើតស្ទុះ រឹងទៅ :

- នែ៎... ធ្វើអីនៅឡានខ្ញុំហ្នឹង?

ស្រាប់តែស្រមោលនោះគេចបាត់ទៅ ។ សុបិនរត់រឹងតាមពីក្រោយដែរ តែក៏តាមមិនទាន់សោះ ។ ស្រមោលនោះក៏បាត់ខ្លួនក្នុងស្បែងងិតនោះ ទៅ ។ លុះនាយបែរងាកក្រោយមកវិញ ស្រាប់តែប្រទះឃើញផ្កាកុលាប មួយទងជ្រុះនៅក្បែរទ្វាររថយន្តរបស់នាយ ព្រមទាំងមានកូនចំណារមួយ ចងជាប់នៅកផ្កា ។ សុបិនឱ្យនរើសយកមកអាន មានសេចក្តីយ៉ាងខ្លីថា :

- នឹកណាស់!!...... ផ្កា

CHANBOKEO.COM

សុបិនអានចប់ក៏ជ្រួញចិញ្ចើម ហើយក៏ចាប់ផ្ដើមមានអារម្មណ៍ចំលែក យ៉ាងណាមិនដឹង។ បន្ទិចមក សុបិនក៏លើកផ្កាយកមកកាន់សំលឹងមើល
រួចហើយ ក៏ស្រដីទៅកាន់ផ្កាកុលាបថា :

- បើម្ចាស់ផ្កាជាលំអង បងក៏នឹកអូនដូចគ្នាដែរ... បងចង់ជួបអូនណាស់! តែបើមិនមែនទេ... យើងសូមរាប់គ្នាជាមិត្តចុះណា៎។

ថៃដន្យ សុបិនមិនបានព្រលែងផ្កាចោលទេ គេកាន់ផ្កាចូលទៅក្នុងរថ យន្តហើយក៏បរចេញទៅ។

នៅក្នុងផ្ទះដ៏តូចចង្អៀតរបស់លំអង សុបិនដើរទៅដើរមកតែម្នាក់ឯង មួយស្របក់ក៏នឹកចាប់ភ្នែកចង់ឆែកថតតុថតទូរកមើលអ្វីមួយ។ នាយក៏យក ស្ទុះទៅបើកទូខោអាវ មិនឃើញមានអ្វីទេ ក្រៅពីខោអាវចាស់ៗបួនដប់ បន្លាស់។ បន្ទាប់មកនាយក៏ស្ទុះបើកថតតុ តែមិនឃើញអ្វីដែរក្រៅពីកូន កន្សែងដៃដែលនាយបានប្រទះថ្ងៃមុនម្តងមកហើយ។ បន្តិចមក នាយអូស យកហិបឈើពីខាងក្រោមគ្រែចេញមក។ លុះបើកមើលទៅឃើញផាមួង និងអាវប៉ាក់ពីរបីកំប្លេ ព្រមទាំងកូនសៀវភៅរូបថតមួយ។ នាយយើងក៏ បើកមើលឡើង ស្រាប់តែប្រទះនឹងរូបថតចាស់ៗពណ៌ខ្មៅស របស់បុរស ស្ត្រីមួយគូសមជាប្តីប្រពន្ធនឹងគ្នា។ លុះនាយបើកមើលបន្តបន្ទាប់ទៀត ស្រាប់តែប្រទះរូបកុមារីមួយអាយុប្រហែល៨ឆ្នាំ សើចគ្រហាញ ឈរកាន់ ដៃដូនចាស់។ នាយក៏ឧទានឡើងថា :

- នេះ! ប្រហែលជារូបលំអងនិងជីដូនរបស់នាងហើយ។

លុះបើកមកដល់ទំព័របន្ទាប់ទៀត ស្រាប់តែប្រទះនឹងរូបថតកុមារី ជំទង់មួយរូបអាយុប្រមាណ១៤-១៥ឆ្នាំ ញញឹមយ៉ាងស្រស់បញ្ចេញថ្ពាល់ ខួចស្រាប់តែនាយនឹកភ្នកដល់រូបថតក្មេងស្រីដែលដាក់តាំងនៅផ្ទះរបស់អ្នក ស្រីបូព្រឹក្សតែម្តង។ មែនហើយ កុមារីទាំងពីរនោះមានមុខមាត់ស្រដៀង គ្នាណាស់! តើគេមានទំនាក់ទំនងយ៉ាងណាហ្នឹងគ្នា? ជាបងប្អូនឬជាមនុស្ស តែមួយ? ពេលនោះ សុបិនក៏ទាញរូបថតចេញមក ស្រាប់តែឃើញមាន ចំណារនៅខ្នងរូបថតនោះថា

- នេះគឺ លំអងផ្កាដែលបងរង់ចាំថ្នាក់ថ្នមពេលអូនពេញវ័យ!

នៅខាងក្រោមចំណារ មានស្នាមស៊ីញ៉េខ្សៀកៗថា " សុបិន " ។ បុរស យើងភ្ញាក់ព្រើត... ត្បិតនោះគឺជាហត្ថលេខារបស់នាយទេតើហ៎។ មែន ហើយ! ពេលនេះសុបិនភ្ញាក់ដូចគេចាប់គ្រវែងទំលាក់ទឹកអញ្ចឹង។ តើនាយ មានទំនាក់ទំនងអ្វីដែរជាមួយកុមារីដែលជាម្ចាស់រូបថតនេះ? ហេតុអ្វីក៏ នាយរកនឹកមិនឃើញសោះ ថានាយធ្លាប់ជួបនាងឬស្គាល់នាងនៅឯណា កន្លែងណា។ សុបិនយកដៃល្អិថ្ងាសយ៉ាងយូរ... នៅតែរកចំលើយមិន ឃើញដដែល។ រំពេចនោះ មាណពយើងក៏ប្រទះឃើញស៊ីឌីមួយបន្ទះដែល មានរូបនាយនៅលើក្របខាងក្រៅ។ គេក៏លើកចេញយកមកមើលហើយក៏ ឧទានឡើងថា :

- នេះជាស៊ីឌីអាល់ប៊ុមលើកទីមួយរបស់យើង ដែលចេញផ្សាយកាលពី៦ ឆ្នាំមុននោះតើហ៎!

លុះនាយប្រែប្រអប់ស៊ីឌីមើលខាងខ្នងក៏ប្រទះនឹងចំណារដែលសរសេរ ខ្សៀកៗថា :

-នេះជារង្វាន់អនុស្សាវរីយ៍ពីបងសុបិនចំពោះអូនលំអងផ្កា! ពេលអូនពេញ វ័យកាលណា បងនឹងដណ្តឹងអូនរៀបការជាភរិយាពេញច្បាប់.. សុបិន!

CHANBOKEO.COM

ពេលនេះ បេះដូងរបស់សុបិនកាន់តែញាប់ញ័រឡើងរន្ធត់ឡើង ។ មើល
ចុះ! ស្នាមអក្សរខ្សៀកៗ ហត្ថលេខាខ្សៀកៗទាំងអស់នេះ សុទ្ធតែជាស្នាដៃ របស់នាយទាំងអស់មិនមានក្លែងក្លាយទេ
តែគួរអោយឆ្ងល់ណាស់ ហេតុអ្វី បានជានាយនឹកមិនឃើញសោះអញ្ចឹងថាខ្លួនបានសរសេរពីកាលណា ហើយ លំអងផ្កាជានរណា?
ឬលំអងផ្កា ជា លំអង?... មែនហើយ លំអងផ្កា... លំអងនិងផ្កា... មានន័យថា នារីឈ្មោះផ្កាដែលជាម្ចាស់ផ្កាកុលាប និងនាង
លំអងជាមនុស្សតែមួយ? សុបិននឹកគិតយូរទៅរិតតែរន្ធត់ក្នុងហឫទ័យ ឡើង ងឿងឆ្ងល់ឡើង :

- លំអងផ្កា... តើយើងបានជួបគ្នាពីអង្កាល់? ហេតុអ្វីក៏ខ្ញុំរកនឹកមិនឃើញ សោះអញ្ចឹង? លំអង... កាលណាទៅ ទើបអូនវិលវិញ?
បងចង់អោយអូន វិលមករកបងពេលនេះណាស់ ដើម្បីនឹងមកពន្យល់ប្រាប់បងអំពីអ្វីៗដែល បងបានឃើញនៅថ្ងៃនេះ...

សុបិនក៏ទាញយកកូនសៀវភៅតូចមួយ ចេញមកពីបាតហិបយកមក បើកមើល
ស្រាប់តែឃើញចំណារទំនុកចំរៀងជាច្រើនបទដែលនាយធ្លាប់ ច្រៀង
ថែមទាំងមានកំណាព្យខ្លីៗសរសេរឆ្លើយតបទៅទំនុកចំរៀងទាំង នោះវិញផង ។
ពិតមែនតែអក្សរនោះសរសេររាងតូចបន្តិចទំនងបែបបិះ សន្សំក្រដាសបន្តិចក៏ដោយ ក៏តួអក្សរសរសេរបានស្អាតណាស់ ។ ភ្លាមនោះ
សុបិននឹកភ្ញាកដល់កាតពីរសន្លឹករបស់ផ្កាដែលនាយរក្សាទុកកាលពីថ្ងៃមុន ។
មាណពក៏ស្ទុះទៅទាញយកមកផ្ទៀបគ្នាមើលឃើញតួអក្សរមានរាងរៅដូច គ្នាបេះបិទ ។ សុបិនឃើញហើយក៏ញញឹមឡើង... :

- ការពិត ផ្កាដែលជាម្ចាស់កំណាព្យនោះគឺជាអូនទេឬលំអង?  បានន័យថា
អូនតាមលួចគយគន់មើលសកម្មភាពរបស់បងគ្រប់វេលាអស់រយៈពេលជា យូរមកហើយ... ប៉ុន្តែ
ហេតុអ្វីក៏បងមិនដឹងខ្លួនយ៉ាងនេះ? គឺ... បងពិតជា មនុស្សយ៉ាប់ណាស់... ឬក៏ប្រហែលពីបងមានចិត្តរាយមាយពេកដឹង
បានជាបងភ្លេចខ្លួនមើលរំលងរូបអូន? ហើយបងនិងអូនធ្លាប់ស្គាល់គ្នាពី អង្កាល់? ធ្លាប់សន្យាអ្វីខ្លះជាមួយគ្នា...?

សុបិនផ្ដេកក្បាលលើខ្នើយអោបសៀវភៅចំរៀងរបស់លំអងផ្កា យក ដៃម្ខាងគងថ្ងាស គេងគិតបែរក្រោយទៅអតីតកាលវិញ
ស្រាវជ្រាវថាតើ នាយនិងលំអងផ្កាធ្លាប់មានប្រវត្តិអនុស្សាវរីយ៍អ្វីខ្លះជាមួយគ្នា...

- លំអង!... ការពិតអូនបែកពីបងទៅនៅពេលនេះ គឺមានបំណងចង់ឱ្យ បងស្វែងរកអតីតកាលរបស់បងវិញមែនទេ?
បងមិនចុះចាញ់ទេណាំអូន! បងនឹងរកចំលើយជូនអូនវិញអោយទាល់តែបាន...!!

បន្ទាប់មក គេក៏លើកយកកាតមួយសន្លឹក ដែលនាយបានទទួលជាចុង ក្រោយពីផ្កា ដែលសរសេរថា "នឹកណាស់..."
យកមកកាន់អានដោយទឹក មុខញញឹម រួចហើយក៏ពោលខ្សិបៗទៅកាន់កាតមួយសន្លឹកនោះថា :

- បងក៏នឹកអូនដូចគ្នាដែរណា៎ លំអងកំពូលដួងចិត្តបងអើយ...!!

រួចហើយគេក៏លើកកាតយកមកផ្ដិតលើបបូរមាត់ យ៉ាងថ្នមៗ ដោយ ហឫទ័យសែនរំភើបញាប់ញ័រ ។

នឹក...!

ព្រឹកព្រាងរៀងរះច្បាស់សុរិយា ចិន្តានឹកគួចដល់ស្រីថ្លៃ
តើសុខយ៉ាងណាទៅចរណៃ ចិត្តអើយអាល័យនឹកតែពៅ ។

CHANBOKEO.COM

ថ្ងៃត្រង់សុរិយង្គក្ដៅដូចភ្លើង　　រលឹកស្នេហ៍ឡើងខ្លាំងពេកកូវ
អារម្មណ៍ស្មារតីហោះគួចទៅ　　ឆោមឆ្មៅអូនដឹងទេដឹវ៉ា?
រសៀលសន្ធិយាអស្ដង្គត　　ចិត្តមិនរលត់ពីស្នេហា
នឹកណាស់គ្មានស្បើយល្ហើយឱរា　　ចិន្ដាសោកសៅស្វិតស្រពោន ។
រាត្រីយប់យន់ឈានមកដល់　　បេះដូងខ្វាយខ្វល់នឹកតែអូន
យប់អាធ្រាតជ្រៅស្ងាត់ឈឹងសូន្យ　　រលឹកនឹកផ្ដួនមួយជាដប់ ។
ព្រឹកថ្ងៃល្ងាចយប់នឹកនួនល្អង　　ប្រណម្យបន់ផ្សងពុំមានឈប់
សូមជួបពិសីជាគូគាប់　　ប្រសព្វជីវិតលុះអវសាន ។

៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO . COM

# វគ្គទី៨
# គូស្នេហ៍ភក្តី

សុបិនចតឡាន ហើយចុះដើរសំដៅទៅក្នុងផ្ទះរបស់អ្នកស្រីបូព្រឹក្ស ដែលអង្គុយនៅក្នុងសាលុង ហាក់ដូចជាកំពុងរង់ចាំទទួលបុរសយើង:

- សួស្តីលោកសុបិន!
- បាទជំរាបសួរអ្នកមីង!
- ម៉ោះ! ចូលលេងផ្ទះមីងសិន!
- បាទ!

សុបិនមិនទាន់ដាក់ខ្លួនអង្គុយចុះស្រួលបួលផង អ្នកស្រីបូព្រឹក្សក៏មាន ប្រសាសន៍បន្តទៅទៀតថា :

- លោកក្មួយមកយឺតបន្តិចហើយ ត្បិតនាងអម្ពរទើបតែចេញទៅមុននេះ មិនបានប្រាំនាទីផង។

ឮដូច្នោះ សុបិនសំដែងទឹកមុខហាក់ដូចជាខកចិត្តបន្តិចដែរ ប៉ុន្តែក៏ខំ ញញឹមឡើងវិញមិនអោយអ្នកស្រីចាប់ភ្លឹកឡើយ រួចក៏តបថា :

- គួរអោយស្តាយមែន! យើងទាំងពីរបានឃ្លាងគ្នាច្រើនដងហើយ!

ស្រាប់តែអ្នកស្រីញញឹមហើយតបវិញថា :

- ចង់មករកនាងអម្ពរនៅទីនេះ មិនងាយជួបទេ។ គេមកផ្ទះមើលថៃទាំ មីងប្រហែលពីរបីម៉ោង រួចគេចេញទៅធ្វើការហើយ មានកាលក៏ជ្រុលយប់ ជ្រៅពេក ក៏មិនត្រលប់មកទេ រហូតដល់ព្រឹកព្រហាមឯណោះ។

សុបិនឮដូច្នោះក៏នៅស្ងៀម។ បន្តិចមកនាយក៏សួរបន្ថែមថា :

- តើអ្នកនាងអម្ពរធ្វើការអ្វីដែរទៅអ្នកមីង?
- គឺគេធ្វើការនៅហាងភោជនីយដ្ឋានស្អែកមិនយកលុយ... អូហ៍! ក្រែង លោកក្មួយធ្លាប់ធ្វើការនៅទីនោះដែរ មិនមែនទេហ៍? ហេតុអ្វីក៏មិនដែល បានជួបគ្នាអញ្ចឹង? ឬក៏បានជួបហើយតែមិនស្គាល់គ្នា?

សុបិនភ្ញាក់ព្រើត នឹកក្នុងចិត្តថា :

CHANBOKEO.COM

- ឬក៏អ្នកនាងអម្ពរនោះជាលំអង ហើយលំអងក៏ជាផ្កា? បីនាក់ជាមនុស្ស តែមួយមែនទេដឹង?

ហេតុអ្វីក៏នាងចាំបាច់មានកិរិយាអាថិកំបាំងចំពោះ សុបិនម្លេះ? ចុះបើអម្ពរជាលំអង... ហេតុអ្វី នាងសុខចិត្តទៅរស់នៅយ៉ាង អត្តខាត់ជាមួយដូនចាស់ទៅវិញ? តើដូនចាស់ត្រូវជាអ្វីនឹងម្ចាស់ផ្ទះនេះ?

ឃើញសុបិននៅស្ងៀម១ អ្នកស្រីបូព្រឹក្សក៏មានប្រសាសន៍ថែមទៀត ថា :

- ក្មួយទៅភោជនីយដ្ឋានស្អែកមិនយកលុយទៅ នឹងបានជួបនាងហើយ ។

សុបិនក៏នៅសំណេះសំណាលលេងជាមួយអ្នកស្រីបូព្រឹក្ស មួយស្របក់ ក៏សំពះលាចេញមកវិញ រួចហើយក៏បរឡានតម្រង់ទៅភោជនីយដ្ឋានស្អែក មិនយកលុយ ។ ចៃដន្យ ថ្ងៃនោះ គេមានរៀបចំពិធីជប់លៀងមង្គលមួយ យ៉ាងធំ ម្លោះហើយភោជនីយដ្ឋានត្រូវបិទទ្វារមិនទទួលភ្ញៀវដូចប្រក្រតី ។

សុបិនមិនអាចចូលទៅបានក៏ចតរថយន្តឈប់នៅមួយកន្លែងរួចមកក៏សំកុក លួចមើលទៅភ្ញៀវដែលនៅអង្គុយខាងក្នុងភ្នែក១ សំលឹងរកមើលនារីណា ដែលមានភិនភាគដូចលំអង ។ គួរអោយអាណិតមាណពយើងណាស់! គេខំ អង្គុយរង់ចាំមើលមួយយប់ហើយ តែមិនបានប្រទះនារីណាមួយដែលមាន រាងរៅគួរអោយកត់សំគាល់បានសោះថាជាលំអង ។ មួយស្របក់ធំក្រោយ មក សុបិនក៏នឹកឃើញមធ្យោបាយមួយ ។

នៅក្នុងបន្ទប់ការិយាល័យរបស់លោកយូនិក្ស...

- លោកសុបិនមករកខ្ញុំមានការអ្វីដែរ?

- គឺ... បើខ្ញុំសូមអនុញ្ញាតឡើងច្រៀងជូនភ្ញៀវម៉ាបទពីរក្នុងពិធីជប់លៀង យប់នេះ បានដែរទេ?

- នេះជាពិធីជប់លៀងឯកជន គេមិនបានអញ្ជើញលោកមកច្រៀងផង បើ ខ្ញុំអនុញ្ញាតទៅ ក្រែងខូចកម្មវិធីពិសេសរបស់គេណា៎!

- ខ្ញុំសន្យាថាមិនធ្វើអោយខូចកម្មវិធីអ្វីឡើយ...

- ធ្វើម៉េចអោយខ្ញុំជឿបានទៅ បើកាលមុនលោកធ្លាប់មានកំហុសម្តងរួច ហើយដែលផឹកស្រវឹងឡើងច្រៀងផ្តេសផ្តាសខូចកម្មវិធីរបស់គេអស់នោះ?

- ខ្ញុំបានលះបង់ស្រាយូរហើយ ហើយក៏មិនវិលត្រលប់ទៅរកវាដែរ ។ បើ លោកពិតជាអនុញ្ញាតពិតមែន ខ្ញុំសន្យាថានឹងធ្វើអោយពេលវេលានៅទី នោះប្រកបដោយភាពរីករាយបំផុត ។

លោកយូនិក្សគិតមួយស្របក់ក៏មានប្រសាសន៍ឡើងថា :

- ណ្ហើយចុះ! ដោយយល់មុខលោកដែលធ្លាប់ជាអ្នកចំរៀងយ៉ាងល្បីនៅ ភ្នំពេញយើងនេះ ខ្ញុំអនុញ្ញាតអោយលោកច្រៀងបីបទ..!

ឮហើយ សុបិនត្រេកអរណាស់ ក៏ឱនសំពះអរគុណលោកយូនិក្សទាំង សេចក្តីត្រេកអរ ។

ភ្លេងចាប់ប្រគំយ៉ាងភិរម្យរណ្តំគួរអោយព្រឺព្រួចហប្ញទ័យ... ក្រោមពន្លឺ រស្មីក្រហមច្រើង១លើវេទិកា សុបិនដើរចេញមកក្នុងសំលៀកអ្នកចំរៀង ដែលនាយធ្លាប់តែស្លៀកឡើងឆាកដូចរាល់ដង ។ គេក៏បន្លឺសៀងដ៏ក្រអួន បកស្រាយនូវបទចំរៀងមួយបទដ៏ផ្អែមល្ហែមដោយក្តីសង្ឃឹមក្នុងដួងចិត្តថា ថាម្ចាស់ស្នេហ៍របស់គេនឹងបានស្តាប់ បានឮផ្ទាល់នូវអារម្មណ៍ប្រតិពទ្ធ័របស់ នាយចំពោះនាង :

CHANBOKEO.COM

បេះដូងបងសំរាប់តែអូន

បេះដូងបងមួយកាត់ជូនចរណៃ   ដោយចិត្តភក្តីចំពោះស្នេហា
បេះដូងបងផ្ញើជូនលំអងផ្កា   មួយទងសោភាពំងាដួងចិត្ត ។
បេះដូងបងប្រាប់ឆាប់វិលណាំពៅ បងនឹកនោមឆ្ងៅស្ទើរផុតជីវិត
បេះដូងបងផ្តាំទៅកែវវរមិត្រ   វិលមករួមស្និទ្ធស្នេហ៍ពិតឥតប្រែ ។
បេះដូងបងយំដង្ហោយហៅអូន   ចិន្តាស្រពោនត្បិតបាត់មាសមេ
បេះដូងរណ្តំហៅរកម្ចាស់ស្នេហ៍   កន្លងថ្ងៃខែអូនបាត់សូន្យឈឹង ។
បេះដូងបងចាំចាំលំអងផ្កា   រញ្ជួយឱរានឹកស្រីព្រលឹង
បេះដូងសោកសៅរង់ចាំដំណឹង   ចាំពៅព្រលឹងវិលវិញណាំអូន...

ស្នូរទះដៃកក្រើកលាន់ឮឡើងយ៉ាងខ្ទ័រខ្ទារអស្ចារ្យ ។ សុបិនញញឹមឱន កាយទទួលស្នូរទះដៃទាំងនេត្រារលីងរលោង និងដួងចិត្តញាប់ញ័របំផុតជា លើកដំបូងក្នុងជីវិតរបស់គេ ។ ការពិត នោះមិនមែនដោយសារសេចក្តី ត្រេកអរចំពោះស្នូរទះដៃ និងការហ៊ោរកញ្ច្រៀវរបស់ភ្ញៀវទាំងឡាយនោះ ទេ... គេរលីងរលោងទឹកភ្នែកដោយសារការរំជួលចិត្ត នឹកទៅដល់លំអង ម្ចាស់ដួងចិត្តរបស់គេទេតើហ៎ ។ ភ្ញៀវជាច្រើនបាននាំគ្នាក្រោកឈរ ទះដៃ ម្តងហើយម្តងទៀត សំដែងនូវការពេញចិត្តចំពោះបទចំរៀងអំបាញមិញ នេះណាស់ ។ ភ្លាមនោះ មានភ្ញៀវជាច្រើនបានយកផ្កាមកបំពាក់អោយ បុរសយើងជាកត្តិយស ។ សុបិនឈ្ងោកអោនទទួលពីមួយទៅមួយ តែភ្នែក របស់គេរេរំពៃរកមើលមនុស្សដែលបេះដូងរបស់គេកំពុងហៅរក.. អនិច្ចា! គេមិនបានប្រទះឃើញនារីនោះដូចបំណងរបស់គេឡើយ ។ បន្ទាប់មក... គេក៏ចុះដើរចេញពីវេទិកា បំរុងនឹងសំដៅទៅរថយន្តរបស់គេវិញ ស្រាប់តែ គេក្រលេកឃើញនារីម្នាក់ក្នុងសំលៀកជប់លៀងរាត្រីពណ៌ស៊ីជំពូលើកសក់បួងឡើងលើយ៉ាងស្អាត កំពុងឈរឈ្ងោកមុខ បែរខ្នងមកវេទិកា នៅដៃ នាងមានកាន់ផ្កាកុលាបមួយទង ធ្វើកិរិយារេរា១... ។ នាយមើលមុខធិតា នោះមិនច្បាស់ទេ ត្បិតគេឃើញនាងពីក្រោយខ្នងប៉ុណ្ណោះ ។ សុបិនហាក់ ដូចជានឹកពិភាល់ក្នុងចិត្តណាស់ ក៏ស្ទុះដើររឹងសំដៅទៅនារីនោះភ្លាម ទាំង ចិត្តភ័យអរ១ញាប់ញ័រយ៉ាងណាមិនដឹង ។ គេឃើញមាណវីពាក់អាវវ៉ាលក លើកសក់ឡើង បង្ហាញនូវប្រជ្រុយក្រហមមួយនៅលើកញ្ចឹងក... មែន ហើយ.. ពេលនេះសុបិននឹកឃើញហើយ... គឺគេធ្លាប់បានឃើញនារីម្នាក់ នោះពីមុនមកនៅក្បែរ១វេទិកានេះឯង ហើយគេក៏ធ្លាប់បានគេចមិនព្រម ទទួលកំរងផ្កាពីរូបនាង ។ ម្យ៉ាងទៀត គឺនាងហើយដែលធ្លាប់គប់កំរងផ្កា ចោលនៅលើកំរាលវេទិកាដែរ... ។ ពេលនេះ សុបិនហាក់ដូចជាស្ងួតទឹក មាត់អស់ពីបំពង់កអស់រលីង ។ ឯបេះដូងមាណពវិញក៏រណ្តំញាប់ញ័ររន្ធត់ តែខ្លាំងឡើង១ ។ គេនឹកអាមាសក្នុងចិត្តណាស់ ដែលគេធ្លាប់មាក់ងាយ មិនព្រមទទួលផ្កាពីនារីមួយរូបនេះកាលពីគ្រាមុន ។ ថ្ងៃនេះតើនាងនឹងមាន

CHANBOKEO.COM

ប្រតិកម្មចំពោះរូបគេយ៉ាងណាទៅ? សុបិនដើរទៅដល់ពីក្រោយខ្នងរបស់នាងហើយឈ្ងោកអោនខ្សិបហៅតិចៗក្បែរត្រចៀកនាងថា :

- លំអងផ្កា!

ឮឈ្មោះនាងភ្លាម ធិតាបែរមកយ៉ាងរហ័ស ក៏ប្រទះនឹងសុបិនដែល ឈរចំពីក្រោយ ហើយក៏ភ្ញាក់ស្រលាំងកាំងមួយស្របក់ ទើបបែរគេចមុខ ទៅវិញដោយមិនស្រដីអ្វីតបទៅនាយវិញឡើយ មើលទៅហាក់ដូចជា កំពុងរន្ធត់ចិត្តខ្លាំងណាស់ ។ រីឯសុបិនក៏ឈរធ្វើភាំងដូចគ្នាដែរ ត្បិតគេកំពុង ភ្ញាក់ផ្អើល នឹងរូបសម្ផស្សរបស់ធិតាមួយរូបនោះដែរ ។ នាងស្រស់ស្អាតអ្វី ម្ល៉េះ គួរអោយគយគន់ភ្លន់ភ្លឹកអារម្មណ៍ ។ ប៉ុន្តែ... ថ្វីត្បិតពេលនេះ នារីបាន ផាត់ម្សៅតែងខ្លួនយ៉ាងស្រស់ស្អាត ហើយប្លែកជាងពីមុនឆ្ងាយសែនឆ្ងាយ យ៉ាងណាក៏ដោយ ក៏សុបិននៅចាំបានដែរថាទំរង់មុខមួយនេះ កែវភ្នែកនេះ ហើយ ដែលបានច្របាច់បេះដូងរបស់នាយ អោយធ្លាក់ក្នុងអន្លង់ស្នេហា ដក ចិត្តមិនរួចជាយូរមកហើយ ។ ភ្លាមនោះ មាណវីយើងក៏ឈ្ងោកមុខ បំរុង នឹងបោះជំហានគេចចេញទៅហើយ ស្រាប់តែសុបិនពោលហៅនាងឡើង ដោយសំនៀងញាប់ញ័រថា :

- លំអងផ្កា! បងតាំងចិត្តមកទទួលផ្កាពីអូនហើយ គឺ...ជាផ្កាដែលបេះដូង របស់បងរង់ចាំទទួលដោយសេចក្តីស្រលាញ់ជាទីបំផុត... ពេលនេះ តើអូន យកផ្កាមកបំពាក់លើកទឹកចិត្តបងដែរទេ?

ស្រាប់តែធិតាទុចដំណើរង៉ក់ ងើយមុខបែរមករកនាយភ្លាមរួចសំដែង ទឹកមុខភ្ញាក់ផ្អើល ។ នាងឈ្ងោកមើលទៅផ្កាដែលនាងកំពុងកាន់នៅក្នុងដៃ ហើយបែរសំលឹងទៅសុបិន ហើយឧទានឡើងទាំងទឹកភ្នែករលីងរលោង :

- បងសុបិន...

បានតែពីរម៉ាត់ ធិតាក៏ស្លាក់ពាក្យនិយាយមិនចេញតទៅទៀត ។ បុរស យើងឃើញដូច្នោះ ក៏ស្ទុះទៅជិតនាងហើយស្រវាទងផ្កាពីដៃឆវីកំណាន់ចិត្ត ព្រមទាំងហៅឈ្មោះនាងទាំងរំភើបចិត្តថា :

- លំអងផ្កា... បងយកសន្យារបស់បង កាលពីអតីតកាល មកសងអូន វិញថ្ងៃនេះហើយណា៎!

សុបិនក៏ស្រវាអោយរាងកាយនារីថ្មីបនឹងឱរា យ៉ាងណែន ដោយចិន្តា រំភើបរកថាមិនត្រូវ ។ រីឯលំអងវិញរន្ធត់ក្នុងចិត្តណាស់ កាលបើសុបិនចុះ មកទទួលផ្កាពីដៃនាងជាលើកដំបូង ។ ទឹកភ្នែកពីរតំណក់បានហូរស្រក់ចាក ចុះពីនេត្រាទាំងគូរបស់នារីយើង ដោយក្តីត្រេកអរនិងការរំជើបរំជួលក្នុង ចិត្ត ត្បិតមាណវីយើងមិនដែលនឹកស្មានពីមុនមកទេថា សុបិននឹងផ្តល់ កិត្តិយសដល់នាងនៅចំពោះមុខសាធារណជនបែបនេះឡើយ ។ ពេលនេះ បេះដូងរបស់នាងរណ្តំញាប់ញ័រខុសចង្វាក់ ដោយក្តីសោមនស្សរំភើបឥត ឧបមា ។ ភ្លាមនោះ សុបិនខ្សិបដាក់ត្រចៀករបស់នារីយើង ដោយវាចា យ៉ាងស្រទន់ថា :

- ផ្កាស្នេហ៍របស់អូនបានរោយលំអងសណ្តំដួងចិត្តបងអោយលង់ក្នុងសេចក្តី ស្រលាញ់មួយដែលបងគ្មានថ្ងៃនឹងរើបំរះគេចទៅណាបានឡើយ... លំអង! បងស្រលាញ់អូន អូនបានឮទេ?... បងស្រលាញ់អូន...ស្រលាញ់អូនណាស់ ណា៎ លំអងផ្កាបណ្តូលចិត្តរបស់បង!!

CHANBOKEO.COM

ធិតាឮហើយ រិតតែរំជួលចិត្តឡើង រំភើបចិត្តឡើង រហូតដល់ស្រក់ទឹក ភ្នែកដោយឥតដឹងខ្លួន ។ នាងរង់ចាំវេលានោះជាយូរមកហើយ... រង់ចាំឱ្យ បុរសក្នុងសុបិនរបស់នាងមកពោលពាក្យពេចន៏បែបនេះចំពោះនាង... រង់ចាំជានិច្ច... មិនថាក្តីមានសង្ឃឹមឬគ្មានសង្ឃឹមក្តី ឥលូវ ក្តីស្រម័យរបស់នារី យើងក៏បានមកដល់ចំពោះមុខ... តើនរណាមួយទៅដែលអាចទប់ចិត្តថា មិនរំភើបនោះ...?

វិនាទីដើរទៅមួយៗ យ៉ាងយឺតៗបំផុត ហាក់ដូចជាកំពុងជួយបណ្តែត បណ្តោយអោយគូគាប់ទ្វេហា មានឱកាសសំរាប់ខ្សិបប្រាប់បេះដូងរបស់គេ ទៅវិញទៅមកនូវអារម្មណ៏សំងាត់ទាំងសងខាង ។ ភ្ញៀវទាំងឡាយដែលមានវត្តមាននៅក្បែរៗនោះ ខំលួចមើលភ្លែកៗ ទាំងមុខញញឹមគ្រប់ៗគ្នា ទំនងហាក់ដូចជាកំពុងតែជួយត្រេកអររីករាយចំពោះសេចក្តីសុខរបស់អ្នក ទាំងពីរហើយ ។ បន្តិចមក សុបិនក៏កាន់ដៃធិតាហើយពោលទៅនាងថា :

- ឡើងវេទិកាច្រៀងជាមួយបងមួយបទទេ? បងមានចំរៀងពិសេសមួយ សំរាប់យើងទាំងពីរនាក់ណា៎អូន!!

ធិតាមិនឆ្លើយទេ តែក៏មិនប្រកែកដែរ ។ នាងក៏បណ្តោយអោយសុបិនដឹកដៃនាងឡើងលើវេទិកាតាមសំរួល ។ ទាំងពីរនាក់សំលឹងគ្នាទៅវិញទៅមកឥតពព្រិចឡើយ ទំនងគេកំពុងប្រើអារម្មណ៏សាសងគ្នាជាជំនួសក្តីរំភើប ញាប់ញ័ររបស់គេហើយមើលទៅ ។ ភ្ញៀវទាំងឡាយក៏ផ្តោតភ្នែកទៅលើ អ្នកទាំងពីរដើរសំដៅទៅវេទិកានោះដោយសេចក្តីងឿងឆ្ងល់ ត្បិតគេកំពុងតែចង់តាមដានថាតើកម្មវិធីនារាត្រីនោះ មានអ្វីខ្លះគួរអោយចាប់អារម្មណ៏ ដែរទេ ។ ភ្លាមនោះ សុបិនញញឹមដាក់ធិតាយ៉ាងត្រកាលបំផុត ហើយក៏ ចាប់ផ្តើមបន្លឺសៀងយ៉ាងពិរោះរណ្តំគួរចេតនាក្រៃលែង ក្នុងរង្វង់មនោសញ្ចេតនាមួយដែលគ្មាននរណាអាចយល់ជំរៅបានឡើយ ក្រៅពីម្ចាស់ បេះដូងរបស់គេតែម្នាក់គត់...

គូស្នេហ៏ភក្តី

| | | |
|---|---|---|
| ប. | ពពករសាត់ខ្យល់ផាត់រំភើយ | ចន្ទ័រះឡើងហើយឮដំនភា |
| | បំភ្លឺស្នេហ៏បងនិងពៅពំងា | រាត្រីសន្ទិយាក្បែមក្សាន្តពីរអង្គ ។ |
| ស. | ក្លិនផ្កាក្រអូបជិតជាប់នាសា | ដូចក្លិនស្នេហាថ្លៃថ្លាសុរិយង្គ |
| | សន្សើមរោយស្បៃប្រស់ពរត្រចង់ | ដល់ស្នេហ៏ផូផង់បងនិងធិតា ។ |
| ប. | ទឹកហូររអឺករណ្តំសព្ទ័សៀង | ហាក់បីចំរៀងពរសាធុការ |
| | ដល់គូនៃបនិត្យទាំងទ្វេកាយា | ស្មោះកាយចិន្តាគ្មានថ្ងៃប្រែបាន ។ |
| ស. | ចន្ទ័អើយសូមរះកំដរគូស្នេហ៏ | ខ្យល់អើយបំពេរសំនៀងក្សេមក្សាន្ត |
| ប. | បើចន្ទ័លិចទៅសូមសូរ្យយាងថ្កាន | បំភ្លឺស្នេហ៏បានសុខសាន្តរៀងអើយ ។ |

ស្នូរទេះដៃលាន់កក្រើកសាជាថ្មីយ៉ាងរំពង ។ រំពេចនោះ ស្រាប់តែសុបិនស្រវាអោបកាយរបស់ធិតាយ៉ាងណែនពេញរង្វង់ដៃ នៅក្រោមក្រសែភ្នែក ភ្ញៀវទាំងឡាយដែលកំពុងសំលឹងមកគ្រប់ៗគ្នា រួចហើយគេអោនខ្សិបដាក់

CHANBOKEO.COM

ត្រចៀកធិតាដោយដួងចិត្តរំភើបញាប់ញ័របំផុតថា :

- បងនឹកអូនណាស់លំអង...! នឹករកអ្វីមកប្រៀបស្មើមិនបានទេ!

ឮដូច្នោះ ធិតាក៏ងើបសំលឹងមុខបុរសយើងញញឹមតបវិញទាំងទឹកភ្នែករលីងរលោង ហើយទទួលយកនូវចំហាយកក់ក្ដៅពីរង្វង់ដៃរបស់បុរសយើង ដោយដួងចិត្តរំជើបរំជួល :

- អូនក៏នឹកបងដូចគ្នាដែរ.. បងសុបិន!

ធិតាឆ្លើយតបទៅវិញខ្សិបៗ ។ សុបិនញញឹមយ៉ាងស្រស់កាលបើឮ ដូច្នោះ ។ បន្ទិចមក គេក៏កាន់ដៃធិតារំកិលខ្លួនឈរខិតទៅមុខ ចំកណ្ដាល វេទិកាហើយក៏ចាប់ឃោសនសព្ទឡើងប្រកាសយ៉ាងក្លាហានថា :

- សូមម្ចាស់កម្មវិធីមេត្តាអាធ្យាស្រ័យ ដែលខ្ញុំបាទសុបិនមករំខានអស់ លោកជាភ្ញៀវកិត្តិយសទាំងអស់នារាត្រីនេះ ក៏ប៉ុន្តែខ្ញុំបាទសូមចិត្តខន្តីពីអស់ លោកទាំងអស់ចំនួនពីរនាទី ដើម្បីជំរាបដំណឹងពិសេសជូនលោកជាភ្ញៀវ ទាំងអស់ ហើយខ្ញុំបាទក៏សូមអញ្ជើញអស់លោកទាំងអស់ចូលរួមជាសាក្សី ចំពោះព្រឹត្តការណ៍ថ្ងៃនេះផង ។

ឮដូច្នោះ ភ្ញៀវទាំងអស់ក៏នាំគ្នាអង្គុយស្ងៀមស្ងាត់ឈឹង ហាក់ដូចជា កំពុងតែរង់ចាំសំណូមពររបស់នាយ ថាតើជាអ្វីទៅ ។ ពេលនោះ បុរស យើងក៏បែរមុខមករកធិតាយើង រួចចាប់ដៃស្ដាំរបស់នាងយកមកកាន់ ហើយក៏ស្រដីទៅរកនាងថា :

- លំអងផ្កា! អូនជាបេះដូង... ជាជីវិតរបស់បង! បងស្រលាញ់អូនណាស់!
សូមអូនរៀបការជាភរិយារបស់បងពេញច្បាប់ទៅណា៎អូនណា៎!

ស្រាប់តែធិតាបើកភ្នែកមូលក្រឡង់ សំដែងការភ្ញាក់ផ្អើលក្នុងចិត្ត ។ ភ្ញៀវទាំងឡាយក៏ទះដៃហ៊ោរឡើងជាការលើកទឹកចិត្តចំពោះគូស្នេហ៍ទាំង ទ្វេហា ។ សុបិនមានកំលាំងចិត្តប្រឹស ញញឹមរិតតែស្រស់ឡើង ។  ស្រាប់តែមាណវីបែរជាធ្វើមុខស្លេកស្វាយល្វក រួចដួលប្រួសទៅលើកំរាល ។ សុបិន ឃើញដូច្នោះ
ក៏ស្ទុះរឹងទៅត្រកងនាងឡើងទាំងភ័យស្លន់ស្លោ :

- លំអង! អូនយ៉ាងម៉េចហ្នឹង? លំអង...

មាណពភិតភ័យរន្ធត់ក្នុងចិត្តណាស់ ។ គេក៏លើកបីនាងរត់សំដៅទៅ រថយន្តដឹកនាងចេញទៅមន្ទីរពេទ្យទាំងប្រញាប់ប្រញាល់ក្រោមក្រសែ ភ្នែកជាច្រើនរយពាន់ដែលកំពុងឆ្ងល់ចំពោះឧប្បត្តិហេតុអំបាញមិញនេះ ។

នៅក្នុងបន្ទប់ពិនិត្យជំងឺ...

ឆវីយើងបើកភ្នែកឡើង បែរមើលជុំវិញខ្លួន :

- លំអង! អូនដឹងខ្លួនហើយ? បងត្រេកអរណាស់លំអង!

- បងសុបិន...! (លំអងខ្សិបហៅឈ្មោះមាណពតិចៗ)

សុបិនកាន់ដៃលំអងយ៉ាងណែន :

- សូមអោយអូនឆាប់ជាសះស្បើយណា៎ នឹងអាលត្រលប់ទៅផ្ទះយើងវិញ!

រំពេចនោះ លោកគ្រូពេទ្យក៏ដើរចូលមកដល់ហើយមានប្រសាសន៍ថា:

CHANBOKEO.COM

- អ្នកជំងឺអត់ងងុយច្រើនយប់ហើយ ហើយក៏មិនបានទទួលអាហារគ្រប់ គ្រាន់ ម្ល៉ោះហើយដំណើរឈាមរបស់នាងធ្លាក់ចុះខ្សោយខុសធម្មតា ។ សូម លោកមើលថែរក្សាភរិយាអោយបរិបូណ៌ផងណា៎ កុំអោយមានរោគដូច្នេះ ទៀតក្រែងប៉ះពាល់ដល់សុខភាពទារកដែលនៅក្នុងផ្ទៃរបស់នាង...

- ទារកក្នុងផ្ទៃ?

សុបិនលាន់មាត់ ហើយបើកភ្នែកធំៗសំដែងការភ្ញាក់ផ្អើល ។ លោកគ្រូពេទ្យមានប្រសាសន៍ចប់ ក៏ដើរចេញទៅ ។ សុបិនរន្ធត់ចិត្តផងភ្ញាក់ផ្អើលផង គេស្រវាអោបលំអងយ៉ាងណែនពេញរង្វង់ដៃ... :

- លំអង! អូនកំពុងតែមានផ្ទៃពោះ? កូនរបស់បងមែនទេ?

លំអងនៅស្ងៀមមួយស្របក់ទើបឆ្លើយថា :

- ចុះបងគិតថា គេគួរតែជាកូនរបស់នរណាដែរទៅ?

ភ្លាមនោះ ស្រាប់តែសុបិនយកដៃទប់មាត់លំអងមិនឱ្យស្រដីតទៅ ទៀតឡើយ ហើយក៏ផ្ដេកថ្ពាល់របស់នាយលើផ្ទៃពោះរបស់លំអងបន្តិចៗ បន្ទាប់មក ក៏ស្រដីថា :

- កូនប៉ា! ប្រាប់ម៉ាក់កូនផងណា៎ ថាកុំអោយម៉ាក់កូនគេគេចទៅណាចោល អោយប៉ាខ្វាយខ្វល់ក្នុងអញ្ចឹងទៀត ឮហើយនៅកូន?

រួចហើយគេក៏ឈ្ងោកផ្ដិតនាសាលើថ្ពាល់លំអងដោយថ្នមៗ :

- ឆាប់ជាណា៎ព្រលឹងមាសបង នឹងអាលបានត្រលប់ទៅផ្ទះរបស់យើងវិញ!

សុបិនសំលឹងមើលមុខធិតាដោយចិត្តត្រេកអររីករាយគ្មានព្រំដែន ។

នៅក្នុងលំនៅចាស់របស់គេ... សុបិនអង្គុយបក់អោយធិតាយើងថ្នមៗ អោយនាងផ្ទេចគេងក្សេមក្សាន្ត ។ នេះជាលើកដំបូងក្នុងជីវិតរបស់នាយ ហើយដែលនាយបង្ហាញឥរិយាបថបែបនេះ ។ ពីដើមនាយជាកូនទំរើសផុត លេខហើយក៏ឆ្មើងកន្ទ្រើងផុតលេខដែរ ។ ចៃដន្យអ្វី ថ្ងៃនេះសេចក្ដីស្នេហាបានមកផ្លាស់ប្ដូរចរិតក្បាលខូចរបស់គេអស់រលីងតែម្ដង ។ ពេលនេះ គេនឹក អ្វីមិនឃើញទេ ក្រៅពីដួងចិត្តត្រេកអរចំពោះការវិលត្រលប់របស់ម្ចាស់ដួង ចិត្តរបស់គេតែប៉ុណ្ណោះ ។ ជាពិសេសទៅទៀតនោះគឺ គេមានមោទនភាពអ្វី ម្ល៉េះកាលបើគេបានដឹងថា ខ្លួនគេកំពុងតែជិតក្លាយទៅជាឪពុករបស់ទារកមួយរូបដែលកំពុងដង្ហោយហៅរកពន្លឺថ្ងៃមិនប៉ុន្មានខែខាងមុខនេះ ។

ថ្ងៃមួយ...

នៅលើស្ពានឫស្សី លំអងអង្គុយបេះត្របកផ្កាបោះចូលទៅក្នុងទឹកបឹង ដ៏ថ្លាឆ្វេងតែម្នាក់ឯង ។ សុបិនលួចសំលឹងមើលនាងពីក្រោយយ៉ាងភ្លន់ភ្លឹក អារម្មណ៍ ។ ថ្ងៃនេះ គេមានអារម្មណ៍ថាគេមានសេចក្ដីសុខណាស់កាលបើរូបគេមានលំអងវិលត្រលប់មករួមរស់ជាមួយគេដូចធម្មតាវិញ ។ បន្តិចមក គេក៏ដើរទៅជិតមាណវីហើយដាក់ខ្លួនអង្គុយចុះក្បែរនាង :

CHANBOKEO.COM

- អូនស្រួលខ្លួនវិញហើយឬ លំអង?

- ចាស! (ធិតាតបរិញទាំងញញឹម)

សុបិនក៏ស្រវាទាញលំអងអោយមកគេងកើយភ្លៅរបស់នាយ។ បន្តិច ក្រោយមក មាណពក៏មានវាចាសួរនវីថា :

- លំអង! អោយបងសូមអ្វីមួយពីអូនបានទេ?

- ចាស បងចង់សុំអ្វីទៅ បើមិនច្រើនពេកទេ លំអងជូនបងបានជានិច្ច

- គឺបងចង់សូមថា កុំអោយអូនទៅណាចោលបងទៀត...

- បង... កំពុងមានខ្លួនរឿងអីមែនទេ...?

- គឺ... ប្រហែលមែនទេដឹង...

សុបិនឈ្ងោកមុខមួយសន្ទុះធំទើបពោលបន្តថា :

- កាលពីដើម បងជាមនុស្សប្រុសរាយមាយណាស់...

- មានន័យថា បងកំពុងមានវិប្បដិសារី...

- មែនហើយ... ហើយក៏មានច្រើនទៀតផង! ពីដើម... បងជាមនុស្សដែល រត់គេចមិនទទួលស្គាល់រូបអូន តែក្រោយមកក៏ក្លាយជាមនុស្សដែលរត់ តាមរកអូនគ្រប់ច្រកល្ហកទៅវិញ ប្រហែលជាទេវតាដាក់ទោសបងហើយ ត្បិតបងធ្លាប់សំលឹងមនុស្សត្រឹមតែសំបកក្រៅ ហើយក៏មើលរំលងសេចក្តី ល្អរបស់មនុស្សដែលនៅជុំវិញខ្លួន...

- តែលំអងបានអភ័យទោសឱ្យរួចហើយតើហ៏... បងគិតច្រើនធ្វើអ្វីទៀត?

- តែនៅរឿងមួយដែលបងរកនឹកមិនឃើញ សូម្បីតែខំរកនឹកយ៉ាងណាក៏ ផ្គុំសាច់រឿងមិនចេញដដែល...

- អូហ៏... ហើយចុះ បងខំរកនឹករឿងណាមួយទៅ?

- គឺ រឿងលំអងផ្កានិងកំលោះសុបិននោះអី?

- ព្រះអើយ! ដែលបងហៅខ្ញុំថាលំអងផ្កានោះ មិនមែនមានន័យថាបង ស្គាល់ឬចងចាំអតីតកាលរបស់លំអងឯណា មែនទេ?

- ... គឺបងស្រពេចស្រពិលណាស់អូន...

- បង ពិតជាមិនចាំសន្យារបស់លោកដែលលោកប្រគល់អោយដល់លំអង កាលពី៦ឆ្នាំមុននោះទាល់តែសោះ មែនទេ? (លំអងសួរផ្ទួន១)

- គឺ... អូនជួយនិយាយ បំភ្លឺអោយបងបានខ្លះ១បានទេហ៏?

ស្រាប់តែលំអងជ្រួញចិញ្ចើមហើយរអ៊ូថា :

- តើអោយនារីទុកចិត្តបុរសយ៉ាងណា កាលបើបុរសគេមិនចាំសន្យាដែល គេបានប្រគល់អោយនារីនោះផង? ដូចគ្នានេះដែរ... បងក៏បានផ្ញើសន្យា ថ្មីទៀតថានឹងថែរក្សាលំអងនិងកូន... តើលំអងគួរទុកចិត្តបានដែរឬទេហ្ន៎?

សុបិនញដូច្នោះក៏នៅស្ងៀមមួយស្របក់ក៏ឆ្លើយវិញ :

CHANBOKEO.COM

- ពេលនេះ បងកំពុងរៀនទទួលខុសត្រូវចំពោះជីវិតរបស់បងវិញហើយ! ទុកពេលអោយបងផងណា៎ ហើយសូមអូនជួយធ្វើជាកំលាំងចិត្តនិងជួយដឹក ដៃបងទៅកាន់ភាពត្រឹមត្រូវក្នុងជីវិតផង... បានទេលំអង?

កាលបើឮសំដីទន់ភ្លន់សារភាពកំហុស លំអងក៏ហាក់ដូចជាទន់ចិត្តនឹក អាណិតដល់បុរសយើងតែម្តង។ នាងក៏សួរទៅសុបិនថា :

- ពិតជាចង់ដឹងរឿងលំអងផ្កាមែនហ្អែស?

- បាទ! ចង់ដឹងប្រាកដណាស់!

- អញ្ចឹង ចាំខ្ញុំជំរាបបងចុះ ហើយពេលខ្ញុំនិយាយចំកន្លែងណាដែលបងនឹក ឃើញ សូមជួយបំពេញសាច់រឿងខ្ញុំផង... ណា៎...!

ភ្លាមនោះ សុបិនញញឹមឡើងយ៉ាងបំព្រង...

៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩



CHANBOKEO . COM

# វគ្គទី៩

# ពាក្យសន្យា

តាមដងផ្លូវក្បែរវត្តបាខែង ក្រោមកំដៅសុរិយាយ៉ាងក្តៅពេញអំណាច កុមារីជំទង់មួយរូបកំពុងតែជួយរែកពោតដើរពីក្រោយម្តាយ យកទៅលក់ នៅមាត់ផ្លូវធំដែលមានចរាចរច្រើនគគ្រឹក សង្ឃឹមថានឹងលក់ដាច់បានប្រាក់ កាសលៀងជីវិតដ៏ក្រីក្រ ។ បន្តិចមក នាងនិងម្តាយក៏បានមកដល់តូបស្បូវដំ ចាស់កំព្រូកមួយ ។ បន្ទាប់ពីដាក់អម្រែកចុះហើយ នាងតូចក៏ជួយរៀបចំ បង្កាត់ភ្លើងស្ងោរពោតភ្លាម ។ ក្នុងខណៈដែលនាងកំពុងតែធ្វើការ ស្រាប់តែមានក្មេង៧ភូមិមួយហ្វូងមានប្រុសមានស្រី ដើរចូលមកដល់ ។ ក្មេងស្រី មួយរូបក៏ស្រែកសួរនាងតូចថា :

- អេហ៍ នាងល្អង! ទៅអុំទូកលេងទេហ៍? ពួកយើងគិតថាចង់ទៅអុំទូក ហែលទឹកលេងម្តង ។
- ខ្ញុំមិនទាន់ចង់ទៅទេ នៅជួយម៉ែលក់ពោតសិន ។

ពេលនោះ ក្មេងប្រុសម្នាក់ទៀតស្រដីថា :

- ទៅបបួលស្អីនាងល្អងហ្នឹង? វាមិនចេះហែលទឹកទេ វាចេះតែរែកទឹក ។

នាងក្រមុំតូចញ្ញហើយក៏ឆ្លើយថា :

- អឺ... បើដឹងអញ្ចឹងដែរ កុំហៅយើងទៅហែលទឹកលេងទៀត...
- អឺ ដឹងហើយ... នៅលក់ពោតហ្នឹងហើយ ក្រែងថ្ងៃណាមួយវាកើតអ្នក មានទៅ...

ពួក្មេងភូមិដៀលខ្លួនដូច្នោះ លំអងក៏ខឹងឆេវ :

- មិនត្រឹមតែក្លាយខ្លួនជាអ្នកមានទេ គឺអ្នកមានទាំងឪពុក អ្នកមានទាំង ម្តាយ ចាយហៀរហូរមិនចេះអស់...
- លក់ពោតស្ងោរហ្នឹងឬ ក្លាយជាអ្នកមាន ហាំសហាំ! មើលគេអួតហ្ន៎!
- អឺ... គ្មាននរណាគេទៅដឹងមុនទេ ចាំមើលតែយើងពេញក្រមុំបានប្តីអ្នក មាន ពួកឯងច្បាស់ជាសើចរៀចមាត់ហើយ!!

លំអងឆ្លើយបញ្ចោះដាក់ក្មេងទាំងនោះទៅវិញ ។ តែពួកក្មេងភូមិនៅ តែសើចវ៉ាស៧ដដែល :

- អឺ អោយតែវាពិតទៅចុះ យើងទាំងអស់ចាំតែមើលទេ

ចំលែកណាស់ ក្មេងភូមិចំអកយ៉ាងហ្នឹងទៅហើយ ម្តាយរបស់លំអង នៅតែធ្វើហី៧ដដែល ។ រំពេចនោះ ពួកក្មេងទាំងនោះក៏ដើរចេញទៅ ។ មួយ ភ្លែតក្រោយមក ស្រាប់តែមានរថយន្តថ្មីស្រឡាងមួយ បោះពួយមកពីខាង ណាមិនដឹង

CHANBOKEO.COM

ហោះបុកជាលពោតរបស់លំអងប៉ើងខ្ចាយពោតព្រោងព្រាត ពាសមេឃពាសដីឡើងហុយដីទ្រលោម ។ មិនតែប៉ុណ្ណោះ ជាលធំមួយក៏ ហោះប៉ើងផ្ទប់ស្ត្រីដែលជាម្តាយរបស់នាងលំអង អោយដួលទាំងជំហរ រមៀលធ្លាក់ជំរាលដីបីបួនជុំ រលាត់ដៃជើងអស់ ។ ឯលំអងក៏ប៉ើងទៅម្ខាង ទៀត ។ សំណាងល្អ គ្រានោះ គ្មាននរណារងគ្រោះថ្នាក់ធ្ងន់ធ្ងរទេ ។ រថយន្ត ពណិសក៏ជ្រុលចង្កូតធ្លាក់ស្នាមភ្លោះ ស្ទុះកង់ក្នុងដីទន់ជ្រាយលែងទៅណារួច តែម្តង ។ រំពេចនោះ ក្មេងកំលោះពីររូបដើរចុះចេញពីឡានមក ។ លំអង ក្រោកឈរហើយស្រែកខ្លាំងៗ ទៅកាន់ក្មេងកំលោះទាំងពីរនោះថា :

- បរឡានយ៉ាងណាហ្នឹង បានជាបុកខ្ទេចពោតរបស់ខ្ញុំអស់រលីង?

ស្រាប់តែក្មេងកំលោះម្នាក់ឆ្លើយថា :

- គ្រាន់តែពោតបួនដប់ប៉ុណ្ណឹងមានទៅថ្លៃស្អី? មិនអីទេ ចាំសុបិនសងវិញ! តែនាងត្រូវទៅហៅគ្នីគ្នាពីរបីនាក់អោយមកជួយរុញឡានយើងសិន ទើប យើងចេញប្រាក់អោយ...

- សន្យាហើយធ្វើផងណា៎... លោកសុបិនមិនប៉ិនបើកឡាន...!

ថាហើយ នាងលំអងក៏ស្ទុះទៅជួយលើកម្តាយដែលកំពុងត្រដររងើប តតេះតតះ :

- មានត្រូវត្រង់ណាទេម៉ែ?

ស្ត្រីជាម្តាយគ្រវីក្បាល ។ រំពេចនោះ កំលោះសុបិនច្រត់ចង្កេះមើលមុខ នាងតូច ហើយស្រដីថា :

- ដើ! ល្អិតតែរូប វ៉ាយឫក ហើយសំដីថ្លោសណាស់តើ! តើមីងបានប្រដៅ កូនយ៉ាងណាបានជាគេមិនស្គាល់ចាស់ទុំមនុស្សធំមនុស្សតូចអីដូច្នេះ?

- ម៉ែខ្ញុំថ្លង់តាំងពីកំណើត ស្តាប់មិនឮទេ ( លំអងឆ្លើយ)

- អូហ៏ពុទ្ធោ! ( សុបិនលាន់មាត់)

រំពេចនោះ លំអងក៏ចេញទៅហៅមិត្តភក្តិដែលជាក្មេងភូមិអោយមក ជួយ ។ លុះត្រលប់មកដល់វិញ ស្រាប់តែបាត់រថយន្តនឹងកំលោះទាំងពីរ នោះទៅ ។ លំអងក៏ស្ទុះទៅរកម្តាយហើយសួរថា :

- ឯណាឡានដែលបុកជាលពោតនោះ?

ម្តាយនាងក៏ចង្អុលទៅទិសម្ខាង ។ លំអងក្រលេកទៅឃើញរថយន្ត នោះចេញដំណើរឆ្ងាយលឹមៗទៅហើយ ។ នាងក៏បែរសួរម្តាយថា :

- ហើយចុះគេមានអោយលុយថ្លៃបុកពោតអស់ខ្ទេចខ្ទីរនោះដែរទេ ម៉ែ?

ម្តាយនាងក៏លាតដៃហុចលុយដុល្លារមួយសន្លឹកអោយលំអង ។ តរុណី យើងយកមកលាតមើលឃើញប្រាក់មួយដុល្លារ ក៏លាន់មាត់ថា :

- ព្រះអើយ! មួយដុល្លារប៉ុណ្ណឹងឯង? ម៉េចនឹងរួចថ្លៃខូចខាតរបស់យើង ទៅ?.... នេះហើយឫចរិតពួកអ្នកមាន កេងប្រវញ្ចអ្នកក្រ...!

CHANBOKEO.COM

លំអងនឹកខឹងក្នុងចិត្តណាស់ តែក៏មិនដឹងថាត្រូវធ្វើដូចម្ដេចនឹងទៅ តាមទារសំណងវិញបាន ។ នាងក៏ស្ទុះទៅរើសពោតដែលខ្ចាត់ខ្ចាយយកមក រៀបចំទុកដាក់អោយល្អវិញ ។

រសៀលថ្ងៃជ្រេបន្តិច...

ថ្ងៃនេះ មានអ្នកដំណើរទៅមកច្រើនខុសធម្មតាម្ល៉ោះហើយចរាចរស្ទះ កកកុញ ។ កំពុងតែរែកជាលពោតត្រលប់មកផ្ទះ ស្រាប់តែលំអងដាក់ភ្នែក ក្រលេកឃើញរថយន្តដែលបុកនាងពីថ្ងៃមិញនោះ កំពុងឈប់សំកាំងនៅតាមផ្លូវដោយស្ទះចរាចរ ។ ធិតាក៏ស្រែកខ្លាំងៗហើយស្ទុះរឹងទៅរក :

- អេហ៏នែ៎ លោកសុបិនខ្មោចចិនឆៅ! សងលុយថ្លៃពោតមកយើងភ្លាម!

ជួនអីពេលនេះ យុវជនសុបិនធ្វើដំណើរតែម្នាក់ឯង ។ កាលបើក្រលេកឃើញក្មេងស្រីជំទង់ស្ទុះប្រវាយអួសទាញក្មេងកំលោះ អោយចេញពីឡានអ្នកស្រុកដែលធ្វើដំណើរតាមផ្លូវក៏បែរមើលព្រោងព្រាត ។ លំអងរលាស់ បាតដៃហុចផ្លាញទៅមុខ :

- ឯណាលុយ? លុយណាំថ្លៃពោតស្មោរណាំ!

សុបិនបែរមើលជុំវិញខ្លួនធ្វើអេះអុញហើយក៏ឆ្លើយវិញថា :

- នែ៎ ក្មេងព្រហើន យើងអោយលុយអស់ហើយ ម៉េចមកទារយើងទៀត?

- ម៉ាដុល្លារហ្នឹងហ្អែស តើវាគ្រប់ដែរទេ? នេះមិនទាំងរាប់ទាំងថ្លៃប្រេង កូឡាដែលខ្ញុំត្រូវទិញលាបរបួសអោយម៉ែផង ។

- តែយើងចាយលុយអស់ហើយមិនមានសល់លុយទេថ្ងៃនេះ!

- ធ្វើអ្នកមានជិះឡានរលោងស្រិល អត់លុយផងហ្អែស? យើងចាំតែជឿ អ្នកដល់ហើយតើហ៏! នែ៎.. អោយមក៏ ឆាប់ឡើង ។

ដោយខ្លាចខ្មាសគេដែលត្រូវក្មេងស្រីស្រវាទាញកអាវ អួសពីក្នុងឡាន សុបិនក៏ងើបចេញមកហើយក៏ទាញកាបូបលុយបើកឱ្យមើល ស្រាប់តែធិតា តូចឆក់ខ្ទាច់យកទៅបើកមើលខ្លួនឯង :

- អុញ៎! អត់មានលុយមែន... (លំអងលាន់មាត់) នែ៎ស្ទួរបន្តិចចុះណាំ! ជាប្រុសកំលោះរូបស្អាតយ៉ាងហ្នឹង បរឡានឡូយយ៉ាងហ្នឹង ហើយអត់លុយ ដាក់កាបូបដូច្នេះ វាដូចជាចំលែកណាស់.... ឬក៏ចាញ់អាប៉ោងហ្អែស?

- រឿងយើងទេ កុំចេះ! (សុបិនថាផងស្រវាឆក់កាបូបលុយវិញផង)

- អញ្ចឹងត្រូវគិតមើលសិនថា នាងល្អងត្រូវដកហូតយកអ្វីជំនួសវិញទៅ?

លំអងខាំដៃយរកនឹកមើល ។ រីម្ដាយនាងនៅឈរយាមជាលពោត ធ្វើឡឹងឡង់ត្បិតមិនដឹងថាលំអងកំពុងចង់ធ្វើអ្វី ។ រីឯសុបិនវិញនោះ មិន ដឹងជាយកមុខទៅទុកឯណាទេពេលនេះ ។ មនុស្សម្នាតាមផ្លូវចោមរោម ឈរមើលពាសពេញអស់ទៅហើយ នឹងចង់បរឡានគេចក៏គេចមិនរួចដែរ ត្បិតចរាចរវាំកកកុញដល់ក៏រិតហើយ ។ ភ្លាមនោះ លំអងក៏ឈ្ងោកទៅក្នុងឡានឃើញស៊ីឌីពីរបន្ទះនិងប្រដាប់ចាក់ស៊ីឌីមួយ ក៏អួសយកចេញមក :

- ខ្ញុំថាអានេះមានតម្លៃគ្រប់ល្មមថ្លៃជំងឺចិត្ត!!! អរគុណ! លាហើយណាំ!

- នែ៎ នេះជាស៊ីឌីសំណៅដើមរបស់ខ្ញុំទេ បើនាងយកទៅតើខ្ញុំបានអីយកទៅ ផលិតលក់? នេះជាអាល់ប៊ុមដំបូងរបស់ខ្ញុំផងណាំ!

CHANBOKEO.COM

- អូហ៎ ជាអ្នកចំរៀងផងហ្អែស កំលោះកូនចិនសុបិនកូនចាប? អញ្ចឹង លំអងខ្ចីប្រើម៉ាពេលសិនចុះ ថ្ងៃក្រោយមានលុយចាំយកមកលោះទៅ។

ថាហើយ លំអងក៏ដើរត្រុយចេញទៅធ្វើព្រងើយ។ សុបិនក៏កូកឡើងៈ

- នែ៎ ក្មេងព្រហើន! អោយរបស់យើងមកវិញភ្លាម..

សុបិនហ៊ានត្រឹមតែស្រែកហៅប៉ុណ្ណោះ ត្បិតនាយមិនហ៊ានរត់តាម នាងតូចដោយទុកឡានចោលនៅលើផ្លូវអោយស្នេះចរាចរទេ ក្រែងប៉ូលីស រករឿង ម្ល៉ោះហើយក៏បណ្តោយអោយលំអងដើរកាន់ស៊ីឌីនិងប្រដាប់ ចាក់ស៊ីឌីស្តាប់ វ៉ាយឫកយ៉ាងក្រអឺតដើរចេញទៅ។

- ហ្អេក៎ នែ៎! ហើយចុះផ្ទះរបស់នាងនៅឯណា? (សុបិនស្រែកសួរ)

តែលំអងបែរជាដើរធ្វើមិនឮ ត្បិតចង់សងសឹកបុរសយើង  ដែលបើក ឡានគេចខ្លួនកាលពីថ្ងៃ ដោយមិនព្រមទទួលសងការខូចខាតរបស់នាង។

ស្អែកឡើង...

សុបិនក៏បើកត្រលប់មករកលំអងនៅកន្លែងដដែល តែមិនឃើញនាង ឬម្តាយនាងមកលក់ពោតស្ងោរទេ។ គេនៅរេរាមួយស្របក់ទើបសួរក្មេង ភូមិដែលរត់លេងម្តុំនោះ ស្រាប់តែមានក្មេងម្នាក់ឆ្លើយថា :

- ម៉ែនាងល្អងដេកពេទ្យហើយ ព្រោះអីតាំងពីត្រូវឡានបុកពីម្សិល ឮថា យប់មិញ គាត់មិនស្រួលខ្លាំងណាស់។

ឮដូច្នោះ សុបិនភ្ញាក់ភ័យភើតពោះ :

- ស្លាប់ហើយ! ម្សិលមិញយើងមានបុកចំគាត់ឯណា? ហើយយើងក៏ឃើញ គាត់ដើរបានទៀតផង ម៉េចក៏ក្លាយទៅជាធ្ងន់ធ្ងរបែបនេះ?

បន្តិចមកសុបិនក៏សួររកផ្លូវទៅផ្ទះលំអង។ ក្មេងភូមិចង្អុលប្រាប់ហើយ ក៏នាំគ្នារត់លេងអស់ទៅ។ ដោយហេតុតែភ័យខ្លួនខ្លាំងពេក សុបិនមិនហ៊ាន ទៅជួបនាងលំអងដើម្បីទារយកស៊ីឌីវិញទេ។ ថ្ងៃដន្ទ្យ លុះនាយត្រលប់មក ការិយាល័យរបស់ឪពុកនាយដែលជាម្ចាស់ផលិតកម្ម លោកសោរិនបានស្តី បន្ទោសនាយជាខ្លាំងដែលនាយបានធ្វើអោយបាត់ស៊ីឌី។ លោកក៏ដេញឱ្យ សុបិនតាមរកលំអងយកស៊ីឌីត្រលប់ទៅវិញ ត្បិតនោះជាសំណៅច្បាប់ដើម ដែលត្រូវថតបញ្ចេញលក់ខែនោះ។ សុបិនទាល់ច្រកក៏ចេញទៅរកលំអង វិញ ដោយមាននាំមិត្តភក្តិមួយរូបឈ្មោះភិរម្យទៅជាមួយផង។ គេក៏ពឹង ក្មេងភូមិមួយហ្វូងឱ្យនាំគេមកដល់ផ្ទះឈើតូចមួយសង់ផ្ទាល់ដី។ នៅទីនោះ សុបិនក៏ប្រទះលំអងក្នុងសំលៀកជាសិស្សសាលា នៅអង្គុយត្របោមជង្គង់ នៅមុខផ្ទះធ្វើមុខស្អុយប៉ែ។ ពេលនោះ សុបិននឹកថា បើនាយសំដីធំៗដាក់ នាងនោះ ធិតាច្បាស់ជាមិនព្រមអោយតវ៉ាន់របស់នាយវិញទេ ម្ល៉ោះហើយ ក៏ប្រើមធ្យោបាយត្រជាក់វិញ។ គេក៏ដើរចូលទៅជិតនាងហើយស្រដីថាៈ

- នាងតូច! បងមកសុំស៊ីឌីរបស់បងវិញហើយណា៎...

តែធិតាធ្វើមិនឮ។ សុបិនដាក់ខ្លួនចុះអង្គុយក្បែរនាងហើយប្រឹងពើជា និយាយល្អតទៅទៀត :

CHANBOKEO.COM

- នាងតូច... អោយបងសុំតវ៉ាន់របស់បងវិញមកណា៎!

ភ្លាមនោះ នាងតូចបែរមុខមករកសុបិនហើយសំលក់នាយស្មើរជ្រុះ គ្រាប់ភ្នែក ព្រមទាំងស្រដីថា :

- នៅមានមុខមកទារសំណងនោះទៀត? អ្នកដឹងទេថា ដែលម្ដាយខ្ញុំត្រូវ ឃើខ្លួនដេកពេទ្យឥលូវនេះ គឺដោយសារនរណា? មិនដោយសារតែមនុស្ស បើកបរខ្ជីខ្ជានោះទេហ៎? បើម្ដាយរបស់ខ្ញុំក្លាយជាយ៉ាងណាទៅនោះ អ្នក នឹងត្រូវជំពាក់ជីវិតគាត់ហើយ...

ភ្លាមនោះ សុបិនភ្ញាក់ព្រើតបើកភ្នែកមូលក្រលង់ ។ ភ្លាមនោះ ក្មេង ភូមិម្នាក់ស្រដីថា :

- បើចង់បានរបស់ទៅវិញ បងប្រុសឯងអោយលុយថ្លៃពេទ្យទៅនាងល្អង ទៅ រួចគ្នាហើយ ព្រោះឥលូវវាក្រគ្មានលុយអោយថ្លៃពេទ្យទេ ។

សុបិនក៏ទាញកាបូបប្រាក់ចេញមក យកលុយ១០ម៉ឺនរៀលហុចអោយ ទៅលំអងហើយស្រដីថា :

- ប៉ុណ្ណេះ ល្មមរួចគ្នាហើយណា៎ប្អូនស្រី!

តែកុមារីបែរជាធ្វើមុខក្រញ៉ូវ ស្រវាលុយពីដៃសុបិនហើយឈ្លីបោះ ចោលទៅដីព្រួស :

- ស្មានថាលុយប៉ុណ្ណឹងអាចទិញជីវិតម៉ែខ្ញុំបានហ្អែស?

សុបិនបែរសំលឹងមើលមុខភិរម្យដែលជាមិត្ត ហាក់ដូចជាកំពុងហៅឱ្យ ជួយរកមធ្យោបាយដោះស្រាយរឿងអោយឆាប់ចប់ ។ ភិរម្យឃើញដូច្នោះ ក៏ពោលទៅក្មេងស្រីជំទង់យើងថា :

- ប្អូនស្រី...! ឱ្យយើងសុំស៊ីឌីរបស់យើងសិនមក ត្បិតយើងត្រូវការវាពេល ឥលូវនេះ ។ ចំណែករឿងរបស់ម្ដាយនាង ចាំពួកយើងជួយដោះស្រាយតាម ក្រោយបានទេ?

ស្រាប់តែលំអងឆ្លើយថា :

- មើលទៅស៊ីឌីរបស់អ្នកមានតម្លៃជាជាងជីវិតរបស់ម្ដាយខ្ញុំណាស់ មែន ទេ? មែនទេ?

ឮនាងតូចនិយាយបញ្ចោះដូច្នោះ ភិរម្យក៏បាត់មាត់ឈឹងតែម្ដង ។ ភ្លាម នោះ មានក្មេងភូមិម្នាក់ឧទានឡើង :

- នាងល្អងអើយ កុំវាយឫកពេកមើល៍ ។ លុយ១០ម៉ឺនរៀលគឺច្រើនណាស់ ណា៎ ។ ឯងលក់ពោតម៉ាខែក៏សន្សំមិនបានដប់ម៉ឺនផង ។ ឯងយកលុយហ្នឹង ទៅអោយថ្លៃពេទ្យសិនទៅក្រែងជួយម៉ែឯងបានខ្លះ ។

ស្រាប់តែក្មេងភូមិម្នាក់ទៀតបែរជាពោលចំអកថា :

- នាងល្អងហ្នឹងមានខួរក្បាលតូចល្អិតដូចធូលីអញ្ចឹង វាគិតស្អីចេញ? ឃើញ លុយច្រើនប៉ុណ្ណឹងហើយ វានៅថាតិចទៀត ប្រយត្ន័តែគេដូរចិត្ត ឯងច្បាស់ ជាអត់លុយជួយម៉ែឯងហើយ នាងល្អងធូលី!

ឮគេដៀលនាងដូច្នោះ លំអងក៏ឆ្លើយភ្លាមថា :

- យើងមិនមែនលំអងធូលីទេ ឯងកុំចេះ! តិចយើងអត់មិនបានទៅ

- បើអត់មិនបាន ឯងចង់យ៉ាងម៉េច?

CHANBOKEO.COM

- មានចង់យ៉ាងម៉េច គឺចង់វាយឯងហ្នឹងអី!

ឃើញលំអងយារដៃបំរុងដាក់ក្មេងភូមិនោះ សុបិនក៏ស្ទុះទៅឃាត់...

- នែ៎! ឈប់ៗ! កុំឈ្លោះគ្នាមើល៏។ លំអង! មិត្តរបស់នាងគេមានបំណងល្អ តើ គ្រាន់តែស្រដីមិនពិរោះប៉ុណ្ណឹងឯង។

រួចហើយសុបិនក៏បែរមកខាងក្មេងភូមិវិញហើយស្រដីថា :

- ឈប់មើលងាយនាងតូចទៀតទៅណាំ គេជាមិត្តរបស់យើង។ ជាមិត្តត្រូវ តែរក្សាទឹកចិត្តល្អចំពោះគ្នា
មិនគួរធ្វើបាបអោយធ្លាក់ទឹកចិត្តទេ។

- តែគេគ្រប់គ្នានៅទីនេះ ធ្លាប់ហៅវាថាជាល្អងធូលីម៉ាអាយ៉ូសមកហើយ

- តែឥលូវបងសុំដូរវិញបានទេ... គេមិនមែនជាលំអងធូលីទេ... នាងគឺជា.. គឺ... ជាលំអងផ្កាណាំ...

ឮដូច្នោះ ក្មេងភូមិប្អូនដប់នាក់នោះនាំគ្នាសើចលាន់តែម្តង :

- ហាំហាំ! លំអងផ្កា... គួរអោយអស់សំណើចណាស់!... មុខដូចស្វាឈ្មោះ លំអងផ្កា... ហាស់ហាស់ហា!ៗៗ

ស្រាប់តែលំអងលោតផ្លោតចង្អុលមុខក្មេងទាំងហ្នឹងភ្លាម :

- នែ៎ ឈ្មោះយើងមិនមែនសំរាប់អោយពួកឯងយកមកលេងសើចទេ

រួចហើយនាងក៏បែរមកសុបិនវិញ :

- ថយចេញពីជីវិតរបស់ខ្ញុំទៅបានទេ? តាំងពីយើងជាជួបអ្នកមក ជីវិតពួក
យើងគ្មានសេរីសួស្តីអ្វីបន្តិចទេ! ជីវិតមនុស្សណាំ... មិនមែនជាការលេង សើចរបស់នរណាទេ!

ស្រាប់តែលំអងទ្រហោរយំហ៊ូតែម្តង ព្រោះនឹកអាណិតខ្លួនដែលកំពុង មានទុក្ខកង្វល់...។ សុបិននឹករំជួលចិត្តតែម្តង
ក៏ឈ្ងោកមុខអោនលួងនាង តូចភ្លាម :

- បងសូមទោសណាំ.. ការពិតបងគ្មានចេតនានិយាយអោយគេមើលងាយ នាងតូចទេ... ! ឥលូវនេះ
តើអោយបងធ្វើដូចម្តេចទើបនាងឈប់ខឹងទៅ?

ឮនាយនិយាយមករកនាងដោយវាចាទន់ភ្លន់ ធិតាក៏ជូតទឹកភ្នែកភ្លាម រួចហើយក៏ចង្អុលទៅក្មេងភូមិទាំងនោះ ហើយស្រដីថា :

- ធ្វើយ៉ាងណាអោយក្មេងភូមិទាំងនេះ ឈប់មើលងាយខ្ញុំថាជាល្អងធូលី តទៅទៀតនោះ យើងនឹងចប់រឿង!

សុបិនឮហើយត្រេកអរណាស់ នឹកថារឿងសាំញ៉ាំទាំងនេះ នឹងត្រូវ បញ្ចប់ដោយសំរួល។ គេក៏និយាយទៅក្មេងភូមិទាំងនោះថា
:

- នែ៎ ប្អូនៗ! ប្អូនដឹងទេ នាងតូចខាងនេះ មានឈ្មោះថាលំអងផ្កា

- មុខដូចស្វាទល់ផ្អកអញ្ចឹង ដាក់ឈ្មោះលំអងធូលី វាសមជាង ( ក្មេងភូមិ ម្នាក់ឆ្លើយឡើង )

ឮដូច្នោះ លំអងបើកភ្នែកសំលក់ក្មេងប្រុសជំទង់នោះភ្លាម។ សុបិនក៏ ពោលកាត់មិនអោយឈ្លោះគ្នាទាន់ :

- នរណាថានាងមុខដូចស្វាទល់ផ្អក... នាងតូចស្រស់ស្អាតណាស់  បើគេតុប
តែងខ្លួនបន្តិចទៅ ច្បាស់ជាដូចទេពធិតាមិនខាន ដូច្នោះបងថាឈ្មោះលំអង

CHANBOKEO.COM

ផ្កាទើបសមជាង។

ស្រាប់តែក្មេងភូមិនាំគ្នាសើចគិលមួយសាទៀត :

- ទេពធិតាមុខជ្រួញមិនដែលញញឹមដូច្នេះ តើមានបុរសណាគេស្នេហ៍ទៅ លោកអើយ ហាស់ហា៎ៗ

ក្មេងៗក៏នាំគ្នាសើចលលេងនឹងលំអងកាន់តែខ្លាំង។ ស្រាប់តែលំអង លើកដៃយាររកវាយក្មេងដែលកំពុងសើចនោះភ្លាម។ ឃើញដូច្នោះសុបិនក៏ ចាប់ដៃនាងជាប់ :

- នែ៎! ឈប់មើល៍ កុំវាយគេអីនាងតូច! ប៉ុនច្រលោតយ៉ាងនេះ គេនាំគ្នា លលេងរូបនាងស្លាប់ហើយ មិនរស់មិនរានទេ។

ដើម្បីបញ្ចប់រឿង សុបិនក៏និយាយទៅកាន់ក្មេងទាំងនោះថា :

- អឺអ្នកទាំងអស់គ្នា... ឈប់លលេងនាងទៀតទៅមើល៍

- យើងលលេងជាមួយនាងម៉ាអាយ៉ូសទៅហើយ វាមានថី... គ្រាន់តែមាន មនុស្សមកកាន់ជើងបន្តិចធ្វើឫកឯងគ្រាន់.. ដើ នាងល្អងធូលី មុខដូចស្វាញី អត់មានអ្នកណាចូលដណ្តឹង...

មើលទៅក្មេងប្រុសអស់នោះដូចជាយកឈ្នះយកចាញ់ នឹងលំអងដល់ ហើយគឺគេមិនព្រមឈប់ទាល់តែសោះ។ សុបិនក៏ទាញលំអងមកអោយ ឈរនៅក្បែររូបនាយហើយឆ្លើយធ្វើហីថា :

- ម៉េចក៏ប្អូនៗដឹងកើតថាគេជាស្វាញីគ្មាននរណាចូលដណ្តឹង? នែ៎បងប្រាប់ ទៅចុះណា៎... ម៉ាម៉ាត់ចុងក្រោយ.. គេឈ្មោះលំអងផ្កា គេមានរូបរាងស្អាត បាត មានស្នេហ៍គួរអោយស្រលាញ់ណាស់...

- មុខស្វាហ្នឹងគួរអោយស្រលាញ់? (ក្មេងភូមិនោះសួរ) នរណាគេទៅភ្នែក អន់ម្លេះ មើលមុខស្វាឃើញជាទេពធិតា?

- គឺបងនេះអី (សុបិនឆ្លើយ) បងឃើញនាងមានរូបស្អាតណាស់ ពេញចិត្ត បងតែម្តង ពេលនាងពេញក្រមុំកាលណា បងនឹងចូលដណ្តឹងនាងជាប្រពន្ធ ភ្លាមតែម្តង!

សក្តិសិទ្ធិមែន! គ្រាន់តែនាយនិយាយដូច្នោះភ្លាម ម្នាក់ៗឈរចំហមាត់ ធ្លុង សឹងមិនជឿត្រចៀកខ្លួនឯង។ លំអងបើកភ្នែកធំៗ សំលឹងមើលសុបិន ទាំងភ្ញាក់ផ្អើល។ រំពេចនោះ ក្មេងភូមិម្នាក់ក៏និយាយបញ្ចោះថា :

- ធ្វើម៉េចអោយយើងដឹងបានទៅ ថាបងប្រុសពិតជាស្រលាញ់នាងល្អង មែន? ម៉ាអាគ្រាន់តែនិយាយ... នរណាក៏ធ្វើបានដែរ...

ដោយខ្លាចចាញ់ក្មេងនោះ សុបិនក៏បែរមើលលំអង រួចហើយក៏អោន ថើបថ្ពាល់នាងខ្សឹត ហើយក៏ញញឹមឡើងរួចហើយពោលថា :

- នេះឃើញហើយនៅ? គឺបងស្រលាញ់នាងល្អងមែនណា៎! ពេលនេះនៅ តូចមិនទាន់គិតគូរទេ តែដល់ពេញក្រមុំ បងនឹងវិលមកគិតគូរមិនខាន ចាំ មើលទៅ។

លំអងភ្ញាក់ដូចគេចាប់គ្រវែង កាលបើត្រូវសុបិនចាប់នាងថើបថ្ពាល់ ចំពោះមុខគេឯង។ នាងយកដៃជូតថ្ពាល់ចេញយ៉ាងរហ័សហើយស្ទុះវាយ ខ្នងសុបិនពីរបីដៃផាច់ៗ :

- តែផ្កាស... ឈ្លើយគួរអោយស្អប់បំផុត!

CHANBOKEO.COM

ស្រាប់តែសុបិនចាប់នាងមកឱ្យបដាក់ត្រចៀក :

- នែ៎ នៅអោយស្ងៀមមើល៍..! បងកំពុងតែជួយលើកមុខមាត់នាងតូច ម៉េចក៏បែរជាខឹងដាក់បងទៅវិញ? ខ្លួននាងជាកូនក្មេងដូច្នេះគ្មាននរណាគេ ស្រលាញ់នាងជាសង្សារកើតទេ... ចំមែន!

ឮដូច្នោះ លំអងក៏ឈ្ងោកមុខនៅស្ងៀមវិញ។ ស្រាប់តែក្មេងភូមិស្រែក បន្តទៀតថា :

- ធ្វើម៉េចនឹងយើងជឿបានថា បងប្រុសនិយាយពាក្យពិត? ស្រាប់តែដល់ ពេលនាងលួងវាក្រមុំ បងភ្លេចនាងបាត់ទៅ តើអោយពួកយើងធ្វើម៉េច?

- អឺ! បើដូច្នេះ ចាំយើងសរសេរចារទុកហើយស៊ីញ៉េអោយចុះណា៎! ថ្ងៃ ក្រោយ ប្អូនមកទារបំណុលជំពាក់ពីបងយកម៉ាស្រលាញ់...

- ល្អ! និយាយហើយធ្វើតាមផង ទើបគេហៅថាមនុស្សធំ!

សុបិនញញឹមរកអស់សំណើចកាលបើឮក្មេងភូមិនិយាយដូច្នេះ។ មើល ទៅគេជាក្មេងភូមិសាមញ្ញសោះតែហាក់ដូចជាមានប្រាជ្ញាណាស់ បើសិនជា គេមានឱកាសចូលសាលា មិនដឹងថាមានអនាគតភ្លឺស្វាងយ៉ាងណាទេ ថ្ងៃ ក្រោយ អាចក្លាយជាបុគ្គលដ៏រឹងមាំមួយរបស់ប្រទេសជាតិផងក៏មិនដឹង។ ភ្លាមនោះ ក្មេង៧ស្ទុះចូលទៅក្នុងផ្ទះលំអង រើយកបានកាវ៉ាន់មួយយកន្ទាំង ចេញមក មានរូបថតនាង អីវ៉ាន់ដេរប៉ាក់ ថែមទាំងមានស៊ីជីនិងប្រដាប់ចាក់ស៊ីឌីទៀតផង។ សុបិនឃើញភ្លាមញញឹម នឹកថានឹងបានរបស់ទៅវិញ ថ្ងៃនេះហើយ។ គេក៏ទាញយករូបថតរបស់លំអងមកមើលហើយធ្វើពើជា លាន់មាត់ថា :

- យី! រូបនេះ ស្រស់ស្អាតណាស់! អញ្ចឹងបងសុបិនសូមចារលើខ្នងរូបថត នោះទៅចុះណា៎!

ថាហើយនាយយើងក៏ទាញប៉ាកកាមកចារខ្សៀកខ្វាច់យ៉ាងរហ័សថា :

- នេះគឺ លំអងផ្កាដែលបងរង់ចាំថ្នាក់ថ្នមពេលអូនពេញវ័យ!

រួចហើយក៏ស៊ីញ៉េខ្វាច់ ទើបហុចអោយក្មេងភូមិយកមើល។ លុះឃើញ ដូច្នោះ ក្មេងភូមិនោះក៏ពោលថា :

- ហើយធ្វើម៉េចយើងនឹងមានភស្តុតាងថាអ្នកស៊ីញ៉េនេះមានមុខមាត់យ៉ាង ណានោះ។ ដូច្នេះត្រូវតែស៊ីញ៉េលើក្របស៊ីឌីនេះដែលមានរូបបងប្រុសទុក ជាសាក្សីទើបបាន។

សុបិនក៏ឆ្លើយថា :

- ណ្ហើយចុះ! បើបងស៊ីញ៉េលើស៊ីឌីហើយ ប្អូនអោយស៊ីឌីមកបងវិញទេ? បងសុំតែស៊ីឌីទេ ក្រៅពីនោះ ប្អូនទុកចុះ បងមិនយកវិញទេ។

ក្មេងនោះក៏យកស៊ីឌីចេញមកហុចអោយ :

- ហា៎នេះយកទៅ ហើយកុំភ្លេចស៊ីញ៉េលើក្របផង។

សុបិនទទួលយកស៊ីឌីដាក់ហោប៉ៅភ្លាមហើយក៏ចាប់យកកំរបស៊ីឌីដែល មានរូបនាយនោះមកសរសេរខ្សៀក៧ថា :

CHANBOKEO.COM

-នេះជារង្វាន់អនុស្សាវរីយ៍ពីបងសុបិនចំពោះអូនលំអងផ្កា! ពេលអូនពេញវ័យកាលណា
បងនឹងដណ្ដឹងអូនរៀបការជាភរិយាពេញច្បាប់.. សុបិន!

- ល្អណាស់! (ក្មេងភូមិនោះលាន់មាត់ឡើង) ហ៉ាកនេះ នាងល្អងផ្កា ឆាប់
យកទៅទុកទៅ ។

លំអងក៏ទទួលកន្ទាំងរបស់នាងត្រលប់មកវិញ ។ រំពេចនោះ ស្រាប់តែ
ក្មេងភូមិអេះក្បាល រួចហើយក៏និយាយទៅសុបិនថា :

- អោយពួកយើងសូម១០ម៉ឺនរៀលថែមទៀតបានទេ? បងប្រុសជាអ្នក មាន ចែកលុយអ្នកក្រខ្លះក៏មិនខុសទាស់អ្វីទេ ។

ភ្លាមនោះ សុបិនជ្រួញចិញ្ចើម នឹកក្នុងចិត្ត :

- យី! ពួកអ្នកក្រនេះយ៉ាប់ម្លេះ ដូចឈ្លើងមិនខុស គិតតែពីចង់បានស្រាប់ៗ
ចេះតែពីសូមគេដូច្នេះ តើថ្ងៃណាមានប្រាជ្ញារកលុយដោយកំលាំងខ្លួនឯង?

ដើម្បីអោយឆាប់ចប់រឿង សុបិនក៏លូកលុយ១០ម៉ឺនរៀលថែមទៅ ហុចអោយក្មេងភូមិនោះហើយក៏ដើរចេញទៅ
ដោយមិនទាំងលានរណា មួយម៉ាត់ ត្បិតគេកំពុងធុញក្មេងភូមិដែលកំពុងកៀរគរសុំលុយពីនាយ រួច
ម្យ៉ាងទៀតគេអាល័យតែរីករាយក្នុងចិត្តដោយបានស៊ីឌីត្រលប់មកវិញទើប
ភ្លេចលានាងលំអងដែលកំពុងឈរជូតថ្ពាល់បោសក្លិនច្រមុះដែលសុបិនថាប់ ថើបអំបាញ់មិញគ្រវាត់ចោលតាមខ្យល់នោះផង ។
លុះឃើញសុបិនចេញ ទៅបាត់ ក្មេងភូមិក៏ឈ្ងោករើសលុយ១០ម៉ឺន ដែលលំអងឈ្លីគប់ចោលនោះ យកមកវិញ
ហើយក៏ហូតយកលុយ១០ម៉ឺនដែលសុបិនទើបនឹងអោយ ថែមទៀត ហុចទៅអោយលំអងទាំងអស់ហើយស្រដីថា :

- ណេះ! ទាំងអស់គ្រប់២០ម៉ឺនហើយ ប្រហែលជាគ្រប់ថ្លៃពេទ្យមើលជំងឺ ម៉ែឯងហើយទេដឹង នាងល្អង?

លំអងងើបមើលមុខនាយ ធ្វើស្រលាំងកាំង :

- ឯងអោយលុយមកយើងទាំងអស់នេះហ្អែស?

- អឺ! យើងជាក្មេងភូមិជាមួយគ្នា បើមិនជួយគ្នាទេ តើអោយនរណាគេមក
ជួយយើងទៅ? ម្យ៉ាងទៀត យើងក៏ជួយរកប្ដីអ្នកមានទុកអោយឯងនៅ ពេលឯងធំឡើងពេញក្រមុំរួចហើយ
កុំអោយធំឡើងរស់ខ្សត់វេទនាដូច សព្វថ្ងៃនេះទៀត ។ យើងពិបាកយកទល់ភ្នែក មើលឯងលក់ពោតស្ងោរ
យកលុយទៅរៀនណាស់ ។ បើសិនថ្ងៃក្រោយប្រុសកំលោះម្នាក់នោះគេមិន ធ្វើតាមសន្យាទេ
ទុកឱ្យក្មេងភូមិដូចជាពួកយើងប្រដៅគេជំនួសឯងចុះណ៎ា

- ឯងកុំនិយាយតែផ្ដាសអញ្ចឹង!... កំប្លែងលេងជ្រុលពេកហើយ (លំអង ឆ្លើយវិញ) ឯងមិនឃើញទេ
ប្រុសកំលោះនោះវាថើបថ្ពាល់យើងណ៎ា!

- អឺ! ថើបម៉ាតិចហ្នឹងមានស្អី! អាហ្នឹងគេហៅថើបផ្ដិតអនុស្សាវរីយ៍នោះ អី ហាស់ហា.. នាងល្អងធូលីមុខដូចស្វាញីទល់ផ្អក...
ហាស់ហា! អូហ៍ ច្រលំមាត់... នាងលំអងផ្ការបស់តារាចំរៀងសុបិន... ហាស់ហា!!!ៗ

- ឆ្កួត យ៉ាប់មែន! (លំអងគំហកឱ្យក្មេងភូមិវិញ) តិចវាយងាប់អាលូវ!

- នែ៎ កុំអាល័យតែគិតផ្ដេសផ្ដាសអី! ឆាប់ប្រញាប់ទៅមើលម៉ែឯងនៅឯ ពេទ្យភ្លាមទៅវើយ! តិចគាត់ចាំមើលផ្លូវ...!

ថាហើយក្មេងភូមិរត់ចេញបាត់អស់ទៅ ។ លំអងក៏ប្រញិបប្រញាប់រត់ ទៅរកមើលម្ដាយឯមន្ទីរពេទ្យដែរ ។

និយាយពីសុបិនដែលទើបនឹងដើរចេញពីដីភូមិនាងលំអងមក ភិរម្យ ដែលជាមិត្តរបស់នាយ ក៏លាន់មាត់ឡើងសួរនាយថា :

- សុបិនឯងដឹងខ្លួនទេហ៎ថា កំពុងតែធ្វើអ្វី?

- ឯងចង់មានន័យថាយ៉ាងម៉េច ភិរម្យ?

- គឺអ្វីដែលឯងសន្យាជាមួយក្មេងៗអំបាញមិញនេះនោះអី... ឯងកំពុងតែ

យកកទៅលអន្ទាក់ហើយ ។

- ហ្អឺយ! ទៅគិតច្រើនធ្វើស្អី... ពួកវាក្មេងៗហ្នឹង គ្នាគ្រាន់តែធ្វើកំប្លែង លេងសប្បាយតើហ៎ ។

- កំប្លែងលេងស្អី? ឯងចាប់កូនក្រមុំគេថើបថ្ពាល់ណា៎...

- នែ៎ ឆ្កួត! យើងមិនបានស្រលាញ់នាងទេវ៉ឺយ! នាងហ្នឹងជាកូនក្មេងតើហ៎ អោយទៅឈ្លក់ស្នេហ៍យ៉ាងម៉េចនឹងកើត?

- មិនមែនកូនក្មេងទេណា៎ គេជិតទង់ជិតក្រមុំហើយ ។ គេជាស្រី! ឯងត្រូវតែ ផ្ដល់កត្តិយសឱ្យគេខ្លះផង!

- ចុះវាហួសទៅហើយអោយគ្នាធ្វើម៉េច? អំបាញមិញ គ្នាធ្វើជ្រុលព្រោះតែ ចង់ជួយនាង

កុំអោយក្មេងប្រុសៗក្នុងភូមិវាចំអកឡកឡឺយនាងទេណា៎ ។

- តែ... ឯងមានចាំទេហ៎...? ឯងមិនត្រឹមតែថើបថ្ពាល់កូនក្រមុំគេទេ ថែម

ទាំងស៊ីញ៉េកុងត្រាថានឹងមកដណ្ដឹងគេជាប្រពន្ធពេលគេពេញវ័យទៀតផង!

- គ្នាគ្រាន់តែសរសេរលេងហ្នឹង... ចេះយកជាការកើតដែរ...

- តែឯងស៊ីញ៉េនៅលើសំបកអាល់ប៊ុមស៊ីឌីសំណៅដើមរបស់ឯងណា៎! ឯង ដឹងទេ តើមានភ្ញៀវប៉ុន្មាននាក់ទៅ

ដែលមានកត្តិយសទទួលស៊ីឌីម៉ាស្ទ័រ របស់ផលិតកម្ម? គឺគ្មានទេ! មានតែឯងប៉ុណ្ណោះដែលយក ម៉ាស្ទ័រ ស៊ីញ៉េ ហុចអោយគេផុយៗ ។

នេះវាមិនប្លែកទេ?

សុបិនព្វហើយយកដៃអេះក្បាល ហើយក៏ឆ្លើយថា :

- កុំទៅគិតពិបាកពេកធ្វើអី... គិតងាយៗវិញទៅ ។ មិនយូរប៉ុន្មានក្មេងវា

ភ្លេចយើងបាត់ទៅហើយ ។

មែនហើយ សុបិនមិនដែលនឹកគិតខ្វល់ពីរឿងអ្វីឡើយ ។ ចាប់តាំងពី ថ្ងៃនោះមក នាយក៏ភ្លេចរឿងទាំងនោះអស់រលីង

ព្រោះគេមិនគិតថា គេ នឹងបានជួបធិតាយើងវិញឡើយ ។ នៅឆ្នាំបន្ទាប់មក គេក៏ចេញទៅរៀន បញ្ចប់ការសិក្សាបណ្ដើរ

ចេញច្រៀងដាក់ស៊ីឌី លក់តាមផ្សារបណ្ដើរ ។ ដោយសារឪពុករបស់គេជាម្ចាស់ផលិតកម្មស្រាប់ គេក៏មានឱកាសបាន

ច្រៀងច្រើនបទក្នុងស៊ីឌីនិមួយៗ ។ សំនៀងរបស់គេក៏បានទទួលប្រិយភាព

និងការជ្រោមជ្រែងយ៉ាងខ្លាំងពីសំណាក់អ្នកស្ដាប់ទាំងឡាយ ។ ក្រោយមក

CHANBOKEO.COM

គេក៏បានឡើងចូលកម្មវិធីទូរទស្សន៍ដែលគេត្រូវឡើងបង្ហាញមុខ បង្ហាញ រូបរាងនិងសំនៀងផ្ទាល់ជូនទស្សនិកជនជាអលជ្ជី។ ដោយសារតែការល្បី រន្ទឺកេរ្តិ៍ឈ្មោះនេះហើយដែលនាំអោយសុបិន ក្លាយជាបុរសរើសអើងឆ្មើង កន្ទ្រើងមើលមិនបាន ជាពិសេសបន្ទាប់ពីបាននៅធ្វើការជាសំនៀងតន្រ្តីករ ប្រចាំនៅភោជនីយដ្ឋានស្នេកមិនយកលុយដ៏ល្បីនោះមក ជើងសុបិនក៏លែងដើរជាប់ដីតែម្តង។

៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO . COM

# វគ្គទី១០
# ម្លប់មេត្តា

សុបិនយកដៃបូតច្រមុះខ្លួនឯងហើយលាន់មាត់ថា :

- គិតទៅ បងជាមនុស្សយ៉ាប់ដល់ម្លឹងផងឬលំអង?
- ប្រហែលទេដឹង... (លំអងញញឹម) ដឹងខ្លួនដែរហ៎?

សុបិនយកដៃអេះត្រចៀក ហើយឆ្លើយវិញថា :

- គឺ... កាលហ្នឹងនៅក្មេងៗ ឈាមរាវធ្វើអ្វីមិនសូវគិតឆ្ងាយទេ... តែឥលូវ បងដូរអស់ហើយតើហ៎។
- ធ្វើម៉េចលំអងបានដឹងទៅថា ពេលនេះ បងមានចិត្តនឹងនពិតមែន?
- លំអង បើអូនមិនជឿចិត្តបង អូនយកចាស់ទុំជាសាក្សីក៏បានដែរ។ បង មិនខ្លាចនឹងធ្វើតាមទេ។ អូហ៎ មែនហើយ! ក្រែងអ្នកស្រីបូព្រឹក្សនិងលោក សុនាថត្រូវជាឪពុកម្ដាយរបស់អូន មែនទេ? ហើយចុះរឿងដែលអូន ទាក់ទងនឹងការឃាត់ខ្លួនរបស់លោកប៉ាបង យ៉ាងណាទៅវិញដែរ? គឺបង គិតរឿងនេះ មិនដាច់ស្រេចយូរហើយណា៎...
- បងពិតជាសំរេចចិត្តជាក់លាក់ហើយឬនៅថា បងនឹងរៀបការជាមួយ លំអងតាមច្បាប់ពិតមែន?
- ច្បាស់ហើយ។
- មិនថាលំអងជាមនុស្សក្រីក្រយ៉ាងណាក្ដី...?
- មែន ! បងមិនដូរចិត្តទេ... បងស្រលាញ់អូន មិនមែនទ្រព្យរបស់អូនទេ
- ការពិតនោះគឺ... អូនមិនមែនជាអម្ពរកូនស្រីរបស់លោកសុនាថនិងអ្នក ស្រីបូព្រឹក្សទេ។
- អូហ៎! ហើយចុះការពិតយ៉ាងណាទៅវិញ?
- បងចង់ទៅជួបអ្នកស្រីបូព្រឹក្សទេ?

សុបិនងក់ក្បាល :

- អ្វីដែលទាក់ទងនឹងជីវិតរបស់អូន... បងទទួលបានជានិច្ច។

មួយម៉ោងក្រោយមក អ្នកទាំងពីរក៏បានមកដល់វីឡារបស់អ្នកស្រី បូព្រឹក្ស។ សំណាងល្អ គេក៏បានជួបអ្នកស្រីដូចបំណងរបស់គេ។ គ្រាន់តែ ក្រលេកឃើញលំអង ស្រាប់តែអ្នកស្រីស្រែកហៅភ្លាម :

CHANBOKEO.COM

- អម្ពរ... កូនស្រីម្ដាយ! បាត់រូបកូនពីរបីថ្ងៃ ម៉ាក់នឹកកូនអ្វីម្ល៉េះទេ!

លំអងស្ទុះទៅជិត លំទោនកាយសំពះអ្នកស្រីភ្លាម :

- ជំរាបសួរម៉ាក់!

អ្នកស្រីបូព្រឹក្សក៏ស្រវាអោបនាង ដោយក្ដីរីករាយត្រេកអរជាខ្លាំង ។ សុបិនសំលឹងមើលតាមអ្នកទាំងពីរ ឃើញកិរិយាគេស្រលាញ់គ្នាណាស់ ហើយអ្នកស្រីក៏ហៅលំអងថាអម្ពរជាប់មាត់មិនដាច់ តែគេមិនយល់សោះ ហេតុដូចម្ដេចបានជាលំអងប្រាប់នាយថា នាងមិនមែនជាកូនរបស់អ្នកស្រី ទេវិញ ។ កំពុងតែលង់គិតវែងឆ្ងាយ ស្រាប់តែអ្នកស្រីស្រែកហៅ :

- អឺលោកសុបិន... សុខសប្បាយទេកូន?

- បាទ ជំរាបសួរអ្នកមីង.. ខ្ញុំជានាធម្មតាទេ ។

- ម៉ោះ ចូលមកក្នុងសិនមក៏ កូន!

- បាទ!

សុបិនក៏ជួយរុញរទេះពិការនាំអ្នកស្រីចូលទៅក្នុងផ្ទះ ។ គ្រាន់តែលំអង ដាក់ខ្លួនអង្គុយចុះភ្លាម អ្នកស្រីក៏សួរនាងថា :

- ហើយចុះកូនយ៉ាងណាដែរតលូវនេះ មុខមាត់ដូចជាស្លេកស្លាំងណាស់!

- ខ្ញុំមិនអីទេ ម៉ាក់កុំបារម្ភអី!

- មានផ្ទៃប៉ុន្មានខែហើយកូន? ល្មមឆាប់គិតគូរហើយទេដឹង កុំឱ្យវាហួស ពេលណា៎!

លំអងឈ្ងោកមុខ ចោលកន្ទុយភ្នែកទៅរកសុបិន ។ នាយយើងឮ ដូច្នោះក៏ភ្ញាក់ស្មារតីព្រើត ត្បិតមិននឹកថាអ្នកស្រីដឹងអំពីរឿងនោះដែរ ។ បន្តិចមក នាយក៏លេបទឹកមាត់ផ្ញើមបំពង់ក ហើយក៏ឆ្លើយឡើងថា :

- គឺខ្ញុំចូលខ្លួនមកសុំយោបល់ពីចាស់ទុំហើយ សូមអ្នកមីងមេត្តាជួយណែនាំ ផ្លូវកូនចៅផង ។

អ្នកស្រីញញឹមហើយក៏ឆ្លើយវិញ :

- ចាស់ទុំបានរង់ចាំកូនអោយមកសាកសួរយោបល់តាំងពីយូរមកហើយ ។ ថ្ងៃនេះឃើញកូនមក ម៉ាក់សប្បាយចិត្តណាស់ ជាពិសេសដែលកូនចូលខ្លួន
មកស្ដារកត្តិយសអោយនាងលំអងវិញ ។

ពេលនេះសុបិននឹកចំលែកក្នុងចិត្តទៀតហើយថា ហេតុអ្វីនៅពេលនេះ អ្នកស្រីបែរជាហៅលំអងថា លំអងវិញ ម៉េចមិនហៅអម្ពរដូចមុនទៀត? កំពុងតែនឹកឆ្ងល់ អ្នកស្រីបូព្រឹក្សក៏មានប្រសាសន៏ថា :

- សុបិន! ម៉ាក់មានរឿងមួយចង់ប្រាប់កូនណា៎! មកតាមម៉ាក់មក៏!

សុបិនក៏ដើរតាមអ្នកស្រីដែលបញ្ជាអោយលំអងរុញលោករហូតដល់ បន្ទប់មួយ ។ លុះនាយច្រានទ្វារទៅក៏ប្រទះ បន្ទប់គេងមួយដែលមានរៀប ចំយ៉ាងស្អាតមានរបៀប ។ ការតុបតែងទំនងបន្ទប់នោះទំនងជាសំរាប់ក្មេង ស្រី តែចំលែកណាស់

នៅលើតុ នៅជញ្ជាំង នៅធ្នើត្រង់ណាក៏មានរូបសុបិន ដែរ មិនថាជាក្របសៀវភៅទស្សនាវដ្ដី ជាសំបកស៊ីឌី ឌីវីឌី កាសែត ឬអ្វីៗ ទេ គឺមានរូបនាយតាំងពាសពេញទាំងអស់ ។ កាលបើឃើញសុបិនសំដែង ការភ្ញាក់ផ្អើល អ្នកស្រីបូព្រឹក្សក៏មានប្រសាសន៍ថា :

- កូនប្រហែលជាចង់ដឹងហើយថាម្ចាស់បន្ទប់នេះជានរណាហើយមែនទេ?

សុបិនងក់ក្បាល ឈរស្ងៀមរង់ចាំស្ដាប់ការពណ៌នារបស់អ្នកស្រីអំពី អតីតកាលមួយ...

នៅវត្តបាខែង កាលពី ៥ឆ្នាំមុន...

លំអងដើរអោបផ្កាឈូកមួយបាច់ធំយកទៅថ្វាយព្រះ ស្រាប់តែប្រទះ ឃើញគេកំពុងប្រារព្ធពិធីបុណ្យខួប១០០ថ្ងៃ របស់សពកុមារីជំទង់ម្នាក់ ។ ឆរីក៏រំលែកផ្ការបស់នាងជាពីរបាច់ រួចហើយក៏យកមួយបាច់ទៅចូលបុណ្យ នឹងលោកតាអាចារ្យ :

- លោកតា! ខ្ញុំមានការសោកស្ដាយណាស់ដែលខ្ញុំគ្មានប្រាក់ចូលបុណ្យ តែ ខ្ញុំមានផ្កាឈូកមួយបាច់លោកតាទទួលទេ?

លោកតាអាចារ្យងក់ក្បាល :

- ចៅអើយ! គ្រាន់តែចិត្តចៅមានសទ្ធាចំពោះបុណ្យនោះ ក៏ចៅបានទទួល កុសលដែរណា៎ ។ នុ៎ះ!

អ្នកស្រីមួយរូបដែលកំពុងអង្គុយនៅក្នុងរទេះអ្នក ពិការនោះហើយជាម្ដាយរបស់កុមារីដែលចែកឋានទៅ ។ លោកស្រីឈ្មោះ បូព្រឹក្សជាមនុស្សល្អណាស់ ។ នាងតូចយកផ្កាទៅចូលបុណ្យនឹងលោកស្រី ចុះ លោកនឹងអោយពរចៅមិនខាន ។ នៅតូចប៉ុណ្ណឹង ចេះស្គាល់បុណ្យទាន ទៅអនាគតចៅប្រាកដជានឹងក្លាយជាមនុស្សល្អប្រពៃម្នាក់មិនខាន ។

លំអងក៏កាន់បាច់ផ្កាទៅជូនអ្នកស្រី ដែលកំពុងតែឈ្ងោកមុខសោក សង្រេង :

- អ្នកស្រី! ខ្ញុំមានផ្កាឈូកសុំយកមកចូលបុណ្យ...

អ្នកស្រីក្រលេកឃើញនាងក៏បើកភ្នែកមូលក្រឡង់រួចលាន់មាត់ថា:

- នាងតូច... អម្ពរ?

- ចា៎ស ខ្ញុំមិនមែនឈ្មោះអម្ពរទេ ។ ខ្ញុំគឺលំអង ជាក្មេងនៅភូមិជិតៗនេះ ។

ខ្ញុំបានបេះផ្កាឈូកយកមកថ្វាយព្រះឧទ្ទិសដល់ម៉ែខ្ញុំដែលអនិច្ចកម្មទៅ តែ ដោយខ្ញុំឃើញអ្នកស្រីកំពុងមានទុក្ខ ទើបរំលែកផ្កាឈូកយកមកចូលបុណ្យ

អ្នកស្រីបូព្រឹក្ស សំលឹងធិតាមិនដាក់ភ្នែកសោះ ។ មួយស្របក់មក ទើបលោកទើបលូកដៃទទួលបាច់ផ្កាឈូកពីនាង ។ ភ្លាមនោះ នាងតូចក៏ ស្រដីថែមទៀតថា :

- ការព្រាត់ប្រាសអ្នកដែលយើងស្រលាញ់ ពិតជាធ្វើអោយបេះដូងរបស់ យើងឈឺចាប់ណាស់... អ្នកស្រីព្រាត់កូន ខ្ញុំវិញក៏ព្រាត់ម៉ែដែរ... ចាំខ្ញុំឧទ្ទិស ជូនដល់ព្រលឹងរបស់ម៉ែខ្ញុំ សុំឱ្យគាត់ជួយតាមថែរក្សាកូនរបស់អ្នកស្រីនៅ ឯឋានបរលោកនោះផង ដើម្បីកុំអោយអ្នកស្រីឈប់កើតទុក្ខបារម្ភច្រើន...

ឮនាងតូចស្រដីដូច្នោះ អ្នកស្រីបូព្រឹក្សរិតតែចាប់អារម្មណ៍នឹងធិតា របស់យើងឡើង ។ អ្នកស្រីក៏បែរមកសួរនាងតូចថា :

- នាងតូចឈ្មោះអីដែរ? កូនចៅអ្នកណាគេ?

- ចា៎ស! ខ្ញុំឈ្មោះលំអង ឪពុកស្លាប់ចោលតាំងពីតូច ចំណែកម៉ែវិញទើបតែ ស្លាប់ទៅប្រហែលកាលពីឆ្នាំមុននេះទេ ។

CHANBOKEO.COM

- ហើយចុះនាងតូចសព្វថ្ងៃរស់នៅជាមួយនរណាដែរ?

- នៅជាមួយយាយ អាយុជិតចិតសិបហើយ ហើយគាត់តែងតែមកស្នាក់ ធមិនៅវត្តយើងនេះឯង ។

- ចំលែកណាស់ ហេតុអ្វីក៏នាងមានមុខមាត់ប្រហាក់ប្រហែលនឹងកូនស្រី របស់ខ្ញុំម្ល៉េះ? តើនាងអាចនាំខ្ញុំអោយទៅជួបនឹងជីដូនរបស់នាងបានទេ...

- ចាស់! អញ្ចឹងចាំម៉ាភ្លែត ។ ខ្ញុំយកផ្កាឈូកទៅសំពះចេតិយរបស់ម៉ែខ្ញុំសិន

ថាហើយនាងតូចក៏រត់ចេញទៅបាត់ ។ មួយសន្ទុះធំក្រោយមក នាងក៏ ត្រលប់មកវិញនាំផ្លូវអ្នកស្រីរហូតដល់ផ្ទះ ។ ពេលនោះ ដូនចាស់មួយរូបក៏ ដើរចេញមកក្រៅផ្ទះ ។ អ្នកស្រីបូព្រឹក្សក្រលេកឃើញដូនចាស់កាលណា ក៏លាន់មាត់ឡើងថា :

- យាយចិត្រ!

ដូនចាស់ភ្ញាក់ព្រើតបែរមើល :

- នរណាគេហ្នឹងហ្ន៎ស?

- គឺខ្ញុំណា៎ បូព្រឹក្ស...

- នាងព្រឹក.. ពុទ្ធោ! បែកគ្នាយូរឆ្នាំ ឯងសុខសប្បាយទេ?

ដូនចាស់ក៏ស្ទុះមកទទួល :

- ឮថាឯងទៅរស់នៅឯបរទេសយូរហើយ ហើយមកស្រុកយើងវិញពីកាល ណាមកនេ៎ះ?

- គឺ ខ្ញុំទៅរកស៊ីនៅក្រៅស្រុក កាក់កបទ្រព្យណាស់ តែជីវិតក្រុមគ្រួសារ មិនសប្បាយទេ ។

- ហេតុអ្វីទៅ? លោកសុនាថគេធ្វើបាបឯងមែនទេ?

- ចាំស! មិនមែនទេ... ពេលយើងត្រលប់មកដល់ស្រុកខ្មែរកាលពីបីខែមុន ស្រាប់តែនាងអម្ពរកូនស្រីរបស់ខ្ញុំក៏មានគ្រោះថ្នាក់រថយន្ត ពេលធ្វើដំណើរ ជាមួយខ្ញុំនិងស្វហ្វ័រឡានម្នាក់ ។ ចៃដន្យខ្ញុំមានគ្រោះថ្នាក់ត្រឹមពិការជើង តែនាងតូចវិញ... គេមិនបាន...

និយាយដល់ត្រង់នេះ ស្រាប់តែអ្នកស្រីបូព្រឹក្សស្រក់ទឹកភ្នែកច្រោក ។ ឃើញដូច្នោះ យាយចិត្រក៏ពោលបន្លប់ភ្លាមៈ

- ណ្ហើយចុះ! កុំយំសោកអី.. កាត់ចិត្តទៅណា៎! ចុះឯណាលោកសុនាថ? គេ មិនមកជាមួយទេហ៏?

- លោកសុនាថ មានការនៅកន្លែងបុណ្យទើបមិនបានមកជាមួយ តែខ្ញុំថា បើលោកបានជួបយាយនិងនាងតូចលំអង ប្រហែលជាគាត់សប្បាយចិត្តជា មិនខាន ។

- អឺហ៎ មែនហើយ... យាយភ្លេចអោយឈឹងតែម្តង!

យាយចិត្រយកដៃទះថ្ងាសលាន់មាត់រួច ក៏អូសដៃលំអងមកជិត :

CHANBOKEO.COM

- នេ៎ះ នាងលំអងដែលជាកូនស្រីច្បងរបស់នាងអម្ពរ ជាកូនរបស់នាង ឡង់ទាំងពីរ ។ គួរឱ្យស្តាយ នាងឡង់គ្រុនពោះវៀនស្លាប់ទៅម៉ាឆ្នាំហើយ ។

អ្នកស្រីបូព្រឹក្សយកដៃអង្អែលក្បាលលំអង :

- ដូចគ្នាណាស់ ដូចអម្ពរបេះបិទ ខុសត្រង់នាងមានរាងស្គាំងស្គមជាងបន្តិច

អ្នកស្រីបូព្រឹក្សក៏បែរទៅដូនចាស់ហើយវាចាថា :

- បើខ្ញុំសូមនាងលំអងទៅចិញ្ចឹមម្នាក់ទៀត តើយាយគិតយ៉ាងណាដែរ?

- អត់ទេវ៉ើយ! យើងអោយចៅអម្ពរមួយហើយតើហ៎... ឥលូវអោយមួយ ទៀត តើយើងសល់អី? ឯងមិនឃើញទេហ៎? យើងជរាហើយ... ត្រូវការ ឱ្យនាងល្អងវាបំរើទឹកក្តៅទឹកត្រជាក់ព្រឹកល្ងាចណា៎!

- តែបើនៅជាមួយយាយ នាងមិនបានរៀនសូត្រទេ... បើទៅនៅជាមួយខ្ញុំ ប្រហែលជាបានរៀនខ្លះ ហើយក៏មិនរស់នៅអត្តខាត់បែបនេះផង...

- ហ៊ឹ... បើអោយលំអងទៅ... តើយាយចិត្ររស់នៅជាមួយអ្នកណា?

ឮអ្នកស្រីបូព្រឹក្សបបួលទៅរៀន នាងលំអងក៏ឆ្លើយកាត់រឹងថា :

- លំអងសុំទៅនៅជាមួយអ្នកស្រីពេលថ្ងៃរៀន ហើយសុំមកបំរើយាយនៅ ថ្ងៃអត់រៀនវិញ... អ្នកស្រីសុខចិត្តទេ? លំអងចង់ចូលរៀនណាស់ ពីរឆ្នាំ ទៀតត្រូវប្រលងបាក់ឌុបហើយ ។ លំអងមិនចងធ្វើជាក្មេងល្ងង់ទេ ។

កាលបើឃើញចៅប្រវេប្រវាចង់រៀន យាយចិត្តក៏ដាច់ចិត្តឱ្យលំអង ទៅរស់នៅជាមួយអ្នកស្រីបូព្រឹក្ស ។ លំអងត្រេកអរណាស់ក៏រៀបចំឥវ៉ាន់ ចេញទៅតាមអ្នកស្រីភ្លាម ។

អ្នកស្រីបូព្រឹក្សនាំខ្លួនលំអងមកដល់បន្ទប់មួយ ដែលមានការតុបតែង ដ៏ស្រស់ស្អាត ។ ឃើញហើយ ធិតាពេញចិត្តសព្វយ៉ាងទាំងអស់នៅក្នុងបន្ទប់ នោះ ដែលនាងតូចអម្ពរប្អូនភ្លោះបង្កើតរបស់នាងធ្លាប់រស់នៅ ។ ចំលែក ណាស់ នៅស្ទើរតែគ្រប់កន្លែងក្នុងបន្ទប់ ត្រង់ណាក៏មានតាំងរូបភាពរបស់ កំលោះអ្នកចំរៀងឈ្មោះសុបិនដែរ តាំងពីទស្សនាវដ្តី ស៊ីឌី ឌីវីឌីឡើងទៅ គ្រាន់តែក្រលេកឃើញរូបភាពរបស់កំលោះសុបិនភ្លាម លំអងជ្រួញចិញ្ចើម ឡើង ។ មែនហើយ! រូបភាពរបស់សុបិនរិះតែរលប់បាត់ពីអារម្មណ៍តរុណី ទៅហើយ ឥលូវ ស្រាប់តែគេលេចធ្លោឡើងមកលងអារម្មណ៍របស់នាងសា ជាថ្មីវិញហើយ...

លំអងមិនដែលបានស្តាប់ចំរៀងរបស់សុបិនទេ ពីមុនៗមក ព្រោះនាង ក្រីក្រគ្មានវិទ្យុទូរទស្សន៍នឹងគេ ។ ប៉ុន្តែ ពេលនេះ តាំងពីបានមករស់នៅក្នុង គេហដ្ឋានដ៏ស្កុកស្គម្ភរបស់លោកសុនាថ អ្នកស្រីបូព្រឹក្ស នាងមានអ្វីសព្វ យ៉ាងទាំងអស់ សូម្បីតែសេចក្តីស្រលាញ់និងសេចក្តីសុខ ព្រោះលោកទាំង ពីរមានមេត្តាចំពោះរូបនាងជានិច្ច ។ ពេលនោះហើយដែលលំអងចាប់មាន ឱកាសមើលទូរទស្សន៍រាល់ល្ងាចពេលចេញពីរៀន សំកុកសំលឹងតែនាយ សុបិនហើយឡើងច្រៀងមួយបទហើយមួយបទទៀត ។ សំនៀងរបស់

CHANBOKEO.COM

បុរសយើងពិរោះរណ្តំផ្សំនិងភាពញញឹមនៅលើផ្ទៃមុខរបស់គេ ធ្វើអោយ លំអងលួចរំជួលដួងចិត្តតែម្នាក់ឯង ។ ប៉ុន្តែ គ្មាននរណាដឹងឡើយនូវរឿង អតិតកាលសំងាត់រវាងនាងនិងសុបិននាគ្រាមួយនោះឡើយ ។ ក្រោយមក ធិតាយើងក៏ចាប់រៀនអក្សរភ្លេងហើយរៀននិពន្ធទំនុកច្រៀង ។ លុះឃើញ កូនស្រីស្រវាស្រទេញខាងផ្នែកនិពន្ធបទភ្លេង អ្នកស្រីបូព្រឹក្សក៏ទំនុកបំរុង រូបនាងយ៉ាងហ្មត់ចត់បំផុតណាស់ដែរ ។

លំអងជាក្មេងល្អ ហើយមានអំណោយទានណាស់ ។ នាងក៏គោរពបំរើ អ្នកមានគុណរបស់នាងមិនអោយលោកពិបាកអ្វី ។ នៅរៀងរាល់ថ្ងៃទំនេរ នាងតែងតែត្រលប់មកបំរើជីដូនរបស់នាងជានិច្ចមិនដែលខាន ។ រីឯក្មេង ភូមិពីរនាក់ដែលធ្លាប់ជាមិត្តកំសត់កម្ររបស់នាង ក៏តែងតែមកជួយមើល យាយចិត្រមិនលោះពេលដែរ ។ ថ្វីបើពេលនេះ ពួកគេធំពេញវ័យរៀងៗ ខ្លួនអស់ហើយក៏ដោយ ក៏គេនៅតែបន្តការចំអកចំអន់ដាក់លំអងដដែលមិន ផ្លាស់ប្តូរឡើយ ។

ឆវីយើងទៅរៀនជាប្រក្រតី រហូតដល់បានបញ្ចប់ការហ្វឹកហ្វឺនខាង ផ្នែកគ្រប់គ្រង ។ នាងមានមិត្តស្រីស្និទ្ធស្នាលពីរនាក់គឺនាងកល្យាណនិង កិរិយា ។ ក្រោយពីគេរៀនចប់ កិរិយាបានហៅលំអងចូលទៅធ្វើការនៅឯ ភោជនីយដ្ឋានរបស់លោកប៉ានាង ជាអ្នកចំណាត់ការហ្វឹកហ្វឺនសិន ។ ជួន ពេលជាមួយគ្នានេះដែរ សុបិនក៏ទទួលកុងត្រាជាមួយភោជនីយដ្ឋានថ្មីនេះ ដើម្បីឡើងជាតារាចំរៀងប្រចាំនៅទីនោះតែម្តង ។ ចៃដន្យ សុបិនឆ្មើង រអើងណាស់ ។ គេមិនដែលរាប់អាន និយាយរក ឬសូម្បីតែមើលមុខនរណា ដែលនៅធ្វើការក្នុងភោជនីយដ្ឋាននោះឡើយ ក្រៅពីលោកយូនិក្សជាម្ចាស់ ហាងនិងនាយចំណាត់ការរងប៉ុណ្ណោះ ។ គេប្រកាន់ខ្លួន ហើយរាប់អានជិត ដិតជាមិត្ត ចំពោះតែអ្នកដែលមានរូបរាងលក្ខណៈបែបអភិជនតែម្យ៉ាង ។ រីឯលំអងវិញ រាល់ពេលដែលនាងទៅធ្វើការបំរើនាទីចាត់ការផ្នែកទទួល ភ្ញៀវ ឆវីយើងតែងតែលួចផ្ទៀងត្រចៀកស្តាប់បទចំរៀងទាំងឡាយ ដែលសុបិនឡើងច្រៀងទាំងអំបាលម៉ាននោះណាស់ មានកាលក៏លួចនិពន្ធ បទចំរៀងច្រៀង តបវិញតែម្នាក់ឯងក៏មានដែរ ។

ថ្ងៃមួយ...

លំអងនៅគេងលេងក្នុងបន្ទប់ក្នុងវិឡាលោកសុនាថ កំពុងតែប្រឹងរៀន ច្រៀងបទថ្មីមួយដែលនាងនិពន្ធដោយខ្លួនឯង ស្រាប់តែកិរិយាដើរចូលមក ដល់សើចគ្រហាញដាក់នាង :

- សួស្តីស្រីស្រស់... ធ្វើអីហ្នឹង?

ស្រាប់តែលំអងទាញសៀវភៅយកទៅលាក់ពីក្រោយខ្នង ។ កិរិយាក៏ ស្ទុះកញ្ឆក់បានហើយក៏យកមកអាន :

- បងគឺជាសុបិនរបស់អូន!...

បងគឺជាសុបិនរបស់អូន

រូបបងគឺជាក្តីស្រម័យ　　　　របស់ចរណៃថ្លៃវរមិត្រ
រូបបងគឺជាបំណងពិត　　　　សូមធ្វើជីវិតនិងបេះដូង ។
រូបបងគឺជាព្រេងសុបិន　　　　ឆោមកែវមាសឆ្អិនសូមបួងសួង
រូបបងគឺជាអ្វីទាំងពួង　　　　លោមជីវិតអូនអោយមានន័យ ។

CHANBOKEO.COM

| | |
|---|---|
| រូបបងគឺជាទីពំនាក់ | ដួងចិត្តវរលក្ខណ៍ដ៏ភក្តិ |
| រូបបងគឺជាព្រេងនិស្ស័យ | ទេវតាដឹកដៃអោយជួបគ្នា ។ |
| រូបបងគឺជាមង្គលសុខ | មានព្រះត្រៃមុខម្លប់ល្អជា |
| រូបបងជាឥន្ទពិសូគា | ចាប់ដៃពំងាជាគូអើយ ។ |

ភ្លាមនោះកិរិយាលាន់មាត់ឡើងថា :

- អីយ៉ា! ក្រមុំរូបស្រស់ ឯងលួចស្រលាញ់អ្នកណាគេហ្នឹងហ្ន៎ាស!

ឮដូច្នោះ ស្រាប់តែលំអងឡើងថ្ពាល់ក្រហមមួយរំពេច :

- នែ៎! កុំចេះតែនិយាយផ្តាស! នេះគឺបទចំរៀងដែលខ្ញុំកំពុងនិពន្ធទេ...

- យើ! កុំភូត! សង្ស័យតែឯងលួចស្រលាញ់កំលោះសុបិនអ្នកចំរៀងដ៏ សង្ហាមួយរូបនោះហើយមើលទៅ ។

- អត់ទេ... គ្នាចូលចិត្តតែចំរៀងរបស់គេតើហ៎

- អឺ.. ស្រលាញ់ចំរៀង ស្រលាញ់សំលេង ហើយក៏ស្រលាញ់អ្នកច្រៀងដែរ សង្ស័យណាស់ ព្រោះម៉្ងៃៗ គ្នាឃើញតែឯងលួចមើលគេអត់ឈប់ទេ...

រំពេចនោះ លំអងហាក់ដូចជានឹកអៀនមិត្តស្រីក៏ទាញសៀវភៅមួយ មកបាំងលាក់មុខភ្លាម ។ កិរិយាលលេងមួយស្របក់ក៏លើកសៀវភៅនោះ បើកមើលបន្តទៀត ស្រាប់តែប្រទះនឹងសំបកកំរបស៊ីឌីដែលមានរូបសុបិន ព្រមទាំងមានចំណារអក្សរខ្មៅៗនៅលើនោះផង ។ នាងក៏លើកយកមក អានមានសេចក្តីថា :

-នេះជារង្វាន់អនុស្សាវរីយ៍ពីបងសុបិនចំពោះអូនលំអងផ្កា! ពេលអូនពេញ វ័យកាលណា បងនឹងដណ្តឹងអូនរៀបការជាភរិយាពេញច្បាប់.. សុបិន!

កិរិយាបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល :

- លំអង! នេះកំលោះសុបិនអ្នកចំរៀងដ៏ល្បីនោះគេសរសេរអោយឯងមែន ទេហ៎? មានស៊ីញ៉េផ្ទាល់ដៃផង?

លំអងកញ្ឆក់សៀវភៅចេញពីមុខយ៉ាងរហ័សហើយស្ទុះងើបឡើង :

- នែ៎! មកលួចមើលស្អីផន់ខ្ញុំហ្នឹង?

- បើមិនលួចមើល ធ្វើម៉េចនឹងដឹងរឿងសំងាត់របស់ឯងទៅ? ហើយនេះគេ សន្យាជាមួយឯងតាំងពីអង្កាល់ដែរ? កុំប្រាប់ណា៎ ថាឯងចេះមានសង្សារ តាំងពីមិនទាន់ពេញវ័យ...

លំអងនឹកអៀនខ្មាសក្នុងខ្លួនណាស់ ជាពិសេសពេលនាងនឹកទៅដល់ ពេលដែលនាងត្រូវនាយសុបិនចាប់ថើបថ្ពាល់នាគ្រាមួយនោះ ។ នាងមិន ដឹងជាត្រូវឆ្លើយនឹងកិរិយាយ៉ាងណាក៏ព្រលយពាក្យថា :

- បើឯងចង់ដឹងរឿងយើង ឯងទៅសួរនាយតាវ៉ៅនិងនាយកាសូទៅ ។

CHANBOKEO.COM

- ហើយចុះនាយពីរនាក់ហ្នឹង គេមកចូលរួមដឹងរឿងផ្ទាល់ខ្លួនរបស់ឯងស្អី ដែរ គ្នាដូចជាមិនយល់សោះ!

កិរិយាមានមាត់ជិតឯណាកាលបើបានដឹងរឿងរបស់លំអងភ្លាម ។ ឆវី រូបស្រស់រត់ទៅជំរាបលោកសុនាថ អ្នកស្រីបូព្រឹក្ស ហើយក៏ប្រាប់កល្យាណ រួចក៏ប្រាប់នរណាទាំងឡាយដែលស្គាល់លំអង ធ្វើអោយលំអងយើងសែន ខ្មាស់មិនដឹងជាយកមុខទៅទុកឯណាទេ ។ ដោយសារហេតុនេះហើយ ទើប នាងចូលចិត្តគេចទៅលាក់ខ្លួននៅផ្ទះរបស់ជីដូននាងវិញ ដើម្បីចៀសវាង ពាក្យចំអែចំអន់របស់មិត្តភក្តិ ។ ប៉ុន្តែ គ្មាននរណាគេចិត្តអាក្រក់នឹងនាងទេ វៀរលែងតែកល្យាណទេ ដែលលួចពេញចិត្តសុបិនដែរ ថៃដន្យកល្យាណ ក៏បានជួបនឹងបុរសម្នាក់ទៀត ដែលមានមុខមាត់គ្រាន់បើ វណ្ណៈគ្រាន់បើ ជាងសុបិន ។ នាងក៏សំរេចចិត្តបោះបង់សុបិនវិញទៅ ។ មានតែកិរិយាទេ ដែលមានសន្តានចិត្តនឹងលំអងមិនមានក្នុងក្រៅ ហើយរាប់អានសុបិនតាម ធម្មតាមិនបានគិតអ្វីហួសព្រំដែនឡើយ ។ ម្យ៉ាងទៀត នាងក៏ជ្រោមជ្រែង លំអងអោយជួបនឹងសុបិនណាស់ ប៉ុន្តែមិនបានជោគជ័យម្តងណាដែរ ។

ថ្ងៃមួយ...

កិរិយាបើកទ្វារចូលមកដល់បន្ទប់ធ្វើការរបស់នាង ក្នុងភោជនីយដ្ឋាន ស្រាប់តែប្រទះនឹងលំអងដែលកំពុងអង្គុយជូតទឹកភ្នែក ហើយឃើញ វ៉ែនតាសរបស់លំអងបែកខ្ទាយពេញបន្ទប់ :

- មានរឿងអ្វីហ្នឹង លំអង?

- គឺខ្ញុំ ចង់ក្លាយជាមនុស្សខ្វាក់កុំអោយបានឃើញរូបគេ ហើយចង់ធ្វើជា មនុស្សថ្លង់ ដើម្បីកុំអោយបានឮសំលេងរបស់គេតទៅទៀត...

ឃើញមិត្តយំសសឹកដូច្នោះ កិរិយាក៏អង្គុយចុះក្បែរនាងហើយយកដៃ អង្អែលខ្នងលំអងបន្ថែរៗ :

- ឯងជាមនុស្សដែលមានអារម្មណ៍ត្រជាក់ណាស់ តើមានរឿងហេតុអ្វីទៅ ដែលអាចដុតចិត្តឯងអោយក្លាយជាមនុស្សម៉ូម៉ៅបែបនេះ?

- គឺគេមើលងាយខ្ញុំនោះអី... គេមើលងាយខ្ញុំណាស់!!

- នរណា....?

កិរិយាសំលឹងមុខលំអងមួយស្របក់ក៏ឧទានថា :

- គឺនាយសុបិនអ្នកចំរៀងនោះមែនទេហ៏?

លំអងងក់ក្បាល ។

- គេប្រមាថឯងយ៉ាងម៉េចខ្លះ?

- គេបំបាក់មុខខ្ញុំដោយគេចមិនព្រមទទួលកំរងផ្កាហើយអំបាញ់មិញនេះ

- អូហ៏ គ្រាន់តែប៉ុណ្ណឹងម៉េចចាំបាច់យំ?

- តែគេបានយកកូនកន្សែងដែលគេជូតអាហារគប់ក្បាលរបស់ខ្ញុំទៀតផង

- ពុទ្ធោ! អីដល់ប៉ុណ្ណឹង? ឈ្លើយម្ល៉េះ? មិនអីទេ ចាំគ្នាចាត់ការអោយ!

CHANBOKEO.COM

- ឯងចង់ធ្វើអីគេហ្នឹង?

- ហៅប្រដៅបន្តិចបន្តួច.. ឯងកុំបាច់បារម្ភអីណា៎ ឈប់យំឮហើយនៅ?

បន្តិចក្រោយមក លំអងក៏ចេញមកពីភោជនីយដ្ឋានដើរតម្រង់ទៅផ្ទះ របស់ជីដូននាង ស្រាប់តែប្រទះនឹងក្មេង១បួនប្រាំនាក់កំពុងសំរាតខោអាវ សុបិនរួចហើយក៏សែងនាយទៅទំលាក់នៅច្រាំងទន្លេ ។ នាងក៏ឧទានថា :

- នែ៎ ប្អូន! ឯងធ្វើអីគេហ្នឹង?

- គឺអ្នកនាងកិរិយាផ្តាំអោយពួកយើងជួយអប់រំគាត់នេះបន្តិច...

- ពុទ្ធោ! ( លំអងលាន់មាត់ ) ហេតុអ្វីចាំប្រើដៃជើងធ្ងន់១យ៉ាងនេះ?

កាលពីមួយស្របក់មុននេះ លំអងនឹកខឹងនឹងបុរសម្នាក់នេះណាស់ តែ ដល់ឃើញគេត្រូវក្មេង១វាយសន្លប់បាត់មាត់ដូច្នោះ ធិតាក៏ប្រែជាមានចិត្ត នឹកអាណិតគេទៅវិញ ។ ភ្លាមនោះ ក្មេង១ក៏នាំរត់បាត់អស់ទៅ ។ ទ្រាំមើល នឹងភ្នែកមិនបាន លំអងក៏ទៅខ្ចីរទេះរុញរបស់ហាងមួយ អូសយកមកដល់ មាត់ទន្លេ ហើយក៏គ្រាហ៏សុបិនដាក់ផ្តេកលើរទេះរុញទៅផ្ទះយាយចិត្រ ។ ក្រោយពីសុបិនដឹងខ្លួនមកវិញ ជីដូនរបស់លំអងក៏អោយប្រាក់នាយជិះម៉ូតូ ឌុបត្រលប់ទៅផ្ទះវិញ ។

នៅគ្រាក្រោយ១មក សុបិនមិនដែលចាប់ភ្លឹកថាលំអងជានរណាទេ ត្បិតគេអាល័យភ្លើតភ្លើន នឹងរូបសម្ផស្សរបស់នារីពីររូបទៀត គឺកល្យាណ និងកិរិយា ម្យ៉ាងមកពីគេពីរនាក់នោះជាបុត្រីអភិជនផង រហូតថ្ងៃមួយ ដែលកល្យាណគេបែកចិត្តទៅ ទើបសុបិនក្លាយជាបុរសដំបៅដួងចិត្ត ត្រូវ ការឱសថព្យាបាលបេះដូង ។ ពេលនោះហើយដែលគេប្រែចិត្តបែរមើល មនុស្សម្នាក់ដែលតែងតែយកចិត្តទុកដាក់ចំពោះគេបំផុត ជាពិសេសនៅ ពេលដែលគេកំពុងអណ្តែតតែលតោលនៅក្នុងពិភពស្នេហ៍ឥតលំនឹង ។

រីកិរិយាវិញនៅតែរាប់អានសុបិនធ្វើធម្មតាដដែល ទោះបីជានាងមិន ចូលចិត្តចរិតឆ្មើងកន្ទ្រើងរបស់នាយក៏ដោយ ព្រោះកិរិយាតែងតែទុកមុខ មាត់អោយលំអងដែលជាមិត្តសំលាញ់ចិត្តជានិច្ច ។ ដោយហេតុកិរិយា ឃើញលំអងកំពុងតែលង់ក្នុងសេចក្តីស្នេហាចំពោះសុបិនខ្លាំងពេក នាងក៏ យករឿងទៅពិគ្រោះនឹងលោកសុនាថ អ្នកស្រីបុប្ផាព្រឹក្ស ដើម្បីរកផ្លូវដោះ ស្រាយខ្លាចលំអងត្រូវសុបិនឆបោកលេងសើចសប្បាយ ។ ចៃដន្យ អ្នកស្រី លីដាដែលជាភរិយាថ្មីរបស់លោកសេរិន នោះគឺមិនមែននរណាក្រៅពីប្អូន ស្រីបង្កើតរបស់អ្នកស្រីបុប្ផាព្រឹក្សដែរ ។ កាលបើដឹងរឿងរបស់សុបិននិង លំអង ចាស់ទុំទាំងបួននាក់ក៏រៀបគំរោងពិធីផ្សេង១ ដើម្បីណែនាំលំអងនិង សុបិនអោយជួបគ្នាជាផ្លូវការ ។

នៅក្នុងបន្ទប់របស់លំអង...

- អត់ទេ កិរិយា! ខ្ញុំមិនចង់អោយគេឃើញមុខខ្ញុំទេ ( លំអងនិយាយ )

- ឯងស៊ូរស់នៅជាមនុស្សអាថិកំបាំងចំពោះគេដូច្នោះតទៅម៉េចនឹងកើត?

- តែគេមិនដែលចូលចិត្តឃើញមុខពិតរបស់ខ្ញុំទេ... ឯងមានឃើញទេ?

CHANBOKEO.COM

រាល់ដងដែលខ្ញុំបង្ហាញមុខពិតរបស់ខ្ញុំនៅចំពោះមុខគេ គេមិនខ្ចីមើលមុខ មិនខ្ចីទទួលផ្កា មិនខ្ចីនឹកចង់រាក់ទាក់ជាមិត្តម្តងណាឡើយ ។

- អញ្ចឹងឯងចង់ធ្វើយ៉ាងម៉េចវិញ?

- ចង់អោយគេស្រលាញ់ខ្ញុំ ព្រោះតែភាពអាថិកំបាំងដែលធ្វើអោយគេឆ្ងល់ នឹងរូបខ្ញុំរហូត... បើគេពិតជាចាប់អារម្មណ៍លើរូបខ្ញុំដោយសារអ្វីៗដែលមិន មែនជារូបសម្ផស្ស នោះខ្ញុំជឿថា ស្នេហាពិតនឹងចាប់ផ្តើមមានពន្លកហើយ..

- ឯងហ៊ានផ្សងដល់ម្លឹង?

- បើសិនសន្តានចិត្តនិងអំពើល្អរបស់ខ្ញុំ មិនអាចទិញយកសេចក្តីស្រលាញ់ពី បេះដូងរបស់គេបាន លំអងក៏លែងប្រាថ្នាផ្ញើចិត្តផ្ញើប្រាណលើគេទៀតដែរ...

- អោយតែឯងនិយាយពិតចុះ... គ្នាខ្លាចតែឯងត្រូវជូតទឹកភ្នែកម្នាក់ឯង ឯណោះទៅវិញទេ...

ពេលនោះ ហើយដែលអ្នកស្រីលីដានិងកិរិយា បញ្ចេញរូបពិតដ៏សែន ស្រស់ស្អាតរបស់លំអងនិងសំនៀងដ៏ពិរោះរបស់នាង នៅក្នុងពិធីជប់លៀង នៅភូមិគ្រិះរបស់លោកសៅរិន ដើម្បីប្រកួតនឹងលំអងដ៏ក្រីក្រហើយមាន ជីវិតដ៏អាថិកំបាំង ។ បន្ទាប់មក សុបិនក៏ត្រូវវង្វេងនឹងស្រមោលមនុស្សពីរ នាក់ដែលកំពុងប្រជែងគ្នាទាំងសងខាង ដើម្បីតាមដណ្តើមបេះដូងមាណព យើង ។

៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩

CHANBOKEO.COM

# វគ្គទី១១
# ល្បិចជើងចាស់

សុបិនអង្គុយត្រដុសដៃនៅក្នុងសាលុង សំដែងការខ្មាសអៀនក្នុងចិត្ត ចំពោះចរិតរបស់នាយពីអតីតកាល។ នាយយើងឈ្ងោកមុខនៅស្ងៀមមិន ស្រដីអ្វីឡើយក្រោយពីបានស្តាប់រឿងដែលអ្នកស្រីនិទានទាំងអំបាលម៉ាន។ លំអងឃើញនាយហាក់ដូចជាបាក់កំលាំងចិត្ត ក៏ស្រវាកាន់ដៃមាណពយ៉ាង ណែនហើយវាចាសួរថា :

- បងសុបិន... កំពុងគិតរឿងអីហ្នឹង?
- បងមានវិប្បដិសារី... នឹកអាមាសនឹងអត្តចរិតមិនបានការរបស់បង...
- ទៅគិតធ្វើអ្វី... រឿងហួសទៅហើយអោយវាហួសទៅ... យើងមកគិត រឿងអនាគតរបស់យើងវិញប្រសើរជាង មែនទេបង?

ឮដូច្នោះ សុបិនក៏ញញឹមឡើង។ បន្តិចមក នាយក៏ស្ទុះទៅក្រាបសំពះ អ្នកស្រីបូព្រឹក្ស :

- សូមអ្នកម្តាយអភ័យទោសអោយកូនផង ចំពោះអ្វីដែលកូនបានធ្វើខុស ចំពោះអូនលំអងកន្លងមក។

អ្នកស្រីបូព្រឹក្សញញឹមហើយយកដៃបបោសក្បាលកូនប្រុស :

- ម៉ាក់មិនដែលប្រកាន់ខឹងនឹងកូនទេណាំសុបិន មិនខុសអីពីលំអងទេដែល អភ័យទោសអោយកូនជានិច្ច មិនថាពេលណា... នោះហើយជាសេចក្តី ស្រលាញ់ដ៏ពិតប្រាកដណាំកូន។

សុបិនឮហើយក៏រលីងរលោងទឹកភ្នែកសាជាថ្មី :

- ព្រោះតែហេតុហ្នឹងហើយទើបកូនរិតតែខ្មាសខ្លួនខ្លាំងឡើងនោះអី!
- ណ្ហើយ! ឈប់គិតរឿងចាស់ៗទៅ ឥលូវយើងគិតរឿងថ្មីៗម្តងវិញ។ ម៉ាក់ ថាកូនទាំងពីរ ល្មមដល់ពេលទៅជំរាបសួរលោកប៉ារបស់កូនហើយ ណាំ។ ពេលនេះប្រហែលជាលោកទាំងពីរនឹកកូនណាស់។

មែនហើយ! សុបិនអាល័យតែព្រួយបារម្ភនឹកគិតតែរឿងសុខផ្ទាល់ខ្លួន របស់នាយ ភ្លេចគិតអំពីសុខទុក្ខរបស់ឳពុកនាយរលីង។ ម្យ៉ាងទៀតនាយក៏ ភ្លេចនឹកថានឹងជូនលំអងទៅជួបលោកសុនាថដែរ។ បន្តិចមកគេក៏សំពះលា អ្នកស្រីបូព្រឹក្សនាំលំអងចេញទៅ។

នៅក្នុងរថយន្ត សុបិនសួរទៅធិតាថា :

- អូនមានដឹងទេ ថាលោកប៉ាបងនិងអ្នកមីងលីជាត្រូវប៉ូលីសនាំយកទៅ ខាងណាដែរ?

CHANBOKEO.COM

- ខ្ញុំមិនដឹងដូចតែគ្នាហ្នឹង គ្មាននរណាគេប្រាប់ខ្ញុំទេ ។

- ចុះក្រែងអូនស្ថិតនៅក្នុងជួរប៉ូលីសដែរ មិនមែនទេហី?

- នរណាថា?

- ចុះហេតុអ្វីក៏ពេលដែលប៉ូលីសមកនាំខ្លួនលោកប៉ា អូនស្លៀកឯកសណ្ឋាន ជាប៉ូលីសមានវត្តមាននៅទីនោះដែរនោះអី...

- នោះប្រហែលទាល់តែលោកអធិការផុនជំរាបសាច់ការបងហើយ លំអង រក្សាការសំងាត់ក្នុងក្រសួង មិនអាចជំរាបរឿងអ្វីដល់បងបានទេ ។

សុបិនឮដូច្នោះក៏ញញឹមដាក់លំអងរួចស្រដីថា :

- មិនអីទេ! បងនឹងតាមរកលោកដោយខ្លួនបងផ្ទាល់ ។

សុបិនក៏ថែមល្បឿនរថយន្តចេញទៅ ។

នៅក្នុងការិយាល័យលោកអធិការផុនៈ

- លោកសុបិនពិតជាចង់ជួបលោកប៉ារបស់លោកមែនហ្អេស?

- បាទពិតហើយ! ខ្ញុំមិនបានជួបលោកពីរខែហើយ.. មិនដឹងថា លោកមាន សុខទុក្ខយ៉ាងណាទេ...

- ជាប់ទោសឧក្រិដ្ឋ សុខទុក្ខពិបាកនឹងរៀបរាប់ហើយ ( លោកផុនតប )

- អញ្ចឹង តើខ្ញុំអាចមានឱកាសជួបលោកប៉ារបស់ខ្ញុំម្តងបានដែរទេ?

- ចាំខ្ញុំដាក់ពាក្យទៅថ្នាក់លើសិន... ស្អែកព្រឹកលោកមកទទួលដំណឹងនៅ ទីនេះចុះ ។

សុបិនក៏សំពះលាលោកអធិការផុន នាំលំអងទៅផ្ទះវិញ ។ យប់នោះ គេនឹករសាប់រសល់ចំលែកណាស់ ។ លំអងឃើញដូច្នោះក៏សួរនាយថា :

- បងខ្វល់ខ្វាយរឿងអ្វីហ្នឹង?

- គឺ... បងនឹកស្តាយក្រោយគ្រប់រឿងហ្នឹងណាំអូន ។ វេលាក្រោយៗនេះ បងហាក់ដូចជាឃ្លាតឆ្ងាយពីលោកប៉ាណាស់ ហើយចេះតែគិតផ្តេសផ្តាសពី ម៉ាក់ចុងរបស់បង ។ តាមពិតគាត់តែងតែមានបំណងល្អលើបងជានិច្ច ខុស អ្វីតែបងដែលមើលរំលងអំពើល្អរបស់គាត់រហូតមក ។

- មិនទាន់ហួសពេលទេណាបង ។ ស្អែកយើងបានទៅជួបគាត់ហើយ ។ បង ពិតជានៅមានឱកាសនឹងទទួលគាត់ជាម្តាយពេញមុខណាំ!

សុបិនអោនថើបភរិយា :

- អរគុណអូនណាស់លំអងដែលតែងតែផ្តល់កំលាំងចិត្តអោយបងរហូតមក បើសិនជាជីវិតរបស់បង មិនបានជួបនឹងរូបអូនទេនោះ មិនដឹងជាសុបិន វង្វេងនឹងភាពឈាមរាវដល់កំរិតណាហើយទេ ។

CHANBOKEO . COM

- ឈប់រំលឹកទៅ! ពេលនេះ យើងមានតែបច្ចុប្បន្នប៉ុណ្ណោះ ដែលយើងត្រូវ ខំប្រឹងកែខៃរៀបចំអោយបានល្អបំផុត ទើបអនាគតរបស់យើងភ្លឺថ្លារៀង រហូតទៅ។

ឮនាងវាចាដូច្នោះ សុបិនស្រវាអោបថិតាយ៉ាងណែនដោយក្តីស្រលាញ់ ពេញបេះដូង។

ព្រឹកស្អែកឡើង អ្នកទាំងពីរក៏បានមកដល់ការិយាល័យលោកអធិការ ផុនដូចការណាត់។ រំពេចនោះ ស្រាប់តែមានលោកអធិការនាំប៉ូលីសពីររូប មកដល់ ព្រមទាំងមានប្រសាសន៍ថា :

- យើងបានទទួលការអនុញ្ញាត្ត អោយអ្នកទាំងពីរចូលសួរសុខទុក្ខពិរុទ្ធជន របស់យើង តែអ្នកទាំងពីរត្រូវអនុវត្តន៍តាមខស្នើរបស់ក្រសួងគ្រប់កិច្ចទាំង អស់ ទើបអាចចូលបាន។

- តើពួកយើងត្រូវធ្វើអ្វីខ្លះទៅ លោកអធិការ? (សុបិនសួរ)

- គឺ... អ្នកទាំងពីរត្រូវចងបិទមុខ ហើយនាយប៉ូលីសពីររូបខាងនេះ នឹងនាំ លោកធ្វើដំណើរទៅ...

- ធ្វើដំណើរ... ? ឆ្ងាយប៉ុនណាទៅ?

- មិនអាចប្រាប់បានទេ។ លោកព្រមទៅទេ?

សុបិនបែរមើលលំអងឃើញនាងញញឹមហើយងក់ក្បាល ក៏ឆ្លើយថា :

- បាទ! អោយតែបានជួបលោកប៉ា ខ្ញុំធ្វើតាមសំណូមពររបស់ក្រសួងគ្រប់ យ៉ាង។

បន្តិចមក សុបិននិងលំអងក៏ត្រូវនាយប៉ូលីសចងមុខហើយនាំខ្លួនចេញ ទៅ។ តាមផ្លូវ សុបិនកាន់ដៃលំអងជាប់មិនរបេះឡើយ ហាក់ដូចជាភ័យ ខ្លាចនាងរត់បាត់ពីរូបនាយអញ្ចឹង។ មួយសន្ទុះក្រោយមក គេក៏បានមកដល់ កន្លែងមួយ ស្រាប់តែនាយប៉ូលីសប្រាប់ថា :

- សូមទោស! ពេលនោះ យើងអាចអនុញ្ញាតអោយលោកចូលម្តងបានតែ ម្នាក់ទេ។ តើមួយណាស្មគ្រ័ចូលមុន?

សុបិនរេរាក្នុងចិត្ត នាយក៏ខ្សិបប្រាប់លំអងថា :

- តើអោយបងធ្វើយ៉ាងណា? បងមិនចង់អោយអូននៅចាំបងតែម្នាក់ឯង នៅខាងក្រៅសោះ... បងបារម្ភពីអូនណាស់។

ឮសុបិននិយាយដូច្នោះ លំអងក៏ឆ្លើយថា :

- អញ្ចឹងខ្ញុំទៅមុនចុះ ចាំបងចូលតាមក្រោយ។

ស្រាប់តែនាយប៉ូលីសនិយាយប្រាប់ថា :

- តាមក្បួនវិន័យទីនេះ មុននឹងអាចចូលជួបសន្ទនាគ្នា លោកត្រូវផ្លាស់ប្តូរ សំលៀកបំពាក់សិនទើបបាន។

- មានច្បាប់អញ្ចឹងដែរហ្ន៎? ចំលែកណាស់! (សុបិនលាន់មាត់) ឱ្យផ្លាស់ ប្តូសំលៀកបំពាក់ ហាក់ដូចជាកំពុងទៅមើលអ្នកជំងឺក្នុងពេទ្យដល់ហើយ។

លំអងក៏យកដៃកេះនាយហើយខ្សិបថា :

- បងកុំរអ៊ូច្រើនអី.. ធ្វើតាមគេទៅ នឹងអាលឆាប់បានទៅជួបលោក ប៉ាទាំង ពីររបស់យើង។

CHANBOKEO.COM

ភ្លាមនោះសុបិននិងលំអង ក៏ត្រូវនាយប៉ូលីសចាប់បំបែកចេញទៅ។ គ្រាន់តែលំអងដើរចេញមិនទាន់បានប៉ុន្មានជំហានផង សុបិនហាក់ដូចជានឹក ពិភាល់យ៉ាងណាមិនដឹងក៏ស្រែកឡើង :

- លំអង! លំអង!

ស្រាប់តែនាយប៉ូលីសគំហកថា :

- នែ៎ រក្សាគិរិយាបថបន្តិចមើល៍! ទីនេះមានសន្តិសុខណាស់ គ្មាននរណាគេ មកធ្វើបាបភរិយារបស់លោកទេ។

បន្តិចមក ស្រាប់តែមានមនុស្សបីបួននាក់មកដល់គគ្រឹកគគ្រាក់ចាប់ នាយយើងផ្លាស់ប្តូរខោអាវ តែគេមិនបានដោះស្នាប់បិទភ្នែកទេម្លោះហើយ សុបិនមិនដឹងថា គេកំពុងតែស្លៀកអីពាក់អីដល់នាយឡើយ។ ប្រហែលកន្លះម៉ោងក្រោយមក គេក៏នាំនាយដើរចេញទៅ។

មកដល់កន្លែងមួយដែលនាយយើងមានអារម្មណ៍ថា ហាក់ដូចជាស្ងាត់ ប្លែកយ៉ាងណាមិនដឹង នាយប៉ូលីសក៏អោយនាយឈរនៅស្ងៀមមួយកន្លែង មិនអោយបែរទៅណា។ បន្ទាប់មកនាយប៉ូលីសក៏ស្រាយភ្នែកអោយសុបិនបានឃើញទិដ្ឋភាពទីនោះ...

ស្នូរទះដៃលាន់កញ្ជ្រៀវឡើងយ៉ាងរំពងទ្រហឹងអឺងអាប់ ក្រោមពន្លឺ ភ្លើងចម្រុះពណ៌ដ៏ភ្លឺរន្ទាល សុបិនបើកភ្នែកឡើងឃើញភ្ញៀវយ៉ាងច្រើនកុះ ករមានទាំងក្រុមតន្ត្រី អ្នកចំរៀង ជាពិសេសនោះ នៅលើឆាក កណ្តាល វេទិកា នាយប្រទះឃើញបុរសចំណាស់ពីររូបក្នុងសំលៀកយ៉ាងថ្លៃថ្នូរបំផុត ព្រមទាំងស្ត្រីចំណាស់មួយរូបក្នុងសំលៀកផាមួងខ្មែរ កំពុងតែឈរញញឹម មករកនាយយ៉ាងពព្រាយតែម្តង។ សុបិនយកដៃញីភ្នែកម្តងហើយម្តង ទៀត ថាតើនាយកំពុងយល់សប្តិឬក៏កំពុងប្រទះការពិត។ សុបិនឧទាន ខ្សិបៗក្នុងមាត់ថា :

- លោកប៉ា? អ្នកមីងលីដា? លោកសុនាថ? ហេតុអ្វីមកនៅទីនេះទៅវិញ?

ព្រមពេលជាមួយគ្នានោះ នាយក៏ប្រទះឃើញលាកយូនិក្ស និងកិរិយា ជាកូនស្រីរបស់លោកនៅឈរក្បែរលោកអធិការផុន ឃើញមិត្តរបស់នាយ ឈ្មោះភិរម្យដែលខានឃើញគ្នាប៉ុន្មានខែមកហើយ និងឃើញនរណាទៀត ទាំងអស់ដែលនាយធ្លាប់ស្គាល់។ គេស្លៀកពាក់ស្អាតបាតថ្លៃថ្នូរ ហាក់ដូច ជាកំពុងរង់ចាំបើកពិធីពិសេសអ្វីមួយអញ្ចឹង។ លុះឃើញកូនប្រុសរបស់ លោកសំដែងការភ្ញាក់ផ្អើលពេក លោកសេរីនក៏មានប្រសាសន៍ឡើងថា :

- សុបិន! ថ្ងៃនេះប៉ាសប្បាយចិត្តណាស់ដែលកូនមកតាមរកប៉ាដល់ទីនេះ!

- លោកប៉ា... ក្រែងលោកប៉ាត្រូវជាប់ពិរុទ្ធ មិនមែនទេហ៎? (សុបិនសួរ)

- នរណាថា? កាលនោះ ប៉ាកំពុងថតកុនសំរាប់ផលិតកម្មវីឌីអូឌីវីឌីរបស់ ប៉ាតើហ៎! ឯងមិនឃើញទេ ការីកាម៉ារ៉ាឈរព្រោងព្រាតនៅទីនោះ?

- អូហ៎! ខ្ញុំស្មានថាគេជាអ្នកកាសែតយកការណ៍តើហ៎ ហើយលោកសុនាថ លោកអធិការផុន... និងក្រុមប៉ូលីសសំងាត់ទាំងអស់នោះ?

CHANBOKEO.COM

- ក៏ជាផ្នែកមួយរបស់ខ្សែភាពយន្តថ្មីរបស់ប៉ាហ្នឹងដែរ ដោយប៉ាខ្ទះតួបានជា
បញ្ហានាយតាវៅទៅតាមរកកូនឯងមួយអោយជួយសម្តែងទៅ ។ ហើយ ម្យ៉ាងទៀត
ចាស់ៗគេដឹងរឿងរបស់កូននិងរឿងលំអងគ្រប់ៗគ្នា ម្ល៉ោះ ហើយទើបរៀបចំឆាកល្ខោនខ្លះឱ្យសប្បាយៗ លលេងកូនឯងបន្តិចទៅ
ណាមួយ ខ្លួនប៉ាក៏នឹកភ្នកចង់កាត់បន្ថយភាពក្រអឺតក្រទមឆ្មើងឆ្មៃមានះ
របស់កូនប្រុសប៉ាចោលខ្លះដើម្បីឱ្យកូនត្រលប់មកទទួលខុសត្រូវជីវិតរបស់ ខ្លួនក្នុងផ្លូវសុក្រឹតវិញ
ទើបប៉ាសុខចិត្តបើកឆាកសំដែងល្ខោនសំដែងមុនគេ ។ ឥលូវល្ខោនជីវិតមួយដែលប៉ាបានដឹកនាំ កំពុងតែឈានមកដល់ភាគបញ្ចប់
ហើយ ហើយកំពុងតែនាំកូនត្រលប់មកជួបនឹងតួឯកស្រីរបស់កូនដែរ...
- ពុទ្ធោ!!!...

សុបិនឧទានហើយក៏ស្ទុះវឹងទៅក្រាបសំពះឪពុកដោយរន្ធត់ចិត្ត:
- លោកប៉ា! កូនត្រេកអរណាស់កាលបើលោកប៉ាមិនមានពិរុទ្ធអ្វី!!

សុបិនស្រដីទាំងរលីងរលោងទឹកភ្នែក រួចហើយក៏ស្ទុះងើបអោបឪពុក របស់នាយយ៉ាងណែន ។ បន្តិចមក
នាយក៏បែរមកឱនសំពះអ្នកស្រីដានី ហើយពោលដោយក្តីគោរពចេញពីក្នុងបេះដូងរបស់នាយជាលើកដំបូងថា :
- សូមអ្នកម្តាយមេត្តាអធ្យាស្រ័យដល់កូនផង! ឱ្យកូនសូមទោសអ្នក ម្តាយ
ដែលកូនបានមើលរំលងសេចក្តីល្អរបស់លោកចំពោះកូន ។

អ្នកស្រីលីដាញញឹមយ៉ាងស្រស់តបវិញ :
- ម៉ាក់មិនដែលប្រកាន់អ្វីនឹងកូនដែរណាសុបិន គឺម៉ាក់មានតែសេចក្តី ស្រលាញ់ប៉ុណ្ណោះ សំរាប់អោយកូនគ្រប់ពេលវេលាទាំងអស់ ។
ឃើញកូន មានសេចក្តីកក់ក្តៅក្នុងជីវិត ម្តាយក៏រីករាយរកអ្វីប្រៀបមិនបានទេ ។

ថាហើយអ្នកស្រីក៏យកដៃទទួលយកការសំពះរបស់សុបិន ធ្វើអោយ សុបិននឹករំភើបចិត្តចំពោះភាពអធ្យាស្រ័យរបស់អ្នកស្រី ។
បន្ទាប់មក មាណពក៏បែរអោនគោរពលោកសុនាថ ហើយក៏ពោលថា :
- សូមលោកប៉ាមេត្តាទទួលយកសុបិនជាកូនរបស់លោកប៉ាម្នាក់ផង ។

លោកសុនាថក៏ស្រវាលើកសុបិនឡើងហើយមានប្រសាសន៍ថា :
- ទ្វារបេះដូងរបស់ប៉ា បើកចំហរង់ចាំទទួលកូនជាយូរមកហើយ គ្រាន់តែ កូនក្រមកដល់បន្តិចប៉ុណ្ណោះ ។ ឥលូវ
ប៉ាឃើញកូនមកដល់ដូចចិត្តដែល យើងទាំងអស់គ្នាប្រាថ្នា ប៉ារំភើបចិត្តណាស់ កូន!

សុបិនត្រេកអរក្នុងចិត្តរហូតរលីងរលោងទឹកភ្នែក កាលបើបានដឹងថា ចាស់ទុំគ្រប់គ្នាគេស្រលាញ់នាយប៉ុនណា ។ ភ្លាមនោះ
នាយបែរមើលចុះ ឡើង មិនឃើញលំអងនិងអ្នកស្រីបូព្រឹក្ស ក៏បែរសួរទៅលោកសុនាថថា :
- លោកប៉ា ចុះម៉ាក់និងអូនលំអងនៅឯណាដែរពេលនេះ?
- ម៉ាក់នៅខាងនេះកូន...!

សុបិនងាកផាំងបែររកមើលម្ចាស់សំលេង ឃើញអ្នកស្រីមកដល់ពី

CHANBOKEO.COM

ក្រោយខ្នងតាំងពីអង្កាល់ណាមិនដឹង :

- ម៉ាក់!

សុបិនស្ទុះលុតជង្គង់ទទួលអ្នកស្រីបូព្រឹក្ស ដែលកំពុងអង្គុយក្នុងរទេះពិការទាំងត្រេកអរកខិបកខុប ។ ប៉ុន្តែបុរសយើងនៅខកចិត្តបន្តិច ត្បិតមិន ឃើញវត្តមានរបស់លំអងម្ចាស់ដួងចិត្តរបស់គេសោះ ។ នាយក៏សួរទៅអ្នក ស្រីបូព្រឹក្សថា :

- ម៉ាក់! ចុះឯណាអូនលំអង?

- ចៅសួររកតែលំអងម្នាក់ មិនចង់ជួបយាយទេហ៎?

សុបិនងាកផាំងរកម្ចាស់សំលេង ស្រាប់តែប្រទះនឹងយាយចិត្រកំពុង តែឈរញញឹមនៅក្បែរនោះដែរ ។ សុបិនបើកភ្នែកធំៗហើយឧទានឡើង ទាំងភ្ញាក់ផ្អើលភន្ត័ភាំង :

- យាយ?... ហេតុម្តេចក៏...?

- យាយសុខសប្បាយទេណាចៅ! អរគុណណាស់ដែលចៅជួយយកយាយ ទៅមន្ទីរពេទ្យ កុំអីថ្ងៃនោះយាយមិនដឹងជាយ៉ាងណាទេ ។

សុបិនសឹងតែមិនជឿភ្នែកខ្លួនថាអ្វីៗដែលនាយប្រទះថ្ងៃនេះជាការពិត សោះឡើយ ។ គេយកដៃញីភ្នែកម្តងហើយម្តងទៀតហើយក៏បន្ទន់ខ្លួនចុះ សំពះយាយចិត្រភ្លាម :

- ចៅមិនមែនយល់សប្តិមែនទេ យាយ?... សុបិនរំភើបចិត្តអ្វីម្ល៉េះទេ កាល បើចៅឃើញយាយសុខសប្បាយ...!

សុបិនពោលញ័រទាំងទឹកភ្នែករលីងរលោង ។ យាយចិត្រក៏យកដៃ អង្អែលក្បាលសុបិនហើយវាចាយ៉ាងស្រទន់ថា :

- អរគុណណាស់ចៅដែលបារម្ភពីសុខទុក្ខរបស់យាយ!

សុបិនបែរមើលទៅក្រោយខ្នងដូនចាស់ធ្វើអើតអើមហើយក៏សួរថា:

- ចុះឯណាមិនឃើញអូនលំអងអញ្ចឹង យាយ?

- បើសុបិនចង់ដឹង សួរខ្ញុំឯណេះវិញ...!! (បុរសម្នាក់ឆ្លើយឡើងពីម្ខាង)

កាលបើឮសំលេងបុរសម្នាក់និយាយមករកខ្លួន សុបិនងាកផាំងទៅរកភ្លាម ក៏ប្រទះនឹងកំលោះអ្នកចំរៀងជើងថ្មីដ៏ល្បីមួយរូបឈរជិតនាយកាសូ ជាមិត្តកំពុងតែសើចគ្រហាញដាក់នាយ ។ សុបិននឹកឆ្ងល់ណាស់ក៏សួរថា :

- តាវ៉ៅ! កាសូ! ហេតុដូចម្តេចបានជាអ្នកទាំងពីរមកដល់ទីនេះដែរ?

តាវ៉ៅសើចខឹកៗ ហើយឆ្លើយថា :

- គឺយើងទាំងពីរបានទទួលការអញ្ជើញជាពិសេស ពីរយ៉ាង មួយអោយ មកធ្វើជាតារាចម្រៀងកំដរភ្ញៀវនារាត្រីនោះ ។ ចំណែកមួយទៀតគឺមក ធ្វើជាសាក្សីតុលាការ ត្បិតល្បងសុបិនឯងបានក្លាយជាពិរុទ្ធជនទៅហើយ នៅពេលនេះ ។

- ពិរុទ្ធជន? តើខ្ញុំមានកំហុសអីទៅ ដែលធ្វើអោយខ្លួនខ្ញុំក្លាយជាពិរុទ្ធជន យ៉ាងនេះ?

CHANBOKEO.COM

- មិនទាន់ដឹងខ្លួនទៀត មែនទេល្បែងសុបិន? គឺល្បែងមានពិរុទ្ធចាប់កូនក្រមុំ គេនោះអី ។

គ្រាន់តែឮដល់ត្រឹមនេះ សុបិននឹកអាមាសខ្លួនបែកញើសសស្រាក់ ដោតថ្ងាសតែម្តងត្បិតភ័យក្នុងចិត្តថា ច្បាស់ជាគេបំរុងបកអាក្រាត រឿង អតីតកាលរបស់នាយហើយ ។ បន្តិចមក នាយយើងក៏តាំងចិត្តក្លាហាន ងើបមុខឡើង ដើម្បីប្រឈមនឹងការពិតគ្រប់យ៉ាងទាំងអស់ អោយជ្រះ ស្រឡះថ្ងៃនេះតែម្តង។ រំពេចនោះ តាវ៉ៅក៏ប្រកាសខ្លាំងៗទៅកាន់ភ្ញៀវនៅទីនោះគ្រប់គ្នា ថា :

- កាលពី៦ឆ្នាំមុន បុរសម្នាក់នេះ (តាវ៉ៅយកដៃចង្អុលទៅសុបិន) បាន ចាប់ថើបកូនក្រមុំរបស់គេម្នាក់ រួចហើយក៏បានសន្យាថានឹងចូលដណ្តឹង ធិតាមួយរូបនោះធ្វើជាភរិយាពេញច្បាប់ ។ ឥលូវនេះ នាយតាវ៉ៅខ្ញុំនិង នាយកាសូ ដែលបានធ្លាប់ធ្វើជាកសិណសាក្សីកាលជំនាន់នោះ សូមចូលខ្លួន មកទាមទារពាក្យសន្យានោះជួសកូនក្រមុំនៅថ្ងៃនេះតែម្តង ថាតើបុរស នេះគេនឹងឆ្លើយយ៉ាងណាដែរ? សូមភ្ញៀវកិត្តិយសទាំងអស់មេត្តាជួយធ្វើ ជាសាក្សីចំពោះចំលើយរបស់គេថ្ងៃនេះផង បាទ!

សុបិនភា្ញក់ព្រើត កាលបើឮតាវ៉ៅនិយាយដូច្នោះ ហើយក៏លាន់មាត់ ខ្សិបៗតែម្នាក់ឯងថា :

- តាវ៉ៅ! កាសូ! ការពិតនាយគឺជាក្មេងភូមិទាំងនោះទេហ៎? ពុទ្ធោ! គួរឱ្យ អាមាសមែន ដែលគេគ្រប់គ្នាដឹងរឿងយើងទាំងអស់ តែយើងបែរជាងោះ មិនដឹងអីតែម្នាក់ឯងទៅវិញ!! នេះហើយឬលទ្ធផលនៃការវាយឫកវើស អើងអណ្តែតលើអាកាស ទីបំផុត យើងក៏ក្លាយជាមនុស្សតែម្នាក់គត់ដែល មិនដឹងខ្យល់អី ។ គិតៗទៅគួរអោយខ្មាសខ្លួនមែន! តែប៉ុណ្ណេះ សុបិនលែង ហ៊ានដើរលើអាកាសតែម្នាក់ឯងទៀតហើយ ។

ភ្លាមនោះ សុបិនឆ្លើយត្រលប់ទៅតាវ៉ៅវិញយ៉ាងម៉ឺងម៉ាត់ថា :

- ខ្ញុំសូមជំរាបតាវ៉ៅនិងកាសូដែលជាសាក្សីពីអតិត សូមជំរាបលោកមេបា ចាស់ទុំនិងភ្ញៀវកិត្តិយសទាំងអស់ថា ថ្ងៃនេះ វេលានេះ សុបិនសូមចូលខ្លួន មកប្រគល់ជូនសន្យាទាំងឡាយនោះវិញគ្រប់ទាំងអស់ ដោយចិត្តស្មោះស ហើយក៏មានបន្ថែមការប្រាក់ជាជីវិតនិងបេះដូងដ៏បរិសុទ្ធពីសុបិនថែមទៀត .... ចំពោះធិតាដែលមាននាមថាលំអងផ្កា...!!!

តន្ត្រីក៏ប្រគំឡើង ព្រមគ្នាជាមួយនឹងស្នូរទះដៃយ៉ាងរំពងអឺងកងយ៉ាង ខ្ញៀវខ្ញា ។ ភ្លាមនោះ វាំងននក៏បើកហើយ... ធិតាដ៏ស្រស់ស្អាតមួយរូប ក៏ដើរចេញមកក្នុងសំលៀកមង្គលការយ៉ាងភ្លឺពណ្ណរាយ ដោយមានបន្លឺ សៀងយ៉ាងពិរោះរណ្តំក្នុងចំរៀងដ៏ផ្អែមល្ហែមមួយ ដែលគ្មាននរណាអាច យល់នូវជំរៅអត្ថន័យបានស្មើនឹងសុបិនរបស់យើងឡើយ :

ភិរម្យស្នេហា

១. ត្រជាក់ភិរម្យពេញក្នុងហឫទ័យ ក្រោមស្បៃរាត្រី រៀមនិងពិសីថ្នមស្នេហ៍ បរិសុទ្ធ សៀងបេះដូងញាប់ញ័រទ្រទ្រត់ ស្នេហាធំធេងប្រាកដ

សមុទ្រក៏ប្រៀបពុំបាន ។

២. លើស្ពានឫស្សីស្នេហ៍ត្រអាលត្រេក សន្សើមពីមេឃរោយចុះត្រជាក់

CHANDBOKEO.COM

អង្អែលថ្នមប្រាណ បងច្រៀងលោមបំពេរកល្យាណ ក្រោមពន្លឺរស្មីចន្ទ

អោយភ្ញុំផានក្សេមក្សាន្តកាយ ។

បន្ទរ. រលកផ្ទៃបឹង ព្រិច១ផ្គុះពណ៌ ហាក់ជួយត្រេកអរសប្បាយ ជំនោរផាយផាត់

ពីជើងមេឃឆ្ងាយ ប្រៀបហាក់ជាចំណងដៃ ពរជ័យផ្ទៃបាចផ្កាស្លា ។

៣. សូមអោយវេលាឈប់នឹងនៅ ដីឈប់វិលទៅ អោយមុំបាននៅគេងកើយ

ហត្ថា ស្តាប់សំនៀងបេះដូងទ្វេហា រណ្តំឆ្លើយឆ្លងចចារ

ពាក្យពេចន៍ ស្នេហាអមតៈ ....

សុបិនឈរទ្រឹង សំលឹងមើលធិតា ដោយដួងចិត្តញាប់ញ័ររំភើបនិង សេចក្តីស្នេហាដ៏សែនធំធេង :

- អូនលំអង... កំពូលដួងចិត្តរបស់បង!

ភ្លាមនោះ សុបិនក៏ញញឹមឡើងយ៉ាងពព្រាយ ជាសញ្ញានៃការទទួល សុភមង្គលពេញបេះដូង ។ រីឯកូនក្រមុំវិញក៏មិនខុសគ្នាដែរ ។ ធិតាយើង ញាប់ញ័ររំជើបរំជួលក្នុងចិត្តក្រៃលែង កាលបើក្តីស្រម័យរបស់នាង បានក្លាយជាការពិតដូចបំណងប្រាថ្នា ។ សុបិនស្ទុះដើរចូលទៅជិតមាណវីហើយ ស្រវាកាន់ដៃទាំងគូរបស់នាងលើកឡើង រួចសំលឹងមុខម្ចាស់បេះដូងរបស់ គេដោយក្រសែភ្នែកដ៏មានទឹកដមមន្តស្នេហ៍ :

- លំអង! បងស្រលាញ់អូនណាស់! អូនគឺជាម្ចាស់ចិត្តតែមួយរបស់សុបិន! ពេលនេះ បងសូមចាប់ដៃអូនជាគូគ្រងរហូតតទៅអស់មួយជីវិត តើអូន ឆ្លើយយ៉ាងណាដែរ?

លំអងញញឹមឡើងតបទៅវិញដោយការពេញចិត្ត :

- លំអងសូមដើរទន្ទឹមជាមួយបងរហូតតទៅក្នុងជីវិត មិនថាមេឃរាំង ឬក៏ មេឃភ្លៀងទេ យើងនឹងកសាងជីវិតជាមួយគ្នា ពុះពារគ្រប់ឧបសគ្គ ដើម្បី សាងសេចក្តីសុខនិងលំនឹងសុភមង្គល ដែលមានសេចក្តីស្រលាញ់និងការ ស្មោះត្រង់រវាងយើងទាំងពីរគោល...

សុបិនស្រវាអោបធិតាពេញរង្វង់ដៃរបស់នាយ :

- ហើយ... រូបអូនក៏ជាបណ្តូលនៃសេចក្តីស្នេហារបស់បង តរៀងទៅ!!

លំអងញញឹមទទួលយកពាក្យពេចន៍របស់សុបិន ដោយដួងចិត្តរំភើប ឥតឧបមា ។ ស្នូរទះដៃប្រាវ១លាន់ឮឡើងយ៉ាងរំពងនៅទីនោះ បានក្លាយ ទៅជាបទចំរៀងសុភមង្គលមួយយ៉ាងពិរោះរងំ និងជាពរជ័យដ៏សុខដុម រមនាបំផុតចំពោះគូស្នេហ៍ទាំងទ្វេហា ។ ចាស់ទុំទាំងអស់សើចក្អាកក្អាយផង ជូតទឹកភ្នែកផង ដោយការរំភើបចិត្ត ត្បិតលោកមានឱកាសឃើញកូនចៅ បានរៀបការសាងសេចក្តីសុខគ្រួសារជាមួយគ្នាដូចបំណង ។

នៅពីក្រោយខ្នងលំអង កិរិយាធិតារូបស្រស់ អ្នកកំដរកូនក្រមុំ កំពុង តែលួចញញឹមចោលកន្ទុយភ្នែកភ្សែក១ ដាក់កាសូនិងតារ៉ៅ ដែលប្រឹង ប៉ែងក្បៀសជើងគ្នាទៅវិញទៅមកមិនឈប់ឈរសោះ ។ មើលទៅតារា ចំរៀងកំលោះដ៏សង្ហាទាំងពីររូបនេះប្រហែលជាកំពុងប្រជែងគ្នា ដណ្តើម

CHANBOKEO.COM

ទទួលកន្ទុយភ្នែកដ៏មានអត្ថន័យជ្រាលជ្រៅរបស់កិរិយាហើយ ។ មិនដឹង ថាតើនរណាឈ្នះ នរណាចាញ់ទៅហ្ន៎ បើទាំងពីរនាក់សង្ហាដូចគ្នា ហើយ ច្រៀងពិរោះដូចគ្នាយ៉ាងនេះ? ឱ!ប្រិយមិត្តអ្នកអានអើយ! ពេលនេះ តើយើងគួរលើកកញ្ញាកិរិយា ទៅអោយបុរសណាមួយទៅ ក្នុងចំណោម បុរសសង្ហាទាំងពីររូបនេះ?

**ចប់**

CHANBOKEO . COM

## តារាយរាយឈ្មោះកំណាព្យ កំរងកែវ និង ទំនុកចំរៀង
## ដែលនិពន្ធឡើងដោយអ្នកស្រីកែវចន្ទ័បូរណ៏


| | | |
|---|---|---|
| ១. | រាំ Hello Hi | ទំព័រ ០៦ |
| ២. | ចំរៀងស្នេហា | ទំព័រ ២២ |
| ៣. | ផ្កាចំប៉ី | ទំព័រ ២៣ |
| ៤. | កន្លង់មាស | ទំព័រ ២៦ |
| ៥. | វណ្ណៈស្នេហ៍ | ទំព័រ ៣០ |
| ៦. | សុំត្រឹមសុបិនឃើញបង | ទំព័រ ៣៦ |
| ៧. | ក្លិនផ្កាស្នេហ៍ | ទំព័រ ៣៦ |
| ៨. | សៀវងបេះដូង | ទំព័រ ៦៣ |
| ៩. | ស្នេហាផ្កាឈូករតន៏ | ទំព័រ ៦៥ |
| ១០. | ជំរៅចិត្តបងយ៉ាងណា | ទំព័រ ៦៨ |
| ១១. | កន្លង់ស្លាបមាស | ទំព័រ ៧៦ |
| ១២. | តស៊ូ | ទំព័រ ៨៨ |
| ១៣. | បក្សីកំព្រា | ទំព័រ ៩១ |
| ១៤. | ភិរម្យស្នេហា ( បទប្រុស) | ទំព័រ ៩៦ |
| ១៥. | ស្ពានឫស្សី | ទំព័រ ១៣២ |
| ១៦. | នឹក | ទំព័រ ១៤២ |
| ១៧. | បេះដូងបងសំរាប់តែអូន | ទំព័រ ១៤៧ |
| ១៨. | គូស្នេហ៍ភក្តី | ទំព័រ ១៥២ |
| ១៩ | រូបបងជាសុបិនរបស់អូន | ទំព័រ ១៨៨ |
| ២០. | ភិរម្យស្នេហា ( បទស្រី) | ទំព័រ ២០៧ |


CHANBOKEO . COM

# វាចាចុងក្រោយ

- ខ្លែងដែលហោះកាន់តែខ្ពស់ទៅ កាន់តែរងាឡើងដោយភាពកំព្រា ត្បិត
ខ្លួនគេបានហើរកាន់តែឆ្ងាយពីភាពកក់ក្ដៅទាំងឡាយដែលនៅលើដី...

- ខ្លែងដែលអាចបង្ហោះខ្ពស់បានអាស្រ័យលើកំលាំងខ្យល់ និងខ្សែបង្ហោះដ៏ ជាប់មាំជាជំហរ
មិនមែនដោយសារតែរូបខ្លែងខ្លួនឯងតែម្យ៉ាងឡើយ ។ បើ គ្មានខ្យល់ ខ្លែងក៏មិនអាចហោះខ្ពស់ឡើងបានដែរ ។ មួយវិញទៀត
បើខ្លែង ភ្លេចរើសខ្សែដ៏ជាប់មាំ អ្នកនឹងអាចដាច់ខ្លួនអណ្ដែតទៅ ដោយគ្មានលំនឹង និងទិដៅ
រហូតដល់ពេលមួយដែលត្រូវធ្លាក់ដីវិញដោយឯកឯង ។

- ម្យ៉ាងទៀត ខ្លែងដែលអាចហើរនៅលើមេឃយូរហើយខ្ពស់បាន ក៏ដោយ សារតែមានអ្នកឈរកាន់តម្រង់ខ្សែពីដីទៅ
អោយខ្លែងហោះទៅតាមទិស និងកំលាំងខ្យល់ដ៏សមរម្យ បើមិនដូច្នោះទេ ខ្លែងក៏មិនអាចងើបហោះហើរ
អណ្ដែតឡើងបានយ៉ាងខ្ពស់ហើយមានលំនឹងរហូតដូច្នោះបានឡើយ ។

- ពាក្យសន្យា មិនមែនជាការលេងសើចទេ ប៉ុន្តែអ្នកប្រគល់សន្យាច្រើន តែភ្លេចនូវពាក្យសន្យារបស់ខ្លួន ខុសអីអ្នកទទួលសន្យា...
គេមិនងាយ បំភ្លេចនូវពាក្យសន្យាទាំងឡាយនោះឡើយ ។ គេតែងតែរង់ចាំទាមទារ ចំលើយចំពោះគេវិញពីម្ចាស់សន្យាជានិច្ច
មិនថាការរង់ចាំនោះមានសង្ឃឹម ឬគ្មានសង្ឃឹមយ៉ាងណាក្តី ។

អ្នកស្រី កែវ ចន្ទ័បូរណ៏

ថ្ងៃ ២០ ឧសភា ២០០៥

CHANBOKEO.COM